# បណ្តាំព្រះមាតាបិតាព្រហ្ម



សាវតាព្រះមាតាបិតាព្រហ្ម

ស្រាវជ្រាវ និងចងក្រង

ដោយ ខ្ញុំព្រះករុណាខ្ញុំបាទ

គៀត ចាន់ថុន

អតីតសិស្សសាលាវិចិត្រសិល្បៈ

ព្រះមាតាបិតាព្រហ្ម

រួចពីទោស

ភាគទី៤

# អារម្ភបទ

ក្រោយពេលខ្ញុំព្រះករុណាខ្ញុំបាទ សរសេរចងក្រងភាគទី៣ចប់ជាងមួយឆ្នាំហើយ ខ្ញុំបាទមិនបាន សរសេរភាគ៤បន្តទៀតឡើយ គ្រាន់តែសរសេរបណ្តាំព្រះម៉ែមហានគរជាពាក្យកាព្យ ស្រាយនូវ ប្រស្នាបង្កប់ក្នុងឈ្មោះកំណាព្យទាំង៣មេ មុនសម័យអង្គរនិងក្នុងសម័យអង្គរ។ ចំណែកការស្រាវជ្រាវឃើញថ្មីខាងក្រោយ ដែលបានលាក់ទុកក្នុងមរតកអច្ឆរិយនេះ ខ្ញុំពឹងឲ្យក្មួយ២នាក់ ម្នាក់នៅខេត្តព្រះសីហនុ និងម្នាក់ទៀតនៅភ្នំពេញ ឲ្យជួយយកការរកឃើញថ្មីនេះទៅផ្សព្វផ្សាយ។

ខ្ញុំព្រះករុណាបាទពុំអស់ចិត្ត ដោយក្នុងបណ្តាំព្រះម៉ែភាគ៣ ខ្ញុំបាទពុំទាន់ដឹងការរួចពីទុក្ខទោសជាស្ថាពរ របស់មាតាបិតានិងញាតិវង្សាមហានគរឡើយ។ ដូច្នេះខ្ញុំព្រះករុណាខ្ញុំបាទ ក៏ចាប់សរសេរភាគ៤នេះឡើង ក្រោយពីមាតាបិតាមហានគរបានរួចផុតពីទោសជាងមួយឆ្នាំ ដោយខ្ញុំបាទចង់ប្រាប់ពេលវេលា រួចពីទោសរបស់ពួកគាត់ក្នុងទីបញ្ចប់ ហើយនឹងបកស្រាយនូវអ្វីដែលខ្ញុំបាទពុំបានបកស្រាយនូវក្នុងភាគមុន។ ម្យ៉ាងទៀតឯកសារបណ្តាំព្រះម៉ែទាំង៣ភាគមុន មិនទាន់អាចបង្កើតបានជាមុខព្រហ្មឡើយ ហើយភាគទី៤នេះទើបអាចបង្កើតបានជាមុខព្រហ្ម ក្នុងអតីតផងនិងសម្រាប់បច្ចុប្បន្នផង ដើម្បីឲ្យកូននាគបាន ឃើញនូវដំបូលព្រហ្មវិហារធម៌ពិត របស់អ្នកកើតមរតកអច្ឆរិយនេះ។ ឯកសារស្រាវជ្រាវនេះទុកជាមរតកគំនិតថ្មីមួយ ដើម្បីផ្សាភ្ជាប់តំណថ្មដែលបានដាច់រាប់ពាន់ឆ្នាំមកហើយនេះឲ្យជាប់គ្នាឡើងវិញ សម្រាប់ទុកឲ្យកូននាគយកទៅពិចារណាទៅតាមផ្លូវលោក ផ្លូវធម៌ និងបានបើកបង្ហាញនៅរឿងពិត ម្ចាស់មរតកអច្ឆរិយពីអតីតរបស់យើង។

ឯកសារនេះស្រាវជ្រាវនិងចងក្រងដោយ

ខ្ញុំព្រះករុណាខ្ញុំបាទ**គៀត ចាន់ថុន**

អតីតសិស្សសាលាវិចិត្រសិល្បៈ

គេហទំព័រ:

http://kietchanthon.blogspot.com

http://kietchanthon.info

អ៊ីម៉ែល:kietchanthon@gmail.com

info@kietchanthon.info

ក្នុងអាថ៌កំបាំងបណ្តាំមហានគរភាគ ១ ២ ៣ ខ្ញុំបាទជាអ្នកស្រាវជ្រាវរៀបរៀងចងក្រង ពុំបានបកស្រាយឲ្យស៊ីជម្រៅ ទៅក្នុងគំនិតប្រស្នាបង្កប់ក្នុងមេកាព្យ ព្យញ្ជនៈ ស្រៈ លេខ ទិស ផ្កាយ..... គឺពន្យល់បានត្រួសៗតែប៉ុណ្ណោះ។ បើយើងពុំបានទាញយកមកពិចារណាត្រិះរិះគិតទេនោះ យើងពិតជាយល់ថាវាជារឿងធម្មតា របស់បុរាណបណ្ឌិតដូនតាយើង។ ពួកគាត់បានទុកមរតកដ៏ច្រើន តែបើយើងយកសូរសម្តីនិយាយនោះមកពិចារណាវែកញែក នៅក្នុងពាក្យសូរស័ព្ទ សញ្ញា យើងនឹងមើលឃើញនូវរឿងផ្សេងមួយទៀត ដែលនឹកគិតស្មានពុំដល់។ ដូចពាក្យសុភាសិតបុរាណខ្មែរមួយបានពោលទុកថា"**សម្តីជាឯក លេខជាទោ អក្សរជាត្រី**" បើយើងសួរខ្លួនឯងថា ហេតុអ្វីបានជាពាក្យសម្តីនៅក្នុងលំដាប់លេខ**១** ចំណែកលេខនៅក្នុងលំដាប់លេខ**២** រីឯអក្សរកត់ត្រាបែរជានៅលំដាប់លេខ**៣**ទៅវិញ។ ចម្លល់នេះយើងត្រូវតែត្រិះរិះរកន័យពិត ដើម្បីស្រាយនូវរាល់បញ្ហា ដែលមានបង្កប់ន័យនៅក្នុងសុភាសិតនេះ ព្រោះអ្វីក៏ដោយដែលកើតមានក្នុងលោក សុទ្ធតែមានហេតុនិងបច្ច័យរបស់វា។ យ៉ាងណាមិញសុភាសិតរបស់ដូនតាយើងក៏ដូច្នោះដែរ ពួកគាត់តាក់តែងឡើងហើយ សុទ្ធតែបង្កប់នូវន័យខ្លឹមសារដ៏មានជម្រៅ ដែលយើងត្រូវត្រិះរិះពិចារណារុករកនៅអត្ថន័យនេះ បើពុំនោះទេយើងបានត្រឹមតែស្ទាបអង្អែល ត្រង់សំបកខាងក្រៅតែប៉ុណ្ណោះ មិនអាចដឹងន័យខាងក្នុង របស់ពួកគាត់ឡើយ។ សព្វថ្ងៃប្រជាជនខ្មែរភាគច្រើន កំពុងកាន់និងគោរពព្រះពុទ្ធសាសនា តើមានប្រជាជនខ្មែរប៉ុន្មាននាក់ ដែលបានយល់ពីខ្លឹមសាក្នុងសាសនៈបណ្តាំ ឬពាក្យប្រៀនប្រដៅនេះ? ដែលនៅក្នុងឪវាទទាំងនោះ ព្រះអង្គបានសម្តែងដោយសង្ខេបថា"**កិរិយាមិនធ្វើនូវអំពើបាបទាំងពួងមួយ កិរិយាបំពេញនូវកុសលឲ្យខ្លួនមួយ កិរិយាធ្វើចិត្តរបស់ខ្លួនឲ្យបានផូរផង់មួយ**" ពាក្យទាំងនេះជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ បើបង្រួញសេចក្តីមកគឺ សីល សមាធិ បញ្ញា ជាលោកិយ នឹងឈានទៅរកសីល សមាធិ បញ្ញា ជាលោកុត្តរៈ ដើម្បីចេញចាកពីវដ្តសង្សារនេះ។ ចំណែកយើងអ្នកកាន់នឹងគោរពភាគច្រើន តែងទៅបួងសួងបន់ស្រន់ឲ្យព្រះសម្មាសម្ពុទ្ធ ឬអាទិទេពផ្សេងៗទៀតមកជួយ តើមានអាទិទេពណាមកជួយយើង ក្រៅពីយើងចេះជួយខ្លួនឯងនោះ? ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា"**សត្វទាំងឡាយមានខ្លួនឯងជាទីពឹង គឺពុំមានអ្នកដ៏ទៃណាជាទីពឹងឡើយ បុគ្គលដែលបានអប់រំខ្លួន(ចិត្ត)បានល្អហើយ នឹងបាននូវទីពឹងដែលគេបានដោយក្រ**"។ តើយើងបានធ្វើទីពឹងឲ្យខ្លួនឯងហើយឬនៅ បើពុំបានធ្វើទីពឹងឲ្យខ្លួនឯងទេ យើងពិតជាធ្វើដំណើរតាមផ្លូវមាតាមហានគរពីអតីតជាពុំខាន ព្រោះពួកគាត់សុខចិត្តតាំងខ្លួនជាម៉ែជាឪ ជាអ្នកគ្រប់គ្រងថែរក្សាទឹកដី ដោយពុំបានធ្វើទីពឹងឲ្យ

ខ្លួនឯង ទីបំផុតបានត្រឹមតែរងទុក្ខតែម្នាក់ឯង ក្នុងអបាយភូមិតែប៉ុណ្ណោះ។ ក្នុងសុភាសិតខ្មែរដែលមានសុភាសិតជាច្រើនបានពោល ទាក់ទងជាមួយនឹងពាក្យសម្ដីដូចជា៖

- ***សំដីសជាតិ មារយាទសពូជ***
- ***មនុស្សគេយកសម្ដី ដំរីគេយកភ្លុក***
- ***រនាបបាក់យករនាបជួស សម្ដីពោលហួសមានតែតាមកែឬបង់ប្រាក់***
- ***បណ្ឌិតនិយាយពីគំនិត អ្នកប្រាជ្ញនិយាយពីហេតុការណ៍ មនុស្សធម្មតានិយាយពីរឿងផឹកស៊ី***

ដែលខ្ញុំលើកយកមកនេះ គ្រាន់តែចង់ពញ្ញាក់ដាស់ស្មារតីកូននាគ ដែលពុំបានពិចារណានូវកាកគំនិតរបស់បណ្ឌិតដូនតាយើង ដែលពួកគាត់បានខំបន្សល់ទុកនេះ ដើម្បីយកមកពិចារណារាវរកសេចក្ដីពិតពីកាកគំនិត ដែលមានបង្កប់ន័យទុកក្នុងមរតកអច្ឆរិយនេះ។

មួយឆ្នាំកន្លងទៅហើយ ដែលខ្ញុំបានស្រាយប្រស្នាមេកាព្យទាំងប្រាំពីរមេ ដែលកើតមានមុនសម័យអង្គរនិងក្នុងសម័យអង្គរ ព្រោះវាជាភស្តុតាងមួយបានប្រាប់បង្ហាញយើងថា ជាមេកាព្យដែលកើតនឹងស្ថិតក្នុងវង្សថ្ម។ ចំណែកឯមេកាព្យ ដែលកើតមានក្រោយសម័យ បោះបង់ចោលក្រុងអង្គរ ឬក្រោយសម័យថ្ម ខ្ញុំបាទពុំបានយកមកបកន័យរបស់វាឡើយ។ ព្រោះតំណនៃភាពអច្ឆរិយ បានដាច់អស់ជាង១០០ឆ្នាំ ដែលពួកបរទេសឈ្លានពាន បានវាយឲ្យខ្មែររត់ចោលក្រុងអង្គរ រហូតដល់ខ្មែរខ្លួនឯង ពុំដឹងថាខ្លួនមានរាជធានីអច្ឆរិយនៅទីនោះផង។ លុះមកដល់សម័យខាងក្រោយ មានស្ដេចមួយអង្គព្រះនាមច័ន្ទរាជា បានចេញទៅប្រពាតព្រៃ ជាមួយនឹងជនជាតិព័រទុយហ្គាល់ ហើយបានរុករកឃើញទីក្រុងចាស់ ដែលមានប្រាសាទដ៏ធំស្កឹមស្កៃ បានលាក់កប់ទុកក្នុងព្រៃដ៏ក្រាស់ ទើបភ្ញាក់ដឹងថាខ្លួនជាពូជពង្សថ្ម (សូមមើលប្រវត្តិសាស្ត្រខ្មែរ ចងក្រងដោយលោក ត្រឹងងាបន្ថែម)។

ក្នុងសម័យព្រះបាទអង្គឌួង មានព្រះសង្ឃមួយអង្គ លោកបាននិមន្តមកពីស្រុកសៀម លោកមានព្រះនាមថាប៉ាងឬប៉ាន ព្រះអង្គជាកវីនិពន្ធ នៅក្នុងរាជព្រះបាទអង្គឌួង និងនរោត្តម លោកបានសរសេរនូវអត្ថបទកំណាព្យមួយឡើង គឺរឿងល្បើកអង្គរវត្ត។ យើងគួរពិចារណាថា ក្នុងសម័យក្រោយបោះបង់ចោលក្រុងអង្គរ អ្នកប្រាជ្ញរាជបណ្ឌិតខ្មែរភាគច្រើន តែងតែទៅសិក្សាបួសរៀននៅស្រុកសៀម ចុះបើគ្រូសៀមគេកុហក យើងមិនត្រូវវង្វេងហើយឬ? ឧទាហរណ៍ដូចជាល្បើកនគរវត្ត(អង្គរ

វត្ត)នេះ បើអ្នកសរសេរបើកអាថ៌កំបាំងអង្គរខុស ក្មេងជំនាន់ក្រោយនឹងត្រូវសិក្សាខុសបន្តគ្នា តែបើបើកអាថ៌កំបាំងជាតិត្រូវ នោះវាជាភ័ពសំណាងរបស់ជាតិនេះ ដែលបានដឹងពីប្រវត្តិសាវតាពិតរបស់ខ្លួន។

## ពន្យល់ពាក្យ

***ល្បើកអង្គរ = ល + បើក + អង្គរ*** មានន័យថា សាកល្បងបើកអាថ៌កំបាំងអង្គរ ឬអាថ៌កំបាំងថ្មបើបើកត្រូវភាពរុងរឿងនឹងកើតឡើង តែបើបែរជាបើកពន្យល់ខុសវិញ នោះនឹងធ្វើឲ្យអ្នកស្នងមរតកថ្មជំនាន់ក្រោយៗ នឹងភ្លេចនូវសាវតារបស់ខ្លួនទេឬ? ដូចមាននៅក្នុងរឿងល្បើកអង្គរនេះស្រាប់ ព្រះអង្គបានពន្យល់ថា មានទេវតានិងអាទិទេពផ្សេងៗ ចុះមកកសាងប្រាសាទ និងមកជួយរៀបចំនគរនេះឲ្យជាតិខ្មែរ ចុះអាទិទេពទាំងអស់នោះមានពេលទំនេរអ្វីម្លេះ ដែលចុះមកកសាងប្រាសាទឲ្យតែប្រទេសខ្មែរនោះ? ចំណែកប្រទេសដ៏ទៃជាច្រើនទៀត ដែលនៅជុំវិញយើង និងនៅលើពិភពលោកទាំងមូល ម្ដេចអាទិទេពទាំងនោះ មិនទៅជួយប្រាប់ជួយកសាងឲ្យផង? នៅក្នុងសម័យពុទ្ធកាល ពេលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្ដែងនូវព្រះធម៌ ព្រះព្រហ្ម ព្រះឥន្ទ្រ ទេវតាម៉ឺនសែនលាន កោដិចក្រវាល បានមកស្ដាប់ព្រះធម៌ ដែលព្រះអង្គបានសម្ដែងប្រោស អាទិទេពទាំងនោះបានស្ដាប់ព្រះធម៌ហើយ ក៏បានសម្រេចមគ្គផល ទៅតាមកម្លាំងបញ្ញារបស់ខ្លួន ហើយក៏ថ្វាយបង្គំលារួចជៀសចេញទៅ។ សម័យនោះមិនបានឃើញ អាទិទេពអង្គណាមួយ មកកសាងប្រាសាទថ្វាយព្រះអង្គដោយកម្លាំងកាយឡើយ បើមានគ្រាន់តែនិមិត្តដោយឫទ្ធិមួយរយៈខ្លីតែប៉ុណ្ណោះ គឺមានតែឧបាសក ឧបាសិកា ដែលបានដល់នូវព្រះរតនៈត្រៃ ជាទីពឹងទីរលឹកដោយមិនញាប់ញ័រ ស្មើដោយជីវិតតែប៉ុណ្ណោះ ដែលបានស្ម័គ្រកសាង ប្រាសាទ ព្រះវិហារ គន្ធកុដិ......ថ្វាយចំពោះព្រះសង្ឃ ដែលមានព្រះសម្មាសម្ពុទ្ធជាប្រធាន។ ក្នុងសម័យពុទ្ធកាលនោះដដែល ព្រះសម្មាសម្ពុទ្ធព្រះអង្គពុំបានខ្វល់ខ្វាយ ក្នុងការកសាងវត្តអារាមទុកឡើយ រួមទាំងអគ្គសាវក អគ្គសាវិកា និងសង្ឃសាវកទាំងឡាយ លោកពុំបានជាប់ជំពាក់ក្នុង កិច្ចកសាងវត្តអារាមនេះទេ ព្រោះភារៈកសាងសេនាសនសង្ឃ គឺជាកិច្ចរបស់គ្រហស្ថ ដែលជាពុទ្ធបរិសទ្ធអ្នកមានសទ្ធាជ្រះថ្លា ជាអ្នកគ្រប់គ្រងផ្ទះ បានលះបង់នូវទ្រព្យ ក្នុងកិច្ចការកសាងនេះ ដើម្បីសន្សំនូវកុសលទុកក្នុងសន្ដានចិត្ត ជាឧបនិស្ស័យតទៅជាតិខាងមុខ។

ដោយការលើកជាឧទាហរណ៍មកបង្ហាញនេះ ខ្ញុំបាទចង់ឲ្យកូននាគពិចារណាឡើងវិញ តើប្រាសាទថ្ម ដែលកើតបន្តគ្នាក្នុងសម័យនោះ កើតឡើងដោយសារអាទិទេពអ្នកសាង ឬក៏កើតឡើងដោយកម្លាំងកូននាគមានកតញ្ញូ និងកតវេទី? បើយើងមើលរឿងល្បើករង្គរ យើងជឿថាមានអាទិទេពមកកសាង តែបើកូនខ្មែរមើលរឿងភាសា**ឥ**ដែលមានក្នុងថ្ម បានឆ្លាក់ពន្យល់ប្រាប់ពីដំណើរនៃរឿងទុក្ខវេទនា របស់មាតាបិតាមហានគរ គឺកើតចេញពីទឹកចិត្តកតញ្ញូនិងកតវេទី របស់កូននាគក្នុងសម័យនោះ បានរួមគ្នាកសាងប្រាសាទថ្មទាំងនេះ។ ហើយរឿងដែលមាននៅក្នុងប្រាសាទទាំងនេះ កើតចេញពីមហិទ្ធិឫទ្ធិព្រះមាតានាគ(ចិនហៅថាបីសាចពស់) ដែលលោកលួចចេញពីទីឃុំ មកប្រាប់កូននាគក្នុងកាលនោះ ឲ្យសាងប្រាសាទឆ្លាក់រៀបរាប់ ប្រវត្តិរឿងទុក្ខវេទនារបស់ខ្លួន ទុកក្នុងគុហារប្រាសាទទាំងនោះ។

ការបកស្រាយពន្យល់ឡើងវិញនេះ គ្រាន់តែជាការពញ្ញាក់សតិស្មារតីកូនខ្មែរ ឲ្យចេះពិចារណាឡើងវិញ នូវន័យប្រស្នាកំបាំង ដែលបានលាក់កប់ទុកក្នុងមរតកមែ៉ ដោយពីមុនយើងពុំបានចាប់អារម្មណ៍នោះ។ នៅក្នុងពិធីបុណ្យទានសែនព្រេន និងពិធីផ្សេងៗទៀត ដែលកើតមានក្នុងនគរនេះពុំចេះដាច់ បន្តពីជំនាន់មួយទៅជំនាន់មួយ កាលបើមានអ្នកឆ្ងល់ណាមួយ សួរអំពីកិច្ចទាំងនោះពួកគាត់ឆ្លើយពុំរួច យើងតែងឮគាត់ឆ្លើយថាជា ទំនៀមទម្លាប់ប្រពៃណី ឧទាហរណ៍ការរៀបចំធ្វើបាយសីស្លាធម៌ដូង ពិធីក្រុងពលី មង្គលការ ....។ល។ ខ្លះឆ្លើយថាជាពិធីក្នុងព្រហ្មញ្ញសាសនា តែព្រហ្មញ្ញនៅឥណ្ឌាពុំស្គាល់បាយសី ដូងស្លាធម៌ ម្លូព័ន្ធ ស្លាពាន់ នឹងពិធីផ្សេងៗទៀត ដែលមាននៅក្នុងស្រុកខ្មែរយើងឡើយ ខ្លះទៀតឆ្លើយដាក់ថាជាទំនៀម ទម្លាប់ប្រពៃណី។ ដូចជាការហែកបិលមហាព្រហ្មក្នុងរដូវចូលឆ្នាំថ្មី យើងពុំបាននឹកឆ្ងល់ថា បើមាតាព្រហ្មបិតាព្រហ្ម ព្រមទាំងប្រាសាទមុខព្រហ្មដែលមាននៅលើទឹកដីនេះទាំងអស់ មានតែសិរសា(ក្បាល) ពុំមានដងខ្លួនយ៉ាងនេះ បើយើងចង់ឲ្យពួកគាត់ជួយការពារ ឬរកសិរីសួស្តីឲ្យ ដែលក្នុងនាមពួកគាត់ជាមាតាបិតា ឬជាអាទិទេពរបស់យើង តើពួកគាត់ជួយម្ដេចបាន បើគាត់គ្មានដៃគ្មានជើង គ្មានដងខ្លួនយ៉ាងនេះ? ហើយយើងសួរទៀតថា ហេតុអ្វីបានមានរឿងយ៉ាងនេះ អ្នកឆ្លើយច្បាស់ជាឆ្លើយថា វាជារឿងទំនៀមទម្លាប់ប្រពៃណី...។ល។ ដូច្នេះយើងត្រូវសាកល្បងយកពាក្យបីម៉ាត់នេះមក ពិចារណាវែក ញែករកការពិត តើវាមានបង្កប់ន័យអ្វីនូវក្នុងពាក្យទាំងបីម៉ាត់នេះ?

# ពន្យល់ពាក្យ

ទំនៀម = ទាមសូរដូចទៀម = ធ្វើឲ្យជាប់ ឧ.ឈ្លើងទាម ខ្សែទាម(ទៀម)

ទម្លាប់ = ធ្លាប់ .អ្វីដែលធ្វើញយៗវាតែងតែធ្លាប់ៗដដែលៗវាក្លាយជាទម្លាប់

ប្រពៃ = ប្រពៃ(ភាសាខ្មែរ) = សាធុ(ភាសាបាលី)

ណី = ពាក្យសម្គាល់ឥត្ថីភាវរូបគឺភេទស្ត្រី . រាជនី . ភិក្ខុនី . ពិធីការនី . កម្មការនី...

ប្រពៃណី = រឿងប្រពៃរបស់ស្ត្រីឬរបស់រាជនី ដែលជាបឋមក្សត្រ អ្នកបង្កើតពូជខ្មែរ ខ្មែរ

ទំនៀមទម្លាប់ប្រពៃណី = ទាមឲ្យជាប់ ក្លាយជាទម្លាប់ រឿងប្រពៃរបស់ស្ត្រី ដែលជាអ្នកកកើតទឹកដីអច្ឆរិយនេះ ដែលប្រព្រឹត្តបន្តគ្នាពុំដាច់ សម្រាប់មនុស្សជំនាន់ក្រោយ ស្រាយនូវប្រស្នានេះ។

ពាក្យប្រពៃណី ក្នុងវចនានុក្រមសម្ដេចព្រះសង្ឃរាជជួនណាតមានន័យថា:

ទំនៀម; ពូជពង្ស, តំណវង្សត្រកូល : រក្សាបវេណី, ធ្វើបុណ្យទានតាមប្រពៃណី។បវេណីទេវតា ដែលគេរាប់អានតាមតំណវង្សត្រកូល តៗមក។ រួមបវេណីរួមសុខទុក្ខរបស់ស្វាមីភរិយា។

តើប្រពៃណីវាជាតំណពូជពង្សវង្សត្រកូលអ្នកណា? គឺជាតំណពូជពង្សវង្សត្រកូលព្រះនាងនាគ ក្រោយមកបានយាក្លាយជាព្រះមាតានាគ (សូមអានអាថ៌កំបាំងបណ្ដាំមាតាមហានគរខ្មែរ ភាគទី១ . ២. ៣)។ ដូចពាក្យរាជធានី គឺមានន័យថា រាជ្យ = ភាវៈជាព្រះរាជា... ធា = ធារស្រូវឬទឹក(សូរធា = ធារ) នី = ភេទស្ត្រី ដូច្នេះពាក្យរាជធានី គឺអ្នកគ្រប់គ្រងទីក្រុងទឹកដីគឺស្ត្រី ព្រោះម្ដាយតំណាងធាតុទឹក ១២ រាជធានីភ្នំពេញ គឺម៉ែពេញ ឬយាយពេញជាអ្នកបង្កើតទីក្រុងនេះ។

មេកាព្យខ្មែរយើងដែលមានមុនសម័យអង្គរ និងក្នុងសម័យអង្គរ តើមេកាព្យទាំងនេះមានបង្កប់នូវប្រស្នាអ្វីខ្លះ? មេកាព្យទាំងប្រាំពីរមេនេះ គឺមានមេបទ:

១ បទមេបួន(៤)

២ បទបឋ្យាវត្ត

៣ បទកាកគតិ

៤ ព្រហ្មគីតិ ឬព្រហ្មគិត

៥ បទពំនោល

៦ បទបន្ទោកាក

៧ បទកុជង្គលីលា

ចំណែកឯមេបទដែលកើតមានក្រោយសម័យអង្គរ ខ្ញុំបាទពុំបានយកមកវែកញែកបកស្រាយឡើយ ព្រោះមេបទទាំងនោះកើតឡើង ក្នុងសម័យដាច់តំណាថ្មជាង១០០ឆ្នាំ ដូច្នេះអត្ថន័យកំបាំងប្រស្នាក្នុងមរតកអច្ឆរិយ យើងមិនអាចរែករកឲ្យឃើញឡើយ។ ម្យ៉ាងទៀតអ្នកប្រាជ្ញកវីនិពន្ធ ក្រោយសម័យ អង្គរ សុទ្ធតែត្រូវបានបរទេសឈ្លានពាន កៀរ ប្រមូល បញ្ជូនឲ្យទៅរៀនបែបបទមនោគម ពីស្រុកគេ(សៀម..) ដូច្នេះចំណេះដឹងខាងក្រោយ ត្រូវប្រែពណ៌ថ្មី លែងមានភាពបរិសុទ្ធ ដូចមុនទៀតហើយ។

# I.អំពីកំណាព្យនិងអត្ថន័យបង្កប់ក្នុងមេកាព្យទាំងប្រាំពីរមេ

ពន្យល់ពាក្យដែលមានសូរសម្លេងដូចកាព្យ:

**កាប** ( ន. ) ឈ្មោះសម្រាប់រឹតគាប : កាបរទេះ(ដកចេញពីវចនានុក្រមសម្តេច)

**កាបៗ** ( ឧ. ) សូរសម្រែកសត្វទាស្រែកយំផ្ទួនៗបន្តគ្នា: ទាស្រែកព្រកាបៗ។(ដកចេញពីវចនានុក្រមសម្តេច)

**កាប** ( ន. ) ខ្សែ.កាប

**កាព្យ** កាបបា.; សំ. ( ន. ) (កាវ្យ) របៀបពាក្យចួនមានឃ្លោងឃ្លា (កំណាព្យ) : ពាក្យកាព្យ, តែងកាព្យ.... កម្រងពាក្យសម្តីដែលមានពាក្យចាប់ចុងជួន ផ្ទួនៗគ្នារណ្តំណែង ណងគួឲ្យចង់ ស្តាប់។ (ដកចេញពីវចនានុក្រមសម្តេច)

**១.បទមេបួន**

ហេតុអ្វីបានជាដូនតាដាក់ឈ្មោះកាព្យនេះថាមេបួន? ដោយហេតុតែសម័យខាងក្រោយកូននាគលែងស្គាល់គាត់ គឺស្គាល់ត្រឹមតែគ្រាប់បាយ(ហូបបាយកុំឲ្យកំពុបត្រូវដឹងគុណព្រះមេ សូមមើលការ បកស្រាយអាថ៌កំបាំងភាគមុន)។ បួនតំណាងឲ្យមុខព្រហ្មដែលមាននៅលើថ្ម មុខព្រហ្មក្នុងមហាសង្ក្រាន្តឆ្នាំថ្មី និងបួនតំណាងឲ្យព្រហ្មវិហារធម៌របស់មេនាគទាំងបី ដែលមកគ្រប់គ្រងកូននាគគ្រប់ជំនាន់។ មេនាគទី១គឺមាតាបិតាបង្កើតរបស់កូនប្រុសស្រី មេនាគទី២គឺមាតាបិតាបង្កើតមហានគរនេះ មេនាគទី៣គឺព្រះអរហន្តសម្មាសម្ពុទ្ធ ដែលមេនាគទាំងបីនេះ បានគ្រប់គ្រងថែរក្សាកូនក្មេរទាំងប្រុសស្រី គ្រប់ៗកាលទាំងបី។ មេបួនមុខបួនមានតែសិរសា(ក្បាល) បាត់ខ្លួនព្រោះហេតុតែមានមាន: អំនួត .លោភ: .ទោស:. មោហ: ប្រកាន់មាំទីបំផុតបានត្រឹមក្លាយខ្លួនជាប្រេត ជាព្រាយបិសាចតែប៉ុណ្ណោះ(ក្នុងឯកសារចិនជាវតាក្វាន់)។ ក្នុងមួយឆ្នាំសង្ក្រាន្តវិលជុំម្តង មានកូនរលឹកឃើញឧបការគុណ៧នាក់ ហើយកូនទាំង៧នាក់នេះ សង្ក្រាន្តវិលត្រូវថ្ងៃរបស់អ្នកណា អ្នកនោះត្រូវមកហែហមព្រះសិរសាម្តាយឪពុក ចំណែកឯកូនដែលសង្ក្រាន្តវិលមិនត្រូវ រវល់ប្រចាំគ្នាពុំបានមកជួបជុំជួយគ្នា

ឡើយ។ កូនកបិលមហាព្រហ្ម ពិតប្រាកដគឺមាន១២នាក់ឯណោះ តែកូនអាចមកហែហមរំលឹកគុណម៉ែឪមានតែ៧នាក់ ហើយប្រចាំគ្នាទៀត។ រឿងព្រេងទាក់ទងនឹងកបិលមហាព្រហ្មនេះ ក្នុងគម្ពីរព្រហ្មញ្ញក៏គ្មាន ហើយក្នុងគម្ពីរព្រះត្រៃបិដកក៏គ្មាន តើរឿងនេះកើតចេញពីណា? រឿងនេះបានបដិសន្ធិចេញពីថ្ម គឺថ្មកើតមានមុន រឿងប្រសូតតាមក្រោយ ហើយសង្ក្រាន្តពីសម័យមុន ត្រូវចូលក្នុងខែមិគសិរ ដែលជាខែទីមួយក្នុងច័ន្ទគតិ។ ដោយសារខែនោះប្រជាកសិករ នៅជាប់រវល់ការងារ ច្រូតកាត់ប្រមូលផលស្រូវ ដូច្នេះត្រូវផ្លាស់សង្ក្រាន្ត ឬចូលឆ្នាំថ្មីត្រូវប្ដូរមកខែចែត្រវិញ។ បើយើងពិចារណាមកលើសង្ក្រាន្ត ទើបយើងដឹងថា ទេវតាផ្លាស់ឆ្នាំចាស់ចូលឆ្នាំថ្មី គឺពុំមែនអាទិទេព ជាអ្នកកំណត់សម្រេចឡើយ គឺដូនតាខ្មែរជាអ្នកកំណត់។ ត្រង់នេះវាជាប្រស្នា ដែលយើងត្រូវតែវែកញែក រកចម្លើយឲ្យឃើញនូវការពិត គឺមិនចេះតែជឿតៗគ្នា ដោយពុំបានពិចារណារាវរក ហេតុផលនោះឡើយ។ ចុះកំណាព្យមេបួនមានន័យអ្វី ទាក់ទងទៅនឹងឬសកែវរបស់អ្នកនគរនេះ? គឺវាមានទាក់ទងនឹងអាថ៌ប្រស្នាប្រវត្តិរឿងរាជនីពីរអតីតនោះ ដែលឬសកែវម្ចាស់ក្សត្រីនេះ បានត្រូវអតីតកាលរួមផ្សំនិងបរទេសចូលមកកប់លាក់ធ្វើឲ្យវង្សត្រកូលនាគ ត្រូវបាត់ឈ្មោះចេញពីសន្ដានកូនខ្មែរ ហើយកប់ទៅក្នុងដីនៃអតីតកាលធ្វើឲ្យកូននាគសម័យក្រោយ ពុំស្គាល់គាត់ឡើយ។ យើងមើលអ្នករាំរបាំអប្សរាឬអច្ឆរា ដែលបានឡើងសម្ដែងនៅលើឆាកសព្វថ្ងៃ ក្បាច់រាំចុងក្រោយនៃរបាំនេះ ពួកគាត់បានទាញយកមែកផ្កាស្លឹកមាសចេញពីចង្កេះ មកបង្ហួតបង្ហាញប្រាប់គ្រប់ទស្សនិកជន។ តើពួកគាត់អ្នករាំនិងអ្នកមើល មានដឹងថា ដើមឬសកែវនៃស្លឹក ផ្កាមាសនេះនៅឯណា? ហេតុអ្វីបានជាមានតែមែកស្លឹកផ្កា? ចម្លើយគឺឆ្លើយដាក់ទៅលើ ទំនៀមទម្លាប់ប្រពៃណីដែលមានក្នុងថ្ម អ្វីដែលខ្ញុំបាទបានឆ្ងល់សួរនិងបកស្រាយ នេះ គឺខ្ញុំចង់រកយុត្តិធម៌ឲ្យឬសកែវ ដែលលោកសុខចិត្តរងទុក្ខតែម្នាក់ឯង នៅក្នុងអបាយភូមិ ព្រោះ ហេតុតែមរតកអច្ឆរិយនេះ ដើម្បីសម្រាប់ទុកជាកេរ ឲ្យកូនខ្មែរជំនាន់ក្រោយបានសេពសោយ។ ម៉ែឪសព្វថ្ងៃទុកដូចជា ឬសកែវនៃដើមឈើ ខ្លួនសុខចិត្តធ្វើពលិកម្ម ចាក់រុលចូលទៅក្នុងដី ដើម្បីជញ្ជាក់ប្រមូលយកនូវជីវជាតិ មិនថាមូត្រលាមកឬគំរង់ដ៏គួឲ្យខ្ពើមដែលកប់នៅក្នុងដី....ហេតុតែដើម្បីយកមកចិញ្ចឹមដើម មែក ស្លឹក ផ្លែ ផ្កា និងចិញ្ចឹមខ្លួន រួមទាំងញាតិដែលនៅជុំវិញ។ ទីបំផុតអ្នកដែលត្រូវគេសសើរ មិនមែនសសើរឬសកែវ ឬដើមឡើយ គេស្ងើចសសើរតែស្លឹកផ្លែផ្កាតែប៉ុណ្ណោះ។ ចំណែកឯខ្លួនជាឬសកែវ បានត្រឹមតែកប់ លាក់បំបាំងខ្លួន និងប្រវត្តិខ្លួននៅក្នុងដី។ តើគួដែរឬទេ ដែលមាតាបិតាហេតុតែកូន សុខចិត្តប្រព្រឹត្តអំពើអាក្រក់គ្រប់បែបយ៉ាង ដោយពុំទូន្មានចិត្តឲ្យមានសីល សមាធិនិងបញ្ញា ហើយចុងបញ្ចប់បានត្រឹមសោយទុក្ខម្នាក់ឯង នៅក្នុងអបាយភូមិ ដោយពុំមានអ្នកខាងក្រោយណាម្នាក់ដឹង។ ដូចជាមាតាបិតា ញាតិវង្សរាមហានគរ ជាភស្ដុតាងស្រាប់ ដែលខ្ញុំបាទបានយកមកបើកបង្ហាញនៅក្នុងភាគ១.២.៣នោះ ក្នុងនាមខ្លួនជាឬសកែវ បរទេសបានកាប់ត្បៀង លុបដីលុបដានសន្ធប់ពីលើយ៉ាងជិត មិនឲ្យកូននាគខាងក្រោយដឹង តើគួឲ្យតក់ស្លុតសង្វេគ

*ប៉ុណ្ណោ ដែលខ្លួនបានត្រឹមតែស្រែកដង្ហោយ ហៅអ្នកជំនាន់ក្រោយរបស់ខ្លួនតែម្នាក់ឯងពីក្នុងឃុំ តើមានកូននាគប៉ុន្មាននាក់ បានដឹងហើយទទួលស្គាល់នូវការពិតនេះ? បទមេបួននេះមានបួនព្យាង្គ ហើយមានបួនរបះ ដែលអត្ថន័យបង្កប់ក្នុងឈ្មោះបទមេបួន ដូចខ្ញុំបានបកស្រាយពន្យល់ ដោយសង្ខេបខាងលើ(សូមមើលអត្ថបទកំណាព្យមេបួនខាងក្រោម)។*

## ស្រណោះមេបួន( បទមេបួន )

| | | | |
|---|---|---|---|
| ១.នឹកឃើញអាឡោះ | ស្រណោះមេបួន | ឈ្មោះកាព្យបាត់ខ្លួន | នៅសល់តែមេ។ |
| ២.បាត់នាមត្រកូល | ពូជពង្សម្ចាស់កេរ | តើឈ្មោះព្រះមេ | លិចបាត់ទៅណា។ |
| ៣.កាបកាបកាបកាព្យ | កាបញើរកបា | កាបខ្សែយុត្តា | កាបគាបរទេះ។ |
| ៤.កាព្យពាក្យចុងជួន | កាព្យជាចំណោះ | ឃ្លាកាព្យមិនធ្វេសប្រហែសបាត់ឃ្លោង។ | |
| ៥.ឱឈ្មោះកាព្យអើយ | នឹកឡើងរលោង | កាព្យសល់តែគ្រោង | មេបួនជាឃ្លា។ |
| ៦.ជាបទកំណាព្យ | រណ្ដំជាប់គ្នា | ហេតុតែវេរា | ម្ចាស់បទបាត់ឈ្មោះ។ |
| ៧.លិចបាត់ទៅក្រោម | ស្រោបរុំដោយគ្រោះ | កាព្យមិនមានឈ្មោះ | មានត្រឹមមេបួន។ |
| ៨.មេបួនជាអ្វី | មេតាងមាសសួន | ម៉ែឱ្យមុខបួន | តែកូនពុំស្គាល់។ |
| ៩.ព្រោះហេតុអំនួត | ហ៊ានលោតហ៊ានឆ្វាល់ | បញ្ចប់ត្រូវទ័ល | មានមុខបាត់ខ្លួន។ |
| ១០.តើកូនដឹងទេ | ម៉ែទុក្ខផ្ទួនៗ | ទុក្ខព្រោះតាំងខ្លួន | ជាសូរតាំងម៉ែ។ |
| ១១.ផ្អែមហើយល្វីងស្វិត | បាបកម្មព្រោះតែ | តាំងខ្លួនជាម៉ែ | ធ្លាក់ក្នុងអបាយ។ |
| ១២.ជាព្រាយជាប្រេត | កម្មតាំងជាម្ដាយ | នឹកឡើងសែនស្ដាយ | ត្រូវកូនបំភ្លេច។ |
| ១៣.នៅសល់តែមេ | ពាក្យបួនរំលេច | កុំឲ្យតែភ្លេច | ខូបកិច្ចនឹកមេ។ |
| ១៤.អ្នកក្រោយចូរចាំ | រិះគិតគ្មាន់គ្នេ | កុំស្គាល់ព្រះមេ | នៅត្រឹមតែបាយ។ |
| ១៥.បញ្ញាភ្លឺឡើង | ខំដោះខំស្រាយ | ខំត្រួសខំត្រាយ | ទើបឃើញការពិត។ |
| ១៦.ពូជវង្សសម្មា | ពូជត្រិះរិះគិត | ពូជវង្សបណ្ឌិត | ពូជចេញចាកទុក្ខ។ |
| ១៧.បើកូនយល់ហើយ | ទើបមេបានសុខ | ចរចាកចោលគុក | សោយផលសួគ៌ា។ |
| ១៨.ចម្លើយឈ្មោះមេ | តាមវង្សព្រហ្មា | ពង្សព្រះចន្ទ្រា | ទិព្វសេដាច័ន្ទ។ |

១៩.ជាមេអ្នកសាង ពូជសោមព្រះឥន្ទ្រ ទាវវង្សអ្នកកាន់ មរតកស្ថាពា។
២០.សង្ខេបដោយខ្លី ស្រដីតាមការ ស្វែងរកនាមា កាព្យបួនប្រពៃ។
២១.បើសមមិនសម សូមជួយអត់ឲ្យ មេបួនមានន័យ បង្កប់ប្រស្នា។៕

ថ្ងៃច័ន្ទ ៦កើត ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃទី៧ មិថុនា គ.ស២០១១

រៀបរៀងដោយឧបាសក **គៀត ចាន់ផុន**

## ២.បទបថ្យាវត្ត

*ពាក្យថាបទបថ្យាវត្តនេះ នៅក្នុងវចនានុក្រមសម្តេច ព្រះអង្គពុំបានពន្យល់ន័យ នៃពាក្យនេះឡើយ ខ្ញុំបាទសូមសាកល្បង ពន្យល់អត្ថន័យដែលបានបង្កប់នៅក្នុងពាក្យនេះ។*

***បថ្យាវត្ត*** *បើយើងបំបែកជាពាក្យរាយ គឺមានតួអក្សរ(**ប . ថ . យា . វត្ត**) មានន័យបង្កប់ក្នុងពាក្យនេះថា ការប្រព្រឹត្តបដិបត្តិ បរទៅមុខផង បរថយក្រោយផង គឺស្វែងយល់អតីតកាលកន្លងទៅ បដិបត្តិក្នុងបច្ចុប្បន្ន និងទទួលផលផ្លែផ្កាក្នុងពេលអនាគត។ ពាក្យ"**បរ**"មានសូរដូចព្យញ្ជនៈ"**ប**"នេះចំពោះសូរស័ព្ទនិយាយ។ ចំណែក"**ថ្យា**"បើយកជើង"**យ**"ចេញពី"**ថ**"នឹងឃើញពាក្យ**ថយា = ថយយា** គឺមានន័យថា យាទៅមុខផងយាថយក្រោយផង អស់កាលដ៏យូរយា។ វត្តគឺការប្រព្រឹត្ត, សេចក្តីប្រតិបត្តិ;,កិច្ចការដែលគួរធ្វើ; នាទី; ការកាន់សីលធម៌; សេចក្តីគោរព; ទំនៀម, សណ្តាប់ធ្នាប់ : មនុស្សមានវត្តល្អមនុស្សមានសេចក្តីប្រតិបត្តិល្អ; សិស្សធ្វើវត្តឬយកវត្តគ្រូ សិស្សធ្វើសេចក្តីគោរពចំពោះគ្រូ។ សរុបន័យរបស់ឈ្មោះមេកាព្យនេះ គឺឈ្វេងយល់ពីន័យ ក្នុងអតីតកាលបច្ចុប្បន្ននិងអនាគត បើពុំប្រតិបត្តិគ្រប់កាលទាំងបីទេ គឺពុំអាចដឹងអាថ៌កំបាំងរបស់មេកាព្យ ឬពុំដឹងពីម្ចាស់គំនិត ដែលបង្កើតឈ្មោះមេកាព្យនេះ។*

*បទបថ្យាវត្តនេះ ក្នុង១របះមាន៤ឃ្លា ក្នុងមួយឃ្លាមាន៨ព្យាង្គ តាមការស្រាវជ្រាវ ដោយភ្ជាប់ទៅនឹងអាថ៌កំបាំងមាតាមហានគរ គាត់ចង់ប្រាប់យើងថា កាលនៅជាបទ**មេបួន** គាត់មានមុខតែបួនប៉ុណ្ណោះ(ព្រហ្មមុខបួន)។ ពេលវិវឌ្ឍន៍មកដល់បទ**បថ្យាវត្ត** គឺមានពាក្យ៨ ព្រហ្មត្រូវមានមុខប្រាំបី គឺមុខបួនត្រួតលើមុខបួន(សូមមើលរូបព្រហ្មក្របខាងក្រៅ)នេះជានិមិត្តរូប។ អត្ថន័យមុខព្រហ្មទីមួយតំណាងឲ្យមាតាបិតាបង្កើត ដែលមានព្រហ្មវិហារធម៌ទៅលើកូនប្រុសស្រី ផ្សាយទៅមិនចេះដាច់ មិនថាពេលយប់ឬពេលថ្ងៃក្របមាន ឈឺឬជា....។ល។ អត្ថន័យព្រហ្មត្រួតទីពីរ តំណាងឲ្យអ្នកអភិបាលដឹកនាំនគរ ដែលត្រូវតែមានព្រហ្មវិហារធម៌ ផ្សាយទៅលើប្រជារាស្ត្រប្រុសស្រី ក្មេងចាស់ គ្រប់ស្រទាប់វណ្ណៈ គឺគ្រប់គ្រងថែរក្សាជនជាតិខ្លួន ទុកដូចជាកូនបង្កើត។ ព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គបានពោលសុភាសិតទុកថា* **ពេលណារាស្ត្ររបស់ខ្ញុំឈឺ គឺខ្លួនខ្ញុំក៏ឈឺ ព្រោះទុក្ខរបស់ស្តេចនិងរាស្ត្រផ្សាភ្ជាប់គ្នា ការឈឺចាប់របស់រាស្ត្រ ជាឈឺចាប់ជាងអាពាធរបស់ខ្ញុំទៅទៀត។** *អ្នកដឹកនាំដែលមានព្រហ្ម*

*ត្រួតលើព្រហ្ម ទើបនគរបានសន្តិភាព ប្រជារាស្ត្ររស់នៅមានសេចក្តីសុខក្សេម ពុំបានរងទុក្ខដោយការបៀតបៀន របស់អ្នករអភិបាលរក្សា ព្រោះអ្នកដឹកនាំគ្រប់គ្រងថែរក្សា ជាព្រហ្មរបស់ខ្លួន ដោយអ្នកដឹកនាំនោះ ទទ្រង់នូវទសពិធរាជធម៌(ទសពិធរាជធម៌នោះគឺ **១-ទាន:** ការធ្វើអំណោយ; **២-សីល:** ការរក្សាសីល ៥ ជានិច្ច ឬរក្សាសីល៨ តាមកាល; **៣-បរិច្ចាគ:** ការចំណាយព្រះរាជទ្រព្យ ទំនុកបម្រុងប្រទេសជាតិ; **៤-អាជ្ជវ:** មានសេចក្តីទៀងត្រង់; **៥-មទ្ទវ:** មានសេចក្តីទន់ភ្លន់ស្លូតបូតសុភាពរាបសា; **៦-តប:** ការកាន់ឧបោសថសីលតាមកាលកំណត់ម្តងៗ (ម. ព. តប: ឬ តបះ ផង); **៧-អក្កោធន:** មិនធ្វើឲ្យអ្នកដទៃក្តៅក្រហាយ; **៨-អវិហឹសា** មិនបៀតបៀនអ្នកដទៃ; **៩-ខន្តិ** មានសេចក្តីអត់ធន់; **១០-អវិរោធន:** មិនបំពានលើធម៌លើច្បាប់ ។)។*

*អត្ថន័យដែលខ្ញុំបាទបានបកស្រាយ ដោយសង្ខេបក្នុងន័យរបស់ឈ្មោះមេកាព្យទី២នេះ ន័យបង្កប់នៅក្នុងមេបទ ដូនតាមហានគរលោកចង់ឲ្យយើងឈ្វេងយល់ រឿងក្នុងអតីតបច្ចុប្បន្ននិងអនាគត របស់ពួកគាត់។ សូមមើលអត្ថបទកំណាព្យខាងក្រោម:*

**ស្រណោះមេបុណ្យខាងលិច** (បទបថ្យាវត្ត)

| | |
|---|---|
| ១.មេបុណ្យខាងកើតមេបុណ្យខាងលិច | កាព្យលើករំលេចតាមកិច្ច[១]ថ្យាវត្ត |
| មេប្អូនផ្ទួនពីរនាំឲ្យវិវឌ្ឍន៍ | កើតបថ្យាវត្តបានពាក្យប្រាំបីៗ |
| ២.បទបថ្យាវត្តប្រាប់បេះដូងស្រី | រូបរាងកប់ន័យក្សត្រីជាមេ |
| បង្កើតតក្រៃព្រហ្មត្រួតផ្ដុំឡើងទ្វេរ | ព្រហ្មមួយជាម៉ែព្រហ្មមួយជាក្សត្រៗ |
| ៣.ដំណើរនៃព្រហ្មអណ្ដែតរសាត់ | លិចចុះកប់បាត់ស្ងប់ស្ងាត់ដំណឹង |
| [២]ទក់ក្លាយជាថ្មអ្នក**ឝ**បាត់ដឹង | **ឝ**គាំងស្មៀមឈឹងគ្មានចេញវាចាៗ |
| ៤.[៣]ព្រហ្មត្រួតរំពឹងអ្នក**ឝ**វាសនា | ពេលណាសិលាចរចារចេញមក |
| មេបុណ្យខាងលិចជាម្លប់ឈប់ជ្រក | ខ្ញុំកែវពន្លកអ្នក[៤]ដេកដល់ណាៗ |
| ៥.ឬក្រពើលេបឲ្យក្ស័យមរណា | មិនឃើញជីវាវាចាស្រដី |
| ឬក្រពើដេញត្របាក់ពិសី | កោះមេបុណ្យជ័យរាងក្បាលក្រពើៗ |
| ៦.សំណាកគាស់បានរូបរាងស្ទាក់ស្ទើរ | មានតែខាងលើនៅទើខាងជើង |
| [៥]បរទេសរុះរើគាស់កាយរំលើង | ចិត្តថ្លើងទំនើងអាងខ្លួនអ្នកដឹកៗ |
| ៧.មេបុណ្យខាងលិចនៅលិចក្នុងទឹក | ទំនាយរំលឹកឲ្យនឹកតគ្នា |

| | |
|---|---|
| កម្មពីរអតីបន្តវេរា | រងទុក្ខវេទនាកប់ក្នុងព្រៃមនុស្ស។ |
| ៨.ទំនាយសុក្រសៅរ៍ចង្អុលគំនូស | ព្រៃហេមពាន្តនោះលាក់សត្វរាជសីហ៍ |
| អាណិតអាសូរដល់ពូជអ្នកថ្លៃ | ទម្រង់ចរណៃត្រឹមតែពួ។ |
| ៩.នេះជាស្រមោលចំណាំងពន្លឺ | ឈ្មោះអ្នកធ្លាប់ឮចាស់ៗនិយាយ |
| មានបុណ្យខាងលិចលេចក្នុងទំនាយ | សូរស័ព្ទបរិយាយតគ្នាមក។ |
| ១០.ឬកែវថ្លើមថ្លៃគ្មានម្លប់ឈប់ជ្រក | ទើបកែវពន្លកមិនមកហាស្តី |
| ឬនៅបន្ទំសន្សំបារមី | គុណធម៌ប្រពៃព្រះពោធិសត្វ។ |
| ១១.ឬកម្មវេរាអតីមកកាត់ | ឲ្យលិចចុះបាត់កប់ស្ងាត់ក្នុងព្រៃ |
| បាត់ដឹងបាត់ដាន់ពូជពង្សធនជ័យ | អ្នកប្រាជ្ញឈ្លាសវៃដោះប្រស្នាចិន។ |
| ១២.ស្រណោះមេបុណ្យសូមស្លេះទុកសិន | ពូជពង្សស្មៀកក្បិនស្លេះសិនប៉ុណ្ណោះ |
| បញ្ចប់ការគិតឈ្វេងយល់រិះគ្រិះ | ទុកឲ្យប្រាជ្ញចេះលោក៩ប្រស្នា។ |

១.បទបថ្យាវត្ត ២.ផ្នូតក់ ៣.ព្រហ្មមុខ៨ ៤.រូបព្រះវិស្ណុដេក ៥.បរទេសធ្លាប់ធ្វើអាណានិគមពីមុន ៦.ពូជជ័យវរ្ម័ន

ថ្ងៃសុក្រ ៩កើត ខែជេស្ឋ ឆ្នាំថោះត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃ១០ មិថុនា គ.ស២០១១

រៀបរៀងដោយឧបាសក **គៀត ចាន់ផុន**

## ៣.បទភាកគតិ

*តើពាក្យកាកគតិមានន័យដូចម្តេច?*

**ពន្យល់ពាក្យ**

**កាក** *( ន. ) អ្វីៗដែលសោះ; ដែលអស់រសជាតិដោយច្របាច់ឬដោយទំពា, ដោយស្ងោរជាដើម : កាកអំពៅ, កាកដូង។សម្លដែលស្រង់យកតែសាច់និងបន្លែមក ឬដួសយកតែទឹកចេញ ក៏ហៅថាកាកដែរ : កាកសម្ល។ កាកសំបុត្រ គឺសំបុត្រដែលគេលែងត្រូវការ។ កាកមនុស្ស គឺមនុស្សដែលប្រើធ្វើការអ្វីមិនកើត....។(ដកចេញពីវចនានុក្រមសម្តេច)*

**គតិ***បា. សំ. ( ន. ) ការទៅ, ការដើរទៅ, ដំណើរ; ផ្លូវគន្លង; ទីកើតផ្សេងៗ; និស្ស័យ; អធ្យាស្រ័យ; ប្រាជ្ញាញាណ; ទីនៅ; បរិសុទ្ធ។(ដកចេញពីវចនានុក្រមសម្តេច)*

**កាកគតិ***កាក-គៈ-តិបា. ( ន. ) ឈ្មោះបទកាព្យពាក្យ៤ (បទដំណើរក្អែកលោត) : នេះគឺច្បាប់ក្រម ប្រសើរឧត្តមទូន្មានអ្នកផង ប្រើឱនលំទោនកុំបីមានឆ្គង ប្រាជ្ញាបុណ្យផងកើតដោយប្រណិប័តន៍..។ (ដកចេញពីក្នុងវចនានុក្រមសម្តេច)*

**កាក + គតិ** = សំណល់គំនិតដែលដូនតា បានបន្សល់ទុកឲ្យកូនខ្មែរជំនាន់ក្រោយ តែវាបានអស់រសជាតិ នឹងទឹកដមពិតរបស់វាទៅហើយ ភាពរុងរឿងរបស់ពួកគាត់ វាគ្រាន់តែជាស្រមោលនៃអតីតកាល របស់កូនខ្មែរ ដែលកំពុងរស់នៅបច្ចុប្បន្ននេះតែប៉ុណ្ណោះ ព្រោះហេតុអ្វី? ការដាច់តំណថ្មអស់ជាង១០០ឆ្នាំ បានធ្វើឲ្យកាកគំនិតថ្ម ធ្វើដំណើរតមកខាងក្រោយ តាមគន្លងផ្លូវដែលត្រូវបានបរទេសលុបដាន សារដាន លក់ដាន(មើលក្នុងពិធីមង្គលការក្នុងភាគ២)។ កូននាគជំនាន់ខាងក្រោយលែងយល់នូវខ្លឹមសារពិត អត្ថន័យពិត រឿងរ៉ាវពិតបានប្រែក្លាយទៅជារឿងសាសនា រឿងអាទិទេពផុតពីបណ្ដាំពិតរបស់ដូនតាមហានគរ ដែលលោកបានយកប្រវត្តិរឿងពិតរបស់ខ្លួន ទៅសរសេរជាភាសាគ ទុកនៅលើថ្មប្រាសាទរាប់ពាន់ ទុកក្នុងទំនៀមទម្លាប់ប្រពៃណី..... ដែលរសជាតិពិតរបស់វាបានបាត់រសអស់ទៅហើយ គឺនៅសល់តែកាកគំនិតតែប៉ុណ្ណោះ។ កាកគំនិតដែលសល់ កំពុងតែឈានទៅរកភាពបាត់បង់ជាបណ្ដើរៗ ដោយកាកគំនិតថ្មីរបស់បរទេស(បច្ចេកវិទ្យាឬមនោគមវិទ្យាសម័យថ្មី) កំពុងតែលុកលុយហូរចូលមក ក្នុងនគរនេះដោយគំហុក ឧទាហរណ៍ពីដើមកូនក្មេងខ្មែរចេះលេងចាក់ទឹកដូង បាយខុំ វាយហ៊ឹង និងល្បែងប្រជាប្រិយផ្សេងៗទៀតជាច្រើន ដែលល្បែងទាំងនោះ បានបង្កប់នូវរឿងជូចត់របស់ពួកគាត់ តើសព្វថ្ងៃមានកូនក្មេងខ្មែរប៉ុន្មាននាក់ ដែលចេះលេងល្បែងទាំងនោះ? របត់ថ្មីនេះ ពួកគេបានចាប់យកកាកសំណល់គំនិតបរទេស ដែលកំពុងបង្ហូរចូលមកក្នុងប្រទេសនេះ គឺល្បែងបច្ចេកវិទ្យាថ្មី លេងហ្គេម....។ល។

អត្ថន័យក្នុងឈ្មោះមេបទកាកគតិនេះ ពុំមែនមានន័យថា ដំណើរក្អែកលោតតែម្យ៉ាងប៉ុណ្ណោះទេ គឺមានបង្កប់នូវកាកគំនិតរបស់ដូនតា ដែលជាសំណល់អច្ឆរិយៈ សព្វថ្ងៃនេះពិភពលោកគេកំពុងស្ងើចសសើរ នៅកាកសំណល់គំនិតទាំងនេះ។ ពិសេសពួកអ្នកស្រាវជ្រាវ រុករកអាថ៌កំបាំងប្រាសាទបុរាណ(discovery) គេឆ្ងល់ថាមនុស្សរាប់ពាន់ឆ្នាំមុន ធ្វើសំណង់ប្រាសាទនៅលើដី តែប្លង់ប្រាសាទទាំងនោះ បានឆ្លុះជាមួយនឹងផ្កាយនៅលើមេឃ ចម្លើយធ្វើឲ្យពួកគេមិនអាចបកស្រាយបានឡើយ គឺមានតែពូជនាគតែមួយគត់ ដែលអាចយល់ប្រស្នានេះបាន។ ដូចជារឿងព្រះអាទិត្យមួយដួង អាចបង្កើតភាពអច្ឆរិយនៅលើពិភពលោក ក្នុងថ្ងៃតែមួយ គឺថ្ងៃទី២១ ខែមីនា(ផ្កាយរូបសត្វត្រី = ស្ត្រី) និងថ្ងៃទី២១ ខែកញ្ញា(ផ្កាយរូបស្ត្រីក្រមុំ)។ ព្រះអាទិត្យមួយដួងក្នុងថ្ងៃតែមួយនេះ ទី១រះចំកណ្ដាលកំពូលប្រាសាទអង្គរតូច ទី២រះចំកំពូលកណ្ដាលប្រាសាទពីរាមីត នៅប្រទេសអេហ្ស៊ីប ទី៣រះបង្កើតស្រមោលខ្លួននាគ នៅប្រាសាទម៉ាយ៉ាប្រទេសម៉ិចស៊ិកូ និងទី៤រះចំកណ្ដាលថ្ម លើកបន្តុបជារាងខ្លោងទ្វារ នៅប្រទេសពែរូ....។ ហេតុអ្វីបានជាមានភាពអស្ចារ្យអ្វីម្លេះ ដែលសំណង់ប្រាសាទថ្មក្នុងប្រទេសទាំងនេះ បានឆ្លុះទៅនឹងព្រះអាទិត្យ តែមួយដួងក្នុងថ្ងៃតែមួយ តើអ្នកប្រាជ្ញណាអាចរកចម្លើយនេះឃើញ? គឺមានតែធនជ័យតែម្នាក់គត់ ដែលអាចយល់ប្រស្នានេះបាន ព្រោះក្នុងរឿងគាត់បានប្រាប់យើងថា ពេលដែលអ្នកប្រាជ្ញចិន មកភ្នាល់យកនគរខ្មែរជាលើកទី២ ភាសាគរបស់គេគឺ

ចិនលើកដៃចង្អុលទៅលើមេឃ ធនជ័យលើកដៃចង្អុលទៅរកព្រះអាទិត្យ ចិនចង្អុលទៅក្រៅលាបាតដៃ ធនជ័យលើកម្រាមប្រាំបញ្ឈរឡើងទៅលើ ចិនចង្អុលចុះក្រោម ធនជ័យចង្អុលមកខ្លួនឯង(ចង់ដឹងពិស្ដាសូមមើលរឿងធនជ័យ)។ ដែលខ្ញុំបាទចង់ប្រាប់កូននាគឲ្យដឹងនោះ គឺដូនតានាគលោកបានដឹងពីភាពអច្ឆរិយនេះ តាំងពីរាប់ពាន់ឆ្នាំមុនម្ល៉េះ ព្រោះធនជ័យចង្អុលទៅព្រះអាទិត្យមានន័យថា ព្រះអាទិត្យបំភ្លឺលោកនេះទាំងមូល ហើយក្នុងថ្ងៃដែលអ្នកប្រាជ្ញធនជ័យចង្អុលនោះ បានបកស្រាយបំភ្លឺនូវភាពអច្ឆរិយ របស់ប្រាសាទរាងពីរាមីត នៅក្នុងលោកនេះទាំងអស់ ដែលប្រាសាទរាងសាជីទាំងនោះបានឆ្លុះទៅនឹងព្រះអាទិត្យមួយដួងនោះ។ សូមកូននាគប្រុសស្រី ពិចារណាបន្ថែមថា ទោះបីជាព្រះអាទិត្យមួយដួង ក្នុងថ្ងៃ២១មីនានិងថ្ងៃ២១កញ្ញា រះចំកណ្ដាលកំពូលពីរាមីតដ៏ច្រើន ក៏ពន្លឺព្រះអាទិត្យមួយដួងនោះ ពុំអាចជះពន្លឺចូលទៅក្នុង ប្រាសាទរាងសាជីទាំងនេះបានដែរ(និមិត្តរូប)។ លុះត្រាតែមានបុគ្គលណា អាចផ្ទារ ប្រាសាទរាងសាជី ឬក៏បើកគំរបកំពូលសាជីទាំងនោះ ឲ្យមានប្រហោងឡើងទើបពន្លឺព្រះអាទិត្យអាចចាំងបភ្លឺ ឲ្យយល់ពីរឿងរ៉ាវក្នុងប្រាសាទ រាងសាជីទាំងអស់នេះបាន។ ប្រស្នាកំបាំងទាំងនេះ ជាកាកគំនិតរបស់មនុស្សផ្កាយ កាលពីរាប់ពាន់ឆ្នាំមុន។ ពន្លឺក្នុងន័យប្រស្នានេះ ពុំមែនពន្លឺចំណាំងរបស់ព្រះអាទិត្យឡើយ វាគឺជាពន្លឺបញ្ញាញាណ ដែលផុះចេញពីគំនិតមនុស្សពូជផ្កាយពូជនាគ ពូជអច្ឆរិយ ដែលកើតចេញពីភ្នែកទីបី នៅចំកណ្ដាលថ្ងាស។ ដូចរូបចម្លាក់អាទិទេពក្មេរដែលមាននៅតាមប្រាសាទ ដូនតាក្មេរបានឆ្លាក់ភ្នែកនៅចំកណ្ដាលថ្ងាស ទាំងអាទិទេពស្រី និងអាទិទេពប្រុស។ ដូច្នេះហើយទើបដូនតា បានទុកប្រស្នាជាពាក្យប្រដៅកូនចៅពីអតីតថា **ល្ងីល្ងើមិនពកថ្ងាស** បើគ្រាន់តែពកថ្ងាសបាត់ល្ងើនោះ យើងមិនចាំបាច់ទៅរៀន តាំងពីថ្នាក់បឋម រហូតដល់សកលវិទ្យាល័យនោះឡើយ យើងគ្រាន់តែយករបស់រឹង មកវាយឲ្យចំកណ្ដាលថ្ងាស នោះថ្ងាសនឹងពកឡើងយើងបាត់ល្ងីល្ងើទៅហើយ។ តែន័យបង្កប់ក្នុងពាក្យនេះ ពុំដូច្នេះឡើយ គឺវាមានន័យផ្សេងរបស់វាទៅវិញ បើកូនក្មេរមិនកើតភ្នែកទីបីចំកណ្ដាលថ្ងាសទេ មិនអាចដឹងពីន័យកាកគំនិត ប្រាសាទរាងសាជីទាំងក្នុងប្រទេស និងនៅក្នុងលោកទាំងមូលនេះបានឡើយ។

បទកាកគតិនេះ ក្នុងមួយរបះមានពឃ្លា ក្នុងមួយឃ្លាមាន៤ព្យាង្គ មានន័យបង្កប់ថា សំណល់គំនិតពួកព្រហ្មពីអតីតកាល(ព្រហ្មមុខ៤) ត្រូវរស់នៅដោយឈឺចាប់ ជាមួយនឹងអ្នកទទួលមរតកទាំងប្រុសស្រី គ្រប់ៗថ្ងៃទាំង៧(ស្មើមួយសប្ដាហ៍) តាំងពីអតីតរហូតដល់បច្ចុប្បន្ន នេះជាន័យពិតដែលបង្កប់ទុកក្នុងឈ្មោះបទកាកគតិ។ សូមមើលអត្ថបទកំណាព្យខាងក្រោម:

**<u>កំណើតធនជ័យ</u>** (បទកាកគតិ)

**១.បទកាកគតិ តំណែលបិតិ**

**ជាកេរដូនតា ជាកាកគំនិត**

ទុកក្នុងសិលា រឿងរ៉ាវអច្ឆរា

មរតកម៉ែៗ

២.កំណើតធនជ័យ កើតដោយប្រពៃ

មានរឿងហូរហែ ម្តាយយល់សុបិន្ត

ដួងបេះទាំងផ្លែ ឃើញវង់ព្រះខែ

ពេញបូណ៌មីៗ

៣.ធ្លាក់ស្វាងពេលណា ម៉ែពិចារណា

សុបិន្តរាត្រី ឃើញហេតុចម្លែក

សែនល្អពេកក្រៃ ចង់ដឹងពីន័យ

ទៅរកគ្រូទាយៗ

៤.ទៅផ្ទះហោរា មិនជួបនឹងតា

បានជួបតែយាយ ស្តាប់ពាក្យរ៉ាយរ៉ាប់

អ្នកមករកទាយ យាយបែរទំនាយ

ប្រាប់ន័យបង្ខុសៗ

៥.ហេតុតែច្រណែន សប្តិល្អមែនទែន

កើតចិត្តប្រទុស្ត ព្រោះកើតមោហ:

និយាយបង្ខុស យាយទស្សន៍ទាយនោះ

ចិត្តបាបពេកក្រៃៗ

៦.ម្តាយចាប់មានគភ៌ គ្រប់ថ្ងៃទ្វារទរ

ប្រសូត្របុត្រថ្លៃ តាំងនាមឲ្យឈ្មោះ

កុលបុត្រធនជ័យ កុំឲ្យបុត្រថ្លៃ

ធំឡើងខ្ញុំគេៗ

៧.ធនជ័យធំឡើង ម៉ែឪ្យតំកើង
មិននៅផ្ទះទេ ទៅលេងឯផ្ទះ
សេដ្ឋីជាមេ អ្នកមានលើសគេ
ក្នុងទឹកដីនោះៗ

៨.រឿងហេតុកើតឡើង សេដ្ឋីនីយើង
ត្បាញហូលគ្រល់ជ្រុះ ប្រើជ័យឲ្យរើស
ឈ្ងួលអំបុកជួស រឿងកើតពេលនោះ
ស្បូត្រនិងអំបុកៗ

៩.ស្បូត្រតាងឲ្យនាង និមិត្តរូបរាង
ជាប់ក្នុងសំបុក គេយកទៅស្ងោរ
នាងនាគរងទុក្ខ ចិត្តកាយជាប់គុក
ព្រោះហេតុតែកេរៗ

១០.ចំណែកអំបុក ប្រស្នាចារទុក
តាងឲ្យព្រះមេ ស្រូវលើងឲ្យឆ្អិន
ទុក្ខកើនឡើងទ្វេរ រួចបុកព្រះមេ
បាត់រូបរាងដើមៗ

១១.នេះគឺជាហេតុ ដែលនាំកើតភេទ
រឿងជ័យចាប់ផ្ដើម កើតពីព្រះមេ
តាងឲ្យម្ដាយដើម ដែលជាសំណើម
ប្រាជ្ញចាប់កំណើតៗ

១២.ជ័យពិចារណា សេដ្ឋីយាយតា
ដែលបានរស់កើត សោយកេរព្រះមេ

មរតកល្អឆើត ម្ដេចឆ្លេចកំណើត
ចិត្តលោភប្រវ័ញ្ចៗ
១៣.សូម្បីតែក្មេង នៅតូចរត់លេង
សេដ្ឋីតាមផ្ចាញ់ មិនសង្វេគសោះ
រិតរូបចម្រាញ់ ប្រឹងកេងប្រវ័ញ្ច
ក្នុងដែនព្រះម៉ែៗ
១៤.ធនជ័យតស៊ូ ធ្វើជាគ្រូ
ក្នុងនាមកូនខ្មែរ ចិត្តងើបប្រឆាំង
គគ្នាហូរហែ តាងឲ្យវង្សខែ
រះពេញបូណ៌មីៗ
១៥.ជ័យផ្ចាញ់ទាំងអស់ មិនឲ្យសល់សោះ
តាំងពីសេដ្ឋី ពីតូចទៅធំ
នាម៉ឺនមន្ត្រី ក្សត្រស្ដេចផែនដី
ដែលពុំដឹងគុណាៗ
១៦.ឲ្យកូនម៉ែឆ្ងាក់ មើលឃើញវង្សត្រកូល
ព្រហ្មរងទុក្ខធ្ងន់ ព្រោះហេតុតែកេរ
ម៉ែឪលោភលន់ ទទួលទុក្ខធ្ងន់
កប់ទឹកគក់ដីៗ
១៧.ជ័យស៊ូនឹងចិន នាំប្រាជ្ញវ៉ៃប៉ិន
មកយកបុរី ស្លាប់ខ្លួនជាតិរស់
ដោះប្រស្នាបី រក្សាទឹកដី
មរតកព្រះរស់ៗ

១៨.ហេតុតែប្រទេស ស្តេចនិរទេស
ជ័យជួបនឹងគ្រោះ ដើម្បីកេរម៉ែ
ជ័យហានប្រទូស្ត ថាស្តេចចិននោះ
មុខដូចសត្វឆ្កែ។

១៩.ចិនចាប់ដាក់គុក កាយចិត្តពុំសុខ
រិះគិតហួរហែ ល្បួចបង្ហោះខ្លែង
តាងឲ្យកេរម៉ែ ឥពូជពង្សខែ
សោមខ្មែរអច្ឆរា។

២០.ចុងក្រោយចិនចាញ់ បណ្ឌិតលោកផ្ចាញ់
ដោយចោទប្រស្នា ទុកឈ្មោះខ្លែងឯក
មរតកជូនតា ទុកជាប្រស្នា
ន័យកាកគំនិត។

២១.ចំណែកខ្លែងឯក មានអ្វីគួរប្លែក
ក្រដាសមួយសន្លឹក មិនបែរចុះចាញ់
ជ័យប្រាជ្ញបណ្ឌិត ប្រស្នាគំនិត
ជ័យទុកឲ្យកូន។

២២.ចុងក្រោយជ័យផ្តាំ ឲ្យកូនម៉ែចាំ
កុំឲ្យសាបសូន្យ សំណល់គំនិត
ជ័យទុកឲ្យកូន ធ្វើជាទូកក្បូន
ដោះប្រស្នាបី។

២៣.កូនកុំបណ្តោយ បើកូនបានសោយ
កូនត្រូវដឹងន័យ ដឹកនាំនគរ

ឲ្យខ្ពស់ថ្លៃថ្លៃ ត្រូវស្គាល់អត្ថន័យ

សត្វត្រី(ស្ត្រី)ប្រស្នា។

២៨.ប្រស្នាជ័យហោង តាមដោយគន្លង

នៃក្បួនតម្រា បណ្ឌិតទុកពាក្យ

បេះដូងទេវតា ដែនដីសួគ៌ា

កត្តញ្ញូនាំសុខ។

២៩.សូមបញ្ចប់ស្លេះ សង្ខេបប៉ុណ្ណោះ

ស្លូត្រនិងអំបុក បង្កើតប្រាជ្ញជ័យ

រៀបរាប់ទំនុក ជ័យជួបតែទុក្ខ

ឲ្យតែជាតិរស់។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស ២៥៥៥ ត្រូវនឹងថ្ងៃទី១៦ មិថុនា គ.ស ២០១១

រៀបរៀងចងក្រងដោយឧបាសក **គៀត ចាន់ផុន**

**<u>៤.បទព្រហ្មគីតិឬព្រហ្មគិត</u>**

*កូនក្មេរជំនាន់ក្រោយតែងហៅមេបទនេះថា ព្រហ្មគីតិឬចម្រៀងព្រហ្ម ឈ្មោះរបស់មេបទនេះន័យពិតរបស់វាតើដូចម្ដេច?*

**<u>ពន្យល់ពាក្យ</u>**

*ព្រហ្មគីតិ(ព្រំម:គីតិ, ម្ម--គីត) ន. (បា. ព្រហ្ម "ព្រហ្ម" + គីតិ "ចម្រៀង") ឈ្មោះកាព្យមួយយ៉ាងមានជើង៤គឺក្នុងមួយរបះមាន៤ឃ្លា, ត្រង់ឃ្លាទី១និងទី៣មាន៥ពាក្យ, ឃ្លាទី២និងទី៤មាន៦ពាក្យ : បទព្រហ្មគីតិ (ដកចេញពីវចនានុក្រមសម្ដេច)ព្រហ្មគិត ការគិតទុក របស់ ព្រហ្ម (ភាសានិយាយ)*

*តើន័យរបស់មេកាព្យនេះ មានខ្លឹមសារពិតយ៉ាងណា? បើតាមការស្រាវជ្រាវ ឲ្យជាប់ទៅនឹងឬសកែវរបស់ដូនតាមហានគរ យើងអាចយល់បានថា គឺពុំមែនព្រហ្មជាទេវតាឬអាទិទេពណា មកគិតតែងចម្រៀងឬមេកាព្យ ទុកឲ្យកូនក្មេរយើងឡើយ។ ព្រោះភារ:នេះជាកិច្ចរបស់ព្រហ្មក្មេរ អ្នកដឹកនាំក្មេរ ដែលជាអ្នកបង្កើតមាតុភូមិនេះ ខំប្រមែប្រមូលមរតកកេរគ្រប់បែបយ៉ាង មកទុកឲ្យកូនក្មេរខាងក្រោយ គ្រប់ជំនាន់សោយនូវផលកេរនេះ។ ដូចនេះយើងតែងឮសូរពាក្យពោលត្អូញត្អែ របស់អ្នកមានទុក្ខព្រួយធ្ងន់តែងនិយាយថា នេះជា**ព្រហ្មលិខិត** យើងមិនបាននិយាយថាកម្មលិខិតឡើយ ក្នុង*

*នាមយើងជាអ្នកគោរពព្រះពុទ្ធសាសនា យើងពុំបានជឿទៅលើអំពើកម្ម ដែលយើងបានសាងទុកក្នុងអតីតកាល បច្ចុប្បន្នកាល ដែលកម្មនេះកំពុងតែឲ្យផល វិបាកជាសុខឬទុក្ខ។ អ្វីទៅជាព្រហ្មលិខិត? តើអាទិទេពព្រហ្មមានអំណាចអ្វី មកដាក់ទុក្ខទោសឲ្យសព្វសត្វ ជាពិសេសគឺកូនខ្មែរនោះ? តាមការស្រាវជ្រាវពាក្យថាព្រហ្មលិខិត យើងអាចយល់បានថា ព្រហ្មដូនតាយើងលោកទុកលិខិតសារបណ្ដាំនៅក្នុងថ្មគ្រប់ប្រាសាទពីអតីត ទំនៀមទម្លាប់ប្រពៃណី..... ដោយកូននាគពុំបានឈ្វេងយល់ យើងបែរជាយល់ច្រឡំថាជាលិខិតព្រហ្ម របស់ព្រហ្មញ្ញសាសនាទៅវិញ។ ដូនតាឲ្យយើងមើលថ្ម ដែលជាភាសាគប្កភាសញ្ញា ហេតុអ្វីរូបចម្លាក់ពួកគាត់មានតែក្បាល? តើដងខ្លួនពួកគាត់បាត់ទៅណា? ក្នុងនាមយើងជាអ្នកទទួលមរតកអច្ឆរិយនេះ តើមានឆ្ងល់ដែរឬទេ? សារលិខិតរបស់ព្រហ្ម របស់កបិល មហាព្រហ្មគឺសិរសា(ក្បាល) ដែលជាប្រស្នារបស់ដូនតាយើង ក្នុងមួយឆ្នាំកូននាំគ្នាហែហម រំលឹកគុណគាត់បានម្ដង ក្នុងថ្ងៃសង្ក្រាន្តចូលឆ្នាំថ្មី តើរឿងនេះកើតមានមុនថ្ម ឬក៏ថ្មកើតមានមុនរឿង? ហេតុអ្វីសិរសាកបិលមហាព្រហ្ម ដែលដង្ហែរាល់ឆ្នាំ សាកសពនេះម្ដេចមិនស្អុយ មិនរលួយមិនស្លាប់ចេញពីសណ្ដានចិត្តកូនខ្មែរ? ចូរកូននាគទាំងឡាយ ពិចារណារកព្រហ្មពិតឲ្យឃើញ ទើបយើងអាចស្គាល់បេះដូងព្រហ្ម ដែលជាពូជនាគនិងពូជអច្ឆរិយ ព្រោះវាជានិមិត្តរូបរបស់ដូនតាយើង។*

*ដូចមេកាព្យព្រហ្មគីតិនេះ បើព្រហ្មចង់ច្រៀងត្រូវតែត្រិះរិះគិត ទើបច្រៀងចេញមកបាន ដូច្នេះចម្រៀងព្រហ្មគ្គី(ព្រហ្មគីតិ) ការគិតទុករបស់ព្រហ្មគ្គី(ព្រហ្មគិត) គឺមានន័យតែមួយដូចគ្នា បើពុំត្រិះរិះគិត គឺពុំអាចច្រៀងចេញបានឡើយ។ ព្រហ្មគីតិឬព្រហ្មគិត គឺជាការស្រែកច្រៀងរៀបរាប់ ប្រាប់ពីទុក្ខវេទនា ដែលខ្លួនបានក្លាយជាព្រាយ ប្រេត.... នៅក្នុងអបាយភូមិ ដោយគាត់មានសង្ឃឹមថា នឹងមានកូននាគណាម្នាក់ បានយល់ពីអាថ៌កំបាំងប្រវត្តិសាវតាររបស់ពួកគាត់ ហើយគេនឹងជួយដោះទុក្ខ។ សូមមើលអត្ថបទកំណាព្យខាងក្រោម:*

## <u>**គំនិតព្រហ្មឬការគិតរបស់ព្រហ្ម**</u> = (បទព្រហ្មគិត)

| | |
|---|---|
| ១.ចិន្ដាឱរាព្រហ្ម | ខំពូតផ្គុំផ្គុំគំនិត |
| ទុកបទព្រហ្មគិត | ជាប្រស្នាឲ្យកូនស្រាយ។ |
| ២.ព្រហ្មពិតជាអ្នកណា | ព្រះមាតាបិតាថ្លៃ |
| គិតកូនគ្មានធ្លោយណាយ | ហេតុតាំងខ្លួនជាព្រះរស់។ |
| ៣.វិហារធម៌ទាំងបួន | គ្រងគ្រប់កូនការពារគ្រោះ |

ម៉ែឪរងជំនួស ហេតុតែកូនសុខចិត្តឫាប១

៤.ធម៌មួយគឺ**មេត្តា** ថែរក្សាឲ្យឱវ៉ាទ

លំបាកលុតលួនក្រាប ទុក្ខលំបាកគិតចម្បែង១

៥.ធម៌ពីរគឺ**ករុណា** គិតបុត្រត្វាអាណិតក្រែង

ខ្លាចកូនពុំប្រឹងប្រែង សន្សំបុណ្យរៀនដឹងចេះ១

៦.ធម៌បីគឺ**មុទិតា** ចិត្តជ្រះថ្លាគិតរិះត្រិះ

សប្បាយនិងកូនចេះ មិនធ្លាក់ខ្លួនដើរផ្លូវខុស១

៧.ធម៌បួនគឺ**ឧបេក្ខា** ចិត្តល្អថ្លាមានសន្តោស

កណ្តាលមិនជ្រុលហួស កូនសុខទុក្ខគិតតាមកម្ម១

៨.ព្រហ្មគិតពិតមានមែន ព្រហ្មជាក់ស្តែងគង់វង់ចាំ

ឲ្យក្មេងស្រាយបណ្តាំ ការគិតទុករបស់ព្រហ្ម១

៩.ធ្លាក់មុខទុកលើថ្ម ពូជអ្នក**ក**បែរជាយំ

ព្រោះកូនពុំស្គាល់ព្រហ្ម ម៉ែឪខំឱបទុក្ខព្រោះបុត្រ១

១០.ពេលណាទើបកូនដឹង ចេះសញ្ជឹងដើបពីចៀត

កើតភ្នែកទើបរួចផុត ព្រោះការគិតភ្នែកក្នុងថ្ងៃស១

១១.កូនក្រោកទើបស្វាងថ្លា ភ្នែកបញ្ញាភ្លឺឱកាស

ស្គាល់ព្រហ្មពិតល្អណាស់ ពុំមែនព្រហ្មនៅឯនាយ១

១២.ព្រហ្មពិតនឹងបានសុខ រួចផុតទុក្ខកម្មពីឆ្ងាយ
ម៉ែពុកអរសប្បាយ គំនិត[២]ព្រហ្មកូនបានយល់ៗ

១៣.ព្រហ្មចរិយធម៌ ថ្លៃថ្លាល្អផ្ដាច់ឫសគល់
អវិជ្ជាអស់គ្មានសល់ ដល់មណ្ឌលឋានអមត:[៣]ៗ

ពន្យល់ន័យ ១.ព្រហ្មញ្ញសាសនា ២.អ្នកបង្កើតប្រាសាទមុខព្រហ្ម ៣.ឋាននិព្វាន

ថ្ងៃព្រហស្បតិ៍ ១កើត ខែជេស្ឋ ឆ្នាំថោះត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃទី២ មិថុនា ២០១១

រៀបរៀងចងក្រងដោយ ឧបាសក **គៀត ចាន់ផុន**

## ទំនួញព្រហ្មលិខិត ឬលិខិតព្រហ្ម

១.ចំណារគតិព្រហ្ម ខំពូតផ្ដុំចារលិខិត
ប្រស្នាកាព្យគំនិត ចារលើថ្មឲ្យកូនស្រាយៗ

២.ពាក្យថាព្រហ្មលិខិត ន័យក្អែរពិត**ឥ**ស្រឡាយ
ពុំមែនព្រហ្មញ្ញនាយ គឺគំនិតព្រះព្រហ្មក្អែរៗ

៣.លិខិតចារលើថ្ម ពេញនគរជាប់ហូរហែ
គំណរាងឲ្យកេរម៉ែ(ក្អែរ) ញញឹមទុកបង្កប់ន័យៗ

៤.ហេតុម្ដេចលោកមិនទុក លិខិតពុទ្ធសាស្ដាស្រី
ពុទ្ធសាសចូលដែនដី សុវណ្ណភូមិស្រុករគ្នាៗ

៥.ទុកតែលិខិតព្រហ្ម យើងទួញយំស្រែកគគ្នា

ព្រហ្មលិខិតតាមចងពៀរ តើព្រហ្មាមានសិទ្ធិអ្វីៗ
៦.មកដាក់បណ្ដាសារ យើងគ្រប់គ្នាទាំងប្រុសស្រី
តាមពិតកម្មអតីត បុត្រប្រុសស្រីបានសាងមកៗ
៧.ពុំមែនលិខិតព្រហ្ម ចាប់បង្ខំឲ្យកូនយក
គ្រោះឬបាបកម្មទុក្ខសោក តាមអំណាចព្រះព្រហ្មឡើយៗ
៨.ឬបាបកូនតឹទង្វើ ដែលកូនធ្វើទុកមកហើយ
ពុំមែនសារព្រហ្មឡើយ ព្រះសាស្ដាព្រះអង្គផ្ដាំៗ
៩.ថាសត្វលោកទាំងអស់ ប្រព្រឹត្តិឆ្ពោះតាមផលកម្ម
ចក្រវិលតាមលំនាំ ដានស្នាមកម្មមានហើយពិតៗ
១០.ហេតុអ្វីបានជាបែរ នាំគ្នាថែព្រហ្មលិខិត
ពាក្យចេញពីគំនិត លិខិតព្រហ្មកប់ក្នុងថ្មៗ
១១.លិខិតតឹសិរី(សិរីបី) ចូលឆ្នាំថ្មីថ្ងៃបវរ
សង្ក្រាន្តនាំតំណរ លិខិតព្រហ្មចាញ់ប្រស្នាៗ
១២.ហេតុតែមានអំនួត មានៈអ្នួតថាអស្ចារ្យ
តាំងខ្លួនជាមាតា បិតាពិតបង្កើតពៀរៗ
១៣.នាំគ្នាប្រព្រឹត្តខុស មានកំហុសនឹងព្រហ្មមារ
លោកត្រូវបណ្ដាសារ កម្មនាំទុក្ខព្រោះតែគេរៗ

១៨.តើកូនម៉ែមានឆ្ងល់ កើតចម្ងល់នឹងព្រហ្មទេ
ព្រហ្មក្មេរពីបុព្វ មានតែក្បាលពុំមានខ្លួនៗ

១៥.តើខ្លួនបាត់ទៅណា មានសិរសាប្រាណបំពួន
បុត្រត្វាថ្លៃនឹមនួន ដោះប្រស្នាលិខិតព្រហ្មៗ

១៦.ធម្មបាលមានវាសនា ស្តាប់ចរចាឥន្ទ្រីធំ
មេកូនក្នុងទ្រនំ និយាយប្រាប់រឿងធម្មបាលៗ

១៧.ឥន្ទ្រីគឺជាអ្វី បុត្រប្រុសស្រីស្តាប់តំណាល
រឿងកើតមានក្នុងកាល កន្លងទៅស្ទើរលុបដានៗ

១៨.ឥន្ទ្រីយ**មួយ**សទ្ធា **ពីរ**វិរិយាតាមលំអាន
**បី**សតិប្បដ្ឋាន **បួន**សមាធិនាំចិត្តស្ងប់ៗ

១៩.ឥន្ទ្រីយ**ប្រាំ**មាំក្លា គឺបញ្ញាហ៊ានគាស់កាប់
មោហ:ឲ្យដេកស្លាប់ កុំច្រឡំសត្វឥន្ទ្រីៗ

២០.ឥន្ទ្រីយក្នុងបស្សនា តាមគម្រាមាន**ម្ភៃពីរ**
ដើមគេចក្ខុន្ទ្រីយ ចុងអញ្ញាតាវិន្ទ្រីយៗ

២១.កបិលមហាព្រហ្ម នៅក្នុងឃុំរូងគីរី
បុត្រីមាន**ប្រាំពីរ** ចរលើលានាំគ្នាថៃៗ

២២.បុត្រពិត**ពីរដណ្តប់** កូនសំណប់តាងម្តាយក្មេរ

តាមពិតអ្នកមកថៃ មាន**ប្រាំពីរ**ដែលចេះនឹកៗ

២៣.ទឹកក្នុងបេះដូងគេ ត្រូវថ្ងៃខែស៊ីសាច់ទឹក(ដួងខែស៊ី)

ធ្វើឲ្យគេភ្លេចភ្លឹក ឈប់រំលឹកពីព្រហ្មថ្លៃៗ

២៤.ឯកូនទាំងប្រាំពីរ ដែលសល់ពីកូនឥតន័យ

ប្រចាំគ្នាពេកក្រៃ ផែនអ្នកណាហ្នឹងទៅហៃៗ

២៥.ចំណែកអ្នកឯទៀត គ្មានពេលឆ្លៀតមកជួបម៉ែ

ដោះសារកិច្ចបង្វែរ ថារវល់ព្រោះអត្តាៗ

២៦.អស់ឪព្រហ្មលិខិត កម្មព្រហ្មពិតតាមយថា

កម្មសាងជាចំណារ ទុក្ខំណែនទ្រូងស្រែកដង្ហោយៗ

២៧.ព្រហ្មថ្មកើតមានមុន ក្បិលមហាព្រហ្មកើតមានក្រោយ

ប្រស្នាទុកកូនស្រាយ ពីសិរិបីប្រការ(ស្រីបី)ៗ

២៨.ធម្មបាលអ្នកឃាមធមី បើកទ្វារតតីដោះប្រស្នា

លិខិតដែលព្រហ្មចារ ម៉ែឪសុខដល់ត្រើយនាយៗ

២៩.សាស្តាត្រាស់ដឹងឯង ទ្រង់សម្តែងសព្វបរិយាយ

ឲ្យសាវ័កត្រួសត្រាយ ដោយបញ្ញាគិតសឹមជឿៗ

៣០.កុំជឿឮគេថា តាមតម្រាឬជំនឿ

ឈ្ងេងយល់ផុតទាបតឿ សច្ចៈមានកូនត្រូវយល់ៗ

៣១.មែកស្លឹកផ្លែផ្កាបាន មានលំអានឬសនិងគល់
លិខិតព្រហ្មបន្សល់ ព្រោះព្រហ្មពិតគឺឪម៉ែៗ

៣២.បើកូនបានសោយកេរ ត្រូវរិះរករកគល់ខ្សែ
រាវរកពូជពង្សខែ ដែលមានកម្មពីអតីតៗ

៣៣.ហូបបាយនឹកឃើញព្រះ ខ្ពស់ល្អណាស់ព្រះមេស្រី
អ្នកទេកើតទឹកដី ព្រះម៉ែក្សត្រពូជពង្សព្រហ្មៗ

៣៤.បើព្រហ្មលោកបានសុខ ចាកផុតទុក្ខពៀរគំនុំ
ចំណាររបស់ព្រហ្ម កូនបានដោះប្រស្នាហើយៗ

៣៥.កូនម៉ែអើយធ្លាក់ឡើង លើកតម្កើងកុំព្រងើយ
ព្រហ្មពិតផុតទុក្ខហើយ ព្រហ្មមុនក្រោយបានសុខាៗ

ថ្ងៃច័ន្ទ ៨កើត ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃទី៦ មិថុនា គ.ស២០១១

រៀបរៀងដោយឧបាសក **គៀត ចាន់ផុន**

**៥.បទពំនោល**

**ពន្យល់ពាក្យ**

***ពំនោល*** ( *ន.* ) *ដំណើរដែលពោល, ពាក្យពោល; បទពោលល្ខោន។ឈ្មោះកាព្យមួយយ៉ាងមានជើងបី គឺក្នុងមួយរបះមានឃ្លាបី, មានចួនបី, ឃ្លាទី១, និងទី៣មាន៦ពាក្យ, ឃ្លាទី២មាន៤ពាក្យ : បទពំនោល, ដូចជា : យក្សក្រោធច្រឡោតខ្លាំងក្រៃ ស្ទុះហោះច្រៀវច្រៃ ពួតដៃកំញើញគួរស្ញែង។ ស្រែកហ៊ោសន្ធាប់ឥតក្រែង ថាវ៉ីយប្រស្តែងម្តេចឯង ពុំកោតចេស្តា។(ដកចេញពីវចនានុក្រមសម្តេច)*

*តើបទពំនោលនេះ ដូនតាយើងគាត់បន្សល់អត្ថន័យ ពោលទុកពីរឿងអ្វី? ឈ្មោះមេកាព្យបួនបទខាងដើម ខ្ញុំបាទបានពន្យល់រួចហើយ ពីន័យរបស់ឈ្មោះ បង្កប់ទុកក្នុងមេកាព្យទាំងនោះ ចំណែកមេបទពំនោលនេះ ក៏មិនខុសអ្វីពីន័យមេកាព្យ ទាំងបួនខាងលើឡើយ។ ដូនតាយើងជាម្ចាស់មរតក*

*អច្ឆរិយ លោកបានពោលជាបទពំនោលត្អូញត្អែ រៀបរាប់ទុក្ខសោករបស់ខ្លួន ដែលបានតាំងខ្លួនជាម៉ែ (ស្ករតាំងម៉ែ)តាំងខ្លួនជាឪជាព្រហ្មជាអាទិទេព ត្រួតត្រាទឹកដីពង្វាតទឹកដី តាំងខ្លួនជាមេជាធំលើគេ ទីបំផុតនៃសេចក្ដីលោភ បានត្រឹមតែពោលរៀបរាប់ ពីការខកខ្លួនស្ដាយក្រោយ ក្នុងនាមជាអ្នកទោស ជាព្រាយ ជាប្រេត បិសាច.... តើមានកូនណាយល់ន័យក្នុងពំនោលរបស់មេ(ម៉ែ) ដែលបានពោលរៀបរាប់នេះ? កូននាគជំនាន់ក្រោយ បានត្រឹមតែយកមេបទ មកតែងបន្តទៅតាមគំនិតរបស់ខ្លួន ធ្វើដូចម្ដេចអាចជួយស្រាយប្រស្នា បង្កប់នូវរឿងទុក្ខព្រួយរបស់ម្ចាស់មេបទនេះបាន? នេះជាផលកម្ម ដែលពួកគាត់ត្រូវទទួល ដោយពួកគាត់បានសាង សាបព្រោះនៅពូជនេះទុកឲ្យខ្លួនឯង ដូច្នេះផលនៃទុក្ខរមែងកើតឡើង។ នៅក្នុងគម្ពីព្រះត្រៃបិដក ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានត្រាស់សម្ដែងរៀបរាប់ប្រាប់ រឿងរបស់អានន្ទសេដ្ឋី ដែលជាបុគ្គលមច្ឆរិយកំណាញ់ មាននូវមច្ឆាទិដ្ឋិគឺការយល់ខុស ពុំជឿទៅលើកម្មនិងផល ទីបំផុតក្រោយពីច្យុតិចិត្តគឺស្លាប់ កម្មបានរៀបចំឲ្យគាត់កើតជាមនុស្ស ក្នុងត្រកូលចណ្ឌាល ដែលជាមនុស្សត្រកូលថោកទាប ក្ររហេមរហាម សូម្បីតែរូបរាងកាយគាត់ ក៏ខុសប្រក្រតីពីមនុស្សធម្មតា។ ឪពុកម្ដាយដែលគាត់ទៅបដិសន្ធិគឺកើតជាមួយ ត្រូវវេទនាក្ររហេមរហាមរកអាហារបរិភោគស្ទើរពុំបាន ដោយអំណាចបាបកម្មរបស់សេដ្ឋីនោះ ចំហាយនៃបាបរបស់គាត់នេះ បានជះផ្សាយទៅឲ្យញាតិដែលនៅជុំវិញ។ ពេលក្រោយមកទើបព្រះសម្មាសម្ពុទ្ធ បានជួបនឹងត្រាស់សម្ដែងគាថា ប្រារព្ធទៅលើរឿងអានន្ទសេដ្ឋី*

***១.បុគ្គលពាលល្ងង់ខ្លៅតែងសម្លាប់ប្រយោជន៍ខ្លួនឯងផង និងសម្លាប់ប្រយោជន៍អ្នកដទៃដែលនៅជុំវិញខ្លួនផង***

***២.បុគ្គលពាលល្ងង់ខ្លៅ តែងប្រកាន់យល់ថាខ្លួនមានទ្រព្យ យសសក្តិ បុត្រ ភរិយា ញាតិ.. ទីបំផុត សូម្បីតែខ្លួនឯង ក៏មិនមានផង តើមានទ្រព្យ យសសក្តិ បុត្រ ភរិយា ញាតិ... មកពីណា?***

*ពំនោលពោលរៀបរាប់ នៅរឿងទុក្ខវេទនាសព្វបែបយ៉ាង ដែលពួកគាត់បានយក ទៅលាក់បង្កប់ទុក ក្នុងទំនៀមទម្លាប់ប្រពៃណី សាសនា សំណង់ប្រាសាទ សិល្បៈ ចម្លាក់...... ជាពិសេសនោះគឺន័យរបស់ឈ្មោះមេកាព្យទាំងអស់នេះ។ ពំនោលពោលរឿងពិត របស់ម្ចាស់មរតក ឬសគល់អ្នកបង្កើតជាតិទាំងមូល ដោយសង្ឃឹមថាថ្ងៃណាមួយ កូននាគនឹងយល់ នូវអាថ៌កំបាំងប្រស្នាទាំងអស់នេះ ហើយគេនឹងជួយដោះទុក្ខខ្លួនជាពុំខាន។ សូមមើលកំណាព្យខាងក្រោម:*

**<u>ពំនោលមាតាមហានគរ</u>** (បទពំនោល)

| | | |
|---|---|---|
| ១.សូសៀងសំនៀងពំនោល | ដូនតាបានពោល | ពំនោលទុកជាមេកាព្យៗ |
| ២.ជាពូជទុកឲ្យកូនសាប | ជានាមកំណាព្យ | មេកាព្យមានតែឈ្មោះបីៗ |

៣.ឲ្យកូនយល់ដឹងអត្ថន័យ ប្រស្នាសិរី ឆ្នាំថ្មីមានបីប្រការ។

៤.សង្គ្រានតំណែលដូនតា ទុកន័យប្រស្នា ចំណារជាលិខិតព្រហ្ម។

៥.ពំនោលពោលប្រាប់ទុក្ខធំ ព្រហ្មជាប់ក្នុងឃុំ រូងគ្គិគិរី[១]សុមេរុ។

៦.ព្រហ្មតាងតំណាងព្រះម៉ែ ម្ចាស់មរតកក្មេរ ព្រះម៉ែជាម្ចាស់[២]សិរី។

៧.កប់ខ្លួនទៅក្នុង[៣]ទក់ដី ព្រះម៉ែនាគថ្លៃ ខ្លួនស្រីត្រូវរាហូលេប។

៨.លោភតោនាំចិត្តឲ្យសេព នាំឲ្យពង្សទេព យក្សលេបក្លាយជា[៤]បីសាច។

៩.អកុសលគួរឲ្យខ្លាច ព្រោះហេតុអំណាច កម្មកាចកើតពីចិត្តលោភ។

១០.កម្មនាំសោយផលស្មោកគ្រោក សោយទុក្ខវិយោគ សោយសោកពុំមានកូនដឹង។

១១.កាលមនុស្ស[៥]ព្រហ្មទ្វេរខំប្រឹង ឱ្យបលោភច្រើនម្លឹង ស្រវឹងនឹងទ្រព្យទុកកេរ។

១២.ទុកឲ្យអ្នកសោយកេរម៉ែ រស់សុខល្មើយល្ហែ កូនក្មេរពុំស្គាល់ពំនោល។

១៣.ដូនតាចងកាព្យរួចពោល កាព្យបំភ្លឺទ្រោល ពាក្យពោលបង្កប់ទុកន័យ។

១៤.កូនកើតឈ្មោះថាប្រាជ្ញជ័យ ដោះប្រស្នាបី ចិន[៦]តែមកយកនគរ។

១៥.ប្រាជ្ញជ័យលោកបើកទ្វារគតិ ដោះតាសាគ រក៏ប្រាជ្ញជួយជ័យជួបជោគ។

១៦.ពំនោលពោលប្រាប់ពីសោក ជ័យមានក្នុងលោក ជួបសោកច្រើនជាងជួបសុខ។

១៧.ជាតិរស់ចិត្តបានស្រណុក ខ្លួនមានក្តីសុខ ជាតិទុក្ខចិត្តខ្លោចផ្សាក្រៃ។

១៨.ជិតស្លាប់ចិត្តនៅរវៃ ពោលប្រស្នាបី ឲ្យស្តេចចងចាំរិះគិត។

១៩.ពំនោលពោលពីគំនិត ពង្ស[៧]ជ័យប្រាជ្ញពិត ពូជពិតសាងប្រាសាទថ្ម។

| | | |
|---|---|---|
| ២០.តំណែលហូរហែបន្ត | រៀបរាប់ដំណា | វង្សថ្មត្រូវដាច់ដំណឹង។ |
| ២១.[8]ចោលក្រុងព្រៃដុះជិតឈឹង | កូនម៉ែលែងដឹង | ឈប់ទ្រឹងគគាំងដូចថ្ម។ |
| ២២.ពំនោលលែងពោលបន្ត | ការត្រិះរិះល្អ | កើតមានគ្រប់ញាតិសន្តាន។ |
| ២៣.ពំនោលពោលត្រូវសុខសាន្ត | ចិត្តសុខក្សេមក្សាន្ត | ស្គាល់ធម៌ដល់អមតៈសុខ។ |

១.ន្ទិព្រះសុមេរ ២.ស្រីបីប្រការ ឬសិរីបីប្រការ ៣.ថ្មតក់ ៤.បីសាចពស់(ឯកសារចិនជីវតាក្វាន់ ៥.ព្រះម៉ែខ្មី ៦.គែបន្លិ៧.ពូជជ័យវ៉ែន ៨.ការបោះបង់ចោលក្រុងអង្គរជាង១០០ឆ្នាំ

ថ្ងៃ១២រោច ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃអង្គារ ទី២៨ ខែមិថុនា ឆ្នាំ២០១១

ដោយខ្ញុំព្រះករុណាខ្ញុំបាទ **គៀត ចាន់ផុន**

## <u>៦.បទបន្ទោលកាកឬបន្ទោកាក</u>

**<u>ពន្យល់ពាក្យ</u>**

***បន្ទោល*** = *ពាក្យនេះក្នុងវចនានុក្រមសម្តេច ពុំមានការពន្យល់ឡើយ*

***បន្ទោ*** *( កិ. ) បញ្ចេញ, បន្លយ, នាំចេញ : បន្ទោឧច្ចារៈ, បន្ទោបស្សាវៈ, បន្ទោសេចក្តីក្រោធ។ (ដកចេញពីវចនានុក្រមសម្តេច)*

*តើន័យពិតរបស់ឈ្មោះមេកាព្យនេះ បន្ទោលកាកឬបន្ទោកាក? ខ្ញុំបាទពន្យល់រួចហើយពីមេបទកាកគតិ ពេលនេះយើងបានមកស្គាល់មេបទទី៦ គឺបន្ទោកាក មានន័យថានាំចេញឬបន្ទោចេញកាកសំណល់គំនិត ដែលបានគិតទុកក្នុងចិត្ត មកដាក់ជាឈ្មោះមេកាព្យ ប្រាសាទ ភូមិស្រុក ភ្នំ...... ដោយលោកសង្ឃឹមថា នឹងមានកូននាគណាមួយគេឆ្ងល់ រួចពិចារណាគេនឹងអាចដឹងពីអាថ៌កំបាំងដែលបង្កប់ក្នុងឈ្មោះមេកាព្យនេះ។ ក្តីសង្ឃឹមនេះទីបំផុត ក៏បានមកដល់គោលដៅ ដែលពួកគាត់បានរងចាំ យើងមានសេចក្តីរំភើបត្រេកអរណាស់ ដោយដូនតាយើងពួកគាត់សុទ្ធតែជាបុគ្គល ទ្រទ្រង់ដោយគុណធម៌ ស្មគ្រចិត្តរងទុក្ខ ព្រោះហេតុតែប្រមូលមរតកកេរ មកទុកឲ្យជាតិនេះទាំងមូល។ មេកាព្យនេះក្នុងមួយរបះមាន៤ឃ្លា ឃ្លាទី១និងទី៣មាន៤ព្យាង្គ ឃ្លាទី២និងទី៤ មាន ៦ព្យាង្គ ហើយអត្ថន័យរបស់មេកាព្យនេះ ដូចខ្ញុំបាទបានបកស្រាយពន្យល់ដោយសង្ខេបខាងលើ។ សូមមើលកំណាព្យខាងក្រោម:*

## <u>**សំណល់មរតកកេរ**</u>(បន្ទោលកាក)

១.បទបន្ទោលកាក　សល់ជាសំណាកឈ្មោះកាព្យ
ជូនតាបានសាប　មេកាព្យជាកេរព្រះរស់ៗ

២.បន្ទោសំណល់　ផ្លែផ្កាជាផលប្រាប់ឈ្មោះ
អត្ថន័យកាព្យនោះ　រង្គោះជ្រុះបាត់ន័យពិតៗ

៣.ដំណើរដើមទង　ថ្លែងតាមទំនងការគិត
បន្ទោគំនិត　ន័យពិតទុកឲ្យក្លូនស្រាយៗ

៤.គំនិតជាកេរ　ក្នុងដែនព្រះមេសុះសាយ
ដំណាំវែងឆ្ងាយ　បានក្លាយជាកេរព្រះម៉ែៗ

៥.តែខ្សែគំនិត　បានបាត់រឿងពិតវង្សខែ
គំនិតព្រះម៉ែ　ដាច់ខ្សែជាង១មួយរយឆ្នាំៗ

៦.សំណល់គំនិត　សាសនមានពិតត្រូវកម្ម
ឲ្យភ្លេចបណ្ដាំ　ភ្លេចចាំយល់ខុសព្រោះបាបៗ

៧.បរទេសឈ្លានពាន　ចូលមករុករានបង្ក្រាប
នាំចិត្តសេពបាប　ព្រោះសាបមនោគមថ្មីៗ

៨.បំភ្លេចការពិត　រាល់កាកគំនិតរឿងស្ត្រី
ព្រះម៉ែម្ចាស់ថ្លៃ　បំភ្លៃថារឿងសាសនាៗ

| | |
|---|---|
| ៩.កូនម៉ែឆ្លេចដឹង | គគាំងស្មៀមឈឹងវាចា |
| ពោលតាមតម្រា | ១វិចារបរទេសគិតឲ្យៗ |
| ១០.បើកូនកើតសុខ | ម៉ែសាងកេរទុកឲ្យសោយ |
| ត្រូវរកមេកោយ | កុំធ្លោយគំនិតជឿងាយៗ |
| ១១.តាំងជាម៉ែឪ | នាំចិត្តខុសផ្លូវព្រោះស្ពាយ |
| មរតកពង្រាយ | រោយរាយពាសពេញនគរៗ |
| ១២.ក្រែងលោកូនដឹង | ត្រិះរិះសញ្ជឹងរុករទាំ(រក) |
| លើកម៉ែឪទ្រ | បញ្ឈរដាក់លើសិរសាៗ |
| ១៣.បើយល់៣ទំនៀម | បេះដូងកូនមានទេវតា |
| ដែនដីសួគ៌ា | ប្រស្នាបន្ទោកាកពិតៗ |
| ១៤.សូមបញ្ចប់ស្លេះ | សង្ខេបរិះត្រិះការគិត |
| បញ្ចប់គំនិត | ម៉ែពិតប៉ុណ្ណេះឯងហោងៗ |

១.ការបោះបង់ចោលក្រុងអង្គរជាង១០០ឆ្នាំ ២.ការពិចារណា ៣.ទំនៀមទំលាប់ប្រពៃណី ៤.រាជបំណាងជ័យវរ្ម័នទី៧

ថ្ងៃ១២រោច ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃអង្គារ ទី២៨ ខែមិថុនា ឆ្នាំ២០១១

ដោយខ្ញុំព្រះករុណាខ្ញុំបាទខ្ញបាសក **គៀត ចាន់ធុន**

## ៧.ភុជង្គលីលា(នាគដើរឬដំណើរនាគ)

### ពន្យល់ពាក្យ

***ភុជង្គ***ភុជង់សំ. បា. ( ន. ) (ភុជគ, ភុជង្គ, ភុជង្គម "សត្វទៅដោយល្បត់") ពស់, នាគ។ភុជង្គនាគ ខ្មែរប្រើសំដៅសេចក្ដីថាពិភពនាគ) (ម. ព. ពិភពផង) ។(ដកចេញពីវចនានុក្រមសម្ដេច)

***លីលា***សំ. បា. ( ន. ) ដំណើរឬលំនាំកែក្រាយ, ដំណើរល្វតល្វៃ, ការយាងយាស; បែបភាពឬទ្រង់ទ្រាយល្អ, សមរម្យ; ការលេងសប្បាយ, ការរាំច្រៀងលោតលេងសប្បាយ : លីលាល្ខោន។ខ្មែរប្រើជាកិ. ឬកិ. វិ. ឬគុ. ក៏មាន : ចរលីលា, ដើរលីលា, លីលាយាត្រា, ដំណើរលីលា។លីលាកមលឬ --បទុម (--កៈម៉ល់ឬ--ប៉ៈទុម) ផ្កាឈូកដែលគេកាន់ដើរលេងឬកាន់រាំ។លីលាគ្រឹះឬ--មន្ទីរផ្ទះសម្រាប់លេងសប្បាយ; រោងរាំ, រោងល្ខោន។ (ដកចេញពីវចនានុក្រមសម្ដេច)

***ភុជង្គលីលា***ភុជង់-- ( ន. ) ឈ្មោះកាព្យមួយប្រភេទក្នុងមួយឃ្លាមានសង្កាត់បី, ត្រង់សង្កាត់ទី១មាន៦ពាក្យ, សង្កាត់ទី២និងទី៣មាន៤ពាក្យហៅថាបទភុជង្គលីលា, ដូចជា : ព្រឹងព្រូសជន្លួសភ្លូភ្លង ក្រូចព្រៃអង្គ្រង ដុះដាសលាយគ្នា។(ដកចេញពីវចនានុក្រមសម្ដេច)

តើឈ្មោះរបស់មេកាព្យនេះ មានបង្កប់ន័យប្រស្នាអ្វីខ្លះ? កូននាគបានដឹងហើយថា អ្នកបង្កើតទឹកដីសុវណ្ណភូមិនេះដំបូង គឺព្រះនាងនាគឬរាជនីនាគ ដែលយាមកដល់សម័យខាងក្រោយ ក្លាយជាមាតានាគឬដូននាគ (មើលបន្ថែមអាថ៌កំបាំងបណ្ដាំមាតាមហានគរភាគ១ ២ ៣)។ លោកបានបំពេញពលិកម្មគ្រប់បែបយ៉ាង ដើម្បីប្រមូលកេរមរតក មកទុកឲ្យកូននាគជំនាន់ក្រោយ។ ការតស៊ូក្នុងដំណើរវារលូន ខំប្រមូលកេរមរតកមកទុកនេះ បានបន្សល់ទុកនៅស្នាមដានព្រះបាទគ្រប់ទីកន្លែងឈ្មោះថាព្រះបាទជាន់ទុក នៅតាមភ្នំប្រាសាទ និងទីជទៃផ្សេងៗ...។ល។ ហេតុអ្វីបានជាព្រះបាទជាន់ទុករបស់ខ្មែរ ខុសពីព្រះបាទជាន់ទុករបស់ព្រះសម្មាសម្ពុទ្ធ? នេះជាការឆ្ងល់ និងជាកាស្រាយបំភ្លឺនៅប្រស្នាឈ្មោះមេកាព្យភុជង្គលីលានេះ។ មាតាបិតានាគ លោកចង់ប្រាប់ឲ្យកូននាគប្រុសស្រី ចេះគិតពិចារណាឈ្វេងយល់ បើគាត់ជាអ្នកវារលូន(និមិត្តរូប) តើស្នាមដែលដឹតជាមក្នុងឈ្មោះកាព្យ លើថ្ម ដីដែលមានគ្រប់ទីកន្លែង ជាដានស្នាមរបស់អ្នកណា? នេះជាហេតុឬចម្លើយតែមួយគត់ ដែលយើងស្រាយនូវចម្ងល់ប្រស្នានេះ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្ដែងថា"**កម្លាំងអ្វីស្មើដោយកម្លាំងកម្ម គឺពុំមានឡើយ**" សូម្បីតែព្រះអង្គក៏ទទួលនូវវិបាករបស់កម្មដែរ ទោះបីជាព្រះអង្គជាព្រះសម្មាសម្ពុទ្ធក៏ដោយ ដូចជាអកុសលកម្មរបស់ព្រះអង្គ ត្រូវធ្វើទុក្ករកិរិយា ទេវទត្តទំលាក់ថ្ម ឲ្យត្រូវព្រះបាទពុះពងព្រះលោហិត ព្រះអង្គបរិនិព្វានក្នុងព្រះជន្ម៨០វស្សា....។ល។ ឯបុញ្ញកម្មឬកុសលកម្ម ដែលព្រះអង្គត្រូវទទួលវិបាកគឺត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ហើយចុងក្រោយគឺព្រះអង្គបរិនិព្វាន ដោយឧបាទិសេសនិព្វាន និងអនុបាទិសេសនិព្វាន....។

ការបកស្រាយពីន័យក្នុងមេកាព្យ យើងបានស្គាល់ពីម្ចាស់គំនិត ដែលបានបង្កើតមរតកមុនគេ ហើយលោកជាឬសគល់របស់ជាតិទាំងមូល។ ពេលនោះសំណោរថ្មី ដែលកើតបន្តខាងក្រោយត្រូវតែ

*មានភាពរុងរោចន៍ ពេលយើងបានដឹងពីប្រវត្តិម្ចាស់មរតកនេះ បានបាត់ដានអស់រាប់ពាន់ឆ្នាំ ពេលនេះយើងជាកូននាគ ត្រូវសើរើឡើងវិញ ដើម្បីរកឲ្យឃើញនូវបេះដូង ខ្លឹម ប្រមាត់របស់ម្ចាស់មរតកអច្ឆរិយនេះ នោះទើបពន្លឺនៃពូជផ្កាយ អាចបញ្ចេញរស្មីជាថ្មីវិញបាន។ សូមមើលកំណាព្យខាងក្រោម:*

**បណ្តាំព្រះមេ ព្រះម៉ែមហានគរ**(តុជង្គលីលា = ព្រះនាងនាគធ្វើដំណើរ)

១.នេះបទកំណាត់ចងជា តុជង្គលីលា និទានរឿងស្រី។

២.អ្នក**ទ**កំណើតបុរី នគរស្ត្រី ឈ្មោះថាតួមិម៉ែ។

៣.ដំណែល**ទ**កើតហូរហែ កាលដែលរូបម៉ែ នៅជាព្រះមេ។

៤.មានឈ្មោះបរិសុទ្ធឋិតថេរ នាងនាគអ្នកថែ រក្សាទឹកដី។

៥.នគរល្វោសុទ្ធតែស្រី សុវណ្ណបុរី មេស្រីដឹកនាំ។

៦.រក្សាការពារថែទាំ លំបាកស៊ូទ្រាំ ព្រោះហេតុទឹកដី។

៧.ហេតុតែកម្មពីអតីត ធ្វើឲ្យនាគស្រី ជាប់ក្នុងធ្លាក់ស្នេហ៍។

៨.បង្កើតជាពូជកេរម៉ែ(ក្មែរ)តំណាហូរហែ តមកខាងក្រោយ។

៩.ម៉ែពុកហេតុតែបណ្តោយ កម្មនាំឲ្យធ្លោយ ក្លាយជាអ្នកទោស។

១០.ចិត្តលោភបង្ខំជ្រុលហួស ចិត្តលោភនាំខុស ព្រោះហេតុតែលួច។

១១.លួចនោះមិនយកតិចតួច នាំចិត្តមុគស្រួច លួចស្ថានយក្សា។

១២.ចង់បានកែវមនោរា យកមករក្សា វង្សរត័ក្របុរី។

១៣.ទុកកេរឲ្យក្មែរប្រុសស្រី ម៉ែឪជួបត័យ ធ្លាក់ក្នុងអបាយ។

១៤.ចិត្តម៉ែហេតុតែនឹកស្តាយ រូបម៉ែតាំងកាយ ព្រមទទួលជួស។

១៥.សុខចិត្តរ៉ែកទម្ងន់ទោស ពុកកូនទាំងអស់ ឲ្យគេសជាតិៗ

១៦.ជាប់ទោសព្រាត់ប្រាសពីញាតិ តែចិត្តម៉ែឆ្ងល់ ថែខ្ញុំបរក្សាៗ

១៧.ក្មេរក្មេរមរតកអស្ចារ្យ វង្សព្រះមាតា មហានាគអតីៗ

១៨.វង្សក្សត្រគ្រប់គ្រងទឹកដី ព្រះម៉ែក្សត្រថ្លៃ វិសេសអស្ចារ្យៗ

១៩.ទ្រាំទុក្ខបង្ហូរនេត្រា រងចាំបុត្រា ពេលណាទើបយល់ៗ

២០.ចុងមែកកើតចេញពីគល់ ឬមួយនិមល មិនយល់សាសនាៗ

២១.ហួបប្រាយដឹងគុណអ្នកណា ឬមួយកូនទ្វេ ដឹងគុណគ្រាប់ប្រាយៗ

២២.ព្រះមេពិតគឺជាម្ដាយ សព្វថ្ងៃម៉ែក្លាយ ជាបីសាចពស់ (ឯកសារចិនជីវិតាក្ជាន់)
ៗ

២៣.ខ្លួនស្លាប់តែបុរីរស់ ម៉ែបានសាបព្រោះ កេរមរតកទុកៗ

២៤.រងចាំមើលទៅថ្ងៃមុខ ពេលកូនសោយសុខ មាននឹកឃើញទេៗ

២៥.អ្នកណាទុកមរកតកេរ កេរម៉ែកេរមេ (ក្មេរក្មេរ) ឲ្យកូនសព្វថ្ងៃៗ

២៦.ចិត្តម៉ែរងចាំបុត្រថ្លៃ ឈឺចាប់ពើតក្រៃ ព្រោះកូនពុំឆ្នាក់ៗ

២៧.ពួកកូនជាប់ជុងអន្ទាក់ មនោគមវិស្រាក់ ពីទ្ធជុំគល់ធ្លកៗ

២៨.ពេលណាទើបកូនពន្លក កើតត្នែកចេញមក មើលឃើញសាសនាៗ

២៩.បណ្ដាំម៉ែក្នុងសិលា កូនមើលប្រស្នា មានសុទ្ធតែនាគៗ

៣០.ក្នុងក្រៅស្ថិតគ្រប់ទ្វមិតាគ ដែនដីមេនាគ ពីអតីតាៗ

| | | |
|---|---|---|
| ៣១.នាមប្រាជ្ញគួរអង្គសាសនា | ទូមិស្រុកប្រពៃណី | សុទ្ធតែរឿងម៉ែៗ |
| ៣២.កូនគិតតាមគំណរខ្មែរ | កូននឹងឃើញម៉ែ | រងទុក្ខម្នាក់ឯងៗ |
| ៣៣.ម៉ែខំសាបព្រោះរួចបែង | ព្រោះម៉ែខ្លាចក្រែង | កូនម៉ែពុំដឹងៗ |
| ៣៤.អកុសលធ្វើឲ្យស្លាក់ដឹង | កូនម៉ែឈប់ទ្រឹង | គ្មានដឹងអ្វីសោះៗ |
| ៣៥.ម៉ែនឹកឃើញស្តាយស្រណោះ | ទូមិម៉ែនៅរស់ | តែរឿងម៉ែស្លាប់ៗ |
| ៣៦.កូនហើយចូរកូនសណ្តាប់ | ម៉ែនឹងរ៉ាយរាប់ | ពីសាសនាម៉ែៗ |
| ៣៧.ឲ្យកូនឃើញគំណរខ្មែរ | ពូជពង្សព្រះម៉ែ | ព្រះនាងនាគក្សត្រៗ |
| ៣៨.រឿងម៉ែត្រូវសាត់ប្លាត់ | បរទេសកំចាត់ | បំផ្លាញបណ្តាំៗ |
| ៣៩.មរតកខ្មាំខ្មេចប្រេះស្រាំ | ព្រោះហេតុតែកម្ម | ផ្តល់ពីបុព្វេៗ |
| ៤០.ធ្លាក់ឡើងបុត្រពូជព្រះមេ | នាំគ្នាខំថែ | មរតកព្រះរស់ៗ |
| ៤១.ម៉ែកូនអាចឆ្លងផុតគ្រោះ | ម៉ែបីសាចពស់ | ក្លាយជានាគពិតៗ |
| ៤២.រក្សាដែនដីពិសិដ្ឋ | ថ្ងៃថ្លាស្មេរស្និត | អនាគតយូរលង់ៗ |
| ៤៣.នេះបទលើលោធុជង្គ | ម៉ែប្រាប់ទម្រង់ | សាវតាម៉ែក្សត្រៗ |
| ៤៤.កុំឲ្យបទឃ្លាតឆ្ងាយប្លាត់ | **ឥ**ខ្មែរវង្សក្សត្រ | អ្នកកើតទឹកដីៗ |
| ៤៥.រឿងពិតគឺម្ចាស់ក្សត្រី | នាមនាគថ្លាថ្លៃ | ដំណើរទៅមុខៗ |
| ៤៦.វាល្មូននាំរឿងក្នុងទុក្ខ | ដើម្បីកូនសុខ | សោយក្នុងសុខាៗ |
| ៤៧.បេះដូងកូនមានទេវតា | ដែនដីសួគ៌ា | ប្រស្នាជ័យហោងៗ |

៤៨.កតញ្ញូនាំសុខចម្បង បារមីចម្លង ដល់ដែនអមតៈៗ

ថ្ងៃពុធ ១៥ រោច ខែពិសាខ ឆ្នាំថោះត្រីស័ក ព.ស ២៥៥៥ ថ្ងៃទី១ ខែមិថុនា គ.ស ២០១១

រៀបរៀងនិងចងក្រងដោយឧបាសក **គៀត ចាន់ផុន**

## <u>ចំណាចដៃឆ្នាំថ្មី</u> (ទំនួញព្រះម៉ែមហានគរ)

១.**ក្ក**កើតទុកកេរក្នុងដែនដី ប្រាប់រឿងស្ត្រីអ្នកប្រសូត

**ខ្ខ**ខុសខខះរឿងរឹងស្ងួត **គ្គ**តាំងរំឭកស្ដីមិនរួចៗ

២.**ឃ្ឃ**ឃុំអ្នកកកើតហេតុកម្ម ក្សត្រីដេកចាំចិត្តព្រឺព្រួច

**ង្ង**ងោកទៅក្រោមព្រោះកម្មលួច **ច្ច**ចាប់ចងតួចព្រោះអទិន្នាៗ

៣.**ឆ្ឆ**ឆេះឈើចាប់តសន្ដាន **ជ្ជ**ជាប់លំអានទុក្ខពុំជា

**ឈ្ឈ**ឈឺងជាថ្នូតជាប់គ្នា **ញ្ញ**ញាតិអ្នកងារតមកក្រោយៗ

៤.**ដ្ដ**ដេកពើតចុកតែម្នាក់ឯង **ឋ្ឋ**ឋានសំដែងទីបង្ហើយ

**ឌ្ឌ**ឌូតតរឿងជាប់កៀកកើយ **ឍ្ឍ**ឍាលចម្លើយក្នុងប្រស្នាៗ

៥.**ណ្ណ**ណែនាំប្រាប់រឿងកំបាំង **ត្ត**តែងចំណាំងក្នុងតម្រា

**ថ្ថ**ថែតម្រុយរឿងមាតា **ទ្ទ**ទៅមូរខារសរសៃសូត្រៗ

៦.**ធ្ធ**ធៀបស្វែងរកអ្នកប្រមូល **ន្ន**នាំត្រកូលអ្នកប្រសូត

**ប្ប**ប្រាខំបីត្រកងពួត **ផ្ផ**ផ្សៀផ្សំពួតបានជាឡើងៗ

៧.ញ្ញពីតខិតខំផ្គុំក្រៀកចង ដ្ឋថ្មែកអៀបក្រងបង្ហោះឡើង

ម្ខមិនខំនេរទាញឲ្យថ្លើង ឈ្មូយកមេឡើងកាន់វេហា។

៨.ព្យូផើរូតរះរួចរិះគិត ល្ហលើកគំនិតព្រះមាតា

ទ្វវេនវាលួនដោះប្រស្នា ស្សសូត្រសាសនាបណ្តាំម៉ែ។

៩.ឃ្នាហាមិនរួចតែនៅខំ ទ្បឡើងទៅផ្គុំរឿងព្រះមេ

រ្អអ្នខ្មែនទទួលមរតកម៉ែ ស្គាល់កាលបុព្វទើបបានសុខ

កំណាព្យប្រស្នានេះចងក្រងរួចនៅថ្ងៃសុក្រ ១២កើត ខែចេត្រព.ស២៥៥៤ ត្រូវនឹងថ្ងៃ១៥ខែមេសាគ.ស២០១១

ដោយខូបាសក **គៀត ចាន់ថុន**

**<u>បណ្តាំព្រះម៉ែមហានគរ</u>**

១.ក្នកើតកេរទុកក្នុងដែនដី ព្រះម៉ែពូជជ័យអ្នកប្រសូត

ខ្ខម៉ែម្ចាស់ជាតិឲ្យរឹងស្អូត ឝ្គគាំងរឹបត្រួតស្ដីមិនរួច។

២.ឃ្យឃុំអ្នកកកើតព្រោះកម្ម ក្សត្រីដេកចាំចិត្តឈឺព្រួច

ខ្ងដោកចងខ្លួនព្រោះកម្មល្អួច ច្ចចាប់ព្រោះល្អួចរួមគ្និគ្នា។

៣.ឆ្នូនាំឲ្យឆេះតសន្តាន ជ្ជជាប់លំអានជាអ្នកងារ

ឈ្ឈ្យក្លាយជាថ្មតជាប់គ្នា ញ្ញញាតិមានពៀរតមកក្រោយ។

៤.ដ្ណដេកឈឺចាប់តែម្នាក់ឯង ឋ្ឋប្រាប់កន្លែងទីបង្ហើយ

ឌ្ឌខ្ទួតពួតរឿងជាប់កៀកខ្នើយ ឍ្ឍណោលចម្លើយដោះប្រស្នា។

៥.ណ្ណនិយាយប្រាប់រឿងកំប្លាំង ត្តខ្សែចំណាំងក្នុងតម្រា

ថ្ថធ្លាប់ប្រវត្តិរឿងមាតា ទ្ទរកសាវតាសរសៃសូត្រៗ

៦.ធ្ធផ្ដើមស្វែងរកអ្នកប្រមូល ន្ននាំត្រកូលអ្នកប្រសូត

ប្បខំបីពត្រកងត្រួត ផ្ផស្រាយពាក្យត្រួតបានជារឿងៗ

៧.ព្ពគិតខិតខំផ្គុំក្រៀកចង ភ្ភរែករៀបក្រងបង្ហោះឡើង

ម្មខំទាញម៉ែឲ្យបានថ្កើង យ្យនាំមេឡើងកាន់វេហាៗ

៨.រ្រឃើញរូតរះផ្គុំគំនិត ល្លបើករឿងពិតព្រះមាតា

វ្វសែងវាលូននាំសាសនា ស្សជាតិម្ហូរខាបណ្ដាំម៉ែៗ

៩.ហ្ហស្ដីប្រាប់គ្នាឲ្យប្រឹងខំ ឡ្ឡព្យាយាមទ្រាំបីព្រះមេ

អ្អអស់ឫបចាស់របស់ម៉ែ ស្គាល់គុណព្រហ្មទេវបានសុខាៗ

កំណាព្យប្រស្នានេះចងក្រងរួចនៅថ្ងៃច័ន្ទ ១២កើត ខែទុតិយសាឍព.ស២៥៥៦ ត្រូវនឹងថ្ងៃ៣០ខែកក្កដា គ.ស២០១២

ដោយឧបាសក **គៀត ចាន់ផុន**

## បណ្ដាំម៉ែ

១.កេរមេ កេរម៉ែ(ក្មេរក្មែរ)ខ្មែរតែមួយ ពូជអ្នកលើកស្ទួយមរតកថ្មី

កម្មកាចកម្ទេចខ្សែតំណា ពូជពង្សដែលល្អត្រាំគំរង់ៗ

២.ហេតុអ្វីក៏កូនមាសពន្លក មិនត្រិះរិះរកមើលទម្រង់

រូបរាងម៉ែពិតល្អផូរផង់ អ្នកផ្ទពូជពង្សវង្សអច្ឆរិយ។

៣.ហេតុអ្វីកូនម៉ែបែរមិនជឿ មិនមានជំនឿលើសិរី(សិរី៣ប្រការ ឬស្រី៣ប្រការ)

ដែលជាអ្នកផ្ទកើតទឹកដី រូបម៉ែសព្វថ្ងៃត្រូវខ្ទេចកាយ(ឈ្មោះនំប៉ែនចុកឬនំបញ្ចុក)។

៤.ព្រះមេត្រូវខ្ទេចទៅជាម្សៅ តំណវង្សផៅជ្រុះមិនស្ដាយ

មិនដឹងព្រះមេតាងឲ្យម្ដាយ ព្រោះកាយម៉ែក្លាយខ្ទេចសាកសព។

៥.ឬាយក្លាយជាម្សៅរៀងត្រូវស្លាប់ ចិត្តម៉ែក្រសោបរួមប្រសព្វ

ជាមួយនឹងបុត្រមិនកំសត់ ទោះមានឬអត់ក៏តាមថៃ។

៦.នេះជាសារជាតិនៃស្ដ្រីពិត ទឹកដក់ក្នុងចិត្តឈ្មោះថាម៉ែ

មិនបោះបង់កូនតជាខ្សែ កេរមេ កេរម៉ែ(ក្មេរក្មែរ)ទ្រព្យព្រះរស់(មាតុទ្ទមិ)។

រៀបរៀងដោយឧបាសក **គៀត ចាន់ផុន**

ថ្ងៃអង្គារ ទី១៥កើត ខែពិសាខ ឆ្នាំថោះ ត្រីស័ក ព.ស ២៥៥៥
គ.ស ២០១១

## ទំនួញ ដ ត្ត

**១.ដ្ត**ដើរដេកដួលឈើចាប់ពើត ព្រោះហេតុកកើតទ្រពទុកកេរ

ភ្លេចការឈើចាប់តាំងជាម៉ែ **ត្ត**ថៃតំណមរតកទុក។

**២.**ចែកឲ្យកូនក្មេរជំនាន់ក្រោយ សេពសោយមរតកម៉ែគ្រប់មុខ

ម៉ែរងឈឺចាប់ត្រាំក្នុងទុក្ខ ដ្ឋឈឺពើតចុកផ្ដួមកក្រោយ។
៣.បើកូនម៉ែស្គាល់ពាក្យថា**អរ**(ររ) **ដ្ឋផ្ទ**ត្រាច់ចរចេញបង្ហើយ
កូននិងជួបសុខព្រោះដល់ត្រើយ ម៉ែបានល្ហែល្ហើយក្នុងសុគតិ។

រៀបរៀងដោយខ្ញុំបាសក **គៀត ចាន់ផុន**

## <u>បណ្ដាំធនជ័យ</u>

១.បណ្ដាំធនជ័យ ប្រាប់កូនប្រុសស្រី ឲ្យប្រឹងលើកស្ទួយ
មរតកព្រះម៉ែ ដែលមានតែមួយ បណ្ឌិតលោកព្រួយ
ខ្លាចកូនហៃអើ(ហៃអើៗធនធានជ័យធ្លាក់ទឹក)ៗ

២.បើកូនបែរដឹង រួតរះខំប្រឹង គិតឆ្លល់សើរើ
នូវមរតកចាស់ ដូនតាបានធ្វើ ចារចាំងទុកលើ
ផ្ទាំងថ្មប្រាសាទៗ

៣.ប្រាង្គរាប់រយពាន់ គាត់បានបំពន់ លាក់ទុកតាមខ្នាត
ខ្លាចអ្នកខាងក្រៅ(បរទេស) មកដាប់សម្អាត ឲ្យរៀបដល់ឬាត
ទ្រព្យកេរព្រះម៉ែៗ

៤.ទោះខ្លួនជាប់គុក កាយចិត្តពុំសុខ ខំប្រវាំថៃ
លួចបង្ហោះខ្លែង តាងឲ្យកេរម៉ែ បន្តវង្សក្មែរ
ពូជពង្សសិលាៗ

៥.ដង្ហើមចុងក្រោយ ពុំបានព្រងើយ មុននឹងមរណា

ហៅស្ដេចមកផ្ដាំ ប្រាប់ក្បួនតម្រា ក្នុងការរក្សា

កេរតំណែលម៉ែៗ

ថ្ងៃពុធ ១រោច ខែពិសាខ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥

រៀបរៀងដោយឧបាសក **គៀត ចាន់ផុន**

**<u>គុកដាក់ធនជ័យ</u>**

១.គុកមួយគុកពីរគុកបី គុកមួយក្រុងស្ដ្រី (សត្វត្រី) ក្នុងអង្រុត

ឃុំឃាំងឲ្យជាប់ឃាមតត់មត់ បំបែររឿងពិតតែន័យផ្សេងៗ

២.គុកពីរឃុំក្រុងព្រះនគរ ប្រជារីករវរព្រោះ ម៉េងឆេង

មនោគមសណ្ដិរួចបំប្លែង ឲ្យសត្វវង្វេងភ្លេចកំណើតៗ

៣.គុកបីដាក់ស្ដ្រីដែលជាន្ទី ដាក់ឃុំក្នុងរូងព្រោះខ្លាចកើត

ពូជពង្សអ្នក**ទរ**ដែនល្អឆើត កុំឲ្យកកើតជាថ្មីវិញៗ

(នេះជាប្រស្នាអ្នកប្រាជ្ញចិនមកយកនគរ) គុកនេះធនជ័យអាចចេញមកបង្ហោះខ្លែងបានៗ

ខ្លែងឯក =>**ខ**លែងឯក =>ឯក = ឯនិងក <=>អរនិងកែ បើយើងព្រមកែនិងជួបអរៗ(ប្រស្នាខ្លែងឯក)

អង្កាម =>អ ង កាម =>អ ងចុះទៅរកកាមគុណាគឺរូប សម្លេង ក្លិន រស ផោដ្ឋព្វៗ

អង្ករ =>អរ ងក ពូជជ័យខាងក្រោយមិនព្រមអរទៅរកកឡើយ គឺអរតែសំបក (ប្រស្នាសាបអង្កាម)ៗ

រៀបរៀងដោយឧបាសក **គៀត ចាន់ផុន**

## <u>II.អំពីព្យញ្ជនៈខ្មែរទាំង៣៣តួបង្កប់ក្នុងន័យបណ្ដាំមហាមហាធាតុ</u>

ព្យញ្ជនៈខ្មែរមាន៣៣តួ ដែលផ្តើមដោយព្យញ្ជនៈ**ក** និងបញ្ចប់ទៅវិញដោយព្យញ្ជនៈ**អ** មានន័យថា បើយើងមិនស្គាល់**ក** គឺយើងមិនអាចស្គាល់**អ**បានឡើយ។ ព្យញ្ជនៈបើចែកជាវគ្គឬសង្កាត់មាន៦វគ្គ ៥វគ្គខាងដើមក្នុង១វគ្គ មានអក្សរ៥តួ ចំណែកឯវគ្គទី៦ មានអក្សរ៨តួ រួមសរុបទាំងអស់ត្រូវជា ៣៣តួ។

## <u>ពន្យល់ពាក្យ</u>

**ព្យញ្ជនៈ**ព្យ័ញ-ជៈនៈបា.; សំ. ( ន. ) (ព្យញ្ជន; វ្យញ្ជន) តួអក្សរដែលសម្រាប់ផ្សំជាមួយនឹងស្រៈ, លុះតែមានស្រៈផ្សំផង ទើបកើតច្បាស់ប្រាកដជាពាក្យសម្តីឡើងបាន។ ព្យញ្ជនៈសម្រាប់ប្រើក្នុងភាសាខ្មែរ ក្នុងសម័យសព្វថ្ងៃនេះមាន៣៣តួ (ស្មើគ្នានឹងព្យញ្ជនៈខាងភាសាបាលីដែរ) គឺកខគឃង, ចឆជឈញ, ដឋឌឍណ, តថទធន, បផពភម; យរលវសហឡអ; កាលពីក្នុងសម័យបុរាណខ្មែរប្រើព្យញ្ជនៈ ៣៥តួព្រោះមានគបពីរតួនេះផងសម្រាប់ប្រើខាងភាសាសំស្ក្រឹត, រៀងរបៀបត្រង់ចន្លោះវនិងស (វគបស), ប៉ុន្តែលើកលែងប្រើយូរហើយ, ត្រង់ពាក្យណាដែលត្រូវប្រើគបដូចជាបគ្និម, បឞ្ជជាដើមនោះប្រើតែសមួយនេះជាជំនួសជាបស្ចិម, ព្រះឱស្ឋដូច្នេះវិញ (សរសេរជាព្យញ្ជនក៏បាន) ។(ដកចេញពីវចនានុក្រមសម្តេច)

**ព្យញ្ជនៈ**( ន. ) (ព្យញ្ជន; វ្យញ្ជន) ម្ហូបក្រៅពីសម្លទឹកគឺម្ហូបក្រៀម, ម្ហូបគោក, ម្ហូបខាប់, ឬទឹកត្រី, ទឹកគ្រឿង, អន្លក់ជាដើមហៅព្យញ្ជនាហារ (ព្យ័ញ-ជៈនាហា) ក៏បាន។ម. ព. សូបៈ និង សម្ល ផង។(ដកចេញពីវចនានុក្រមសម្តេច)

**ព្យញ្ជនៈ**បា. ឧត្តរិភង្គឈ្មោះម្ហូបគោកមួយប្រភេទក្នុងវិ. ព. ថាជាព្យញ្ជនៈដែរប្រែហៃលជាប្រហិត ? (ដកចេញពីវចនានុក្រមសម្តេច)

បើតាមការបកស្រាយពន្យល់ខាងលើ ន័យទីមួយគឺតួអក្សរ ចំណែកឯន័យទីពីរគឺឈ្មោះម្ហូបអាហារ តើព្យញ្ជនៈខ្មែរមានន័យបង្កប់ខាងក្នុងអ្វីខ្លះ? ខ្ញុំបាទសុំធ្វើការស្រាយបំភ្លឺ តាមការយល់ដឹងពីន័យ ដែលមានបង្កប់ក្នុងព្យញ្ជនៈទាំង៣៣តួនេះ ក្នុងបណ្តាំដូនតាមហានគរខ្មែរ។

**<u>ក.វគ្គទី១</u>**( មានតួអក្សរ៥តួគឺ **ក ខ គ ឃ ង**)

**<u>១.អំពីតួអក្សរ( ក )</u>** ( ព្យញ្ជនៈទី១ក្នុងវគ្គទី១)

សូរសម្លេងរបស់ព្យញ្ជនៈ**ក** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្តាប់យល់បាន ចំពោះភាសានិយាយ។

## <u>ពន្យល់ពាក្យ</u>

**ក**( ន. ) អវយវៈដែលតពីក្បាលទៅស្មា ឬទៅខ្លួននៃមនុស្សសត្វ។ ដៃជើងមនុស្សក៏មានកដែរៈ កដៃ, កជើង។ ទងខាងដើមក្បូរស្រូវក៏ហៅកដែរ : កស្រូវ។កន្លែងដែលតជាប់ពីមាត់ដប ជាដើមចុះទៅទល់នឹងក្អេងក៏ហៅកដែរ : កដប, កក្អម។(ដកចេញពីវចនានុក្រមសម្ដេច)

**ក** ( កិ. ) តាំងផ្ដើម, តាំងធ្វើ : កសាង, កកើត, កចេតិយ, កភូមិ។(ដកចេញពីវចនានុក្រមសម្ដេច)

**ក៏**( និ. ) ពាក្យជាសន្ធានមានសំឡេងកញ្ចាក់ខ្លី សម្រាប់និយាយតប្រយោគដោយឡែក : អ្នកក៏ទៅ, ខ្ញុំក៏ទៅ, ធ្វើដូច្នេះក៏បាន, របស់នេះរូបក៏ល្អ តម្លៃក៏ថោក។ (ដកចេញពីវចនានុក្រមសម្ដេច)

**ករ**បា. ( ន. ) ដៃ : លើកករប្រណម្យ។ (ដកចេញពីវចនានុក្រមសម្ដេច)

សូរដូចក្នុងន័យបង្កប់ព្យញ្ជនៈ**ក**ខាងលើ បានពន្យល់បង្ហាញប្រាប់យើងថា តួអក្សរ**ក**នេះបង្កើតខ្លួនឯងផង បង្កើតព្យញ្ជនៈទាំង៣២ពីក្រោយខ្លួនទៀតផង មានន័យថាបើគ្មានព្យញ្ជនៈ**ក** ក៏គ្មានព្យញ្ជនៈ**អ**ខាងចុងឡើយ។ នេះជាហេតុដែលដូនតាខ្មែរ បានយកព្យញ្ជនៈដំបូងនេះ បង្កើតជាពាក្យសម្គាល់ជាតិមួយ មានឈ្មោះថា ពូជខ្មែរ(កេរមេ) ឬខ្មែរ(កេរម៉ែ) ដែលមានព្យញ្ជនៈ**ក**ជាបេះដូង ជាពាក្យសម្រាប់សម្គាល់ជាតិនេះ។ តើន័យពិតរបស់ពាក្យខ្មែរ កើតឡើងដោយសារហេតុអ្វី? ពីដំបូងយើងហៅម៉ែថា**មាតា** ភាសានិយាយបានក្លាយជា**ម្ដា ម្ដា**គាត់បានចាស់យាត្រូវថែម**យ** ក៏ក្លាយជា**ម្ដាយ ម្ដាយ**កាន់តែចាស់យា បានក្លាយជា**យាយ** ព្រោះហេតុតែយាឆ្ងាយដោយចាស់យូរ យាយកាន់តែយាយូរគាត់មានចៅបន្តគ្នា យើងហៅថា**យាយទួត**មកពីពាក្យត្រួតលើគ្នា **យាយត្រួត**លើគ្នាច្រើនដងបានយាក្លាយជា**យាយលួត** មានន័យថាចៅលែងចង់ទទួលស្គាល់គ្នា ចុងបញ្ចប់គឺ**យាយលា** មានន័យថាឈាមជ័រពូជពង្សត្រកូល តគ្នាលែងជាប់ហើយ គឺកូនចៅជំនាន់ក្រោយ លែងទទួលស្គាល់នឹងរាប់អានគ្នា។ នេះជាហេតុដែលម្ចាស់មរតកអច្ឆរិយ លោកត្រូវបង្កើតពាក្យសម្រាប់សម្គាល់ជាតិមួយដែលកូននាគជំនាន់ក្រោយ ទទួលមរតកគាត់រួមគ្នា គឺជាតិ**ខ្មែរ**(កេរម៉ែ)។ ទោះបីជាតំណខាងក្រោយត្រូវផ្លាស់ប្ដូរត្រកូល ផ្សេងៗគ្នាយ៉ាងណាក៏ដោយ កូននាគទាំងនោះត្រូវប្រសូត ចេញពីទ្វារមាសគឺមាតុភូមិនេះ អ្នកនឹងបានទ្រព្យសម្បត្តិពីម៉ែគ្រប់ៗគ្នា គឺកេរមរតកម៉ែ(ខ្មែរ)។ បើអ្នកពុំបានប្រសូតចេញពីទ្វារមាសគឺមាតុភូមិនេះទេ តើអ្នកបានមរតកអច្ឆរិយនេះ មកពីណា? ក្នុងបណ្ដាមរតកអច្ឆរិយទាំងនេះ មានមរតកដ៏អស្ចារ្យមួយ គឺព្រះពុទ្ធសាសនា ជាសារបណ្ដាំរបស់មេនាគទីបី ដែលអាចដឹកនាំ អ្នកទទួលមរតកម៉ែទាំងឡាយ ឲ្យចេញចាកបានពីសេចក្ដីទុក្ខ ឆ្លងដល់ត្រើយអមតសុខ គឺព្រះនិព្វាន។ ព្រះពុទ្ធសាសនាអាចមក ប្រតិស្ឋានក្នុងមាតុភូមិនេះបាន បើមេនាគទីពីរ ពុំអនុញ្ញាតិទទួលយកមកទុកជាមរតកទេ ធ្វើដូចម្ដេចប្រជាជនខ្មែរ អាចមានព្រះពុទ្ធសាសនា សម្រាប់គោរពប្រតិបត្តិបូជា រហូតមកដល់សព្វថ្ងៃ? នេះជាអត្ថន័យពិតដែលបានបង្កប់ ក្នុងព្យញ្ជនៈ**ក**ជាព្យញ្ជនៈទី១ ដែលមានន័យដ៏អស្ចារ្យ ដោយដូនតាបានបង្កប់ក្នុងបេះដូងពាក្យ សម្រាប់សម្គាល់ជាតិខ្មែរនេះ បើ

កូនខ្មែរពុំស្គាល់អ្នក**ក**គឺម៉ែទេ កូននាគមិនអាចស្គាល់ពាក្យឬព្យញ្ជនៈ**អ**បានឡើយ។ នេះជាអត្ថន័យពិត ដែលបានបង្កប់លាក់ទុកក្នុងព្យញ្ជនៈ**ក** ដោយពុំទាន់លាយពណ៌នៅក្នុងភាសាបាលី ឬសំស្រ្កិត ព្រោះវាជាន័យត្រង់របស់ភាសាខ្មែរ ដែលកើតចេញពីព្យញ្ជនៈដំបូងគឺ**ក**។

**២.អំពីតួអក្សរ(ខ)** (ព្យញ្ជនៈទី២ក្នុងវគ្គទី១)

សូរសម្លេងរបស់ព្យញ្ជនៈ**ខ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ខ**)

**ខ** ( កិ. ) ចម្អិនម្ហូបដែលហៅខ : ខត្រី, ខសាច់។(ដកចេញពីវចនានុក្រមសម្ដេច)

**ខ** ( ន. ) ត្រីឬសាច់ដែលចម្អិនដោយមានគ្រឿងផ្សេងៗលាយផ្សំផង, ជាម្ហូបមានទឹកទីទៃពីសម្លនិងត្រីស្ងោរ : ត្រីខ, ជ្រូកខ។(ដកចេញពីវចនានុក្រមសម្ដេច)

**ខ**( ន. ) ឈ្មោះដាវដងវែងមានស្នៀងនៅខ្នង : ដាវខ។(ដកចេញពីវចនានុក្រមសម្ដេច)

**ខ** ( ន. ) ប្រការ, ចំពូក, មាត្រា, បទ, ន័យ, សេចក្ដីស្រង់រួមចំនួនខ្លីៗ : ខ១, ខ២, ខ៣។(ដកចេញពីវចនានុក្រមសម្ដេច)

**ខរ**សំ. បា. ( ន. ) ("សត្វលា; រណារ"; គុ. កាច, រឹងរូស) ឈ្មោះយក្សមួយក្នុងរឿងរាមកេរ្ដិ៍។(ដកចេញពីវចនានុក្រមសម្ដេច)

ហេតុអ្វីបានជាព្យញ្ជនៈ**ខ**ត្រូវនៅក្នុងលំដាប់ទីពីរ? សព្វថ្ងៃពាក្យសម្រាប់សម្គាល់ជាតិសាសន៍នេះ យើងសរសេរជាទូទៅ គឺ**ខ្មែរ** = **ខេមរៈ**

**ពន្យល់ពាក្យ**

**ខេមរៈ**ខេម៉ៈរ៉ៈ ( ន. ) **ខ្មែរ**; (ពាក្យនេះ**មានទំនង**ជាបាលីភាសាដែលប្រែថា "មនុស្សមានសេចក្ដីក្សេម" មកអំពីវិគ្គហៈថា "ខេមំយស្សអត្ថីតិខេមរោ" ឬជាពហុវចនៈថា "ខេមំយេសមត្ថីតិខេមរា"; **ប៉ុន្តែនឹងពោលឲ្យប្រាកដ**ថាបានជាហៅ "ខេមរៈៗ" នោះពីព្រោះប្រែថាមានសេចក្ដីក្សេមដូច្នេះក៏**អាចដឹងប្រាកដពុំបាន** ព្រោះក្នុងសិលាចារឹកបុរាណសរសេរ "**ក្មែរ** " ក៏មាន។ (ដកចេញពីវចនានុក្រមសម្ដេច)

បើយើងមើលការពន្យល់ពាក្យខ្មែរ របស់អ្នកប្រាជ្ញខាងលើ គឺព្រះអង្គពុំទាន់ហ៊ានអះអាងថាពាក្យខ្មែរនេះត្រឹមត្រូវដាច់ខាតនូវឡើយទេ ព្រោះព្រះអង្គប្រើពាក្យថា**ទំនង**ក្នុងឃ្លាទី១ ឃ្លាទី២ព្រះអង្គបានប្រាប់ថា**ដឹងប្រាកដពុំបាន** ព្រោះក្នុងសិលាចារឹកគេសរសេរពាក្យក្មែរ ម្យ៉ាងទៀតអ្នកប្រាជ្ញជំនាន់ព្រះអង្គ សុទ្ធតែប្រសូតក្រោយសិលាចារឹក។ ដោយសម្អាងទៅលើការពន្យល់ពាក្យខ្មែរ = ខេមរៈខាងលើ អ្នកប្រាជ្ញរាជបណ្ឌិតសម័យមុន លោកពុំបានបិទច្រកទ្វារគំនិតត្រិះរិះពិចារណា សម្រាប់អ្នកជំនាន់ក្រោយឡើយ គឺលោកទុកឲ្យកូនខ្មែរខាងក្រោយ រាវរករុករកស្វែងរកន័យពិត របស់ពាក្យ

សម្គាល់ឈ្មោះជនជាតិនេះ។ ពាក្យសម្រាប់សម្គាល់ឲ្យជនជាតិមួយ បើយើងបែរជាយកភាសាបាលី គឺជាភាសាអ្នកដែនមគធៈពីបុរាណ សព្វថ្ងៃគឺប្រទេសឥណ្ឌា មកសម្គាល់ឲ្យជាតិយ៉ាងនេះ តើត្រឹមត្រូវដែរឬទេ? បើយើងខ្ចីពាក្យគេយកមកប្រើសម្គាល់ជាតិ តើជាតិយើងជាឥណ្ឌាទីពីរឬ? ឬមួយក៏ខ្មែរយើងជាជនជាតិភាគតិច របស់ឥណ្ឌាពីបុរាណ? តើពាក្យខ្មែរនេះ បើបកតាមន័យរបស់ពាក្យ ជាភាសាខ្មែរ ដោយកុំឲ្យលាយឡំ ជាមួយភាសាបាលី តើមានន័យដូចម្ដេច?

**ខ្មែរ** = **ខ** + **ម៉ែ** + **រ** មានន័យថាម៉ែ ដែលជាអ្នកបង្កើតនគរអច្ឆរិយនេះ ត្រូវគេ**ខ**ជាប់បាត់ទៅហើយ ព្រោះហេតុអ្វី? **ខ**គឺឈ្មោះម្ហូបម្យ៉ាង ដែលគេត្រូវយកស្ករ ទៅធ្វើឲ្យជាតាំងម៉ែសិន ទើបគេបង់គ្រឿងផ្សំផ្សេងៗ នឹងសាច់ចូលទៅ។ នៅក្នុងមុខម្ហូបនេះ មានឈ្មោះស្ករតាំងម៉ែ ដែលខ្ញុំបាទពន្យល់រួចហើយ(ភាគ១) គឺមានន័យថាតាំងខ្លួនជាម៉ែគេ ត្រូវផ្អែមល្ហឹងស្អិត តែពណ៌ខាងក្រៅត្រូវក្រម៉ៅ ពណ៌ក្រម៉ៅនេះហើយជានិមិត្តរូប ដែលត្រូវរារាំងពួកគាត់ ឲ្យជាប់ក្នុងអបាយភូមិ ព្រោះហេតុតែពួកគាត់គ្មាន គុណធម៌ថ្នាក់ទីមួយគឺសីល។ ចំណែកព្យញ្ជនៈ**រ** ដែលនៅពីខាងក្រោយ ន័យរបស់វាបាន និយាយប្រាប់ឲ្យកូន**រ** ព្រោះភាសានិយាយ**រក៏** = **រក** អ្នកចាប់ម៉ែ**ខ**រម្ទាស់ឲ្យរលួយ បាត់រូបរាងម្ចាស់ដើម (សូមមើលអត្ថន័យប្រាសាទហាន់ជ័យ នំប៉ែនចុក សរសៃសូត្រ.... ភាគមុន)។ ន័យត្រង់ព្យញ្ជនៈ**ខ**រម្ទាស់ឲ្យរលួយអ្នក**ក** គឺមិនអាចឲ្យស្គាល់អ្នក**ក**បានឡើយ បើក្មេរស្គាល់ពាក្យសម្គាល់ជាតិត្រឹម**ខ** ធ្វើដូចម្ដេចអាចស្គាល់**អ**(**អរ**)បាន? នៅក្នុងរឿងធនជ័យ អ្នកប្រាជ្ញលោកបានទុកប្រស្នាប្រាប់យើងថា គាត់ជាប់នៅក្នុងគុក គាត់អាចលួចបង្ហោះខ្លែងឯកបាន ទីបំផុតត្រូវចិនចុះចាញ់គាត់ជាលើកទីបី ដោយយល់ព្រមដោះលែងគាត់ ហើយឈប់មានមហិច្ឆតាមកឈ្លានពាននគរក្មេរទៀត។ គុកដែលអាចចេញមក បង្ហោះខ្លែងបានជាគុកអ្វី? តើក្រដាសតែមួយសន្លឹក យកមកធ្វើខ្លែង ហេតុអ្វីបានជាចិនចុះចាញ់? តើពាក្យខ្លែងឯកមានន័យពិតដូចម្ដេច ទើបធ្វើឲ្យចិនចុះចាញ់គាត់នោះ?

គុកដែលធនជ័យអាចចេញមកបង្ហោះខ្លែងបាន គឺជាគុកមនោគមវិជ្ជា ព្រោះវាជាគុកឥតជញ្ជាំង ទើបគាត់អាចចេញមកបង្ហោះខ្លែងបាន។ ខ្លែងឯកបើយើងសម្រាយពាក្យនេះ យើងនឹងឃើញអត្ថន័យពិតរបស់វា គឺប្រាប់ពីឈ្មោះព្យញ្ជនៈ**ខ** លែងដើរតួជាទីមួយជំនួសព្យញ្ជនៈ**ក**។

**<u>ពន្យល់ពាក្យ</u>**

**ខ្លែខឯក** = **ខ** + **លែខ** + **ឯក**បើយើងដកព្យញ្ជនៈ**ល** ចេញពីក្រោម**ខ**កុំឲ្យត្រួតគ្នា យើងឃើញពាក្យពន្យល់ប្រាប់ន័យថា **ខលែងឯក** បើ**ខ**លែងដើរជាតួឯក គឺមានតែ**ក**ជាតួឯក។ ឯពាក្យឯក គឺ**ឯនិងក** ទើបក្លាយជាពាក្យ**ឯក** បើយើងត្រឡប់ពាក្យ**ឯនិងក** = **អនិងកែ** មានន័យថា បើកូននាគព្រមកែយើងនឹងស្គាល់**អ** បើពាក្យសម្គាល់ជាតិលែងប្រើព្យញ្ជនៈ**ខ** រួចកែមកប្រើព្យញ្ជនៈ**ក** ទើបយើងស្គាល់ព្យញ្ជនៈ**អ**។ នេះជាន័យពិតរបស់ពាក្យខ្លែងឯក ដែលធនជ័យលួចបង្ហោះធ្វើឲ្យចិនចុះចាញ់ ពុំមែនគ្រាន់តែក្រដាសមួយសន្លឹក ធ្វើឲ្យចិនចុះចាញ់នោះឡើយ បើងាយស្រួលដូច្នេះមែន កូនក្មេរបង្ហោះខ្លែង

ឯករាល់ឆ្នាំ ចិនព្រមចាញ់ក្មែរទៅហើយ។ ខ្លែងឯកដែលបង្ហោះនោះ វាជារឿងអាថ៌កំបាំងរបស់ពាក្យសម្រាប់សម្គាល់ជាតិមួយ ដែលត្រូវបានគាត់សើរើ យកមកគិតពិចារណាឡើងវិញតែប៉ុណ្ណោះ ព្រោះពាក្យ**ក្មែរ**នេះ ត្រូវដេកលក់អស់**៣៤ឆ្នាំ** គឺពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ២០០៩។ ពួកកាន់អំណាចផ្ដាច់ការខ្មែរក្រហម បានកៀរប្រជាជនក្មែររាប់លានអ្នក យកទៅធ្វើទារុណកម្មហើយសម្លាប់ នៅក្នុងបណ្ដាប្រជាជន ដែលត្រូវយកទៅសម្លាប់ទាំងនោះ មាននិស្សិតបញ្ញវន្តអ្នកប្រាជ្ញរាជ្យបណ្ឌិត ទាំងគ្រហស្ថនិងបព្វជិត ត្រូវពួកគេធ្វើបាបរួចសម្លាប់ចោល ស្ទើរតែទាំងអស់។ ក្រោយថ្ងៃរំដោះ៧មករាឆ្នាំ១៩៧៩ អ្នកចេះដឹងដែលនូវសេសសល់ពីស្លាប់ អ្នកខ្លះត្រូវរត់គេចខ្លួនទៅនៅប្រទេសក្រៅ ចំណែកអ្នកនៅក្នុងស្រុក ត្រូវភ័យបាក់ស្បាតផ្លូវចិត្តពីរបបផ្ដាច់ការ លែងហ៊ានយកពាក្យក្មែរនេះ មកបញ្ចេញមតិជជែកវែកញែក ដូចសម័យមុនទៀត។ មកដល់ឆ្នាំ២០០៩ខ្ញុំបាទបានគាស់ ពាក្យសម្គាល់ជាតិមួយម៉ាត់នេះ ដែលមាននៅក្នុងសិលាចារឹក ហើយបានត្រូវដេកលក់អស់ជាង៣០ឆ្នាំ មកគិតពិចារណាសើរើវែកញែកឡើងវិញ ដើម្បីរកឲ្យឃើញនូវន័យពិត របស់ពាក្យសម្គាល់ជាតិនេះ ដោយសង្ឃឹមថានឹងអាចរកឬសកែវពិត របស់ពាក្យសម្គាល់ជាតិអច្ឆរិយនេះ ថា**ក្មែរឬខ្មែរ**។

**៣.អំពីតួអក្សរ(ឝ)** (ព្យញ្ជនៈទី៣ក្នុងវគ្គទី១)

សូរសម្លេងរបស់ព្យញ្ជនៈ**ឝ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ឝ**)

**ឝ**( គុ. ) ឥតសំដី : មនុស្សគ។បើលោហជាតិវិញថាឥតសូរ : ប្រាក់គ។(ដកចេញពីវចនានុក្រមសម្ដេច)

**ឝ**( ន. ) ឈ្មោះឈើជាដំណាំផ្លែមានសរសៃជាប៉ុយសំឡីសម្រាប់ច្រកញាត់ខ្នើយ, កែប, ពូកជាដើម : ព្រះសម្ពុទ្ធទ្រង់បញ្ញត្តហាមមិនឲ្យភិក្ខុសាមណេរប្រើប្រាស់ពូកញាត់សំឡីគ, ទ្រង់អនុញ្ញាតឲ្យប្រើពូកញាត់ស្មៅ, ញាត់ជក់ដូងជាដើមបាន, ឯកែប, ខ្នើយឲ្យញាត់សំឡីគបាន ។ (ដកចេញពីវចនានុក្រមសម្ដេច)

**ឝរ** ( កិ. ) ធ្វើឲ្យជាគំនរ។(ដកចេញពីវចនានុក្រមសម្ដេច)

ហេតុអ្វីព្យញ្ជនៈ**ឝ**ទី៣នេះ នៅក្រោយលំដាប់ព្យញ្ជនៈ**ខ**? ក្រោយពី**ខ**ម៉ែឲ្យបាត់រូបរាងដើមហើយ រឿងរ៉ាវទាំងអស់ត្រូវភ្លេចភ្លាំង គគាំងនិយាយលែងចេញ ហេតុនេះគាត់ត្រូវប្រើភាសាសញ្ញាគឺភាសា**ឝ** តើភាសាសញ្ញា**ឝ**របស់ជាតិយើង សព្វថ្ងៃនៅឯណា?

– ទីមួយភាសា**គ**បង្កប់ទុកនៅក្នុងរឿងធនជ័យ អ្នកប្រាជ្ញលោកបានប្រាប់ឲ្យយើងរៀនភាសាសញ្ញាគឺភាសាគ ដើម្បីទប់ទល់នឹងបរទេស(ចិន...) ដែលមានមហិច្ឆតាចង់មកដណ្ដើមយកនគរខ្មែរ (មើលភាសាសញ្ញានៅក្នុងរឿងធនជ័យ)។

– ទីពីរភាសា**គ**បានបង្កប់លាក់ទុក ក្នុងរូបរឿងនិងក្បាច់ចម្លាក់ ដែលមាននៅលើជញ្ជាំងប្រាសាទរាប់ពាន់ ក្នុងទឹកដីនេះពីបុរាណ ដែលភាសា**គ**ទាំងនេះ បានបង្កប់នូវប្រវត្តិរឿង តាមរូបភាពចម្លាក់នៅលើជញ្ជាំង ផ្ដែរ ក្បាំងក្លែង.....។ល។ នៅក្នុងខេត្តពោធិសាត់បច្ចុប្បន្ន មានស្រុកមួយឈ្មោះថាស្រុកក្រគ តើក្រគនេះក្រគសំឡីសម្រាប់ច្រកពូក ខ្នើយ ឬមួយក្រលែងនិយាយបាន? ដំបងគ្រញូងបានជ្រែករាជ្យ ដណ្ដើមយករាជ្យបានក្នុងសម័យអង្គរ ក្រោយពីបានគ្រប់គ្រងទឹកដីមហានគរទាំងមូល ពួកគេបានវាយធ្វើបាបកូនខ្មែរ ឲ្យស៊ីផ្លែដំបងបន្តគ្នា (មើលបទសារិកាកែវភាគ១) វាយរហូតដល់កូនខ្មែររត់ចោលទីក្រុងអង្គរ ឲ្យភ្លេចដើមកំណើតខ្លួន ថាជាពូជថ្មពូជនាគពូជផ្កាយពូជអច្ឆរាអស់ជាង១០០ឆ្នាំ តើគួរឲ្យអាសូរដែរឬទេ? ដែលជាតិមួយធ្លាប់ថ្កុំថ្កើងរុងរឿង លេចធ្លោឡើងពីអតីតកាលនោះ។ ចុងក្រោយក្រុមខ្មែរក្រហម អនុវត្តលិទ្ធិផ្ដាច់ការជ្រុលនិយម បានទទួលយកមនោគមវិជ្ជាកុម្មុយនិស្ត បានមកវាយធ្វើបាបកាប់សម្លាប់កូនខ្មែរ ដោយគ្មានក្ដីអាណិតអាសូរជាតិសាសន៍ឯង បាត់បង់អស់នូវគុណធម៌អ្នកកាន់នឹងគោរពព្រះពុទ្ធសាសនា។ អ្នកដែលនៅរស់សេសសល់ពីស្លាប់ ក្នុងសម័យនោះត្រូវតែចេះធ្វើគថ្លង់ ទើបអាចមានជីវិតរស់រានឆ្លងផុត ពីសម័យផ្ដាច់ការ ប្រល័យពូជសាសន៍នោះបាន។ នេះជាន័យបង្កប់ក្នុងព្យញ្ជនៈ**គ** ដែលត្រូវ**ខ**ម៉ែឲ្យលួយ រួចវាយកូននាគខាងក្រោយឲ្យ**គ** ភ្លេចភ្លាំងភាន់ភាំងច្រឡំវង្វេង នៅពេលណាដែលយើងមិនគាស់កកាយ រុករកឫសកែវដែលត្រូវគេកប់លាក់ទុក អស់រាប់ពាន់ឆ្នាំទេនោះ យើងច្បាស់ជាមិនអាច ដឹងពីប្រវត្តិជាតិពិតបានឡើយ។

នៅក្នុងរឿងធនជ័យ អ្នកប្រាជ្ញលោកបានប្រាប់យើងឲ្យដឹងថា អ្នកប្រាជ្ញចិនចាញ់លោកដោយសារភាសាក្ដាម តើភាសាក្ដាម មានបង្កប់អត្ថន័យអ្វី? ក្ដាមជាសត្វដែលដើរនៅលើភក់ តាមវាលស្រែ នឹងកាយរន្ធនៅក្នុងដីភក់ទន់ ពេលដែលវាដើរស្នាមក្រចកជើងរបស់វា បានទុកដាមជាប់ទៅលើដីភក់ទន់នោះ។ ពាក្យក្ដាមបើយើងសម្រាយពាក្យតម្រួតនេះ **ក្ដាម** = **ក** + **ដាម** អ្នកកកើតទឹកដីបានយករឿងរបស់ខ្លួន ទៅដាមនៅលើភក់ ក្រោយមកភក់នោះបានរឹងក្លាយជាថ្ម ឈ្មោះថាថ្មភក់។ ហេតុនេះហើយ គ្រប់ប្រាសាទថ្មទាំងឡាយពីបុរាណ ដូនតាយើងបានយកថ្មភក់ជានិមិត្តរូប មកកសាងប្រាសាទ រួចដាមភាសាគឬភាសាក្ដាម ទុកនៅគ្រប់ប្រាសាទទាំងនោះ។ ដែលចិនចុះចាញ់ភាសាក្ដាមក្នុងពេលនោះ ព្រោះពួកគេមើលភាសាទាំងនេះពុំទាន់យល់ ទើបគេយកភាសាក្ដាម ដែលក្មេងៗបានស្រែកអាននោះ យកទៅសិក្សានៅប្រទេសគេ ទីបំផុតគេបានយល់ពីភាសាគឬភាសាក្ដាមនេះ។ ចំណែកឯក្មេងៗ បានអានភាសាក្ដាមរបស់អ្នកប្រាជ្ញជ័យ ពុំមាននឹកឆ្ងល់ឬក៏សួរកចម្លើយ ថាហេតុអ្វីបានជាអុំជ័យ ឲ្យពួកយើងចេះតែអាន ថាតាមតែនឹកឃើញយ៉ាង

នេះ ដូចជារឿងដែលស្ដេចទៅស្ដាប់បណ្ដាំចុងក្រោយ ពីការបរិភោគត្រី ស្ដេចក៏ពុំចេះឆ្ងល់ឡើយ ដោយគិតថាធនជ័យនិយាយពីរឿង សោយត្រីធម្មតាទៅវិញ ដោយភ្លេចគិតពិចារណាថា អ្នកប្រាជ្ញក្មេងទាំងមូលរៀបនឹងស្លាប់ តើមានពេលឯណានៅនិយាយពាក្យលេងសើចធម្មតាទៀត? នេះជាប្រស្នាដែលបានបង្កប់លាក់ទុកក្នុងព្យញ្ជនៈ**គ** គឺភាសាក្ដាមឬភាសាអ្នកប្រាជ្ញធនជ័យ ហើយសត្វក្ដាមនេះ គឺជាដួងផ្កាយមួយក្នុងសុរិយគតិ ខែកក្កដា និងចន្ទគតិ គឺខែបុស្ស

**<u>៤.អំពីព្យញ្ជនៈ(ឃ)</u>** (ព្យញ្ជនៈទី៤ក្នុងវគ្គទី១)

ព្យញ្ជនៈ**ឃ**នេះពុំមានន័យគ្រប់គ្រាន់ បង្កើតជាពាក្យបានឡើយ នៅពេលដែលពុំបានផ្សំជាមួយនឹងស្រៈឬព្យញ្ជនៈ។ ព្រោះតំណអ្នក**ក** ត្រូវផ្ដាច់ត្រឹម**ខ** នឹងត្រូវវាយឲ្យ**គ**គាំងទៅហើយ ដូច្នេះប្រវត្តិរបស់អ្នកកកើតទឹកដី ត្រូវលុបដានសាដានលក់ដាន ស្នាមដានដែលសេសសល់ ត្រូវលាយចំរុះពណ៌លែងមានភាពបរិសុទ្ធ។

**<u>៥.អំពីព្យញ្ជនៈ(ង)</u>**(ព្យញ្ជនៈទី៥ក្នុងវគ្គទី១)

សូរសម្លេងរបស់ព្យញ្ជនៈ**ង** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**<u>ពន្យល់ពាក្យ</u>**(មានសូរដូច**ង**)

**ង**( គុ. ) ដែលមានរំពត់ខាងគល់ឬខាងចុងងើយស្ទើតឡើង : ស្នែងគោងស្ទើត, ទូកង, (ប្រើឲ្យងាយមើលងាយអានគួរសរសេរស្នែងគោ-ងស្ទើត, ទូក-ង) ។(ដកចេញពីវចនានុក្រមសម្ដេច)

**ងរ** ( កិ. ) សំដែងអាការមាយានាំឲ្យងរ : ងរចុះ, ងរឡើង។(ដកចេញពីវចនានុក្រមសម្ដេច)

បើយើងពិនិត្យមើលព្យញ្ជនៈក្នុងវគ្គទី១ ដែលមានប្រាំតួអក្សរនេះ គឺត្រូវបញ្ចប់ត្រឹមព្យញ្ជនៈ**ង** ហើយព្យញ្ជនៈ**ង**នេះ សក់ត្រូវចងក្បួចខ្លួនឯងដូចលេខ៩ដែរ អក្សរ**ង**ចងគួចចង្កុលបែរទៅក្រោយ (អតីត) ឯលេខ**៩**ចង់គួចខ្លួនឯង ចង្កុលបែរទៅមុខ(អនាគត)។ បើយើងពុំបានយករូបភាពព្យញ្ជនៈទាំង៣៣តួ មកវិភាគរូបរាងសណ្ឋាននោះទេ គឺយើងពុំបានចាប់អារម្មណ៍ពីរាងរបស់វាឡើយ ហើយក្នុងបណ្ដាព្យញ្ជនៈវគ្គទីមួយនេះ មានតែតួអក្សរងតែមួយប៉ុណ្ណោះ ដែលចងខ្លួនឯងឲ្យជាប់ក្នុងវគ្គទីមួយនេះ ដែលជាតួអក្សរទី៥ក្នុងវគ្គទី១។ ចំណែកសូរសព្ទនិយាយ និងន័យដែលបង្កប់ក្នុងព្យញ្ជនៈនេះ គឺមានន័យថា ងរចុះឬធ្លាក់ចុះ មិនថាមនុស្សឬសត្វ ចាស់ក្មេង បុរសស្ត្រី គ្រហស្ថបព្វជិត ពេលដែលសេចក្ដីងរថ្នាំងថ្នាក់ចិត្តកើតឡើង(ទោមនស្ស) ធ្វើឲ្យចិត្តធ្លាក់ចុះទៅរកទោសៈមូល ហេតុដោយសេចក្ដីវង្វេងដោយមោហៈនិងលោភៈ។ ទោមនស្សចិត្តនេះ បើកើតឡើងនៅពេលជិតស្លាប់ អាចឲ្យចុតិចិត្តចុងក្រោយរបស់បុគ្គលនោះ ទៅបដិសន្ធិនៅក្នុងអបាយភូមិបាន ព្រោះហេតុអកុសលចិត្តនេះ (ងរ)។ យ៉ាងណាមិញ អត្ថន័យក្នុងប្រស្នាព្យញ្ជនៈក្នុងវគ្គទី១ ដែលមានតួអក្សរង ជាតួអក្សរបញ្ចប់ក្នុង

វគ្គនេះ ន័យជារួមក្នុងវគ្គគឺ អ្នក**ក**ត្រូវ**ខ**ឲ្យរលួយ បាត់សភាពទ្រង់ទ្រាយដើមរបស់ខ្លួន ហើយត្រូវវាយឲ្យ**គ**និយាយលែងចេញ បាត់ដានស្នាមត្រឹម**ឃ** រួចក៏ងធ្លាក់ចុះទៅក្នុងអបាយភូមិ។ (សូមអានបន្ថែមបណ្តាំមាតាមហានគរភាគ១ ២ ៣)

**ខ.វគ្គទី២**( មានតួអក្សរ៥តួគឺ **ចឆជឈញ**)

**៦.អំពីព្យញ្ជនៈ(ច)**(ព្យញ្ជនៈទី១ក្នុងវគ្គទី២)

សូរសម្លេងរបស់ព្យញ្ជនៈ**ច** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្តាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ច**)

**ច**( កិ. ) ពុះឈើបំបែកជាពីរដោយដឹងភ្លុក : មនុស្សក្នុងជាន់បុរាណច្រើនចឈើធ្វើជាក្តារក្រាល ព្រោះក្នុងសម័យនោះមានតែដឹង មិនទាន់មានរណារ។(ដកចេញពីវចនានុក្រមសម្តេច)

**ច**ស. ( ន. ) (ច្នូអ. ថ. ច) ស្បៃហ្នាំងគឺស្បៃសដែលគេត្រដាង បញ្ចាំងស្រមោលរូបស្បែកដាប់រំហោក : ចហ្នាំងឬចណាំងសំពត់ស ដែលសម្រាប់បញ្ចាំងភាពយន្តសម័យបច្ចុប្បន្ន ក៏គឺចនុះឯង (ម. ព. ណាំង, ហ្នាំងផង)។(ដកចេញពីវចនានុក្រមសម្តេច)

**ច**យ ( ន. ) (ខ្មែ) ឈ្មោះឆ្នាំទី១១ (សុនខ) : ឆ្នាំច។(ដកចេញពីវចនានុក្រមសម្តេច)

**ចរ**ចសំ. បា. ( កិ. ) ត្រាច់, ដើរ, ទៅ; ប្រព្រឹត្ត។(ដកចេញពីវចនានុក្រមសម្តេច)

បើតាមសូរព្យញ្ជនៈក្នុងតួអក្សរ**ច** ន័យត្រង់ចង់ប្រាប់យើងថា សម័យខាងក្រោយតំណថ្ម ការ**ចរ**នាំប្រវត្តិរឿងអ្នក**ក**(កកើត)ចេញ គឺគ្រាន់តែជាស្រមោល**ច**ណាំង លើក្រណាត់សមួយផ្ទាំង ដែលឆ្លុះទៅតាមរូបជាស្រមោល បានមកចាំងប៉ះឲ្យឃើញ ជាស្រមោលខ្មៅតែប៉ុណ្ណោះ មិនអាចឲ្យយល់រូបភាព ពិតប្រាកដច្បាស់លាស់បានឡើយ។ ភាពជាស្រមោលនេះហើយ ដែលសម្តេចប៉ានលោកបាន ចងក្រង សរសេររឿងល្បើកអង្គរវត្ត ត្រូវរកភាពពិតរបស់អច្ឆរាលែងឃើញ គឺគ្រាន់តែជាការស្មានតាមស្រមោល របស់ភាសា**គ** ដែលចាំងមកលើផ្ទាំងសំពត់សតែប៉ុណ្ណោះ។ រយកាលជាង១០០ឆ្នាំ ដែលខ្មែរបានបោះបង់រាជធានីអច្ឆរិយរបស់ខ្លួន បូករួមទាំងពួកបរទេសគេមានបំណង ចង់លាក់នឹងបំផ្លាញប្រវត្តិដានស្នាមរបស់ជាតិ ពួកគេបានលាយពណ៌ជាតិបញ្ចូលជាមួយនឹងសាសនា... តើធ្វើដូចម្តេច យើងអាចទទួលបាននៅភាពបរិសុទ្ធ នៃប្រវត្តិជាតិខ្មែរនេះបាន? កូនខ្មែរបានត្រឹមតែមើលប្រវត្តិរឿងខ្លួន ក្នុងស្រមោលចណាំង រួចចរនាំប្រវត្តិជាតិជាស្រមោលនេះបន្តគ្នា។ ឧទាហរណ៍ដូចជាសិល្បៈនៃយ៉ាំ ពាក្យពិតរបស់ពាក្យ នៃយ៉ាំ គឺឆាយ៉ាំ(ភាសានិយាយ) ដែលក្លាយមកពីពាក្យឆាយាមានន័យថាស្រមោលនៃការរីករាយសប្បាយ ពីអតីតកាល ក្នុងស្រមោលរឿងរបស់អ្នកនគរនេះ។ ព្រោះអ្នករាំទាំងនោះ ពុំបានប្រើមុខពិតរបស់ខ្លួនឡើយ គឺប្រើមុខត្លុកពាក់ក្លែងក្លាយ បង្ហូតបង្ហាញប្រាប់

អ្នកមើល ថាដូចជាខ្លួនសប្បាយតាមមុខដែលពាក់នេះ។ ចំណែករូបពិតមុខពិត កំពុងតែហត់ហើយព្រួយបារម្ភ ពីការចិញ្ចឹមជីវិតដោយត្រូវការប្រាក់ ដើម្បីយកទៅចិញ្ចឹមក្រុមគ្រួសារ រីឯមុខពាក់ជាស្រមោលចេះតែញញឹម សើចចេញធ្មេញតែឯងទៅ។ ម្យ៉ាងទៀតសិល្បៈផៃយ៉ាំក្ដី ល្ខោនបាសាក់ក្ដី ពេលលេងបើកឆាកក្ដី អ្នកលេងតែងស្រែកពោលថា **យក្សអររឆ្មើមមុន**រហូត ម្ដេចបានជាយក្សអរសប្បាយម្ល៉េះ! ហេតុដូចម្ដេចបានជាអ្នកលេងមិនស្រែកថា**ខ្មែរអរ**? ន័យបង្កប់នេះ គ្រាន់តែជាការឆ្ងល់នឹងពន្យល់ពីអត្ថន័យ ដែលបង្កប់ក្នុងព្យញ្ជនៈ**ច** និងសិល្បៈល្ខោនបាសាក់ផៃយ៉ាំតែប៉ុណ្ណោះ(សូមមើលបណ្ដាំមាតាមហានគរភាគ១ ២ ៣)។

<u>**៧.អំពីព្យញ្ជនៈ(ឆ)**</u> (ព្យញ្ជនៈទី២ក្នុងវគ្គទី២)

សូរសម្លេងរបស់ព្យញ្ជនៈ**ឆ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

<u>**ពន្យល់ពាក្យ**</u> (មានសូរដូច**ឆ**)

**ឆ**( កិ. ) បំភាន់ដោយសំដីដើម្បីនឹងយកទ្រព្យរបស់គេ : ឆយកទ្រព្យគេ, ឆបោកប្រាក់គេចងកសត្វពាហនៈរូបព័ទ្ធឃ្លុំមាត់ ជួសកន្ត្រុះជួសបង្ហៀរឆច្រមុះកូនគោ បង្ខានមិនឲ្យបៅដោះ។ (ដកចេញពីវចនានុក្រមសម្ដេច)

**ឆ** ឆឞ្ឆៈបា.; សំ. ( ប. សំ. ) (ឆស៑) ប្រាំមួយ (៦) ។ឆមាស (ឆ-មាស) "ប្រាំមួយខែ" ។តាមសំយោគវិធានត្រូវតម្រួតមជាចម្មាស, ព្រោះឆ "៦" នេះកាលបើផ្សំនៅពីខាងដើមសព្ទដទៃត្រូវតែតម្រួតព្យញ្ជនៈខាងចុងនោះជាដរាប, ដូចជាឆ + ទន្ត>ឆទ្ទន្ត "ដំរីមានភ្លុក៦ព័ណ៌"; ឆ + វិធ>ឆព្វិធ "៦ប្រការ, ៦យ៉ាង" ជាដើម។ បើមានស្រៈនៅខាងចុងត្រូវចុះអាគមមកផ្សំ, ដូចជាឆ + អង្គ>ឆឡង្គ "អង្គ៦" ។ល។ (ដកចេញពីវចនានុក្រមសម្ដេច)

**ឆ**( ឧ. )សូរព្ទដោយទឹកហូរ ឬចាក់គ្រាប់អ្វីនីមួយតូចៗ មានស្រូវអង្ករជាដើម។ (ដកចេញពីវចនានុក្រមសម្ដេច)

**ឆរ** ( ប. ) ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យឈូៈ មនុស្សឆ្អើលឈូឆរ។ (ដកចេញពីវចនានុក្រមសម្ដេច)

ពាក្យដែលបានបង្កប់ន័យសូរដូច ទុកក្នុងព្យញ្ជនៈ**ឆ** គឺមានន័យថាបញ្ឆោតយើង កុហកឲ្យយើងឆ្អើលឈូឆរឡើង។ **ចរ**នាំរឿងចេញបែរជាត្រូវ**ឆ**បញ្ឆោតកុហក ប្រវត្តិពិតរបស់អ្នក**ក** ព្រោះចង់បំបែកបំបាក់ ដើម្បីប្រមូលយកទ្រព្យសម្បត្តិ មរកតរបស់ដូនតា ធ្វើឲ្យសតិបញ្ញាកូននាគខាងក្រោយវង្វេងរកប្រវត្តិពិតពុំឃើញ ដោយឬសកែវរបស់ជាតិ បានត្រូវគេកប់លាក់ទុកទៅក្នុងអតីតកាល។ អ្វីដែលបានយកមកបង្ហាញនេះ គ្រាន់តែជាស្រមោលចណាំង**ឆ**បោកកុហក រឿងពិតរបស់អ្នក**ក** គឺមាតាមហា

នគរ គេឆក់ហកថាជារឿងរបស់សាសនាទៅវិញ ធ្វើឲ្យពូជនាគលែងដឹងពីសាវតាពិតរបស់ខ្លួន ដោយចាញ់កលល្បិចអ្នកប្រាជ្ញបរទេស មកបំភាន់បិទទ្វារបញ្ញាក្នុងទិសធំទាំង៦ លែងឲ្យដឹងរឿងពិត នេះជាន័យត្រង់ក្នុងភាសាខ្មែរ ដែលបង្កប់ទុកក្នុងសូរព្យញ្ជនៈ**ឆ**។

**<u>៨.អំពីព្យញ្ជនៈ(ជ)</u>** (ព្យញ្ជនៈទី៣ក្នុងវគ្គទី២)

សូរសម្លេងរបស់ព្យញ្ជនៈ**ជ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្តាប់យល់បាន ចំពោះភាសានិយាយ**ជ** = **ជរ**។

**<u>ពន្យល់ពាក្យ</u>** (មានសូរដូច**ជ**)

***ជរ*** ( ន. ) ក្បាច់រំលេចសម្រាប់ដាក់ប្រកបត្រង់ជាយ, ត្រង់រឹម, ត្រង់ហាម : សំពត់មានជរ (គុ.) ដែលមានជរ : ហូលជរ, អាវជរ។ (ដកចេញពីវចនានុក្រមសម្តេច)

តួអក្សរ**ជ**ក៏មានន័យជាពាក្យអាចស្តាប់បាន ទោះបីផ្សំជាមួយព្យញ្ជនៈដូចគ្នា ក៏សម្លេងនូវមានសូរ**ជរ**ដដែល ចំពោះភាសានិយាយ។ តើព្យញ្ជនៈនេះមានបង្កប់ន័យអ្វី សម្រាប់ឲ្យយើងពិចារណា? ពាក្យ**ជ** = **ជរ** បើពុំបានកាត់ផ្តាច់ គឺនៅតែបន្តគ្នារហូត ឲ្យតែយើងព្យាយាមថែរក្សា កុំឲ្យបាត់បង់(ជរសំពត់)។ <u>*ឧទាហរណ៍:*</u>ទេវតាដែលថែរក្សាក្នុងផ្ទះ ភាសានិយាយ ខ្លះហៅថា**ជីនាង**ផ្ទះ ខ្លះទៀតហៅថា**ជរនាង**ផ្ទះ និង**ជំនាង**ផ្ទះ តើពាក្យទាំងបីម៉ាត់នេះ ពាក្យមួយណាត្រឹមត្រូវ បើពាក្យផ្តើមសុទ្ធតែប្រើព្យញ្ជនៈ**ជ**?

**<u>១.ជីនាង</u>**

នៅក្នុងពាក្យសម្គាល់ទេវតាថែរក្សាផ្ទះ មានពាក្យ**ជី** + **នាង** ជីគឺអ្នកបានបួសជាសាមណេរ ហើយសឹកមកវិញ ពីសម័យមុនហៅថាជី តែសម័យសព្វថ្ងៃ ហៅថាបណ្ឌិតឬអន្ទិត។ ជីមួយទៀតគឺសំដៅសម្គាល់ ទៅលើបុរសស្ត្រីនៅជាគ្រហ្ថ តែបានប្រព្រឹត្តិព្រហ្មចរិយធម៌ ថ្នាក់សីល៥, ៨, ១០ ក៏ហៅថាជីដែរ ដូចជាយើងហៅអ្នកដែលស្លៀកសពាក់សថា តាជី ដូនជី យាយជី...។ល។ ដូច្នេះពាក្យជីនាង គឺនាងដែលថែរក្សាផ្ទះសម្បែង នោះជាស្ត្រីដែលបានកាន់និងគោរពព្រះពុទ្ធសាសនា មានគុណធម៌ថ្នាក់សីល ដូចបានរៀបរាប់ខាងលើ ហើយចិត្តគាត់បានជាប់ជំពាក់នឹងមរតក ធ្វើឲ្យកម្មត្រូវរៀបចំឲ្យគាត់ មកថែរក្សាទឹកដីក្នុងផ្ទះទាំងនេះ។

**<u>២.ជរនាង</u>**

ជរនាងគឺជាតំណវង្សត្រកូល តគ្នាមិនដាច់របស់ព្រះមេ ដែលជាអ្នកបង្កើតទឹកដីពីដំបូង ហើយក្រោយមកបានក្លាយជាព្រះម៉ែ(មើលឯកសារជីវតាក្វាន់និយាយពីរឿងបិសាចពស់) ដែលព្រះម៉ែជាព្រះភូមិរក្សាមាតុភូមិនេះទាំងមូល ព្រោះទឹកដីនេះវាជាមរតកតែមួយគត់ ដែលកើតចេញពីញើសឈាមរបស់គាត់។

### ៣.ជំនាងឬជុំនាង

ជំនាងគឺនាងដែលជាអ្នកធ្វើឲ្យជុំញាតិ ជុំទ្រព្យសម្បត្តិ.... ទាំងខាងប្តីទាំងខាងខ្លួន និងធ្វើឲ្យជុំរឿងសុខទុក្ខគ្រប់បែបយ៉ាង អ្នកធ្វើឲ្យជុំគឺនាង។ ក្នុងពិធីលើកផ្ទះថ្មី(ផ្ទះឈើ) មុននឹងលើកបញ្ឈរសសរកន្លោង គេតែងយកសំពត់ជាតិ ព្រៃពណ៌ក្រហម (ពណ៌តំណាងឲ្យជនជាតិចិន)ប្រមាណកន្លះម៉ែត្រ មានគូរយ័ន្ត៨ទិស រួចយកមកវាយភ្ជាប់នឹងមេដំបូល ត្រង់សសរកណ្តាលគឺសសរកន្លោង។ រួចគេមានរៀបចំទ្រនឹបជាង មានបង្អែមចម្អាប ទៀនធូប ភ្ញីផ្កាជាដើម ទៅតាមសមគួរនឹងកម្លាំងទ្រព្យ ដើម្បីសែនព្រេនរំលឹកដល់ទេវតាមួយអង្គ ដែលពួកជាងពីបុរាណ តែងប្រកាន់ជឿថាជាគ្រូធំបំផុតរបស់ពួកខ្លួន។

បើយើងពិនិត្យតាមបណ្តាំភាសា**គ** របស់ព្រះម៉ែមហានគរដែលផ្តាំទុក រឿងរបស់មេឬនាងបានបន្តគ្នាមកមិនដាច់ រហូតមកដល់សព្វថ្ងៃនេះ(ជរនាង)។ ហេតុអ្វីបានជាជាងត្រូវវាយយ័ន្តសីមា៨ទិស ព័ទ្ធមេដំបូលចំកណ្តាលសសរកន្លោង?

## ពន្យល់ពាក្យ

**កន្លោង** ( ន. ឬគុ. ) ម្តាយ; ដែលជាធំ, ដែលជាមេខ្លោង, ជាចំបងលើគេ : ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងព្រះអភិធម្ម ប្រោសព្រះកន្លោង (ព្រះមាតា) សសរកន្លោងគឺសសរទ្រូង។

កន្លោងគឺតំណាងឲ្យព្រះមេឬព្រះម៉ែ គាត់ជាមេខ្លោងគ្រប់គ្រងនគរនេះទាំងមូល បើមេខ្លោងត្រូវចាក់សោដោយយ័ន្តក្រហម មានព័ទ្ធសីមា៨ទិស មកចាក់បោះបិទលើមេដំបូលនោះទៅហើយ តើឲ្យគាត់ចេញមកជួយថែរក្សាកូនចៅម្តេចបាន? នេះមិនទាន់លើកផ្ទះបញ្ឈរឲ្យត្រង់ផង កូនក្មេរវាយចាក់សោបិទឃុំគាត់ ដែលជាទេវតាថែរក្សាផ្ទះដោយពុំដឹងខ្លួន។ ព្រះម៉ែលោកមិនអាចនៅពីខាងលើបានក៏ចុះមកនៅត្រឹមកណ្តាលផ្ទះ ដែលជាកន្លែងតម្កល់**ជីនាង ជរនាង ជំនាង**សព្វថ្ងៃ តែត្រូវកូនយកយ័ន្តក្រហមមានសសេរអក្សរចិន មកបិទចាក់សោឃុំគាត់បន្ថែមទៀត។ សព្វថ្ងៃនេះមិនត្រឹមតែយ័ន្តទេគឺមានរូបអ្នកតាកុងដៀឬអុងដៀ មកអង្គុយជំនួសកន្លែងគាត់ តើឲ្យគាត់ទៅនៅឯណា? ក្នុងនាមខ្លួនជាម្ចាស់មរតក? បើយើងសាកសួរខ្លួនឯងដោយឆ្លល់ថា ពេលមានគ្រោះភ័យកើតឡើង យើងបន់ស្រន់រូបអ្នកតានោះ តើអ្នកតានោះគាត់សុខចិត្ត ជិះយន្តហោះពីស្រុកគាត់(ស្រុកឆ្ងាយ)មកជួយយើង ឬក៏គាត់ជួយកូនចៅគាត់សិន? ចុះអ្នកណា? ដែលទុកមរតកកេរនេះឲ្យយើងគ្រប់គ្នា ហើយថែមទាំងជួយថែរក្សាយើងសព្វថ្ងៃ? ធម្មតាកូនកើតចេញពីផ្ទៃ ឬទ្វារមាសរបស់គាត់ តើគាត់សុខចិត្ត ឱបដៃមើលកូនដែលកំពុងរងគ្រោះកើតដែរឬទេ? ពូជនាគជាពូជដឹងគុណ ជាពូជប្រសើរ ជាពូជព្រហ្ម ហេតុអ្វីបានជាពូជនាគពេលស្លាប់ គេលើទង់ក្រពើឲ្យម្នាក់មួយៗ? បញ្ហាទាំងនេះហើយ ដែលយើងត្រូវតែចេះឆ្លល់ ហើយត្រូវចេះស្វែងរកចម្លើយ ដោយសមតាមហេតុផល ទោះបីមានឧបសគ្គមករារាំង រហូតដល់ជីវិតក៏ដោយ ក៏ត្រូវតែរកយុត្តិធម៌ឲ្យមេដំបូល ដែលជាព្រះកន្លោង ព្រោះលោកសុខចិត្តបំពេញ

ពលិកម្មរងទុក្ខរាប់ពាន់ឆ្នាំ ធ្វើជាព្រាយបិសាច ជាប្រេត ព្រោះហេតុតែថែរក្សា កេរមរតកអច្ឆរិយទាំងនេះទុកឲ្យយើង។

ពេលដែលកូននាគចាក់សោកន្លែង**ជរនាង ជីនាង ជំនាង**ជាប់ តើឲ្យគាត់ទៅនៅឯណា? គាត់ទៅនៅពីខាងក្រោមរនាប **គឺមេរត** ព្រោះហេតុនេះ បានជាយើងមានរឿងនិទានអាជ័យ មេរត មេរតគរបន្តគ្នាពីមួយជំនាន់ទៅមួយជំនាន់ បានក្លាយជាមេត្រិត ពាក្យត្រិតក្លាយមកពីពាក្យ**គរត=ត្រត** លើគ្នា(មើលរូបព្រះមាតាទូលយោនីនៅពីលើក្បាល រួចកប់ត្រឹម**ក**នៅត្រូបក្នុងគុហារប្រាសាទនាគព័ន្ធ)។ នេះជាន័យប្រស្នាដែលបានបង្កប់ លាក់ទុកក្នុងព្យញ្ជនៈ**ជ** បង្កើតបានជារឿង**ចរ**ចេញនាំរឿង**ឆ**បោកបញ្ឆោត**ជ**រនាង អ្នក**ឥ**ទ្រព្យឲ្យទៅធ្វើជាមេរត ទ្វរនាបបាត់ឈ្មោះព្រះកន្លោងចេញពីក្នុងសន្តានកូននាគប្រុសស្រី។

**៩.អំពីព្យញ្ជនៈ(ឈ)** (ព្យញ្ជនៈទី៤ក្នុងវគ្គទី២)

សូរសម្លេងរបស់ព្យញ្ជនៈ**ឈ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ សូរ**ឈ = ឈរ**។

**ពន្យល់ពាក្យ**(មានសូរដូច**ឈ**)

**ឈរ** ( កិ. ) ឋិតពេញជំហរជើងជាន់ត្រង់, ជាឈ្មោះឥរិយាបថមួយ ក្នុងឥរិយាបថទាំង៤គឺ ដើរ, ឈរ, អង្គុយ, ដេក។ស្ថិតនៅ, នៅស្ដីទីរាជការ : រាជការត្រូវចាត់លោក... ឲ្យទៅឈរខេត្រស្វាយរៀង;ខ្ញុំបានឈរធ្វើរាជការទីអភិបាលខេត្រ នៅខេត្រកំពតអស់៥ឆ្នាំ។ នៅទ្រឹងមិនឡើងមិនចុះ, មិនគ្រាន់បើ មិនរឹតឡើង(ជំងឺ) : ជំងឺឈរឲ្យមើលយូរណាស់ មិនគិតរកគ្រូមើលគ្នា។ (គុ. ឬន.) អក្សរដែលមានតួរាងត្រង់ : អក្សរឈរ។ (ដកចេញពីវចនានុក្រមសម្ដេច)

រឿងព្រះកន្លោងដែល**ច**បំបែក រួច**ចរ**នាំចេញមក ត្រូវ**ឆ**បោកកុហកទៅហើយ តើរឿងរបស់**ជ**រនាង អាច**ឈរ**បង្ហាញពីភាពពិតរបស់ខ្លួន ឬក៏ក្លែងក្លាយ? នេះជាហេតុពិត ដែលប្រវត្តិរឿងសម្គាល់ជាតិមួយ នៅតែជាស្រមោល មិនទាន់អាចក្លាយជាការពិតបាន ព្រោះអ្នកលើកប្រវត្តិជាតិឲ្យឈរពីសម័យមុន ភាគច្រើនសុទ្ធតែអ្នកប្រាជ្ញបរទេស។

**១០.អំពីព្យញ្ជនៈ(ញ)** (ព្យញ្ជនៈទី៥ក្នុងវគ្គទី២)

សូរសម្លេងរបស់ព្យញ្ជនៈ**ញ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ញ**)

**ញ**( ន. ) ឈ្មោះឈើមានផ្លែប្រើជាថ្នាំឬជាអាហារ ស្លឹកក៏ប្រើជាអាហារបាន; ញមានពីរប្រភេទគឺញស្រុកមួយ,ញព្រៃមួយ;ញព្រៃនឹងប្រើផ្លែឬស្លឹកជាអាហារពុំបានទេ។ (ដកចេញពីវចនានុក្រមសម្ដេច)

**ញ** ( គុ. ) ដែលមានសណ្ឋានដូចផ្លែញ ដោះញ, ស្ដ្រីដោះញ (ប្រើចំពោះតែដោះស្ត្រី)។ (ដកចេញពីវចនានុក្រមសម្ដេច)

ព្យញ្ជនៈទី៥ក្នុងវគ្គទី២នេះ ត្រូវបញ្ចប់ដោយតួអក្សរ**ញ** ព្រោះហេតុអ្វី? កូននាគអាចស្គាល់ម្ដាយបាន លុះត្រាតែបៅដោះម៉ែ ចុះបើក្បាលដោះម៉ែ ជាស្ត្រីដោះញទៅហើយ តើឲ្យកូនបៅម្ដេចបាន? ហើយបើកូនបៅពុំបាន ធ្វើដូចម្ដេច អាចទៅឋិតក្នុងទ្រូងម្ដាយកើត? ប្រស្នាជានិមិត្តរូបនេះហើយ បានជាមានស្រុកមួយនៅក្នុងខេត្តព្រៃវែង ឈ្មោះហៅថាស្រុកក្របៅ។ ប្រស្នាព្យញ្ជនៈ**ញ**នេះបានបើកបង្ហាញបញ្ជាក់ ឲ្យកូននាគដឹងថា យើងពុំបានស្ថិតនៅក្នុងដើមទ្រូងគាត់ ពុំបានបៅដោះគាត់ ដូច្នេះទើបយើងមិនដឹងថា ម្ចាស់អ្នកបង្កើតមាតុភូមិនេះជានរណា? ម្ចាស់សមុទ្រទឹកដោះជានរណា? អ្នកណាជាម្ចាស់ទឹកអម្រឹត នៅក្នុងសមុទ្រទឹកដោះ?

**គ.វគ្គទី៣** (មានតួអក្សរ៥តួគឺ **ដ ឋ ឌ ឍ ណ**)

**១១.អំពីព្យញ្ជនៈ(ដ)** (ព្យញ្ជនៈទី១ក្នុងវគ្គទី៣)

សូរសម្លេងរបស់ព្យញ្ជនៈ**ដ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ដ**)

**ដ** យ. ទីចម្លង, កំពង់ចម្លង : កំពង់ដ។ ទូកសម្រាប់ចម្លងនៅកំពង់នោះក៏ហៅដដែរ : ទូកដ។ល។ (ដកចេញពីវចនានុក្រមសម្ដេច)

**ដរ** ( គុ. ) អំពីរោគដែលរើឡើងដោយប៉ះទង្គិច : ដំបៅដរ, បូសដរ, ជាដើម។ (ដកចេញពីវចនានុក្រមសម្ដេច)

**ដ៏** និ. ដែល, ដែលជា; ពាក្យជាវិសេសនៈ, មានសំឡេងខ្លីកំបុត សម្រាប់និយាយផ្សំនឹងគុណនាម ប្រើរៀងរបៀបត្រង់ខាងដើមគុណនាម ដែលគួរប្រកបជាមួយផងបាន: ធមិដ៏បវរ, ទ្រព្យដ៏ប្រសើរ។ មិនប្រើជាវិសេសនៈចំពោះមនុស្សសត្វផងទេ កុំប្រើជាមនុស្សដ៏ស្រែ, ដ៏ចម្ការ; ត្រូវប្រើពាក្យថា : មនុស្សអ្នកស្រែ, អ្នកចម្ការ។ល។ (ដកចេញពីវចនានុក្រមសម្ដេច)

ក្នុងនាមជាព្រះព្រហ្មជាបុព្វទេវតា គាត់សុខចិត្តធ្វើបាបគ្រប់បែបយ៉ាងដើម្បីកូន ចុងក្រោយបានទទួលផលតបស្នង គឺត្រឹមឈឺចាប់**ដរ**ពើតផ្សាតែម្នាក់ឯង។ ទោះបីជាខំស្រែកហៅអ្នកខាងក្រោយឲ្យជួយ ក៏គេមិនដឹងមិនឮមិនស្គាល់ខ្លួន ក្នុងនាមជាអ្នកធ្វើទូកក្បូន ធ្វើទីចម្លងឲ្យគេ បានត្រឹមតែប្រមូលមរតកមកទុក ហើយទៅសោយទុក្ខ។ ព្យញ្ជនៈ**ដ**នេះបានបង្ហាញ ប្រាប់ន័យរបស់ខ្លួនថា មានទុក្ខធ្ងន់

ឈើចាប់**ដរ**ពើតខ្លោចផ្សាដ៏ក្រៃលែង ហើយតែម្នាក់ឯងទៀត ព្រោះគ្មានអ្នកដឹងក្រៅពីខ្លួនអ្នកប្រព្រឹត្ត សាង ព្រោះហេតុតែធ្វើទីចម្លងដល់ពពួកញាតិ មានកូននិងក្រុមគ្រួសារ...។ល។

**១២.អំពីព្យញ្ជនៈ(ឋ)** (ព្យញ្ជនៈទី២ក្នុងវគ្គទី៣)

**១៣.អំពីព្យញ្ជនៈ(ឌ)** (ព្យញ្ជនៈទី៣ក្នុងវគ្គទី៣)

**១៤.អំពីព្យញ្ជនៈ(ឍ)** (ព្យញ្ជនៈទី៤ក្នុងវគ្គទី៣)

**១៥.អំពីព្យញ្ជនៈ(ណ)** (ព្យញ្ជនៈទី៥ក្នុងវគ្គទី៣)

ក្នុងព្យញ្ជនៈវគ្គទី៣នេះ ត្រូវបាត់ដានរឿងក្នុងបួនតួអក្សរ **ឋ ឌ ឍ ណ** ព្យញ្ជនៈទាំងបួននេះ មិនអាចបង្កើតជាពាក្យ ឲ្យមានន័យគ្រប់គ្រាន់ស្ដាប់បាន គឺរឿងរបស់ពួកគាត់ស្ថិតក្នុងភាពងងឹត ដោយពុំបានបង្ហាញ ឲ្យកូននាគខាងក្រោយបានឃើញ ពីការ**ដរពើត**ឈឺចាប់តែម្នាក់ឯង របស់អ្នក**ត** ទ្រព្យមរតក គឺមាតាមហានគរ ព្រោះរឿងពិតរបស់លោក បានបាត់ដំណឹងសូន្យឈឹង ក្រោយពេល ដែលបោះបង់ចោលក្រុងអង្គរ។ ព្រះមាតាមហានគរ លោកលែងមានកម្លាំងឫទ្ធិ អាចលួចចេញពីទី ឃុំបានទៀតហើយ សេចក្ដីសង្ឃឹមតែមួយគត់ គឺពឹងទៅលើកូននាគណា មាននិស្ស័យចេះដោះនូវ ប្រស្នាភាសា**ត** ដែលបានបង្កប់ក្នុងមរតករបស់លោក។

**ឃ.វគ្គទី៤**( មានតួអក្សរ៥តួគឺ **ត ថ ទ ធ ន**)

**១៦.អំពីព្យញ្ជនៈ(ត)** (ព្យញ្ជនៈទី១ក្នុងវគ្គទី៤)

សូរសម្លេងរបស់ព្យញ្ជនៈ**ត** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសា និយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ត**)

**ត** ( កិ. ) ភ្ជាប់, ភ្ជាប់គ្នាឲ្យវែងតទៅទៀត : តដៃដែលបាក់, តខ្សែដែលដាច់, តខ្សែឲ្យវែង, ត ហប់ផ្ទះ...។(ដកចេញពីវចនានុក្រមសម្ដេច)

**ត**កិ. វិ. ឬគុ. ដែលជាលំដាប់ៗគ្នា, ដែលមានពីមួយទៅមួយ, ពីនេះទៅនោះ : ឮតពីគេមក, ឮ តៗគ្នា, នាំតៗគ្នាមក; ផ្លូវតគ្នា...។(ដកចេញពីវចនានុក្រមសម្ដេច)

**ត**ដៃកិ. ប្រយុទ្ធតវិញ, តស៊ូមកវិញដោយដៃឬដោយគ្រឿងប្រហារ។តតបកិ. ឆ្លើយឆ្លងសងសម្ដី, ជជែកសងពាក្យសម្ដីរកខុសត្រូវ។(ដកចេញពីវចនានុក្រមសម្ដេច)

**ត**តាំងកិ. ប្រណាំងប្រជែងសម្ដីដោយអាងភ័ស្ដុតាង, តពាក្យសម្ដីឬតដំណើរសេចក្ដីដោយមាន ក្រិយាតំណាំង។(ដកចេញពីវចនានុក្រមសម្ដេច)

**ត**តួកិ. វិ. ដែលតស៊ូគ្នាតែមួយនិងមួយ : វាយតតួ, ចំបាប់តតួ; តែមួយនិងមួយឥតមានថែម : ដូរ គោតតួ។(ដកចេញពីវចនានុក្រមសម្ដេច)

**ត**ទល់កិ. និយាយសើរើរកខុសរកត្រូវទល់មុខគ្នា, លើកទ័ពឬពួកកងទៅមកប្រឈមទល់គ្នា។ (ដកចេញពីវចនានុក្រមសម្ដេច)

**ត**ទៅនិ. រៀងទៅ, ដរាបទៅ (ដកចេញពីវចនានុក្រមសម្ដេច)

ព្យញ្ជនៈ**ត**នេះ បានផ្ដើមប្រាប់ន័យរបស់វាឲ្យយើងដឹងថា រឿងរ៉ាវអ្នក**ត**ដែលបាត់ដំណឹងរាប់ពាន់ឆ្នាំនោះ ត្រូវសើរើ**ត**ភ្ជាប់សារជាថ្មីឡើងវិញ។ អ្នកកកើតមរតកទុក ចាប់ផ្ដើមមានក្ដីសង្ឃឹម ព្រោះមានកូននាគចាប់ដឹងរឿងរួច**ត**តំណ ដែលដាច់ឲ្យជាប់គ្នាវិញ គឺអតីតកាល ភ្ជាប់ជាមួយនឹងបច្ចុប្បន្នកាល។

**<u>១៧.អំពីព្យញ្ជនៈ( ថ )</u>** (ព្យញ្ជនៈទី២ក្នុងវគ្គទី៤)

តួអក្សរ**ថ**នេះពុំមានន័យបង្កើតជាពាក្យ អាចមានន័យគ្រប់គ្រាន់ស្ដាប់យល់បានឡើយ តែវាជានិមិត្តរូបតាងឲ្យអ្នក**ត**អ្នករែក។ ព្យញ្ជនៈទាំង៣៣តួ បើយើងយកមកចែកនឹង២ គឺមិនអាចចែកដាច់ឡើយ ត្រូវនៅសល់តួអក្សរមួយនៅចំកណ្ដាល គឺតួអក្សរ**ថ**ជាអ្នករែកតួអក្សរទាំង១៦សងខាង។ ហេតុអ្វីបានជាជនជាតិសៀម ផ្លាស់ឈ្មោះទៅជាថៃ? តាមការយល់នឹងស្រាវជ្រាវ រកឃើញនៅក្នុងព្យញ្ជនៈនិងស្រៈ យើងអាចឈ្វេងយល់បានថា ការផ្លាស់ប្ដូរឈ្មោះពីសៀមមកថៃ អ្នកប្រាជ្ញគេបានគិតទុករួចជាមុនទៅហើយ នូវន័យប្រស្នាបង្កប់ ក្នុងព្យញ្ជនៈខ្មែរទាំង៣៣តួនេះ។ សៀមមកពីពាក្យពីរម៉ាត់ សៀ + ម (សសៀរម៍) គឺព្យញ្ជនៈ**ស**ផ្សំនឹងស្រៈ**ៀ**បូកនឹង**ម** ភាសានិយាយ**ម៍** ភាសាសរសេរ**មក** ។ ថៃគឺព្យញ្ជនៈ**ថ**+ស្រៈ**ៃ** ដែលព្យញ្ជនៈ**ថ**ជាតួរែក ដូចខ្ញុំបានពន្យល់ខាងលើរួចហើយ គឺ**ថ**រែកតួអក្សរ១៦ខាងដើម និងព្យញ្ជនៈ១៦ខាងចុង។ ចំណែកស្រៈ**ៀ**(សៀម) និងស្រៈ**ៃ**(ថៃ)នៅអមសងខាងបិទស្រៈ**េ** និងស្រៈ**ៃ**ជាប់ ដោយយើងសរសេរពាក្យសម្គាល់ ជាតិយើងក្មេរ ឬខ្មែរ។ ស្រៈ**ៀ**និងស្រៈ**ៃ**បាននៅសងខាងឃុំស្រៈ**េ**និងស្រៈ**ៃ**ជាប់ ព្រោះវាជានិស្ស័យរបស់ជាតិខ្មែរនេះ ត្រូវតែប្រើប្រាស់ស្រៈ**េ**និងស្រៈ**ៃ**។ ជានិមិត្តរូប ពួកគេចង់ប្រកាសឈ្មោះ ដែលដូរនេះឲ្យយើងដឹងថា ភ្នំដងរែកដ៏ធំវែង សម្រាប់រែកម៉ែនិងឪ យកទៅដាក់នៅលើកំពូលប្រាសាទភ្នំព្រះវិហារវិញ គឺមានតែជនជាតិ ដែលមានតួអក្សរ**ថ**ជាឈ្មោះសម្គាល់ទេ ដែលមានចំនួនមនុស្សជាង៨០លាននាក់ ទើបអាចលើកភ្នំដងរែកនេះរួច នេះជាមហិច្ឆតាដែលសព្វថ្ងៃ ពួកគេចង់បានប្រាសាទព្រះវិហារ។ តួអក្សរ**ថ** ត្បិតថាពុំមានន័យគ្រប់គ្រាន់ បង្កើតជាពាក្យបាន ក៏ប៉ុន្តែគុណធម៌បង្កប់របស់វាគឺជាតួរែក ព្យញ្ជនៈខាងដើម១៦ និងព្យញ្ជនៈខាងចុង១៦ បើប្រៀបធៀបមកមនុស្ស គឺតំណាងឲ្យកូនកតញ្ញូ។ តើអ្នករែកព្រះមាតាព្រះបិតា ទៅដាក់លើកំពូលភ្នំប្រាសាទព្រះវិហារធម៌វិញ **ថ**តំណាងថៃ ឬ**ថ**តំណាងខ្មែរ?

**<u>១៨.អំពីព្យញ្ជនៈ( ទ )</u>** (ព្យញ្ជនៈទី៣ក្នុងវគ្គទី៤)

សូរសម្លេងរបស់ព្យញ្ជនៈ**ឆ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូចឆ)

**ទ**( ន. ) ប្រដាប់ធ្វើដោយឈើ, ឬស្សីឬដោយស័ង្កសីជាដើមសម្រាប់រង, សម្រាប់បង្ហូរទឹក : ទឹកហូរតាមទ; ផ្ទះភ្លោះ៥ខ្នងមានទ៤កន្លែង។ធ្នារទឹកភ្លៀងដែលធ្លាក់ពីអាកាស : ទនៃទឹកភ្លៀង (បា. ហៅឧទកធារ, ជលធារ "ធារទឹក, ទនៃទឹក") ។ទនេះជាសព្ទកំព្រា, ត្រូវសរសេរទ-ទឹក (ទនៃទឹក), កុំឲ្យច្រឡំនឹងភ្លៀងទទឹក, សំពត់ទទឹក។ឧទាហរណ៍សម្រាប់ប្រើពាក្យទនិងទរ : ទស័ង្កសីនៅផ្ទះបាយវាធ្លុះលេចទឹក, ខ្ញុំអាល័យតែផ្សារ-ទឲ្យជិតឡើងវិញ, ស្រាប់តែឆ្មាមួយចូលទៅក្នុងផ្ទះបាយទរត្រីអាំងម៉ែអស់មួយតម្បុត, ម៉ែមិនទរឆ្មា, បែរជាទរខ្ញុំកំពុងផ្សារ-ទធ្លុះឯណោះទៅវិញថាខ្ញុំមិនជួយមើលត្រីអាំងឲ្យផងបណ្ដាលឲ្យឆ្មាទរអស់ (ម. ព. ទរទៀតផង) ។(ដកចេញពីវចនានុក្រមសម្ដេច)

**ទរ** ( កិ. ) កិន. គឺជេរ, ស្ដីឲ្យ, បន្ទោស; វាយ, ទះ, តប់... (ជាពាក្យសាមញ្ញសម្រាប់និយាយបញ្ឆៀងមិនចំពោះដំណើរជេរ, បន្ទោសជាដើមនោះទេ) : ខ្ញុំឥតដឹងរឿងហ្នឹងសោះស្រាប់តែគាត់មកដល់ភ្លាមតាំងទរខ្ញុំតែម្ដង។ស៊ី (ព. សា.) ឆ្កែទរនំអស់។ល។(ដកចេញពីវចនានុក្រមសម្ដេច)

ទឹកចិត្តព្រះម៉ែហូរតាមទចេញពីទរូង(ទ្រូង) ពេលណាដែលកូននាគព្រមចាក់ទឹកចិត្ត ម៉ែចេញពីក្នុងបេះដូង (មើលល្បែងចាក់ទឹកដូងក្នុងភាគ១) នោះយើងនឹងស្គាល់ព្រហ្ម។ គាត់តែងបន្ទោសជេរស្ដីទរឲ្យកូននាគថា អ្នកទាំងអស់មិនដឹងគុណគាត់ បំភ្លេចគាត់ ស្គាល់គាត់បានត្រឹមគ្រាប់បាយ(ព្រះមេ) បើបានជារំលឹកឃើញឈ្មោះគាត់ កូននាគ ភាគច្រើន គឺយកគាត់មកជេរ(ជេរម៉ែឬជេរម្ដាយ)។ នេះជាហេតុអកុសលកម្មឲ្យផល ពេលនឹករលឹកឃើញឈ្មោះគាត់ ពុំបានបញ្ជូនបុណ្យឧទ្ទិសបុណ្យ ចែកបុណ្យទៅដល់ពួកគាត់ ដែលជាអ្នកនាំមរតកទាំងអស់ មកទុកឲ្យកូនប្រុសស្រី ជាពិសេសគឺមរតកព្រះពុទ្ធសាសនា គឺជាសាសនាដែលអាចនាំអ្នកប្រព្រឹត្តប្រតិបត្តិ ជួយឲ្យអ្នកមានទុក្ខ ដែលជាញាតិបានរួចផុតពីទុក្ខ និងជួយខ្លួនឯងឲ្យបានចាកចេញ ពីវដ្ដសង្សារនេះផង។ ព្យញ្ជនៈ**ទ**នេះក៏ចងក្បួចខ្លួនឯងក្នុងវគ្គទីបួននេះ ឯកំនួចបានចង្អុលប្រាប់ទៅអតីតកាល ដែលមិនទាន់អាចស្រាយប្រស្នារួច តភ្ជាប់បាន តែ**ទ**នូវក្បួចឲ្យជាប់នៅក្នុងទ្រូងនៅឡើយ ដោយមិនអាចនិយាយចេញ។

**<u>១៩.អំពីព្យញ្ជនៈ(ធ)</u>** (ព្យញ្ជនៈទី៤ក្នុងវគ្គទី៤)

**<u>២០.អំពីព្យញ្ជនៈ(ន)</u>** (ព្យញ្ជនៈទី៥ក្នុងវគ្គទី៤)

ព្យញ្ជនៈទាំងពីរតួនេះ មិនទាន់ផ្សំជាមួយស្រៈឬព្យញ្ជនៈ ពុំអាចបង្កើតជាពាក្យមានន័យគ្រប់គ្រាន់បានឡើយ បានត្រឹមតំណាងឲ្យតួព្យញ្ជនៈខ្លួនឯងតែប៉ុណ្ណោះ ប៉ុន្តែតួអក្សរទាំងពីរនេះ មានប្រស្នាកំបាំងមួយ ដែលលាក់ទុកនៅជិតគ្នា។ បើព្យញ្ជនៈទាំងពីរបញ្ចូលគ្នា បង្កើតបានជាពាក្យ**ធន** = **ទ្រព្យ**

**សម្បត្តិ**ហេតុអ្វីព្យញ្ជនៈទាំងពីរនេះ នៅជិតគ្នាបែរជាមិនអាចបង្កើតជាពាក្យបាន? បើយើងងាកទៅអតីតកាល យើងនឹងធ្លាប់ឮចាស់ៗនិយាយសួរគ្នាថា តើអ្នកចេះអក្សរឬទេ? ចាស់ដែលមិនបានបួសរៀនគាត់តែងឆ្លើយថា ខ្ញុំមិនចេះ**ន**ខ្វាក់មួយទេ ហេតុអ្វីបានជាព្យញ្ជនៈ**ន**បែរជាខ្វាក់? ហើយព្យញ្ជនៈ៣២ទៀតមិនខ្វាក់? ប្រស្នានេះហើយ ដែលបានបញ្ជាក់ប្រាប់ថា ព្យញ្ជនៈ**ន** មើលព្យញ្ជនៈ**ឆ**មិនឃើញ ទើបមិនអាចបង្កើតជាពាក្យឆនបាន ព្រោះ**ន**បានខ្វាក់ទៅហើយ។

**<u>ពន្យល់ពាក្យ</u>**(នខ្វាក់)

**នខ្វាក់**ន-ខ្វាក់ព. បុ. ( ន. ) អក្សរនដែលមានរាងសណ្ឋានក្បូចខ្វែងជាត្រីកោណ (បីជ្រុង)  នេះសម្រាប់សរសេរចុះក្នុងផ្ទៃកន្សែងយ័ន្ត ក្នុងសម័យបុរាណ ដោយគេសន្មតថាជាតួអក្សរពិសេស មានអានុភាពពូកែស័ក្តិសិទ្ធិសម្រាប់ជួតក្បាលចូលកាន់សង្គ្រាម...។ អ្នកដែលមិនចេះអក្សរច្រើននិយាយប្រាប់គ្នីគ្នាថា ខ្ញុំឥតចេះអក្សរមួយតួទេសូម្បីតែនខ្វាក់ក៏ឥតចេះដែរ។ (ដកចេញពីវចនានុក្រមសម្តេច)

ឆនជ័យបានផ្តាំថា ពេលកូននាគស្គាល់ឆនធានរបស់ជ័យ គ្រប់ជំនាន់ប្រាសាទថ្ម ពេលនោះតួអក្សរ**ន**ឈប់ខ្វាក់ទៀតហើយ នឹងមានភ្នែកទីបីក្រឡេកមើលក្រោយ ឃើញ**ឆ**ដែលជាអ្នកជំនាន់មុនរបស់ខ្លួន រួមជាមួយនឹងខ្លួនជាតួអក្សរ**ន** បង្កើតបានជាទ្រព្យឆនអច្ឆរិយ។

**<u>ខ.វគ្គទី៥</u>**( មានតួអក្សរ៥តួគឺ **ប ផ ព ភ ម**)

**<u>២១.អំពីព្យញ្ជនៈ(ប)</u>** (ព្យញ្ជនៈទី១ក្នុងវគ្គទី៥)

សូរសម្លេងរបស់ព្យញ្ជនៈ**ប** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្តាប់យល់បាន ចំពោះភាសានិយាយ។

**<u>ពន្យល់ពាក្យ</u>**(មានសូរដូច**ប**)

**បរ** ( កិ. ) ដឹក, នាំ, បញ្ជូន, បណ្តេញឲ្យទៅមុខដោយជិះ, ដោយដើរកាល់, ដើរអម, ដើរតាម, តម្រង់ឲ្យត្រង់តាមលំអានតាមផ្លូវដែលត្រូវការ : បររទេះ, បររថ, បរសេះ, បរដំរី។បរពល (--ពល់) លើកកងទ័ពត្រួតពលបណ្តើរ។ល។ លលកបរគឺសត្វលលកដើរបណ្តើរបញ្ចេញសំឡេងញាប់រន្ថាន់រនៗបណ្តើរ។(ដកចេញពីវចនានុក្រមសម្តេច)

បើតាមន័យពាក្យមានសូរដូច**ប** គឺដល់ពេលវេលាត្រូវដឹកនាំបញ្ជូនចេញមកក្រៅ ក្រោយពីបានដឹងរួចតភ្ជាប់ នៅរឿងរបស់អ្នក**ភ**មរតកអច្ឆរិយពីអតីតកាល ហើយបរនាំយករឿងចេញ មកផ្សព្វផ្សាយប្រាប់ឲ្យកូននាគទាំងអស់ បានដឹងរួចឈ្វេងយល់ នៅសាវតានាគពីអតីត។ នេះជាអត្ថ

ន័យបង្កប់ក្នុងព្យញ្ជនៈ**ច**ក្នុងវគ្គទី៥ ក្នុងតួអក្សរទី១ ដែលបង្ហាញពីន័យពិត និងភារកិច្ចតួនាទីរបស់ខ្លួន។

**២២.អំពីព្យញ្ជនៈ(ឆ)** (ព្យញ្ជនៈទី២ក្នុងវគ្គទី៥)

ព្យញ្ជនៈ**ឆ**នេះ មិនទាន់ផ្សំជាមួយស្រៈឬព្យញ្ជនៈ ពុំអាចបង្កើតបានជាពាក្យមានន័យគ្រប់គ្រាន់ឡើយ បានត្រឹមតំណាងឲ្យតួព្យញ្ជនៈខ្លួនឯងតែប៉ុណ្ណោះ។ នៅក្នុងវគ្គទី៤ ព្យញ្ជនៈ**ត**រួចព្យញ្ជនៈ**ថ** ចំណែកវគ្គទី៥ ព្យញ្ជនៈ**ច**រួចព្យញ្ជនៈ**ឆ** ហេតុអ្វីបានជាអ្នកដែល**ត**រឿងគឺ**ថ** ចំណែកអ្នក**ច**រនាំរឿងចេញផ្លាស់ទៅជា**ឆ**? តើហេតុបច្ច័យវាយ៉ាងដូចម្ដេច?

**២៣.អំពីព្យញ្ជនៈ(ព)** (ព្យញ្ជនៈទី៣ក្នុងវគ្គទី៥)

សូរសម្លេងរបស់ព្យញ្ជនៈ**ព** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូចព)

**ព**( កិ. ) លើកដាក់ចង្កេះកៀកនឹងដៃឈរឬដើរ : ពកូន។ព. ប្រ. ពផែនដីរក្សាផែនដីគឺគ្រប់គ្រងរក្សាអាណាចក្រនីមួយៗ។ពពោះមានផ្ទៃពោះ (ផើម) ។ទទួលរងធ្វើកិច្ចការរបស់អ្នកដទៃឲ្យនៅលើខ្លួនទាំងអស់; ទទួលរ៉ាប់រងទុក្ខលំបាកជាងគេឬជាជំនួសអ្នកដទៃ : ពកិច្ចការ, ពគំនរទុក្ខ, ពការនឿយហត់, ពរវល់។(ដកចេញពីវចនានុក្រមសម្ដេច)

**ពរ**សំ. បា. ( ន. ) (វរ) គុណជាតិដ៏ប្រសើរ; គុណជាតឬអ្វីៗដែលគួរប្រាថ្នា, គួរចង់បាន, គួរជ្រើសរើសយកតាមគាប់ចិត្ត : សូមពរ, ឲ្យពរ, ទទួលពរ។ឲ្យពរសព្ទសាធុការបញ្ចេញសូរសព្ទថាសាធុសូមឲ្យ... បានប្រកបតាមបំណង!... ។ស្រែកឲ្យពរឲ្យជ័យស្រែកឲ្យពរថាសូមឲ្យ... មានជ័យជម្នះ ! ដូចយ៉ាងស្រែកថាជយោ ! ឬជយោ ! ជយោ ! ជាដើម (ម. ព. នោះផង) ។ពាក្យនេះសំ. បា. ប្រើជាគុ. ក៏បានប្រែថា "ប្រសើរ; ដែលគួរប្រាថ្នា, គួរចង់បាន, គួរជ្រើសរើសយកតាមគាប់ចិត្ត"; ខ្មែរប្រើក្លាយមកជាព្រះក៏មាន, នៅជាវរឬវរៈតាមរូបដើមក៏មាន (ម. ព. ព្រះនិងវរឬវរៈទៀតផង) ។(ដកចេញពីវចនានុក្រមសម្ដេច)

**ពរ** ( ន. ) លាបបូកព្រលាំងដោយជ័រឲ្យក្រាស់ជិតសាច់ពុំឲ្យជ្រាបទឹកបាន : ពរទូក, បិទពរ។(ដកចេញពីវចនានុក្រមសម្ដេច)

នៅក្នុងព្យញ្ជនៈ**ព**នេះ ន័យបង្កប់ក្នុងតួអក្សរ គឺមានកូននាគចាប់ផ្ដើម**ព**នាំគាត់ចេញមកក្រៅហើយ ដោយបរនាំចេញផង **ព**បើលើកគាត់ចេញពីសមុទ្រទឹកដោះផង។ **ពរ**ដែលជាគុណធម៌ប្រសើរ តែងកើតមានដល់កុលបុត្រណា ដែលបានបំពេញនូវកតញ្ញូនិងកតវេទី។ ការបដិបត្តិដ៏ប្រសើរនេះ សម្លេង**ពរ**ជ័យសិរីសួស្ដីទាំងឡាយ តែងកើតមានចំពោះកុលបុត្រនោះ ព្រោះបានបិទពរ (បិទបាប) មាតាបិតា និងពពួកញាតិ មិនឲ្យទឹកលេចចូលក្នុងចិត្ត នាំឲ្យធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិទៀត។

**__២៤.អំពីព្យញ្ជនៈ(ភ)__** (ព្យញ្ជនៈទី៤ក្នុងវគ្គទី៥)

សូរសម្លេងរបស់ព្យញ្ជនៈ**ភ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**__ពន្យល់ពាក្យ__**(មានសូរដូច**ភ**)

**ភរ** ( កិ. ) ពោលពាក្យមិនពិត, កុហក។គុ. ឬកិ. វិ. ដែលមិនពិត, កុហក : មនុស្សភរ, សម្ដីភរ; និយាយភរ។ភរភាយភររហាចរហតាមតែរួចពីមាត់។ ភរភូតឬភូតភរភរទាំងស្រុង; ដែលសុទ្ធតែភរ។ (ព. កា.) : មនុស្សមេភរ ចេះតែកម្ហូរភរឲ្យគេស្ដាប់ ភរទៅភរទៅត្រូវលង់ចំណាប់ អ្នកផងគេចាប់-ផ្ទាក់ព្រោះតែភរ។(ដកចេញពីវចនានុក្រមសម្ដេច)

ព្យញ្ជនៈ**ភ**នេះ តាមសូរសព្ទនិយាយយើងអាចស្ដាប់ន័យបាន ថាកុហក ឬពាក្យមិនពិត(ភរ) មានន័យថា ពីមុនបរទេសគេ**ភរ**ឆបោកយើង ឲ្យយល់ច្រឡំថា មរតកអច្ឆរាទាំងអស់ជាមរតករបស់សាសនា។ ពេលនេះយើងឈប់ជឿ ដោយមិនទាន់បានពិចារណាឈ្វេងយល់ ព្រោះមានអ្នក**ភ**រឿង មានអ្នក**ប**រនាំរឿង ចេញមកខាងក្រៅហើយ បើបរទេសចង់**ភរ**តទៅទៀត ត្រូវទុកឲ្យកូននាគពិចារណាសិន បើសមតាមហេតុសឹមជឿតាមក្រោយ ក៏មិនយឺតពេលដែរ។ ខ្លួនជាប្រមុខ ជាប្រភពដើមនៃព្រហ្មញ្ញសាសនា ទីបំផុតបានត្រឹមមកសុំចម្លងប្លង់សំណង់ប្រាសាទអង្គរ ចេញពីគំនិតកូនខ្មែរទៅវិញ តើវាសមហេតុផលដែរឬទេ?

**__២៥.អំពីព្យញ្ជនៈ(ម)__** (ព្យញ្ជនៈទី៥ក្នុងវគ្គទី៥)

សូរសម្លេងរបស់ព្យញ្ជនៈ**ម** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**__ពន្យល់ពាក្យ__**(មានសូរដូច**ម**)

**ម៍ម** ( កិ. ) ពាក្យសាមញ្ញ ឬជាគ្រាមភាសាមានសូរបញ្ចាក់ខ្លី ឬសូរបង្អូសជាជំនួសសម្ដីថា មក ដូចជានិយាយថា : ម៍ទៅផ្ទះ ! ឬថាមក៍, មក៍អង្គុយឯណោះម៍ !; ឬថា : ម៉ុះ ! តុះ ! ដូចជាថា:ម៉ុះ, ទៅផ្ទះ !, តុះ, ប៉ុណ្ណឹងចុះ ! (ហៅថាសម្ដីម៉ុះតុះ សម្រាប់និយាយចំពោះមនុស្សអ្នកមានសភាពស្មើគ្នា) ។មក៍ (ដកចេញពីវចនានុក្រមសម្ដេច)

**មរ**មបា. ; សំ. ( កិ. ) (មរ៑, ម្រ, ម្ទ) ស្លាប់ (សម្រាប់ប្រើចំពោះតែក្នុងកាព្យដែលកវីត្រូវការប្រើខ្លះ កុំឲ្យខ្វះដូចជា) : ព្រឹកមិញគាត់ត្រាច់ចរ ល្ងាចគាត់មរឥតដឹងខ្លួន នេះគឺការគាប់ជួន នាំឲ្យខ្លួនមានគ្រោះកាច។(ដកចេញពីវចនានុក្រមសម្ដេច)

**មរ**( ន. ) ភក់ដែលកើតអំពីទឹកត្រាំដើមត្រុំ ព្រមទាំងស្លឹកត្រុំស្រស់ផងឲ្យរលួយ ហើយកូរឲ្យខះកក មានសម្បុរខ្មៅខៀវទៅជាឆ្លុះ សម្រាប់ប្រើជាគ្រឿងជ្រលក់ : គាត់ភ័យស្លុតឡើងមុខខ្មៅប៉ៃដូចជាមរ។ (ម. ព. ឆ្លុះទៀតផង) ។(ដកចេញពីវចនានុក្រមសម្ដេច)

តាមន័យបង្កប់ក្នុងពាក្យ ដែលមានសូរសម្លេង**ម**ខាងលើ បានបញ្ជាក់ប្រាប់យើងថា ប្រវត្តិរឿងអច្ឆរាមាតាមហានគរ ត្រូវដេកស្លាប់(**មរ**) ចេញពីសន្តានកូននាគប្រុសស្រី រាប់ពាន់ឆ្នាំមកហើយ ដែលរូបគាត់ត្រូវទៅកប់លាក់ក្នុងភក់ខ្មៅ( សមុទ្រទឹកដោះ ឬសមុទ្រគំរង់ ) តែម្នាក់ឯង។ តើធ្វើដូចម្ដេចអាចឲ្យកូននាគជំនាន់ក្រោយ ទទួលស្គាល់គាត់ បើបាបកម្មរបស់គាត់ ឲ្យផលមិនទាន់អស់នោះ ដូច្នេះទើបម្រាមដៃយើងក្នុងន័យខ្មែរ មានឈ្មោះកូនដៃ នាងដៃ ចង្អុលកណ្ដាលឬចង្អុលខ្មោច ចង្អុលដៃមេដៃ។ កូនម៍(មក) ជួយនាងដៃៗបានមរ(ស្លាប់)ទៅហើយ ដូច្នេះត្រូវប្រើចង្អុលកណ្ដាលឬចង្អុលខ្មោចចង្អុលប្រោះគាត់ឲ្យរស់ ហើយបានរួចពីឃុំ ដែលយក្ស(ម្ករ)បានចាប់គាត់ ឃុំអស់រាប់ពាន់ឆ្នាំនោះ (មើលរូបចម្លាក់នៅក្នុងភាគ៣)។ ការរៀបរាប់នេះ ហាក់ដូចជារឿងនិទាន តែនេះជាការពិតរបស់កម្លាំងកម្ម ដែលគាត់បានសាងទុកមក ដូច្នេះកូននាគជាអ្នកកាន់ព្រះពុទ្ធសាសនា គួរតែយល់ពីកម្លាំងវិបាករបស់កម្មឲ្យផល។ ដូចអ្នកត្រូវគេសម្លាប់ក្នុងរបបប៉ុលពត ប្រជាជនដែលត្រូវគេសម្លាប់ទាំងនោះ មុននឹងស្លាប់សុទ្ធតែបានអង្វរករ ឲ្យពេជ្ឈឃាតទាំងនោះ ដោះលែងនិងទុកជីវិតឲ្យ ហេតុអ្វីបានជាពួកឃាតករទាំងនោះ គ្មានចិត្តមេត្តាករុណាយ៉ាងនេះ? នេះមិនគឺជាកម្លាំងកម្មទេឬ? ដែលមិនអាចឲ្យមនុស្សមានឈាមជ័រជាតិដូចគ្នា ប្រៀបដូចជាបងប្អូន មិនអាចអនុគ្រោះអធ្យាស្រ័យឲ្យបានបែរជាមានភ្នែក(បញ្ញា) តែងងឹតមិនដឹងបាបបុណ្យគុណទោស សម្លាប់ជាតិឯងយ៉ាងព្រៃផ្សៃដូចនេះ។ ដូចជាអ្នកសម្លាប់សត្វលក់រាល់ថ្ងៃ សត្វទាំងនោះមុននឹងត្រូវគេសម្លាប់ តែងតែស្រែកអង្វរករចំពោះពេជ្ឈឃាតទាំងនោះ មិនថាជ្រូក មាន់ ទា គោ ក្របី.... តើដែលឃើញអ្នកសម្លាប់ទាំងនោះ ធ្លាប់ឲ្យអភ័យដល់សត្វទាំងនោះទេ? នេះជាការសាងកម្មទុក ដែលកម្មនេះត្រូវរៀបចំ ឲ្យសមទៅតាមពូជ (អំពើ) ដែលខ្លួនបានសាបព្រោះទុក យ៉ាងណាមិញមាតាបិតាមហានគរនិងញាតិវង្សា ក៏លោកត្រូវ

ទទួលផលវិបាករបស់កម្ម ដែលខ្លួនបានសាងសន្សំទុកមកហើយនោះ គឺពុំអាចកែប្រែនឹងគេចឲ្យរួចបានឡើយ (សូមមើលកម្លាំងកម្ម ដែលបានសម្ដែងទុកក្នុងគម្ពីរព្រះពុទ្ធសាសនា)។

**ច.វគ្គទី៦**( មានតួអក្សរ៨តួគឺ យ រ ល វ ស ហ ឡ អ)

**២៦.អំពីព្យញ្ជនៈ(យ)** (ព្យញ្ជនៈទី១ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**យ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូចយ)

***យក៍***ព. សា. ( កិ. ) (អ. ថ. យ) យក : ហ៎យក៍ចុះ ! (ហ៎យកចុះ); អាវំបល់យក៍ ! (ពាក្យជេរទ្រគោះច្រទ្បោះបោះ); ចុះឯងយក៍អីវ៉ាន់អស់ហ្នឹងពីណាមក៍ ? (និយាយចំពោះឥស្សរជនពុំបានឡើយ)។ (ដកចេញពីវចនានុក្រមសម្ដេច)

បើតាមន័យរបស់ព្យញ្ជនៈ**យ** ភាសានិយាយគឺ**យក៌** = **យក** ដល់ពេលវេលា ដែលត្រូវយករឿងសាសនៈបណ្ដាំព្រះម៉ែ មកបើកបង្ហាញឲ្យកូននាគទាំងអស់បានដឹង ពីសាវតាពិតរបស់អ្នកកកើតទឹកដីមាតុភូមិនេះ ដែលលោកគឺជាឬសកែវរបស់យើងទាំងអស់គ្នា។

**២៧.អំពីព្យញ្ជនៈ(រ)** (ព្យញ្ជនៈទី២ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**រ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូចរ)

***រ*** ស. ( ន. ) បង្គោល, ឃ្មង, របងបោះរាំងក្នុងទឹកជាគ្រឿងការពារសត្វទឹកដែលសាហាវមិនឲ្យចូលមកបាន : បោះររាំងបាំងកន្លែងចុះងូតទឹកទន្លេ។ (ដកចេញពីវចនានុក្រមសម្ដេច)

***រក៍រ*** ( កិ. ) រក។ពាក្យសាមញ្ញសម្រាប់និយាយរហ័ស : មក៍រក៍អី ? ដើររក៍សព្វអន្លើហើយមិនឃើញទេ។ (ដកចេញពីវចនានុក្រមសម្ដេច)

សូររបស់ព្យញ្ជនៈ**រ** បានបញ្ជាក់ប្រាប់ន័យដល់យើងថា ត្រូវ**រក៌** = **រក** អ្វីមកបញ្ជាក់ជាភស្ដុតាងសំអាង ដើម្បីការពារនៅឧបសគ្គ ដែលត្រូវមករារាំងជាថ្មី បង្កើតជាគ្រោះភ័យទៀត។ **យក៌**ចេញ**ម៍**ហើយ រួចបើកបង្ហាញ**រក៌**អ្នកយល់ចិត្ត ជួយរែកពុនគាំទ្រ អ្នក**ក**ឲ្យចាកចេញពីទុក្ខធ្ងន់ ហើយតបគុណអនន្តដល់ព្រះទាំងពីរ។

**២៨.អំពីព្យញ្ជនៈ(ល)** (ព្យញ្ជនៈទី៣ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**ល** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ល**)

***ល***( កិ. ) ល្បង, លង : លឲ្យដឹង; កុំអាលចាំលមើលសិន ! ។ជន្លល្បងមើល : លកាប់។លលើកាប់ក្រោមកិ. វិ. ឬគុ. (ព. ប្រ.) ដែលនិយាយលូកលាវរកផ្លូវរកទំនងហាក់ដូចគេលើកគ្រឿងសស្ត្រាជន្លខាងលើឲ្យភ័ន្តហើយលូកកាប់ខាងក្រោម : និយាយលលើកាប់ក្រោម;សម្ដី-- ។លលេងល្បងលេង, ជន្លលេង : និយាយលលេង; សម្ដី- ។លលែងៗលហើយលែងៗហើយលរឿយៗ។ល។ព. ទ. បុ. យកកទៅលអន្ទាក់ហុចទំនងឲ្យជាប់កុនជាប់ដំណើរ... ។(ដកចេញពីវចនានុក្រមសម្ដេច)

បើតាមសូរព្យញ្ជនៈ**ល**នេះ បានប្រាប់ន័យឲ្យយើងដឹងថា ល្បង**ល**សាកមើលថា តើកូននាគទាំងអស់ សុខចិត្តបែរក្រោយ សាកល្បងពិចារណារឿងគំនិត បង្កប់ទុកក្នុងភាសាថ្ម(គ) ភាសានិយាយ សរសេរ ទំនៀមទម្លាប់ប្រពៃណី សាសនា ឈ្មោះភូមិស្រុក ល្បែងប្រជាប្រិយ ពិធីបុណ្យផ្សេងៗ.... ឬទេ? បើយើងមិនសាកល្បងឆ្ងល់នោះ អ្វីៗដែលជាកេរមរតករបស់អច្ឆរា នឹងក្លាយជារឿងក្នុងសាសនាទាំងអស់ ដែលបរទេសធ្លាប់**ឆ**កុហកយើង។

**២៩.អំពីព្យញ្ជនៈ(វ)** (ព្យញ្ជនៈទី៤ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**វ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**វ**)

***វ*** ស. ( ន. ) យានមួយប្រភេទមានក្រែ, ដងស្នែង, ដំបូលសម្រាប់ឥស្សរជនថ្នាក់ខ្ពស់ជិះមានមនុស្សសែង : គង់លើ-វ, ជិះវ (មានប្រើច្រើនតែក្នុងសម័យពីដើម); វ. ស. ព្រះវរធម្មតា; (ព្រះសិវិកាឬព្រះទីន័ងសិវិកាវមានក្បាច់រចនាវិចិត្រ) ។(ដកចេញពីវចនានុក្រមសម្ដេច)

***វរ*** ( កិ. ) ទាស់ការ, ទាស់ទំនង; នាំឲ្យមានរវល់ឥតប្រយោជន៍; នាំឲ្យទាស់ដំណើរ។វរហើយ ! ទាស់ហើយ ! ។កុំវរ ! កុំរវល់ !; នាំវរនាំរវល់; វរវឹកឬវឹកវរច្របូកច្របល់; ធ្វើឲ្យច្រឡំបល់, ឲ្យទាស់ការ។វរវឹកទទឹកស្ងួត (ព. ប្រ.) ច្របូកច្របល់ដូចគេយករបស់ទទឹក ដាក់លាយនឹងរបស់ស្ងួត (ព. សា.) : វរវឹកទទឹកស្ងួតអស់ទៅហើយ ! (ដកចេញពីវចនានុក្រមសម្ដេច)

***វរ*** *សំ. បា. ( គុ. ) (វរ) ប្រសើរ, ខ្ពស់ខ្ពស់, លើសលន់, ថ្លៃថ្លា; ជាចម្បង; ដែលគួរប្រាថ្នា, គួរចង់បាន, គួរជ្រើសយក; ដែលគួរសូម,... ។ន. ពរ (ម. ព. ព្រះផង) ។ប្រើផ្សំនឹងសព្ទដទៃបានតាមគួរដល់ការប្រកប, ដូចជា : វរគុណាគុណដ៏ប្រសើរ, គុណាគាប់។វរចក្រចក្រដ៏ប្រសើរ។វរជនជនប្រសើរ។វរជ័យជម្នះដ៏ប្រសើរ។វរញ្ញូអ្នកដឹងធម៌ដ៏ប្រសើរ (ព្រះពុទ្ធ) : ព្រះវរញ្ញូ។វរតនូឬវរនារីស្ត្រីល្អឆ្នើម។វរទានការឲ្យពរ; ការឲ្យរង្វាន់។វរនាថពំនាក់ដ៏ប្រសើរ។ វរបិតាបិតាប្រសើរ (បិតាក្សត្រិយ៍) : ព្រះវរបិតា។វរបុរសបុរសប្រសើរ, ប្រុសថ្លៃ។វរមន្ត្រីមន្ត្រីប្រសើរ; ខ្មែរប្រើជាថ្នាក់ឋានន្តរនៃមន្ត្រីជាន់ខ្ពស់ផ្នែករដ្ឋបាល, នៅត្រង់ចន្លោះថ្នាក់អនុមន្ត្រីនិងឧត្ដមមន្ត្រី។វរមាតាមាតាប្រសើរ (មាតាក្សត្រិយ៍) : ព្រះវរមាតា។វរមិត្តឬ--មិត្រមិត្រប្រសើរ។វរយោសិតស្ត្រីមានរូបល្អ, នាងឆើតឆោម, ស្រីថ្លៃ។វររាជស្ដេចប្រសើរ។វរលញ្ឆករត្រាដ៏ប្រសើរ (ព្រះរាជមុទ្រា) : ព្រះវរលញ្ឆករ។វរលក្ខណ៍លក្ខណៈដ៏ប្រសើរ; ដែលមានលក្ខណៈដ៏ប្រសើរ។ វរវង្សវង្សដ៏ប្រសើរ; ដែលមានវង្សខ្ពង់ខ្ពស់។វរវណ្ណិនីស្ត្រីមានសម្បុរល្អ, នាងឆើតឆោមឬនាងឆោមឆាយ។វររៀងជ័យ (ម. ព. រៀងជ័យ) ។វរសេនិយឬវរសេនីយ៍ (វៈរៈសេនី) : វរសេនីយ៍ត្រីឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់បន្ទាប់ពីវរសេនីយ៍ទោ។វរសេនីយ៍ទោឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់នៅត្រង់ចន្លោះវរសេនីយ៍ត្រីនិងវរសេនីយ៍ឯក។វរសេនីយ៍ឯកឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់, ខ្ពស់ផុតក្នុងថ្នាក់វរសេនីយ៍។វរោកាស (<វរ + ឱកាស) ឱកាសប្រសើរ។វរោត្តម (វៈរោត-ដំ; <វរ + ឧត្តម) ឧត្ដមថ្លៃថ្លា, ប្រសើរខ្ពង់ខ្ពស់។ល។(ដកចេញពីវចនានុក្រមសម្ដេច)*

*សូរស័ព្ទរបស់ព្យញ្ជនៈ**ខ** ន័យរបស់វាគឺត្រៃស្នែងដ៏វិចិត្រ សែងអ្នក**ឝ**មរតកគឺអច្ឆរាយកទៅឃុំ (មើលរូបនៅក្នុងភាគ៣ រូបភាពទី៥៩រូបនៅជញ្ជាំង) នឹងសែងអ្នក**ឝ**មរតកចេញពីទីឃុំវិញ។ ទោះបីមានសត្រូវជិតឆ្ងាយ មករារាំងបង្កភាព**ខ**វរីក អ្នកត្រូវតាំងចិត្តឲ្យខ្ពស់ ដើម្បីបំពេញកិច្ចកតញ្ញូនេះ ព្រោះកតញ្ញូនិងកតវេទី ជាគុណធម៌ខ្ពង់ខ្ពស់ថ្លៃថ្លាចម្បង។ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង កាលព្រះអង្គនៅបំពេញបារមី ជាព្រះពោធិសត្វនៅឡើយ មិនថាព្រះអង្គនៅក្នុងកំណើតមនុស្សទេ សូម្បីតែមានកំណើតជាសត្វតិរិច្ឆាន ក៏ព្រះអង្គបំពេញនូវកតញ្ញូនិងកតវេទីនេះដែរ ចុះទំរាំកូននាគប្រុសស្រីជាមនុស្ស ហើយគោរពបដិបត្តិតាមឱវាទ ដែលជាពាក្យបណ្ដាំ(សាសនៈ) របស់ព្រះសម្មាសម្ពុទ្ធទៀតនោះ តើគួរលើកតំកើងខ្លួន ឲ្យមានគុណធម៌នេះដែរឬទេ?*

**<u>៣០.អំពីព្យញ្ជនៈ( ស )</u>** *(ព្យញ្ជនៈទី៥ក្នុងវគ្គទី៦)*

សូរសម្លេងរបស់ព្យញ្ជនៈ**ស** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូចស)

**ស**( គុ. ) ដែលមានសម្បុរដូចសំឡីកប្បាស : ព័ណ៌ស, សំពត់ស។សក្បុសសណាស់។សត្រសុស សម៉ដ្ឋប៉ផូរ, សផូរផង់។សភ្លឺសស្អាត។សស្គុសសត្រសោល, សបរិសុទ្ធ។សស្វាច សភ្លឺមើលទៅឃើញស្វាច។ល។(ដកចេញពីវចនានុក្រមសម្ដេច)

**ស** ( កិ. ) ចាក់បុះព្រាវដោយស្នូ : សត្រី។ព. ប្រ. សរកឲ្យឃើញសង្កេតរកព្រាវៗដោយស្នានៗឲ្យឃើញ។(ដកចេញពីវចនានុក្រមសម្ដេច)

**ស** ( កិ. ) សម្ដែងអាការឲ្យឃើញច្បាស់, បញ្ចេញបែបឲ្យឃើញជាក់ : សសេចក្ដី, សហេតុ។ ហែកកេរ្តិ៍ : សកេរ្តិ៍ឬសកេរ្តិ៍សគល់។ព. ទ. បុ. សម្ដីសជាតិមារយាទសត្រកូលសំនៀងភាសាសប្រាប់ឲ្យគេស្គាល់ជាតិឬកពាមារយាទសម្រាប់ឲ្យគេស្គាល់ពូជត្រកូល។(ដកចេញពីវចនានុក្រមសម្ដេច)

**សរ**សបា.; សំ. ( ន. ) (គរ) ព្រួញ, កាំ, កាំធ្នូ, កាំស្នា : ស្ដេចថ្លែងសរ ; ត្រូវសរ។សរជ័យសរមានជ័យ។កូនសរព្រួញ; គ្រាប់កាំភ្លើង។ល។(ដកចេញពីវចនានុក្រមសម្ដេច)

**សរ** បា. ( កិ. ) រឭក, រឭកឃើញ, នឹកឃើញ, សាដឹងឡើងវិញ។សរជាតិដឹងជាតិ។សរញាណពិចារណាឬរំពឹងដឹងហេតុច្បាស់ ទៅខាងអតីតកាលឬខាងអនាគតកាល : ព្រះពុទ្ធទ្រង់សរញាណ... (បា. សរញ្ញាណន. ញាណឬប្រាជ្ញាជាគ្រឿងរឭកឃើញ) ។(ដកចេញពីវចនានុក្រមសម្ដេច)

បើតាមន័យបង្កប់នៅក្នុងសូរព្យញ្ជនៈ**ស** មានន័យថាភាពបរិសុទ្ធមិនប្រែពណ៌ យើងត្រូវរុករក**ស**ឲ្យឃើញ នោះនឹង**ស**បើកបង្ហាញ**ស**សេចក្ដី បើកទ្វារកេរ**អ៊ំ**ឬសកែវ**យអ៊ំម៉**មើល តើអ្នកណាជាឬសកែវរបស់ជាតិ? បញ្ញាតាំងឡើងឲ្យខ្ពស់ បាញ់**សរ**ឲ្យឆ្ងាយ **សរ**ជាតិទៅនាយខាងក្រោយពិត នឹងឃើញសាវតារឿងអតីត អ្នកកកើតជីវិតជាតិមិនខាន។ បើគ្រាន់តែជឿអ្នកប្រាជ្ញក្រៅ ភាពល្ងិតល្ងង់ខ្លៅជិតជាប់ប្រាណ កូនដោះប្រស្នាក្នុងសង្រ្គាន្ដ ឃើញព្រហ្មមានខ្លួន ពេញបរិបូរណ៍។

**៣១.អំពីព្យញ្ជនៈ( ហ )** (ព្យញ្ជនៈទី៦ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**ហ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ហ**)

**ហ** !ឬហ៎!( និ. ) ពាក្យសម្រាប់ប្រើក្នុងការហុច, ក្នុងការប្រគល់អ្វីៗឲ្យគ្នា ឬប្រើក្នុងការតឿនជាសញ្ញាឲ្យស្រុះគ្នា; ប្រើបានចំពោះតែទៅរកបុគ្គល អ្នកតូចជាងឬស្មើគ្នា។ ហជាពាក្យបង្អួសវែងសម្រាប់តឿនឲ្យស្រុះគ្នា ឬឲ្យអ្វីៗយ៉ាងយឺតមិនប្រញាប់មិនបង្ខំ : ហលើក ! ។ហ៎ជាពាក្យស្ទួះមានសំឡេងខ្លីសម្រាប់ប្រើការប្រញាប់ : ហ៎យកចុះ ! ។ម. ព. ហេះហ៎ឬហែះហ៎ផង។ហ៎ ! (ដកចេញ ពី វចនានុក្រមសម្ដេច)

សូរបង្កប់ក្នុងព្យញ្ជនៈ**ហ**(ហ៍) ន័យរបស់ពាក្យគឺហុចឲ្យគ្រប់គ្នា ទទួលយកនៅបណ្ដាំព្រះម៉ែមហានគរ ទៅគិតពិចារណាឈ្វេងយល់ ថាតើរឿងនេះត្រឹមត្រូវ សមតាមហេតុនិងផលដែរឬទេ? បើត្រឹមត្រូវកូននាគទាំងអស់ ត្រូវលើកតំកើងមាតានាគបិតានាគ ដោយស្រុះគ្នាឈប់មើលបំណាំគ្នាទៀតហើយ។ មនុស្សអាចទៅបដិសន្ធិក្នុងពិភពផ្កាយបាន(សុគតិភព) ទាល់តែបុគ្គលនោះមានបេះដូងផ្កាយ (**គឺកតញ្ញូនិងកតវេទី**)។

**៣២.អំពីព្យញ្ជនៈ( ឡ )** (ព្យញ្ជនៈទីពក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**ឡ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ឡ**)

**ឡ** ( ន. ) គុកឬជើងក្រាន គុកធំទូលាយបិទភ្ជិត ទុកឲ្យមានប្រហោងតែត្រង់កន្លែង ដែលត្រូវទុកសម្រាប់ដុតឥដ្ឋ ជាដើមបង្កប់កម្ដៅឲ្យឆ្អិន : ឡឥដ្ឋ, ឡក្បឿង, ឡធ្យូង។ (ដកចេញពី វចនា នុក្រមសម្ដេច)

**ឡ** ( ឧ. ) សូរស្រែកឬយំឮខ្លាំង : ស្រែកឡ, យំឡ។(ដកចេញពីវចនានុក្រមសម្ដេច)

សូរសម្លេងរបស់ព្យញ្ជនៈ**ឡ** ន័យរបស់វាគឺសូរសម្រែកស្រែកយំ(ឡ) ជាប់ឃុំក្នុងគុហារ(ឡ) ដូចជាធនជ័យគាត់ជាប់នៅក្នុងឃុំ ហើយអាចលួចចេញមកបង្ហោះខ្លែងឯក ឲ្យស្រែកប្រាប់សត្រូវនិងកូននាគ ដែលជាអ្នកទទួលមរតកម៉ែ(ខ្មែរ)ថា បើពូជជ័យនៅរស់ គឺពុំមាននរណាអាចយកដែនដីនាគនេះបានឡើយ។ នៅក្នុងព្យញ្ជនៈ**ឡ**នេះ គឺជាព្យញ្ជនៈដែលខុសពីព្យញ្ជនៈទាំង៣២តួ គេមានជើងសម្រាប់ឈរគ្រប់គ្នា ចំណែកព្យញ្ជនៈឡ ពុំមានជើងនឹងគេឡើយ។

**៣៣.អំពីព្យញ្ជនៈ(អ)** (ព្យញ្ជនៈទី៨ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**អ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្តាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូចអ)

**អ** ស. (ន.) ឈ្មោះប៉ីមួយប្រភេទធ្វើដោយដើមបបុស ទាំងតួទាំងអណ្តាត ឬយកដើមបបុសធ្វើតែអណ្តាត ឯតួធ្វើដោយដើមពកជាដើម : ផ្លុំប៉ីអ។ តាមដោយធ្លាប់បានសង្កេតរូបគំនូរ នៅជញ្ជាំងឧបោសថាគារ គឺវិហារនៅខេត្រក្រៅក្នុងប្រទេសសៀម ដែលជាងសៀមគូរក្នុងសម័យបុរាណព្រេងនាយឃើញមានរូបអ្នកភ្លេង លេងភ្លេងខ្មែរមានអ្នកផ្លុំប៉ីបបុស, ប្រហែលជាសៀមហៅថាប៉ីអខ្មែរក៏ហៅតាមសៀមដែរទៅទេដឹង ? (គួរហៅប៉ីបបុសតាមខ្មែរវិញ) ។(ដកចេញពីវចនានុក្រមសម្តេច)

**អ** ! (ឧ.) សូរលាន់មាត់ដោយបញ្ជាក់សេចក្តី ឬដោយបាត់ងឿងឆ្ងល់ជាដើម : អ ! ដូច្នោះទេឬ ?; អ៎ ! ឯណោះទេហ: ? អ៎ ! អញ្ជើញមក ! អ៎ !(ដកចេញពីវចនានុក្រមសម្តេច)

**អរ** អ (កិ.) មានអំណរ, មានសោមនស្ស, រីករាយចិត្ត, មានចិត្តរីករាយ : អរព្រោះបានទ្រព្យគាប់ចិត្ត; បានឮថាកូនប្រឡងជាប់ខ្ញុំអរណាស់ ! ។អរគុណអរចំពោះគុណគេ, មានអំណរគុណគេ : ដោយគេបានជួយសង្គ្រោះខ្ញុំបន្តិចប៉ុណ្ណឹង ខ្ញុំនឹងអរគុណគេមិនភ្លេច។អរគុណ ! ពាក្យសម្រាប់ទទួលអំណរចំពោះគុណគេ ក្នុងទីចំពោះមុខ។ តាមធម្មតារបស់អ្នកសុភាពឬអ្នកមានច្បាប់, សូម្បីគ្រាន់តែគេហុចអ្វីបន្តិចបន្តួច ឲ្យមកខ្លួនឬគេគូសឈើគូសកាន់ឲ្យខ្លួនអុជបារីប៉ុណ្ណោះ ក៏ត្រូវបញ្ចេញវាចារអរគុណគេថាអរគុណ ! ឬថាអរគុណលោក !, អរគុណអ្នក ! ... ។អរភិតអរភ័យអរៗភ័យៗគឺអរខ្លះភ័យខ្លះម្តងៗ។ អរសាទរអររីករាយដោយសាទរ។ អរអេកអរខ្លាំងស្ទើរភ្លេចខ្លួន,អរឆ្អែតឆ្អន់។ល។ (ដកចេញពីវចនានុក្រមសម្តេច)

សូរសម្លេងក្នុងព្យញ្ជនៈ**អ** ន័យបង្កប់ក្នុងពាក្យគឺសម្លេងភ្លេង(ប៉ី) ដែលស្រែកប្រកាសប្រាប់ ពីសោមនស្សចិត្តកើតឡើង ដោយហេតុអ្វី? ពេលដែលកូននាគដឹងន័យ បង្កប់ក្នុងព្យញ្ជនៈតួទីមួយ ដាច់ខាតត្រូវតែស្គាល់ន័យក្នុងព្យញ្ជនៈតួបញ្ចប់គឺ**អ**នេះ។ បើក្មេរស្គាល់ជាតិ ត្រឹមព្យញ្ជនៈ**ខ** គឺមានតែយក្សនឹងបក្សពួកទេ ដែលស្គាល់**អ**(យក្សអរ)។ ការបកស្រាយន័យក្នុងព្យញ្ជនៈទាំង៣៣តួនេះ គឺសម្រាប់ឲ្យកូនក្មេរ យកមកគិតពិចារណាឈ្វេងយល់សើរើឡើងវិញ តើយើងគួស្គាល់ប្រវត្តិសាវតាបេះដូងអច្ឆរា ជាម្ចាស់មរតកអច្ឆរិយនេះដែរឬទេ? សូម្បីតែតួអក្សរក្នុងព្យញ្ជនៈក្មេរទាំង៣៣តួនេះ ក៏បង្កប់នូវភាពអស្ចារ្យដែរ ពេលដែលយើងឆ្ងល់ រួចយកមកវែកញែករកន័យពិត ក្នុងតួព្យញ្ជនៈមួយៗ។ ទោះបីមិនទាន់ផ្សំជាមួយនឹងស្រៈ ឬព្យញ្ជនៈឲ្យផ្លាស់ប្តូរសម្លេងថ្មីផង វាក៏មានន័យ

គ្រប់គ្រាន់អាចឲ្យយើងយកមកប្រើ ជាពាក្យនិយាយឬសរសេរបាន។ បណ្ឌិតជំនាន់បុរាណ លោកបានយកព្យញ្ជនៈទាំង៣៣តួ ទៅបកពន្យល់ន័យលាយបញ្ចូលទៅក្នុងសាសនា ដើម្បីទុកប្រស្នាឲ្យយើងចេះឆ្លល់ ហេតុអ្វីបណ្ដាំរបស់ព្រះសម្មាសម្ពុទ្ធ មកទើនៅក្នុងព្យញ្ជនៈទាំង៣៣តួនេះ? ចំណែកការឈ្វេងយល់របស់ខ្ញុំ ន័យពិតរបស់ព្យញ្ជនៈទាំង៣៣តួ គំនិតក្នុងបណ្ដាំមាតាមហានគរ លោកភ្ជាប់ន័យរបស់ព្យញ្ជនៈទៅនឹងភាសាគឬភាសារូប ដែលមាននៅក្នុងប្រាសាទរាប់ពាន់ រួមទាំងមរតកម៉េដទៃទៀត ចំណែកការភ្ជាប់ព្យញ្ជនៈ ជាមួយនឹងសាសនា វាគ្រាន់តែជាសំបកសម្រាប់បិទបាំងសារតាពិត របស់មាតាបិតាមហានគរតែប៉ុណ្ណោះ។ នៅក្នុងពាក្យភាសាខ្មែរ ជាភាសាដែលមានន័យក្នុងន័យ នៅពេលណាដែលបណ្ដុលពាក្យ កើតចេញពីព្យញ្ជនៈណា ពាក្យនោះបានប្រាប់ន័យយើងជាមុនរួចស្រេចហើយ។ ឧ. ទ្វារ = ទ + វា + រ មានន័យថា **ទ**របស់**វា** តើច្រកសម្រាប់ចេញចូលនោះ ជា**ទ**របស់អ្នកណា? គឺជា**ទ**របស់ម្ចាស់ផ្ទះ ព្រោះ**ទ**នោះតែងនាំទឹកចិត្តម្ចាស់ផ្ទះ ចេញចូលតាមច្រកនោះ។ ក៏ប៉ុន្តែគាត់សរសេរមានថែម**រ** មានន័យថាគាត់ឲ្យយើង រក៍(រក)អ្វីមកបិទបាំងច្រកនោះ ការពារមនុស្សអាក្រក់ ដែលមានឈ្មោះថាចោរ។ ព្រោះពាក្យចោរ ក៏សរសេរដាក់**រ**ដែរ គឺរក៍លួច ដូច្នេះច្រកទ្វារនោះត្រូវរក៍អ្វីមកបិទបាំងការពារ នេះគ្រាន់តែជាការបកស្រាយក្នុងពាក្យមួយ ក្នុងចំណោមរាប់ម៉ឺនពាក្យ។

## III.ព្យញ្ជនៈខ្មែរទាំង៣៣តួ នៅក្នុងន័យអ្នកប្រាជ្ញពីបុរាណ បានបញ្ចូលក្នុងព្រះពុទ្ធសាសនា

### ធាតុទឹកគុណម្ដាយ១២

ន ប ផ ព ភ ម យ រ ល វ ស ហ នៅក្នុងខ្លួនគឺ៖

- ន ជាទឹកប្រមាត់
- ប ជាទឹកកស្លេស្ម
- ផ ជាទឹកខ្ទុះ
- ព ជាទឹកឈាម
- ភ ជាទឹកញើស
- ម ជាខ្លាញ់ខាប់
- យ ជាទឹកភ្នែក
- រ ជាខ្លាញ់រាវ
- ល ជាទឹកមាត់
- វ ជាទឹកសម្បោរ
- ស ជាទឹករំអិល

- ហ ជាទឹកមូត្រ

ចប់គុណម្ដាយធាតុទឹក១២។

**ធាតុដីគុណឪពុក២១**

*ក ខ គ ឃ ង ច ឆ ជ ឈ ញ ដ ឋ ឌ ឍ ណ ត ថ ទ ធ ឡ អ*នៅក្នុងខ្លួន៖

- ក បង្កើតជាសក់
- ខ បង្កើតជារោម
- គ បង្កើតជាក្រចក
- ឃ បង្កើតជាធ្មេញ
- ង បង្កើតជាស្បែក
- ច បង្កើតជាសាច់
- ឆ បង្កើតជាសរសៃ
- ជ បង្កើតជាឆ្អឹង
- ឈ បង្កើតជាខួរក្នុងឆ្អឹង
- ញ បង្កើតជាទាច
- ដ បង្កើតជាបេះដូង
- ឋ បង្កើតជាថ្លើម
- ឌ បង្កើតជាវាវ(សន្ទះខ្យល់)
- ឍ បង្កើតជាក្រពះ
- ណ បង្កើតជាសួត
- ត បង្កើតជាពោះវៀនធំ
- ថ បង្កើតជាពោះវៀនតូច
- ទ បង្កើតជាអាហារថ្មី
- ធ បង្កើតជាអាហារចាស់
- ឡ បង្កើតជាអំបែងក្បាល(លលាដ៏ក្បាល)
- អ បង្កើតជាខួរក្បាល

ចប់គុណឪពុកធាតុដី២១។

ហេតុអ្វីបានជាអ្នកប្រាជ្ញពីបុរាណ លោកយកព្យញ្ជនៈទាំង៣៣តួ ទៅបញ្ចូលលាយជាមួយសាសនា? ការសន្សំបារមីទាំង៣០ ឲ្យពេញបរិបូរណ៍ ព្រះអង្គត្រូវប្រើរយៈពេលសន្សំ អស់បួនអសង្ខេយ្យនិងមួយសែនផែនដី ទើបអាចត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធបាន ហេតុអ្វីបានជាគុណធម៌

*របស់ព្រះអង្គ មកទើត្រឹមព្យញ្ជនៈទាំង៣៣ និង ស្រៈ....? តើប្រស្នានេះ គាត់ចង់ឲ្យយើងស្វែងយល់ពីអ្វី? គឺការបកស្រាយន័យ ក្នុងព្យញ្ជនៈទាំង៣៣តួនិងស្រៈ។*

## IV.អំពីស្រៈនិស្ស័យនិងស្រៈពេញតួ

**ក.ស្រៈនិស្ស័យឬនិស្ស័យស្រៈ** *(ស្រាក់)*

**ពន្យល់ពាក្យ***(មានសូរដូចស្រៈ)*

***ស្រៈ****បា.; សំ. ( ន. ) (សរ; ស្វរ) អក្សរដែលអាច បញ្ចេញសំឡេងខ្លួនឯងបានផង អាចនាំព្យញ្ជនៈឲ្យចេញសំឡេងបាន មានសូរឮតាមរំពងរបស់ព្យញ្ជនៈផង។ | ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ | ះ, (ដកចេញពីវចនានុក្រមសម្ដេច)*

***ស្រាក់*** *( កិ. ) ដាក់តម្រួតៗលើគ្នាចង់រុំឬចងរួតរឹត : ស្រាក់ស្កររផែន, ស្រាក់ចាន។ចង់រុំប្រទាក់ឆ្វាក់ឲ្យណែន : ស្រាក់ដៃនឹងចូលដាល់។(ដកចេញពីវចនានុក្រមសម្ដេច)*

***ស្រាក់****( ន. ) អ្វីៗដែលដាក់តម្រួតៗលើគ្នាចង់រុំឬចងរួតរឹត : ស្ករមួយស្រាក់, ចានពីរស្រាក់។ ឈ្មោះចានមួយប្រភេទ មានត្រចៀកទាំងពីរខាង សម្រាប់ស៊កដាក់តម្រួតលើគ្នាក្នុងដៃយួរ : ម្ហូបមួយចានស្រាក់។គុ. ដែលចងជាស្រាក់ : ស្ករស្រាក់ស្ករផែនដែលដាក់តម្រួតៗគ្នា ខ្ចប់ដោយស្លឹកត្នោតចង់រុំ។ (ដកចេញពីវចនានុក្រមសម្ដេច)*

*ហេតុអ្វីតួអក្សរនេះមានឈ្មោះថាស្រៈ? ហេតុអ្វីស្រៈនេះ មានឈ្មោះថាស្រៈនិស្ស័យ? បើយើងមើលតាមន័យមកជាខ្មែរ ដូនតាយើងបានប្រាប់យើងថា ការច្របាច់ចូលគ្នាចងប្រមូលចូលគ្នា ការតម្រួតគ្នាចងជាបាច់ បានមានឈ្មោះថាស្រៈ សម្លេងសូរនិយាយស្មើនឹងស្រាក់។ ស្រៈមិនពេញតួ ឬស្រៈនិស្ស័យនេះមាន២១តួ គឺការប្រមូលផ្ដុំស្រាក់បញ្ចូលគ្នា បង្កើតបានជាមរតកភាសាមួយ ដែលមានន័យអាចឲ្យយើងយល់បាន។ ចំពោះពាក្យនិយាយថាស្រៈនិស្ស័យ ដូនតាគាត់បានប្រាប់យើងថា បុគ្គលណាមាននិស្ស័យ ទើបយល់ពីការស្រាក់សាមគ្គីគ្នានេះ ដើម្បីរួមប្រមូលផ្ដុំគ្នាបង្កើតជាកម្លាំង អាចគាស់កកាយនូវអាថ៌កំបាំងរបស់ជាតិ។ ក្នុងស្រៈនិស្ស័យនេះ ស្រៈ**អ**(ា)ជាអ្នកនាំមុខ តើយើងមានឆ្ងល់ទេ? ហេតុអ្វីបានជាដូនតាយើង មិនយកសូរសម្លេងស្រៈ* **ក ខ ច ឆ**.... *ដែលព្យញ្ជនៈ*

ទាំងនេះមានសម្លេងតូចដូច**អ**ដែរ គាត់បែរជាយកព្យញ្ជនៈ**អ** ធ្វើជាបណ្តូលសម្លេងស្រៈនិស្ស័យនេះ? ព្រោះគាត់ចង់ឲ្យកូននាគ ជំនាន់ក្រោយបានយល់ថា ពេលកូននាគមាននិស្ស័យបុណ្យ(កតញ្ញូ)កើតឡើង គឺយើងនឹងស្រាក់គ្នា ព័ន្ធគ្នា សាមគ្គីគ្នា នោះសូរសម្លេង**អ**(អរ) នឹងកើតឡើងក្នុងសន្តានចិត្តកូននាគ។ ស្រៈ**អ**(|) នេះមានរាងជាបន្ទាត់ ឬបង្គោលបញ្ឈរមួយ បង្គោលនេះបើយើងយកទៅភ្ជាប់ព្យញ្ជនៈ**រ**ពីរ(ររ)ឲ្យជាប់គ្នា នឹងកើតបានព្យញ្ជនៈ**អ**នេះ។ ពាក្យ**អរ**មាន**រ**បី(រររ) រទីបីសែងស្ពានឬបង្គោលទៅភ្ជាប់ រទីពីរនិងទីមួយភ្ជាប់គ្នា ទើបកើតបានជាពាក្យ**អរ** មានន័យថាភ្ជាប់រឿងអតីតនិងបច្ចុប្បន្ន ធ្វើឲ្យយើងដឹងសាវតាពិត សេចក្តីត្រេកអរនឹងកើតឡើង។ យើងតែងនាំគ្នាហៅសញ្ញាស្ពាននេះ ថាជាសញ្ញាវះពោះទៅវិញ វះពោះមានន័យថាកាត់ផ្តាច់ចេញពីគ្នា បើភ្ជាប់គ្នាពី**រ**ម្ខាងទៅ**រ**ម្ខាងទៀត ពុំមែនវះពោះឡើយ តែវាគឺជាស្ពាន។ ការបកស្រាយពន្យល់ពីពាក្យ ស្រៈឬស្រាក់នេះ ខ្ញុំបាទគ្រាន់តែចង់ ឲ្យកូននាគបែរមកពិចារណា រាវរកហេតុផលពិត នៅក្នុងមរតកបណ្តាំមាតាមហានគរ ដែលបានបង្កប់លាក់បញ្ចូលទុក ទៅក្នុងស្រៈនិស្ស័យនេះ។

**ខ.ស្រៈពេញតួ**

ស្រៈពេញតួមាន១៣តួគឺ**អអា**, **ឥឦ**, **ឧឩ**, **ឫ**, **ឬ**, **ឭ**, **ឯឮ**, **ឱឪ**;ថែមស្រៈឮមួយដោយឡែកមកទៀតជា១៤តួ។ ហេតុអ្វីបានជាដូនតាយើង ហៅស្រៈនេះថាជាស្រៈពេញតួ? កាលនៅជាស្រៈនិស្ស័យ គ្រាន់តែជាសញ្ញាបង្កប់នៅ បន្ទាត់មួយតែប៉ុណ្ណោះ ដែលយើងហៅថាស្រៈ**អ**។ លុះមកដល់ស្រៈពេញតួ តួអក្សរស្រៈ**អ** បានបង្ហាញរូបរាងច្បាស់ឲ្យយើងស្គាល់ គឺព្យញ្ជនៈ**អ** ពុំមែនគ្រាន់តែជាបន្ទាត់ត្រង់ ឬបង្គោលឈរដូចមុនឡើយ។ កាលបើយើងស្រាក់គ្នា(ស្រៈ) សូរសម្លេង**អ**នាំមុខ ពេលដែលយើងស្វែងរកអ្នក**ឥ** **អ**ទៅនៅពីខាងក្រោយវិញ ប្រស្នាគាត់ចង់ប្រាប់យើងថា កាលនៅជាស្រៈ **អ** ជាអ្នកនាំមុខ ពេលក្លាយជាព្យញ្ជនៈ**អ**ទៅនៅពីក្រោយ (សូមមើលការពន្យល់ព្យញ្ជនៈទាំង៣៣តួទំព័រមុន)។ នេះជាប្រស្នាបង្កប់ ដែលដូនតាយើងបានបញ្ចូលទៅលាក់ទុក ក្នុងស្រៈទាំងពីរបែបនេះ គឺស្រៈនិស្ស័យនិងស្រៈពេញតួ ហេតុដែលមានឈ្មោះយ៉ាងនេះ ដូចបានពន្យល់រៀបរាប់ខាងលើ។ ឈាមជ័ររបស់អ្នក**ឥ**មរតកនេះទុក មិនអាចផ្តាច់ចិត្តចេញពីកេរ ដែលខ្លួនបានហួងហែងឡើយ សេចក្តីប្រកាន់ខ្ជាប់នៅសណ្ឋិតជាប់ជានិច្ច ឲ្យតែកូននាគចេះយកមក រែកញែករូចពិចារណា នោះនឹងឃើញរឿង របស់ម្ចាស់មរតកនេះជាពុំខាន។

## V.អំពីអត្ថន័យបង្កប់ក្នុងលេខខ្មែរ (សម្ដីជាឯក លេខជាទោ អក្សរជាត្រី)

ហេតុអ្វីនៅក្នុងសុភាសិតខ្មែរនេះ បណ្ឌិតលោកទុកលេខ ក្នុងលំដាប់លេខ២ដូច្នេះ? តើក្នុងលេខខ្មែរ មានបង្កប់ប្រស្នាអាថ៌កំបាំងអ្វីខ្លះ ទៅនឹងរឿងបណ្ដាំមាតាមហានគរ? លេខខ្មែរបើយើងរាប់ គឺមានចំនួនត្រឹមប្រាំ(៥ចំពោះខ្ទង់រាយ) ផុតពីប្រាំទៅត្រូវបូក ប្រាំបូកមួយស្មើប្រាំមួយ(៦) ប្រាំបូកពីរស្មើប្រាំពីរ(៧) ប្រាំបូកបីស្មើប្រាំបី(៨) ប្រាំបូកបួនស្មើប្រាំបួន(៩) លេខដប់គឺប្រាំដណ្ដប់លើប្រាំ(ដប់ស្មើនឹងប្រាំដណ្ដប់ប្រាំ)។ ផុតពីដប់ទៅគឺមួយដណ្ដប់(មួយដណ្ដប់លើដប់) ពីរដណ្ដប់(ពីរដណ្ដប់លើដប់)..... ចំពោះភាសានិយាយ ចំណែកភាសារអាន គឺដប់មួយដប់ពីរ...។ល។ ហេតុអ្វីលេខខ្មែរមានត្រឹម**ប្រាំ** ផុតពីប្រាំត្រូវបូកយ៉ាងនេះ? ពាក្យប្រាំបើដកជើង**រ**មកដាក់ខាងមុខ ក្លាយជាពាក្យ**របាំ** យក**រ**ទៅត្រួត**បាំ**ឃើញពាក្យ**ប្រាំ** យក**រ**មកដាក់ពីក្រោយ**ប**ឃើញពាក្យ**បរាំ**។ ហើយលេខ៥នេះ បើយើងតំរៀបលេខដូចម្រាមដៃ ជាកញ្ចុំរង្វង់មូល រួចយើងផ្គុំចំណុចពីម្រាមមួយទៅម្រាមមួយ នោះសញ្ញាគំនូសបានបង្ហាញប្រាប់យើងថា ខ្មែរពូជប្រាំគឺជាពូជផ្កាយ ពូជផ្កាយនេះហើយ ដែលបានបន្សល់ទុក នៅសំណង់ប្រាសាទថ្មរាប់ពាន់ ដែលប្រាសាទទាំងនោះ បានឆ្លុះទៅនឹងផ្កាយលើមេឃ។

### ក.អត្ថន័យបង្កប់ក្នុងលេខមួយ(១)

មួយពាក្យសរសេរជាអក្សរ មួយប្រកបចេញពីព្យញ្ជនៈ**ម** ហើយពាក្យមនេះខ្ញុំបានពន្យល់ ក្នុងព្យញ្ជនៈខាងលើហើយ ម៍(ទៅ) មរ(ស្លាប់) មរ(ភក់ខ្មៅ)។ លេខមួយគឺមុនគេមុខគេ ដូច្នេះន័យឬឋានៈរបស់វា ស្មើនឹងព្យញ្ជនៈ**ក** ព្រោះអ្នក**ក**ត្រូវដេកស្លាប់(មរ) ក្នុងភក់ខ្មៅ(មរ) រងចាំកូននាគទៅជួយស្រង់គាត់ ចេញពីទីទុក្ខនោះ។ នៅក្នុងរឿងព្រះធម្មសេនាបតីសារីបុត្រ ព្រះអង្គជាអគ្គសាវកស្ដាំ លោកបានជួយស្រង់មាតាលោក ដែលមានកំណើតក្នុងអបាយភូមិ កាលពីប៉ុន្មានជាតិកន្លងទៅ។ ព្រោះមាតាលោក បានមកឲ្យនិម្មិតដល់លោក ដើម្បីឲ្យលោកជួយ ពេលព្រះសារីបុត្រលោកបានជ្រាបដឹង លោកក៏បានថ្វាយទានចំពោះសង្ឃ ដែលបដិគ្គាហកអ្នកទទួល គឺសុទ្ធតែជាព្រះអរហន្តអស់អាសវៈកិលេស ទីបំផុតមាតាលោក ដែលមានកំណើតជាប្រេតនោះ បានរួចចាកផុតពីទុក្ខហើយទៅសោយសម្បត្តិសុខក្នុងទេវលោក។

យ៉ាងណាមិញ រឿងមាតាមហានគរខ្មែរ ប្រវត្តិសាវតាររបស់លោក ក៏ដូចជារឿងមាតាព្រះសារីបុត្រដែរ ពាក្យត្រឡប់ មួយចាំកូនជ = មរចាំកូនជួយ ព្រោះភក់ខ្មៅនិងមរណៈ គឺតំណាងឲ្យទីទុក្ខ

និងស្លាប់ មានតែរង់ចាំកូននាគ ជំនាន់ក្រោយរបស់គាត់តែប៉ុណ្ណោះ ទើបមានសង្ឃឹមរួចពីមរភក់ និងមរណៈ នេះជាអត្ថន័យបង្កប់ក្នុងពាក្យ សរសេរជាអក្សរលេខមួយ(១)។

**ខ.អត្ថន័យបង្កប់ក្នុងលេខពីរ(២)**

ហេតុអ្វីអក្សរសរសេរ ពាក្យលេខ២មាន**ះ**? ព្រោះដូនតាគាត់ចង់ឲ្យយើងរក៏មួយ មកគួបបូក និងមួយកើតបានជាពីរ គ្រប់ពាក្យខ្មែរពេលដែលសរសេរ មានដាក់**ះ**ពីខាងក្រោយ គឺប្រស្នារបស់ពាក្យឲ្យយើង**ះ**(រក៏)។ លេខ២សរសេរជាអក្សរគឺ**ពីរ** ដែលមានព្យញ្ជនៈ**ព**ជាបណ្តូលពាក្យ ហើយសូរព្យញ្ជនៈ**ព**នេះ ន័យទីមួយគឺលើកឡើង ន័យទីពីររក្សាផែនដី ន័យទីបីគុណជាតិប្រសើរគួប្រាថ្នា ន័យទីបួនគឺបិទរន្ធទឹកកុំឲ្យលេចចូល (សូមមើលការបកស្រាយពិស្តារនៅក្នុងព្យញ្ជនៈព)។ ពាក្យត្រឡប់របស់លេខពីរគឺ ពីរាជន = ពរាជនី លើកឡើងចេញពីទីទុក្ខ ដែលគាត់បានដេកស្លាប់ចេញពីសន្តានចិត្តកូននាគសម័យក្រោយ ក្នុងភក់ខ្មៅ ឬអបាយភូមិ(មរ)តែម្នាក់ឯង យើងគួនាំគ្នាជួយលោក ឲ្យបានរួចពីទុក្ខ ហើយទៅសោយសុខក្នុងសុគតិភព ដោយអំណាចការដឹងគុណ នឹងតបគុណ។

**គ.អត្ថន័យបង្កប់ក្នុងលេខបី(៣)**

អត្ថន័យបង្កប់នៅក្នុងពាក្យសរសេរលេខបី ទោះពុំទាន់បកស្រាយ ក៏អាចងាយយល់ជាងពាក្យពីរ ព្រោះពាក្យបីគឺបីត្រកងឡើង យកមកផ្អោបជាប់នឹងដើមទ្រូង ន័យគឺពផងបីផង លើកគាត់ឡើងចេញពីទីទុក្ខ នាំទៅដាក់ក្នុងទីសុខ ដោយកម្លាំងកតញ្ញូនិងកតវេទី។ ពាក្យសរសេរសម្គាល់លេខ៣ នេះ មានព្យញ្ជនៈ**ប**ជាបណ្តូលរបស់ពាក្យ ហើយព្យញ្ជនៈ**ប**នេះ សូមមើលការបកស្រាយក្នុងព្យញ្ជនៈ៣ពាក្យខាងលើ។ ពាក្យត្រឡប់លេខបីគឺ បីស្រៈអ = បស្រៈី គឺបីផងស្រាក់ដៃសាមគ្គីគ្នាផង ទើបជួបអរ ឬបរនាំចេញរឿងសិរី(ស្រី)បីប្រការ។

**ឃ.អត្ថន័យបង្កប់ក្នុងលេខបួន(៤)**

អត្ថន័យនៅក្នុងពាក្យសរសេរលេខបួន អក្សរសរសេរក៏មានព្យញ្ជនៈ**ប** ជាបណ្តូលពាក្យដែរ ពាក្យត្រឡប់លេខបួន គឺបួនទាំងខ្លី = បីទាំងខ្លួន។ ហេតុអ្វីបានត្រូវបីទាំងខ្លួន? ព្រោះទេពធីតាទាំង៧រាល់ឆ្នាំ ក្នុងថ្ងៃមហាសង្ក្រាន្ត ទេពធីតាដែលត្រូវវេន គឺពបីដង្ហែតែសិរសា(ក្បាល) កបិលមហាព្រហ្មតែប៉ុណ្ណោះ។ នៅក្នុងឆ្នាំរោង ចត្វាស័ក ពុទ្ធសករាជ ២៥៥៦នេះ ព្រហ្មម៉ែ ព្រហ្មឪមាន ដងខ្លួន

ពេញលេញវិញហើយ ដូច្នេះឆ្នាំនេះគឺជាឆ្នាំព្រហ្មម៉ែឪ លោកមានរូបរាងកាយគ្រប់គ្រាន់ មិនដូចពីមុន ព្រហ្ម នាគ និងរូបតំណាងឲ្យមាតាផ្សេងៗទៀត មានតែសិរសា(ក្បាល) ពុំមានដងខ្លួននិងអវយវគ្រប់គ្រាន់(និមិត្តរូប)។

**ខ.អត្ថន័យបង្កប់ក្នុងលេខប្រាំ(៥)**

នៅក្នុងអត្ថន័យបង្កប់ពាក្យសរសេរលេខ**ប្រាំ** = **បរាំ** = **របាំ** ពាក្យនេះមានព្យញ្ជនៈ**ប**ជាបណ្ដូល នឹងថែមជើងព្យញ្ជនៈ**រ**មួយអមខាងក្រៅទៀត។ ក្នុងលេខទាំងបីខាងចុងនេះ មានព្យញ្ជនៈ**ប**ទាំងបីលេខ គឺលេខបី លេខបួន លេខប្រាំ ព្រោះបរនាំគាត់ចេញពីទ្វារឃុំទាំងបី (មើលការពន្យល់រូបក្នុងភាគ២ និង៣)។






លក្ខណៈរូបភាពរបស់លេខ**៥** និងព្យញ្ជនៈ**ង ទ** សុទ្ធតែចងគួចខ្លួនឯងដូចគ្នា គ្រាន់តែព្យញ្ជនៈ **ង ទ** ចង្អុលប្រាប់ទិសពីអតីតកាល គឺគួចបែរទៅក្រោយ រីឯលេខ**៥**ចង្អុលគួចប្រាប់ទិសទៅខាងមុខ ប្រស្នាចងគួចព្យញ្ជនៈនិងលេខនេះ ពេលដែលយើងផ្គុំគ្នារួចស្រាយលា នោះនឹងឃើញចម្លើយសាវតារបស់ជាតិ។ បើតាមការបកស្រាយលេខ**៥**នេះ ឲ្យភ្ជាប់ទៅនឹងន័យរបស់ព្យញ្ជនៈ និងភ្ជាប់ទៅក្នុងរឿងបណ្តាំមាតាមហានគរ ទើបយើងដឹងថា លោកយករឿងរបស់ខ្លួន ទៅលាយបញ្ចូលក្នុងមរតកអច្ឆរិយទាំងអស់ ដែលមាននៅក្នុងមាតុភូមិនេះ។ ហើយប្រស្នាលេខខ្ទង់រាយក្បៀរ មានត្រឹម**៥**នេះ ត្រូវផ្សាភ្ជាប់ទៅនឹងប្រស្នា ប្រាសាទពីរាមីតលើពិភពលោក គឺមានតែពូជ**៥** ដែលជាពូជផ្កាយ ពូជនាគទេ ដែលអាចយល់ពីអាថ៌កំបាំង រូបភាព គំនូរចម្លាក់ ក្នុងប្រាសាទពីរាមីតនៅពិភពលោកនេះបាន ទាំងក្នុងអតីតនិងបច្ចុប្បន្ន។



**ច.អត្ថន័យបង្កប់ក្នុងលេខដប់(១០)**

អត្ថន័យបង្កប់ពាក្យសរសេរនៅក្នុងលេខដប់(១០) គឺមានព្យញ្ជនៈ**ដ** ជាបណ្តូលរបស់ពាក្យ (មើលការពន្យល់ ព្យញ្ជនៈដខាងលើ) ពាក្យដប់នេះគឺ ចេញមកពីពាក្យ**ប្រាំដណ្តប់លើប្រាំ** = **១០**។ ប្រាំតំណាងឲ្យបរទេស មកបិទដណ្តប់លើពូជប្រាំ ពូជនាគ ពូជផ្កាយ ពូជអ្នកទទួលកេរមរតកម៉ែ (ក្មែរ) ពូជអច្ឆរិយ(អច្ឆរា) ឲ្យលិចចុះក្នុងទីងងឹត មិនអាចបញ្ចេញពន្លឺរស្មីរបស់ខ្លួនបាន (មើលការពន្យល់រូប នេះក្នុង ភាគបី)។ ទាល់តែមានកូននាគណា ស្ម័គ្រចិត្តចុះទៅញែកការដណ្តប់នេះ ឲ្យឃ្លាតចេញពីគ្នា ទើបអាចបើកអាថ៌កំបាំងរាប់ពាន់ឆ្នាំមុន របស់អ្នកបង្កើតពូជនាគ និងទឹកដី (មើលប្រស្នាភាសាគចិនមកយកនគរ ដែលអ្នកប្រាជ្ញចិនលើកម្រាមប្រាំ ធនជ័យលើកម្រាមមួយ)។ ហើយផុតពី

ដប់ទៅ គឺគេរួមគ្នាដណ្ដប់ពីលើយើង ធ្វើឲ្យយើងលែងមើលស្គាល់ សារតាពិតរបស់ខ្លួន ចង់ស្គាល់ពូជក្មេរ ប្រវត្តិក្មេរ ត្រូវតែសិក្សាពីបរទេស (និមិត្តរូបវត្ថុដែលដណ្ដប់ពីលើប្រាំ)។

**ឆ.អត្ថន័យបង្កប់ក្នុងលេខម្ភៃ(២០)**

អត្ថន័យបង្កប់ពាក្យសរសេរក្នុងលេខម្ភៃ(២០) បើយើងសម្រាយន័យរបស់ពាក្យ យើងឃើញពាក្យពីម៉ាត់គឺ **ម** + **ភៃ** ភាសានិយាយស្មើ **ភ័យ**ហេតុអ្វីមងើបឡើងវិញបែរជាភ័យ? ព្រោះមាតាមហានគរ (ឯកសារចិនគេ ហៅគាត់ ថាបិសាចពស់) ដែលជាមេ ជាម៉ែ ជាយាយ ត្រូវបានបាបកម្មឃុំគាត់ទុក រាប់ពាន់ឆ្នាំហើយ។ បើស្ត្រីនេះបានរួចពីឃុំឃាំងវិញ គ្រោះភ័យទាំងឡាយនឹងកើតមាន ដោយការតាមចងពៀរ បិទសន្ធប់ពីសំណាក់បរទេស ខាងក្រៅមកលើរូបគាត់។ តើព្រោះហេតុអ្វី? ពីព្រោះពួកគេមិនចង់ឲ្យមាតានាគ ដែលគេបានឃុំគាត់ជាប់រាប់ពាន់ឆ្នាំនោះ រួចចេញមកសារជាថ្មីវិញឡើយ តែកម្លាំងឫទ្ធិរបស់មនុស្ស ពុំអាចឈ្នះកម្លាំងកម្មបានឡើយ ទោសរបស់គាត់បានត្រូវបញ្ចប់ជាស្ថាពរក្នុងថ្ងៃទី២ មិថុនា ឆ្នាំ២០១១។ ទោសរបស់គាត់ ដែលយក្សបានចាប់គាត់ឃុំទុកនោះ គឺម្ដាយឪពុកកូន ព្រោះពួកគាត់បានរួមគ្នា ទៅលួចយកកែវមណីរបស់យក្ស ព្រោះកែវមណីនេះ អាចឲ្យពួកគាត់សម្រេចប្រយោជន៍បានគ្រប់យ៉ាង ហេតុនេះការលួចគឺជាចោរ គេចាប់បានត្រូវដាក់ឃុំឃាំង នេះជាច្បាប់កម្ម។ ការរៀបរាប់នេះ កូននាគច្បាស់ជាយល់ថា ជារឿងហួសនិស្ស័យយល់ មិនអាចទទួលយកបាន។ ក៏ប៉ុន្តែបើកូននាគបានសិក្សា ឲ្យស៊ីជំរៅទៅក្នុងព្រះពុទ្ធសាសនា នោះគឺគ្មានអ្វីជាការលាក់កំបាំងឡើយ ព្រោះព្រះអង្គបានសម្ដែង រឿងកម្មនិងផលនេះទុកក្នុងត្រៃបិដក ដែលមានរយៈពេលជាង២០០០ឆ្នាំមកហើយ គឺមុនប្រវត្តិរឿងមាតាមហានគរ។ មិនត្រឹមតែសម្ដែង ក្នុងរឿងកម្មផលប៉ុណ្ណឹងទេ ព្រះអង្គបានសម្ដែងនូវផ្លូវឬមគ្គ លោកកុត្តរធម៌ដែលជាធម៌ដឹកនាំសត្វលោក ឲ្យចេញចាកពីបញ្ចក្ខ័ន្ធ ឈប់ឲ្យសត្វវិលកើត វិលស្លាប់បានទៀតផង ព្រះអង្គបានចង្អុលប្រាប់យើងនៅត្រើយសុខ គឺអមតមហានិព្វាន។

**ជ.អត្ថន័យបង្កប់ក្នុងលេខសាមសិប(៣០)**

អត្ថន័យបង្កប់ពាក្យសរសេរក្នុងលេខសាមសិប ពាក្យបង្កប់ក្នុងន័យគឺ **សាមសិប** = **សាមខ្សឹប** តើសាមសិប ឬខ្សឹបពីរឿងអ្វី? គឺខ្សឹបពីរឿងកុកទាំងបី មកលេបសត្វត្រី(ស្ត្រី) មើលចាក់ទឹកដូងលើកទី២ គឺចាក់ ទឹកដូងពីទ្រូងមាតា កន្ទុយត្រីប្រាក្បាលនាងកុក អកកំបោរចាំកូនស្រង់ បំពង់ស្រីចាំកូន

រ៉ែក ក្បាលម៉ែប្រែកន្ទ្រកជុះអាចម៍ដាក់ប៉ក់។ ន័យចាក់ទឹកដូងនេះខ្ញុំបានពន្យល់រួចហើយនៅក្នុងភាគ ១ ដែលខ្ញុំលើកយកមកបង្ហាញនេះ ចង់បញ្ជាក់ពីន័យលេខសាមសិប គឺខ្សឹបប្រាប់ពីរឿងកុកទាំងបីមកលេបត្រីប្រា ដែលត្រីប្រាតំណាងព្រះម៉ែ ឲ្យនៅសល់តែកន្ទុយ។ ដូច្នេះកូននាគសម័យខាងក្រោយ បានយកក្បាលក្រពើមកពាក់ សូមមើលល្បែងចាក់ទឹកដូងលើកទី១ ដែលបានបង្ហាញប្រាប់ថា កន្ទុយខ្លែងខ្មែរ(កេរម៉ែ) ពាក់ក្បាលក្រពើ។

**ឈ.អត្ថន័យបង្កប់ក្នុងលេខសែសិប(៤០)**

អត្ថន័យបង្កប់ពាក្យសរសេរក្នុងលេខសែសិបនេះ គឺខ្សឹបប្រាប់ពីរឿងក្រសែ(សែ) លំអានជំនួរវង្សត្រកូលខ្មែរ ដែលដាច់តំណាខ្សែលោហិតរាប់រយពាន់ឆ្នាំ ឲ្យដឹងក្រសែជំនួរឡើងវិញ។ កូននាគទាំងឡាយ ពេលអ្នកទៅទស្សនាប្រាសាទបុរាណ អ្នកនឹងប្រទះឃើញនូវចង្អូររន្ធទឹកតូចមួយ ដែលមានទរលៀនចេញមកក្រៅជញ្ជាំង។ ពេលណាដែលអ្នកចាក់ទឹក ក្នុងយោនីពីខាងក្នុងប្រាសាទ ទឹកនឹងហូរធ្លាក់ចេញ តាមរន្ធចង្អូរតូចនេះមកខាងក្រៅ ដែលសព្វថ្ងៃគេពន្យល់ថាជាទឹកមន្ត ឬទឹកអង្គបំពង់ស្រី។ រន្ធចង្អូរនេះ ឃើញមាននៅប្រាសាទអាស្រមឥសី នៅអង្គរបុរី ប្រាសាទបាយង្កោរ ប្រាសាទភ្នំជីសូរ....។ល។ និម្មិតរូបរន្ធចង្អូរនេះ ដូនតាយើងគាត់ចង់ប្រាប់ ឲ្យកូននាគដឹងថា រឿងក្រសែជំនួរក្នុងទឹកចិត្តម៉ែ ឬរឿងរបស់មាតា ពុំអាចស្រែកឲ្យឮខ្ទរខ្ទារបានឡើយ បានត្រឹមតែខ្សឹប(សិប)ប្រាប់ឲ្យកូននាគខាងក្រោយ ដឹងពីក្រសែស្រឡាយរបស់ខ្លួនតែប៉ុណ្ណោះ។ ព្រោះគាត់ត្រូវឃុំក្នុងគុហារ ទូលយោនីនៅពីលើក្បាល ដែលយោនីនោះតំណាងឲ្យទឹកដី(មាតុភូមិ) រួចមាត់ហាបញ្ចេញទឹកចិត្តពីក្នុងទ្រូង (មើលរូបមាតាកប់ត្រឹមកនៅភាគ៣) មកលាតត្រដាង បង្ហាញពីភាសាគ ឬខ្សឹប ដល់កូននាគខាងក្រោយ ឲ្យបានដឹងពីរឿងពិតរបស់ខ្លួន។ ដោយសង្ឃឹមថា ពេលដែលកូននាគខាងក្រោយដឹង ពួកគេនឹងរួមគ្នា លើកត្រកងពបីពួកគាត់ឡើង ទៅដាក់លើប្រាសាទភ្នំព្រះវិហារវិញ ដែលជានិម្មិតរូបព្រហ្ម ដំបូល ឬបល្ល័ង្ក។

**ញ.អត្ថន័យបង្កប់ក្នុងលេខហាសិប(៥០)**

អត្ថន័យបង្កប់ពាក្យសរសេរក្នុងលេខ៥០នេះ គឺន័យរបស់ពាក្យ មាត់ហាស្រែកហៅកូន តែសម្លេង ឮត្រឹមតែខ្សឹបខ្សៀវគ្នាតែប៉ុណ្ណោះ មិនអាចឲ្យឮបានពេញទំហឹងជាទូទៅឡើយ។ ព្រោះការស្រែកហៅ របស់គាត់រាប់រយពាន់ឆ្នាំធ្វើឲ្យស្អកក នឹងម្យ៉ាងទៀតផលនៃបាបចាស់របស់គាត់ ឲ្យ

វិបាកកម្មមិនទាន់អស់។ ហាសិបបើយើងត្រឡប់ពាក្យ គឺហិបសា ឬហិបទុកសាសនៈបណ្ដាំ របស់មាតាមហានគរនេះឯង។

**ជ.អត្ថន័យបង្កប់ក្នុងលេខហុកសិប(៦០)**

ពាក្យថាហុកសិប បើត្រឡប់ពាក្យគឺហិបសុកឬសុខ បានសុខព្រោះអ្វី? ព្រោះទ្រព្យមរតកអច្ឆរិយនេះ កូននាគចាប់ផ្ដើមបើកហិបរើកកាយ រកប្រវត្តិម្ចាស់មរតកអច្ឆរិយនេះហើយ ថាតើម្ចាស់មរតក គាត់ជានរណា? បើកូននាគសើរើរកម្ចាស់ដើម អ្នកប្រមូលទ្រព្យមរតកឃើញ នឹងបានសុខ ព្រោះការដឹងគុណនឹងតបគុណ ដល់អ្នកដែលបានបំពេញពលិកម្ម ខិតខំប្រមូលទ្រព្យមរតកមកទុក ឲ្យយើងទាំងអស់គ្នា។ វាគឺជាច្បាប់របស់ធម្មជាតិឬធម្មៈ ព្រោះមាតាបិតាទុកដូចជាអ្នកស្រែកហៅ ចំណែកឯកូនប្រុសស្រី ទុកដូចជាអ្នកឆ្លើយ តើយើងគួរឆ្លើយតបទៅពួកគាត់វិញ ដោយពាក្យកតញ្ញូ ឬអកតញ្ញូ?

**ឈ.អត្ថន័យបង្កប់ក្នុងលេខចិតសិប(៧០)**

អត្ថន័យបង្កប់ទុកក្នុងលេខចិតសិបនេះ សូរសម្លេង **ចិត** = **ចិត្ត** ចំពោះសូរស័ព្ទនិយាយសាសនបណ្ដាំមាតាមហានគរ បាននិយាយខ្សឹបប្រាប់ ហូរចូលទៅដល់ក្នុងចិត្ត កូននាគហើយ ទោះជាមិនទាន់បានដឹងជាទូទៅ ក៏ដំណឹងនេះបានជ្រាបបន្តិចម្ដងៗ។ ពេលចិត្តកូននាគបានដឹងរឿងសាវតារបស់ខ្លួន តាមរយៈការនិយាយខ្សឹបនេះ ចិត្តកូននាគបានភ្ញាក់កន្ត្រាក់អារម្មណ៍ ថាគួរឲ្យសង្វេគនិងអស្ចារ្យណាស់ ដែលពីមុនខ្លួនពុំបានដឹងពីប្រវត្តិ របស់ម្ចាស់មរតកអច្ឆរិយនេះ។ ចំណែកបរទេសដែលដឹងរឿងពិតរបស់ក្មេរ បែរជាមកកុហករួចបំភាន់ ឲ្យកូនក្មេរនៅក្នុងទីងងឹតមិនអាចយល់ដឹង ពីប្រវត្តិរបស់អ្នកបង្កើតជាតិ ដោយបង្វែរឲ្យដឹង ពីរឿងផ្សេងទៅវិញ។

**ញ.អត្ថន័យបង្កប់ក្នុងលេខប៉ែតសិប(៨០)**

អត្ថន័យបង្កប់ទុកក្នុងលេខប៉ែតសិបនេះ គឺខ្សឹបប្រាប់ឲ្យបានដឹង ពីរឿងប្រវត្តិកំណើតរបស់ខ្លួន ហើយត្រេកអរព្រឺព្រួចសប្បាយ ពេលដែលកូននាគបានដឹងពីសាវតាពិតរបស់ខ្លួន ព្រោះពាក្យ **ប៉ែត** = **ប៉ែតី** = **បេតី** = **បីតិ** ឬសោមនស្ស ត្រេកអរ។

**៧.អត្ថន័យក្នុងលេខកៅសិប(៩០)**

នៅក្នុងពាក្យសរសេរលេខ៩០នេះ ន័យរបស់ពាក្យគឺមានពាក្យ **កៅ** = **កៅអី** = **បល្ល័ង្ក** តើខ្សឹបប្រាប់ពីរឿងអ្វី? ខ្សឹបប្រាប់ពីរឿងកៅអីទទេ ឬបល្ល័ង្កទទេ ព្រោះយើងមានឈ្មោះប្រាសាទ បយ័ង្កកោរ ឬបាយ័ង់កោរ ដែលមានន័យថាបល្ល័ង្កទទេឬកៅអីទទេ។ តើម្ចាស់ដែលអង្គុយលើកៅអីឬបល្ល័ង្កនេះទៅណា? ទើបពាក្យសម្គាល់លេខកៅសិបនេះ បានខ្សឹបប្រាប់ពីរឿងម្ចាស់បល្ល័ង្ក ឬកៅអីដែលលោកបានទៅសោយទុក្ខ ក្នុងអបាយភូមិតែម្នាក់ឯង ដោយទុកឈ្មោះបល្ល័ង្កទទេថា មាតុភូមិ ឬភូមិមាតុ = មាតា ដែលម្ចាស់មាតុភូមិនេះ កូននាគពុំបានដឹងប្រវត្តិរឿងជូរចត់គាត់ឡើយ។

**៨.អត្ថន័យបង្កប់ក្នុងលេខមួយរយ(១០០)**

នៅក្នុងពាក្យសរសេរសម្គាល់លេខមួយរយនេះ មានពាក្យ **មួយ** + **រយ** ពាក្យសរសេរមួយខ្ញុំបានពន្យល់រួចហើយ ចំណែកពាក្យរយគឺមានន័យថា រៀបចំឲ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយ។ ព្រោះភាសានិយាយ យើងតែងប្រើពាក្យថារៀបនិងរយ គឺរៀបចំឲ្យមានបែបផែន រយរៀប ឬរយ អ្នករៀប គឺ**មួយ** = **ម៉**= **មរ** ឡើងមករៀបចំឲ្យបានរៀបរយឡើងវិញ។

**៩.អត្ថន័យបង្កប់ក្នុងលេខមួយពាន់(១០០០)**

ពាក្យសរសេរសម្គាល់លេខមួយពាន់(១០០០) អត្ថន័យបង្កប់ក្នុងពាក្យសរសេរ ដូនតាគាត់ចង់និយាយប្រាប់កូននាគឲ្យបានដឹងថា សូរក្នុងពាក្យនិយាយ **ពាន់** = **ព័ន្ធ**។ កូននាគក្នុងនគរនេះ ពីអតីតនិងបច្ចុប្បន្នទាំងមូល ពេលណាដែលព័ន្ធចូលគ្នាជាធ្លុងមួយហើយ ពន្លឺនៃភាពអច្ឆរិយរបស់ពូជផ្កាយ នឹងត្រូវចែងចាំងរស្មីសាជាថ្មីឡើងវិញ នឹងត្រូវផ្សព្វផ្សាយ ទូទៅពេញក្នុងលោកទាំងមូល។

**៩.អត្ថន័យបង្កប់ក្នុងលេខមួយម៉ឺន(១០០០០)**

ពាក្យសរសេរសម្គាល់លេខខ្ទង់ម៉ឺនឬមួយម៉ឺន(១០០០០) អត្ថន័យរបស់ពាក្យម៉ឺន ដូនតាគាត់ចង់ប្រាប់យើងថា ពេលដែលកូននាគព័ន្ធ(ពាន់) គ្នាហើយ ភាពជាជាតិថ្កើង គឺពូជម៉ឺន(នាម៉ឺន) ពូជផ្កាយ ពូជនាគ ពូជអច្ឆរិយ នឹងកើតផុលផុសឡើងជាថ្មី នៅលើទឹកដីចាស់នេះ។

**ឆ.អត្ថន័យបង្កប់ក្នុងលេខមួយសែន(១០០០០០)**

អត្ថន័យបង្កប់នៅក្នុងពាក្យមួយសែន(១០០០០០) ដូនតាមហានគរ លោកចង់ប្រាប់យើងថា ពូជនាគគឺជាពូជខ្ពង់ខ្ពស់ប្រសើរ ដូច្នេះពូជនេះគឺជាពូជដឹងគុណ ពូជអ្នកមានកតញ្ញូនិងកតវេទី។ ពេលដែលកូនខ្មែរ ចាប់ផ្ដើមដឹងប្រវត្តិកំណើតនៃជាតិ នោះយើងនឹងរួមសាមគ្គីគ្នា ធ្វើនូវមហាកុសល ក្នុងបុញ្ញកិរិយា១០យ៉ាង **សែន**បញ្ជូនឧទ្ទិសថ្វាយ ចែកជូនទៅដល់អ្នកមានឧបការគុណទាំងនោះក្នុងទិសទាំង១០ ឲ្យលោកបានត្រេកអរទទួលអនុមោទនា រួចបានទៅសោយសុខក្នុងសុគតិភព។ **ពាក្យសែន** = **ឧទ្ទិសជូន** ផ្សាយជូននូវមហាកុសល ដែលកើតចេញពីការតាំងចេតនាក្នុងកុសល **សែន**បញ្ជូនទៅដល់ញាតិធម៌ ដែលសុទ្ធតែជាអ្នកមានឧបការគុណទាំងនោះ។

**ជ.អត្ថន័យបង្កប់ក្នុងលេខមួយលាន(១០០០០០០)**

អត្ថន័យដែលបង្កប់ នៅក្នុងពាក្យមួយលានឬលៀន(១០០០០០០) ពេលដែលកូន នាគបានរៀប **រយ**ហើយ ក៏ចាប់ផ្ដើម**ពាន់**សាមគ្គីគ្នា រួចបង្កើតបានជាពូជ**ម៉ឺន** ហើយក៏នាំគ្នា**សែន**បញ្ជូនឧទ្ទិសមហាកុសល ពេលនោះពូជអច្ឆរិយ ពូជផ្កាយ ពូជនាគ ក៏ចាប់ផ្ដើម**លាន**ចេញ ឲ្យពិភពលោកបានឃើញ ព្រោះភាសានិយាយពាក្យ **លាន** = **លៀន**។

**ឈ.អត្ថន័យបង្កប់ក្នុងលេខមួយកោដិ(១០០០០០០០)**

សូរសព្ទសម្លេងនិយាយពាក្យថា **កោដិ** = **កោដ្ឋ** = **កោត** ន័យបង្កប់ក្នុងពាក្យកោដិនេះ ដូនតាមហានគរលោកចង់ប្រាប់យើងថា ពេលដែលព្រះមាតាមហានគរ លោកបានរួចពីមរ (ស្លាប់ ភក់ខ្មៅ...) ហើយ អ្វីៗនឹងត្រូវប្រែប្រួលក្នុងលោកនេះ។ ព្រោះន័យតាំងពីខ្ទង់រយ ពាន់ ម៉ឺន សែន លាន ទីបញ្ចប់ពិភពលោកទាំងមូល នឹងត្រូវកោតស្ញប់ស្ញែង ពូជផ្កាយ ពូជនាគ ជាពូជអច្ឆរិយ ដែលត្រូវអកុសល បិទសន្ធប់លាក់ទុករាប់ពាន់ឆ្នាំនោះ ចាប់ផ្ដើមបញ្ចេញប្រវត្តិពន្លឺអច្ឆរិយរបស់ខ្លួនឡើងវិញហើយ។ ដូច្នេះលេខខ្មែរយើង មានត្រឹមចំនួនខ្ទង់កោដិតែប៉ុណ្ណោះ បើកូននាគពុំស្គាល់ អត្ថន័យបង្កប់ទុកក្នុងលេខ**មួយ**ទេ គឺពុំអាចមកស្គាល់អត្ថន័យ**កោដិ**(កោត)ខាងក្រោយបានឡើយ នេះចំពោះលេខ។ ចំណែកឯព្យញ្ជនៈ បើកូនខ្មែរពុំស្គាល់អត្ថន័យ**ក** កូនខ្មែរក៏មិនអាចស្គាល់**អ**បានឡើយ លុះត្រាតែបុគ្គលមាននិស្ស័យស្រាក់ឬបូក ទើបអាចរកឃើញប្រស្នាបង្កប់ របស់ដូនតាទាំងនេះ។

# VI.អំពីអត្ថន័យបង្កប់ក្នុងទិស

ដូនតាមហានគរយើង បានយករឿងទិសនេះ ទៅបញ្ចូលលាក់ទុកក្នុងទំនាយ នឹងក្នុងមរតក និងពិធីផ្សេងៗទៀត ហើយអត្ថន័យរបស់ទិស បានបង្កប់ក្នុងពាក្យបណ្ដាំមាតាមហានគរ។ យើង តែងឮចាស់ៗពោលដំណាលបន្តគ្នាថា នឹងមានអ្នកមានបុណ្យចេញពីទិសខាងលិច(ភាសានិយាយ ទៀច) តើទំនាយប្រស្នានេះ ន័យពិតរបស់វាយ៉ាងដូចម្ដេច? បើយើងមិនបានឈ្វេងយល់ពិចារណា ទេ គឺបានត្រឹមតែនិយាយបន្តគ្នា រហូតដល់បង្កើតបានជាពាក្យឃោសនា បោកបញ្ឆោតគ្នាទៀត ផង។ យើងអាចបកស្រាយ ប្រស្នាទំនាយដូនតានេះបាន លុះត្រាតែយើងទៅស្វែងយល់ អំពីទិស ដែលមាននៅក្នុងគម្ពីរព្រះពុទ្ធសាសនា ទើបអាចរកនូវការពិតឃើញ ព្រោះដូនតាយើងលោកបាន យករឿង ទុក្ខសោករបស់ខ្លួន ទៅលាក់ទុកក្នុងស្រោមរបស់សាសនា។ ព្រោះមានតែសាសនា ទេ ដែលងាយលាក់ទុក នៅបណ្ដាំរបស់គាត់គ្រប់បែបយ៉ាង កុំឲ្យពួកបរទេសគេងាយមើលយល់ តែ ទីបំផុតបរទេស គេមើលយល់មុនកូននាគ ចំណែកកូនខ្មែរមើលរឿងបណ្ដាំ របស់មាតាមិនយល់ ព្រោះវាជាភាសាគម្ពីរភាសាក្លាម។ ហេតុអ្វីបានជាអ្នកប្រាជ្ញខ្មែរពីបុរាណ ទាយថានឹងមានអ្នកមាន បុណ្យមកពីទិសខាងលិច ហើយជាពោធិសត្វព្រះសិរិអារ្យមេត្រីទៀតផង? ហេតុម្ដេចក៏អ្នកមាន បុណ្យនេះ មិនទៅបដិសន្ធិ(កើត) នៅប្រទេសដែលកាន់ នឹងគោរពព្រះពុទ្ធសាសនាដូចយើង ដូចជា ប្រទេសសៀម ភូមា ស្រីលង្កា លាវ.... ហើយបែរជាគាត់ត្រូវមកកើត នៅក្នុងប្រទេសខ្មែរនេះទៅ វិញ? រហូតក្នុងទំនាយបានប្រាប់ថា មានចិនលិគម្ពីរស្វែងរកអ្នកមានបុណ្យឲ្យខ្មែរ ដែលអ្នកមាន បុណ្យគឺជាកំណប់ទ្រព្យ ខាងសេចក្ដីល្អ ដែលមនុស្សសាមញ្ញធម្មតាពុំអាចធ្វើបាន គឺមានតែព្រះ ពោធិសត្វដែលបំពេញបារមី ដើម្បីឲ្យបានត្រាស់ដឹងជាព្រះពុទ្ធទេ ទើបអាចបំពេញបារមីទាំង៣០ នេះ ឲ្យពេញបរិបូរណ៍បាន។ ហើយបុគ្គលនេះ បើបដិសន្ធិក្នុងនគរណាហើយ នគរនោះនឹងមាន ភាពរុងរឿងលេចធ្លោកើតឡើង ចុះហេតុអ្វីបានជាហោរាចិនចិត្តល្អអ្វីម្ល៉េះ សុខចិត្តលះបង់ពេលវេលា របស់ខ្លួន មកលិគម្ពីរតាមស្វែងរកអ្នកមានបុណ្យឲ្យខ្មែរ? សម័យផ្ដាច់ការ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលដឹកនាំដោយ លោកប៉ុលពតនិងបក្សពួក បានកៀរប្រជាជនខ្មែរចេញពីទីក្រុង ដែលនៅក្នុង នោះ មានអ្នកប្រាជ្ញ បណ្ឌិត និស្សិត បញ្ញវ័ន្ត.... ទាំងប្រជារាស្ត្រស្លូតត្រង់ ទាំងគ្រហស្ថ និងបព្វជិត យកទៅធ្វើទារុណកម្ម ហើយសម្លាប់យ៉ាងព្រៃផ្សៃនូវជាតិសាសន៍ឯង អស់ចំនួនរាប់លានអ្នក។ តើ

ពួកគេចង់រកអ្នកមានបុណ្យដើម្បី សម្លាប់ចោលឬ? ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គជាកំពូលអ្នកមានបុណ្យ លើអ្នកមានបុណ្យទាំង ឡាយក្នុងលោក ដោយការត្រាស់ដឹងនូវបរមត្ថសច្ចៈ គឺសម្មាសម្ពោធិញ្ញាណរបស់ព្រះអង្គ បានធ្វើឲ្យពន្លឺនៃការត្រាស់ដឹង ជះផ្សាយទៅគ្រប់ទិសទាំង១០ និងទៅគ្រប់ភពតូចនិងភពធំ រកបុគ្គលណាមួយឲ្យស្មើនឹងព្រះអង្គគ្មាន។ ចុះអ្នកមានបុណ្យ ក្នុងទំនាយក្មេរយើង មានន័យយ៉ាងណាដែរ? ដូនតាយើងបានប្រាប់ថា អ្នកមានបុណ្យនោះ ជាតួរអង្គព្រះសម្មាសម្ពុទ្ធព្រះសិរអារ្យមេត្រី ដែលនឹងបានត្រាស់ដឹងក្នុងចុងនៃភទកប្បនេះ។ បើតាមការពន្យល់ក្នុងគម្ពីរព្រះត្រៃបិដកបានប្រាប់ថា ពោធិសត្វព្រះសិរអារ្យមេត្រី ព្រះអង្គកំពុងតែសោយសម្បត្តិជាសុខ នៅក្នុងស្ថានតុសិតឯណោះ ហេតុអ្វីបានជាក្នុងទំនាយក្មេរ ថាព្រះអង្គបានមកចាប់បដិសន្ធិជា កូនក្មេរទៅវិញ? ចម្លើយគឺមានតែបុគ្គល អាចសម្រេចបាននូវអភិញ្ញាប្រាំមួយ និងវិជ្ជាប្រាំបី ទើបអាចឆ្លើយ នូវសំនួរចម្ងល់ខាងលើនេះបាន។

ទិសធំនៅក្នុងព្រះពុទ្ធសាសនាមានប្រាំមួយ(៦) ហើយទិសទាំង៦គឺតំណាងឲ្យ ឋានៈរបស់សត្វ ឬមនុស្ស ទៅតាមទិសនោះៗ។ រឿងទាក់ទងនឹងទិសនេះ កូននាគអាចអានដោយពិស្ដារបាន នៅក្នុងរឿងសិង្គាលកសូត្រ ដែលសិង្គាលកបុត្រនេះ គឺជាបុត្ររបស់គហបតី នៅក្នុងក្រុងរាជគ្រឹះ។ សិង្គាលកបុត្រ ត្រូវបានព្រះសម្មាសម្ពុទ្ធជាម្ចាស់ យាងទៅប្រោសសម្ដែងធម្មទេសនា ឲ្យបានយល់ច្បាស់ពីទិស ដែលខ្លួនបានថ្វាយបង្គំរាល់ថ្ងៃ តាមបណ្ដាំបិតា ផ្ដាំឲ្យខ្លួនប្រព្រឹត្តបដិបត្តិ មុនពេលស្លាប់។ ពេលព្រះអង្គសម្ដែងបញ្ចប់ធម្មទេសនា សិង្គាលកបុត្របានដល់នូវព្រះរតនៈត្រៃ ជាទីពឹងទីរលឹកស្មើដោយជីវិត នៅក្នុងថ្ងៃដែលបានស្ដាប់ការបកស្រាយពន្យល់ ដោយពិស្ដារអំពីទិសនោះ។

**<u>ក.អត្ថន័យទិសក្នុងព្រះពុទ្ធសាសនា</u>**

**<u>១.ទិសខាងកើត</u>**

មាតាបិតាទុកជាទិសខាងកើត កូនប្រុសស្រីគប្បីប្រតិបត្តិដោយស្ថាន៥យ៉ាង៖

- កូនត្រូវតាំងចិត្តថាអញនេះ ម៉ែឪបានចិញ្ចឹមបីបាច់ថែរក្សាមកហើយ អញត្រូវ ចិញ្ចឹមបីបាច់ថែរក្សាគាត់វិញ។
- កូនត្រូវតាំងចិត្តថា កាលណាបើមាតាបិតាលោកមានកិច្ចរវល់ នោះអញត្រូវបញ្ឈប់ការងារ របស់ខ្លួនទុកសិន ហើយត្រូវទៅជួយធ្វើកិច្ចការមាតាបិតាវិញ។

• កូនត្រូវតាំងចិត្តថា អញត្រូវតម្កល់វង្សត្រកូលមាតាបិតា ទុកដោយល្អ មិនឲ្យវិនាស និងអាប់កេរ្តិ៍ឈ្មោះ មិនធ្វើឲ្យទ្រព្យមាតាបិតាវិនាស ដោយឥតប្រយោជន៍ និងសង្គ្រោះមាតាបិតាឲ្យផុតពីវង្ស ដែលមិនប្រកបដោយធម៌ ហើយនែនាំឲ្យពួកគាត់សេពគប់នៅវង្ស ដែលប្រកបដោយធម៌។ មិនផ្ដាច់នៅអំពើជាកុសលទាំងឡាយ មានការឲ្យទាន រក្សាសីល ស្ដាប់ធម៌ អប់រំសមាធិ បញ្ញា ដែលមាតាបិតាបានប្រព្រឹត្តធ្វើតាម កន្លងមកហើយនោះទេ។

• កូនត្រូវតាំងចិត្តថា អញនឹងតាំងគំនិតមារយាទឲ្យល្អ ឲ្យជាទីពេញចិត្តរបស់មាតាបិតា ឲ្យជាមនុស្សគួរមាតាបិតា ប្រគល់ទ្រព្យសម្បត្តិកេរមរតកឲ្យ។

• កូនត្រូវតាំងចិត្តថា កាលបើមាតាបិតាធ្វើកាលកិរិយា(ស្លាប់) អញត្រូវធ្វើទក្ខិណាទាន ឧទ្ទិសកុសល ផលបុណ្យជូនដល់ពួកគាត់ជារឿយៗ ចាប់តាំងពីថ្ងៃគម្រប់៧អំពី ថ្ងៃដែល មាតា បិតា ដល់នៅសេចក្ដីស្លាប់នោះ។

ចំណែកមាតាបិតាវិញ ត្រូវអនុគ្រោះកូនដោយស្ថាន៥យ៉ាងគឺ៖

• ហាមឃាត់កូនមិនឲ្យធ្វើនូវអំពើអាក្រក់ មានហាមកូនមិនឲ្យសម្លាប់សត្វ មិនឲ្យលួចទ្រព្យគេ មិនឲ្យប្រព្រឹត្តខុសក្នុងបុត្រភរិយាគេ មិនឲ្យនិយាយភូតកុហក និងមិនឲ្យផឹកនៅទឹកស្រវឹង ដែលជាហេតុនាំឲ្យបាត់នៅសតិស្មារតី។

• ឲ្យកូនប្រព្រឹត្តនូវអំពើជាកុសលផ្សេងៗ មានការឲ្យទាន និងការរក្សាសីលជាដើម... ។ល។

• ឲ្យកូនរៀនសិក្សាសិល្បៈវិជ្ជា មានលេខនិងអក្សរ និងវិជ្ជាសម្រាប់ចិញ្ចឹមជីវិត ទៅតាមការវេលា។

• រៀបចំឲ្យកូនមានស្វាមីឬភរិយា សមគួរទៅដល់ជាតិត្រកូល និងទ្រព្យសម្បត្តិ។

• ឲ្យទ្រព្យដល់កូនក្នុងសម័យពីរយ៉ាង គឺនិច្ចសម័យមួយ និងកាលសម័យមួយ។ និច្ចសម័យគឺឲ្យទ្រព្យរឿយៗ ឲ្យកូនចាយវាយប្រើប្រាស់តាមសមគួរ ឬឲ្យដើម្បីធ្វើអំពើជាកុសលណាមួយ កាលសម័យគឺឲ្យក្នុងពេលកូនមានភរិយា ឬស្វាមី ឬឲ្យក្នុងកាលដែលខ្លួនជិតដល់មរណភាព។

**២.ទិសខាងត្បូង**

គ្រូអាចារ្យទុកដូចជាទិសខាងត្បូង សិស្សត្រូវប្រតិបត្តិដោយស្ថានកិច្ច៥យ៉ាង៖

- ដោយកិរិយាធ្វើនូវការក្រោកឡើងទទួល បើសិស្សកំពុងអង្គុយក្នុងទីណាមួយ ដែលមិនមានបុគ្គលជាធំជាងគ្រូអាចារ្យ ហើយបានឃើញគ្រូអាចារ្យមកកាន់ទីនោះ សិស្សត្រូវក្រោកឡើងទទួល។ បើលោកមានបរិក្ខារអ្វី យើងត្រូវទទួលអំពីដៃលោក ត្រូវរកទឹកលាងជើង រកក្រណាត់ជូតជើង រកទីអាសនៈដើម្បីជូនលោក លុះលោកអង្គុយចុះហើយ ទើបយើងអង្គុយទៅតាមក្រោយ។ បើលោកក្រោកលាទៅវិញ យើងត្រូវក្រោកឈរជូនដំណើរលោក យ៉ាងជិតបំផុតក៏ត្រឹមមាត់ទ្វាររបងដែរ។

- ដោយកិរិយាចូលទៅបំរើគ្រូអាចារ្យ ក្នុងមួយថ្ងៃ៣ដង គឺវេលាព្រឹក ថ្ងៃត្រង់ និងល្ងាច ….។ល។

- ជឿស្តាប់ពាក្យឱវាទរបស់គ្រូអាចារ្យ ដែលលោកបានពោលទូន្មាន ប្រៀនប្រដៅយើងឲ្យធ្វើនូវអំពើល្អ គ្រប់បែបយ៉ាង។

- ដោយការបំរើផ្សេងៗ មានឲ្យឈើស្ទន់(ឈើសម្រាប់សំអាតធ្មេញ) និងទឹកលុបលាងមុខជាដើម។

- រៀនដោយយកចិត្តទុកដាក់ នូវសិល្បសាស្ត្រ និងចំណេះវិជ្ជាផ្សេងៗ អំពីគ្រូអាចារ្យ ដោយគោរពនឹងយកចិត្តទុកដាក់ គឺរៀនទៅតាមសមគួរ ដល់កម្លាំងប្រាជ្ញារបស់ខ្លួន ហើយខំស្វាធ្យាយទន្ទេញ ដរាបដល់ចាំចូលចិត្ត។

ចំណែកគ្រូអាចារ្យ ត្រូវអនុគ្រោះសិស្សដោយស្ថាន៥យ៉ាងគឺ៖

- អប់រំទូន្មានប្រៀនប្រដៅសិស្សដោយល្អ គឺទូន្មានឲ្យសិស្សចេះរៀបចំឥរិយាបទទាំងបួន រៀនដេក ដើរ ឈរ អង្គុយ នឹងទូន្មានហាមប្រាមមិនឲ្យសិស្ស សេពគប់បាបមិត្ត ណែនាំពន្យល់ឲ្យសិស្សសេពគប់ នូវកល្យាណមិត្តនិងសប្បុរសទាំងឡាយ។

- បង្ហាត់បង្រៀនសិស្សដោយល្អ គឺបង្ហាត់ដោយត្រឹមត្រូវ ទៅតាមអត្ថនិងព្យញ្ជនៈ ទៅតាមរបៀបពាក្យរបៀបសេចក្តី ដើម្បីឲ្យសិស្សងាយយល់ចាំចូលចិត្ត។

- ពោលពាក្យលើកសសើរ ចំពោះសិស្សដែលរៀនពូកែ មានកិរិយាមារយាទល្អនោះឲ្យបានច្បាស់ពិតប្រាកដ នៅចំពោះមុខមិត្ត អាមាត្យ និងមហាជន។

• ការពាររក្សាសិស្សក្នុងទិសទាំងឡាយ គឺថាឲ្យសិស្សសិក្សារៀនសិល្បសាស្ត្រ ចំណេះវិជ្ជាមិនឲ្យទើសទាល់ ក្នុងវេលាដែលសិស្ស ចេញទៅចញ្ចឹមជីវិតនៅក្នុងទិសនោះៗ(ពុំលាក់ចំណេះ)។

**៣.ទិសខាងលិច**

ទិសខាងលិចទុកដូចជាភរិយានិងបុត្រ ស្វាមីគប្បីអនុគ្រោះដោយស្ថាន៥យ៉ាងគឺ៖

• មានសេចក្ដីស្រឡាញ់រាប់អានទៅរកភរិយា ដោយសម្ដីទន់ផ្អែម
• ដោយកិរិយាមិនបៀតបៀន មិនមើលងាយភរិយា ដូចទាសកម្មករ
• ដោយកិរិយាមិនប្រព្រឹត្តកន្លងចិត្ត គឺក្បត់ចិត្តភរិយា
• ដោយប្រគល់នូវឥស្សរិយស គឺភារៈជាធំក្នុងការចាត់ចែង ប្រាយទឹកនំចំណីភោជនីយហារ និងកិច្ចផ្សេងៗទៀតផ្ដាច់មុខឲ្យទៅភរិយា។
• ផ្គត់ផ្គង់នូវគ្រឿងប្រដាប់តាក់តែងរាងកាយ ដល់ភរិយាតាមសមគួរ ដល់សម្បត្តិរបស់ខ្លួនដែលមាន។

ចំណែកភរិយាវិញ ត្រូវទំនុកបម្រុងស្វាមីដោយស្ថាន៥យ៉ាងគឺ៖

• ចាត់ចែងការងារ មានការចម្អិនម្ហូបអាហារ មានប្រាយទឹកបបរជាដើម ដោយផ្ចិតផ្ចង់ឲ្យត្រូវទៅតាមកាលវេលា។
• សង្គ្រោះដល់ញាតិខាងប្ដី និងញាតិរបស់ខ្លួន ដោយស្មោះស្មើមិនលំអៀង
• មិនប្រព្រឹត្តក្បត់កន្លងចិត្តស្វាមី (កិរិយាផិតក្បត់)។
• ភរិយាជាស្ត្រីឆ្លាតឈ្លាស ប្រសប់ក្នុងកិច្ចការទាំងពួង ក្នុងការងារចាត់ចែងរៀបចំផ្ទះសម្បែង និងភោជនីយអាហារជាដើម ជាអ្នកមិនខ្ជិលច្រអូសក្នុងកិច្ចការទាំងឡាយ ហើយអាចញ៉ាំងកិច្ចការទាំងពួងឲ្យសម្រេចបាន។

**៤.ទិសខាងជើង**

ទិសខាងជើងទុកដូចជាមិត្តសម្លាញ់ កុលបុត្រត្រូវទំនុកបម្រុងដោយស្ថាន៥យ៉ាងគឺ៖

• ឲ្យទ្រព្យដែលគួរឲ្យដល់មិត្តសម្លាញ់
• ពោលពាក្យសម្ដីពីរោះ ផ្អែមល្ហែមទៅរកមិត្ត

- ប្រព្រឹត្តធ្វើនូវប្រយោជន៍ ឲ្យកើតដល់មិត្តទាំងផ្លូវលោក ទាំងផ្លូវធម៌
- ដោយភាវៈជាអ្នកមានចិត្តស្មើទៅរកមិត្ត(មិនស៊ីលើស៊ីក្រោម)
- ដោយមិនក្លែងពោលពាក្យ មិនពិតដល់មិត្ត

ចំណែកខាងមិត្តសម្លាញ់ត្រូវអនុគ្រោះ កុលបុត្រវិញដោយស្ថាន៥យ៉ាងគឺ៖

- ជួយថែរក្សាមិត្ត ដែលបានប្រព្រឹត្តភ្លាំងភ្លាត់ ឬធ្វេសប្រហែស
- ជួយថែរក្សាទ្រព្យសម្បត្តិរបស់មិត្ត ដែលមិត្តបានភ្លេចភ្លាំង ធ្វេសប្រហែស
- កាលបើមិត្តមានភ័យកើតឡើង ក៏អាចជាទីពឹងពាក់អាស្រ័យដល់មិត្តបាន
- មិនលះបង់ចោលមិត្ត ពេលដែលមិត្តជួបគ្រោះភ័យ និងការក្រផ្សេងៗ
- ស្រឡាញ់រាប់អាន ពូជពង្សវង្សត្រកូលកូនចៅរបស់មិត្ត ដោយមិនរើសអើង

__៥.ទិសខាងក្រោម__

ទិសខាងក្រោមទុកដូចជាបាវព្រាវឬកម្មករ ដែលជាអ្នកធ្វើការឈ្នួល ចៅហ្វាយនាយគប្បីអនុគ្រោះ ទំនុកបម្រុងដោយស្ថាន៥យ៉ាងគឺ៖

- ចាត់ចែងនូវការងារឲ្យកម្មករធ្វើ ទៅតាមសមគួរដល់កម្លាំងកាយ ឬបញ្ញានៃកម្មករ គឺដាក់ការងារទៅតាមកម្លាំងក្មេង ចាស់ ប្រុស ស្រី។
- ឲ្យនូវបាយទឹកនំចំណី ប្រាក់ឈ្នួលបំណាច់ ទៅតាមសមគួរទំនងសាច់ការដែលត្រូវឲ្យ
- មានការថែរក្សាព្យាបាលរោគ កាលដែលពួកគេមានជំងឺ ហើយមិនបៀតបៀន ឲ្យធ្វើការអ្វីឡើយ នៅក្នុងពេលដែលឈឺនោះ។
- ចែករំលែកនៅម្ហូបចំណី ដែលមានរសឆ្ងាញ់ពិសា ឲ្យដល់កម្មករបានបរិភោគ
- បើកឱកាសឲ្យកម្មករបានឈប់សម្រាក ពីធ្វើការក្នុងនិច្ចសម័យ កាលបើដឹងថា ទាសកម្មករធ្វើការហត់នឿយពេញមួយថ្ងៃ ឲ្យគ្នាបានឈប់សម្រាកកម្លាំង ឬក៏ឲ្យឈប់សម្រាកក្នុងថ្ងៃបុណ្យទានផ្សេងៗ មានបុណ្យភ្ជុំបិណ្ឌ ចូលឆ្នាំជាដើម...។ល។

ចំណែកខាងបាវព្រាវនិងមនុស្សធ្វើការឈ្នួល ត្រូវយកចិត្តទុកដាក់បំពេញកិច្ចការ តបទៅចៅហ្វាយនាយវិញ ដោយស្ថាន៥យ៉ាងគឺ៖

- ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ
- ឈប់ធ្វើការងារក្រោយចៅហ្វាយនាយ
- មិនលួចឬកេង យកទ្រព្យសម្បត្តិរបស់ចៅហ្វាយនាយ យកតែទ្រព្យសម្បត្តិណា ដែលចៅហ្វាយនាយឲ្យ ជាគុណបំណាច់ឬប្រាក់ថ្លៃឈ្នួល
- ធ្វើការងារឲ្យចៅហ្វាយនាយ ដោយយកចិត្តទុកដាក់ផ្ចិតផ្ចង់ គឺមិនធ្វេសប្រហែស
- នាំយកសេចក្ដីល្អរបស់ចៅហ្វាយនាយ ទៅពោលសសើរក្នុងទីដែលខ្លួនត្រូវនិយាយ។

**៦.ទិសខាងលើ**

ទិសខាងលើទុកដូចជាសមណព្រាហ្មណ៍ កុលបុត្រជាគ្រហស្ថគឺអ្នកគ្រប់គ្រងផ្ទះ ត្រូវផ្គត់ផ្គង់ដោយស្ថាន៥យ៉ាងគឺៈ

- គ្រហស្ថត្រូវប្រព្រឹត្តដោយកាយកម្ម(អំពើធ្វើដោយកាយ) ប្រកបទៅដោយមេត្តា គឺថាធ្វើនៅកិច្ចដោយទៅនិមន្តលោកដល់វត្ត និងទទួលយកចម្ពក្រកទៅដងទឹកប្រគេនលោក នឹងជួយគក់ច្របាច់ ជាដើម ដោយសេចក្ដីរាប់អាន ដោយស្មោះអស់ពីដួងចិត្ត។
- គ្រហស្ថត្រូវប្រព្រឹត្តដោយវចីកម្ម(អំពើធ្វើដោយវាចា) គឺពោលពាក្យប្រកបដោយមេត្តាមានការពោលពាក្យដាស់តឿនដល់អ្នកដទៃ ឲ្យចេះធ្វើទានដល់សមណព្រាហ្មណ៍ ចេះបន្លឺនូវសព្ទសាធុការ ក្នុងពេលស្ដាប់ធម្មទេសនាចប់ និងធ្វើនូវបដិសណ្ឋារកិច្ច ដោយសម្ដីរាក់ទាក់ជាដើម ក្នុងការរាប់អាន ដោយស្មោះត្រង់អស់ពីចិត្ត។
- គ្រហស្ថត្រូវប្រព្រឹត្តដោយមនោកម្ម(អំពើធ្វើដោយចិត្ត) ប្រកបដោយមេត្តា គឺការធ្វើនូវកិច្ចដោយចិត្តគិតថា ព្រះថេរៈទាំងឡាយ ដែលលោកនិមន្តមកកាន់ត្រកូលរបស់យើង សូមឲ្យលោកបាននូវសេចក្ដីសុខ ដោយសេចក្ដីរាប់អានដ៏ស្មោះចេញពីដួងចិត្ត។
- ដោយភាពជាអ្នកមិនបិទទ្វារផ្ទះ គឺមិនកំណាញ់ មិនត្អូញត្អែរ ពេលឃើញសមណព្រាហ្មណ៍មកដល់ ក៏ឲ្យនៅទានតាមសមគួរ ដល់ទ្រព្យធននិងពេលវេលា។
- ដោយកិរិយាឲ្យនូវអាមិសទាន គឺភោជនីយហារ មានបង្អែមនិងចម្អាបជាដើម ដល់សមណព្រាហ្មណ៍ ដែលបាននិមន្តមកដល់នោះ។

ចំណែកសមណព្រាហ្មណ៍ ត្រូវអនុគ្រោះកុលបុត្រ ដោយស្ថាន៦យ៉ាងគឺៈ

- ហាមឃាត់កុលបុត្រ វៀរចាកអំពើអាក្រក់
- ពន្យល់កុលបុត្រ ឲ្យប្រព្រឹត្តតម្កល់ចិត្តក្នុងអំពើល្អ(កុសល)
- អនុគ្រោះដល់កុលបុត្រដោយចិត្តល្អ គឺតាំងចិត្តផ្សាយនូវព្រហ្មវិហារធម៌
- បំភ្លឺអត្ថសេចក្តីក្នុងធម៌ ដែលកុលបុត្របានស្តាប់ហើយ ឲ្យកាន់តែយល់ច្បាស់ភ្លឺថ្លូរផង់ឡើងថែមទៀត។
- ប្រាប់ផ្លូវដល់កុលបុត្រ ក្នុងការប្រព្រឹត្តបុញ្ញកិរិយាទាំង១០ ដែលជាធម៌នាំទៅកាន់សុគតិភព ដោយអំណាចទាន សីល សមាធិ បញ្ញា...។ល។

ចំណែកឯទិសបង្កប់ទៅដោយប្រស្នា ដែលមានក្នុងព្រះពុទ្ធសាសនាគឺ៖

១.ពេលដែលព្រាហ្មបានថ្វាយស្បូវក្តាំង ព្រះអង្គបានយកស្បូវនោះទៅក្រាល ពីទិសខាងជើង ពីទិសខាងលិច ពីទិសខាងត្បូងដើមពោធិព្រឹក្ស រតនៈបល្ល័ង្កពុំបានផុសឡើងឡើយ លុះត្រាតែព្រះអង្គយកស្បូវក្តាំងនោះ ទៅក្រាលពីទិសខាងកើតដើមពោធិព្រឹក្ស ទើបផែនដីរញ្ជួយផុសឡើងនៅរតនៈបល្ល័ង្កនេះ តើហេតុអ្វីបានជាទិសខាងលិច ទិសខាងត្បូង ទិសខាងជើង មិនអាចផុសរតនៈបល្ល័ង្ក ហើយបែរជាផុស ក្នុងទិសខាងកើតទៅវិញ?

២.ពេលដែលព្រះអង្គរៀបនឹងបរិនិព្វាន ព្រះអង្គបានផ្ទំនៅចន្លោះដើមសាលព្រឹក្សទាំងគូ ព្រះអង្គបានដាក់ព្រះសិរិសាទៅទិសខាងជើង ដាក់ព្រះបាទទៅទិសខាងត្បូង និងបែរព្រះភ័ក្ត្រទៅទិសខាងលិច តើហេតុដូចម្តេចបានជាព្រះអង្គ បន្សល់ទុកនូវឥរិយាបទដូច្នេះ? ហេតុដូចម្តេចបានជាព្រះអង្គមិនដាក់សិរិសា ព្រះបាទ និងព្រះភ័ក្ត្រទៅទិសផ្សេង?

**ខ.អត្ថន័យទិសក្នុងព្រហ្មញ្ញសាសនា**

**១.ទិសឦសាន្ត**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសឦសាន្តគឺជាលំនៅរបស់ព្រះអាទិត្យ។

**២.ទិសបូព៌**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសបូព៌គឺជាលំនៅរបស់ព្រះច័ន្ទ។

**៣.ទិសអគ្នេយ៍**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសអគ្នេយ៍គឺជាលំនៅរបស់ព្រះអង្គារ។

**៤.ទិសទក្សិណ**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសទក្សិណគឺជាលំនៅរបស់ព្រះពុធ។

**៥.ទិសនិរតី**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសនិរតីគឺជាលំនៅរបស់ព្រះសៅរ៍។

**៦.ទិសបស្ចិម**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសបស្ចិមគឺជាលំនៅរបស់ព្រះព្រហស្បតិ៍។

**៧.ទិសពាយព្យ**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសពាយព្យគឺជាទីលំនៅរបស់ព្រះរាហូ។

**៨.ទិសឧត្តរ**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសឧត្តរគឺជាលំនៅរបស់ព្រះសុក្រ។

**គ.អត្ថន័យទិសបង្កប់ក្នុងពាក្យខ្មែរ**

ទិសនៅក្នុងន័យរបស់ខ្មែរ ដូនតាលោកបានបង្កប់ទុកក្នុងពាក្យតែម្តង ។

១.ទិសខាងកើតជាភាសាខ្មែរ ភាសាបាលីគឺទិសបូព៌ ពាក្យថាខាងកើតគឺមានន័យថា អ្វីដែលកើតចេញពីភាពងងឹត(យប់) គឺភ្លឺ។ ក្នុងន័យពាក្យកើត គឺស្មើនឹងតាំងឡើង រះឡើង ឧបត្តិកឡើង... មិនថាជាសភាវៈល្អឬអាក្រក់ឡើយ។ នេះជាន័យត្រង់ ដែលបញ្ជាក់ប្រាប់ពីន័យពិតរបស់ទិសនេះ គឺដូនតាយើងគាត់ពុំបានលាក់លៀមឡើយ។

២.ទិសខាងលិចជាភាសាខ្មែរ ភាសាបាលីគឺទិសបស្ចិម ភាសានិយាយយើងច្រើន និយាយ ថា ឡិច = លិច។ ពាក្យថាខាងលិច គឺបានន័យថាលិចចុះ រលត់ចុះ បាត់ចេញពីខ្សែភ្នែកឬស្លាប់។ កើតគឺផុយនិងលិច កើតផុយនិងស្លាប់ ន័យត្រង់របស់ពាក្យលិចនេះ ដូនតាលោកចង់ប្រាប់យើងថា អ្វីដែលកើតមានហើយ តែងតែរលត់ចុះវិញជាធម្មតា នេះជាធម្មៈ។

៣.ទិសខាងត្បូងជាភាសាខ្មែរ ភាសាបាលីគឺទិសទក្ខិណាពាក្យថាខាងត្បូង មានន័យថា ក្បាល។ ព្រោះពាក្យត្បូងស្មើនឹងក្បាល ឬស្មើនឹងកែវវិសេសម្យ៉ាង ដូនតាយើងគាត់ចង់ប្រាប់ថា ទិស នេះគឺជាទិសដំណេក ទើបដូនតាយើងចងក្រងជាសុភាសិតមួយទុកថា **ត្រពាំងពីទិសខាងត្បូង អណ្ដូងពីទិសខាងលិច គោក្រយ៉ៅក្រឡាច់ ស្ត្រីដោះញ្ញ ត្បាល់ដើមដូង អន្លង់ពងទ្រ ខ្ញុំឆ្ងាសម្បុរបីធ្វើម្ដេចអាចជួយអ្នកបាន**។ ក្នុងន័យសុភាសិតនេះ គាត់បានប្រាប់ន័យប្រស្នា ដែលបង្កប់ ក្នុងទិសរបស់ខ្មែរ។

៤.ទិសខាងជើងជាភាសាខ្មែរ ភាសាបាលីគឺទិសឧត្តរ ពាក្យថាខាងជើងគឺផ្ទុយពីក្បាល គឺផ្នែកខាងក្រោមក្បាលគឺជើង នេះជាន័យត្រង់បង្កប់ក្នុងទិសរបស់ខ្មែរ។

តាមការបកស្រាយពន្យល់ដោយសង្ខេប អំពីទិសក្នុងន័យព្រះពុទ្ធសាសនា ព្រហ្មញ្ញសាសនា និងក្នុងន័យខ្មែរ យើងអាចស្វែងយល់ដល់ទំនាយ របស់ដូនតាខ្មែរ ដែលបានព្យាករណ៍ទុកមកថា នឹងមានអ្នកមានបុណ្យមកពីទិសខាងលិច(ឡិច)។ បើយើងមើលតាមការពន្យល់ របស់ព្រះសម្មាសម្ពុទ្ធ ដល់សង្គាលកបុត្រនោះ ទិសខាងលិចទុកដូចជាភរិយា និងបុត្រ ព្រោះពេលក្លាយជាភរិយា និងវិវឌ្ឍន៍ក្លាយជាម្ដាយគេ។ ទិសខាងលិចវាផ្ទុយពីទិសខាងកើតៗគឺរះឡើង ទិសខាងលិចគឺលិចចុះ (មើលការពន្យល់ន័យខ្មែរខាងលើ)។ ប្រស្នាដែលគាត់បានប្រាប់បង្ហាញយើងថា អ្នកដែលកកើតទឹកដីនេះ ទុកដូចមាតាបិតា ឯអ្នកដែលលិចចុះ គឺភរិយា ពុំមែនឪពុកឬស្វាមីទេ តើព្រោះហេតុអ្វី? ក្នុងបណ្ដាទិសទាំង៦ ក្នុងន័យព្រះពុទ្ធសាសនា ឥតមានទិសដែលតំណាងឲ្យស្វាមីទេ គឺមានតែទិស តំណាងឲ្យភរិយា។ ចំណុចនេះយើងគួរឆ្ងល់ថា ទិសខាងកើតទុកដូចមាតាបិតា(ឪពុកម្ដាយ ឬម៉ែឪ) ទិសខាងលិចហេតុអ្វីមានតែភរិយានិងបុត្រ បាត់ប្ដី ឬស្វាមីទៅណា? ក្នុងបណ្ដាំមាតាមហានគរ ទាំង៣ភាគមុន ឪពុកនិងកូនគាត់បានព្យួរទោស នៅខាងក្រៅឃុំ មានតែម៉ែទេដែលសុខចិត្តយកទោស របស់ឪពុកនិងកូនមកទទួលតែម្នាក់ឯង។ ដូច្នេះពាក្យថាអ្នកមានបុណ្យងើបពីទិសខាងលិច ឬចេញពីទិសខាងលិច គឺមាតាអ្នកបង្កើតនគរនេះឯង ដែលតំណាងឲ្យព្រះម៉ែ មហេសីរាជនី ដែលលោកបានបំពេញបុណ្យ សុខចិត្តធ្វើជាប្រេត ជាបិសាច(មើលឯកសារជីវិតាក្ខាន់)។ ដើម្បីធ្វើជាឬសកែវ ឬដូងកែវ រក្សានគរនេះឲ្យនៅគង់វង្ស រហូតទោសនិងបាបកម្ម របស់គាត់ឲ្យផលអស់ តើសព្វថ្ងៃនេះ មានស្ត្រីតាំងខ្លួនជាម៉ែប៉ុន្មាននាក់ ដែលហ៊ានធ្វើពលិកម្មធ្វើជាប្រេត បិសាចដើម្បីរក្សាទឹកដីមាតុភូមិនេះ? គឺពុំងាយនឹងរកស្ត្រី ដែលមានចិត្តហ៊ានលះបង់ដូច្នេះបានឡើយ គឺមាន

តែព្រះម៉ែទេ ដែលលោកសុខចិត្ត រងទុក្ខវេទនាតែម្នាក់ឯងយ៉ាងនេះ ដូចជាព្រះបរមពោធិសត្វ ដែលខំសន្សំបារមីរាប់អសង្ខេយ្យផែនដី ដែលជាបញ្ញាធិកគឺសន្សំបារមី២០អសង្ខេយ្យ សទ្ធាធិកសន្សំបារមី៤០អសង្ខេយ្យ វិរិយធិកសន្សំបារមី៨០អសង្ខេយ្យផែនដី តើសត្វធម្មតាណាអាចធ្វើបាន គឺមានតែព្រះអង្គទេ ដែលសុខចិត្តហែលកាត់មហាសមុទ្រសង្សារវដ្ដ ព្រោះហេតុតែករុណាដល់សព្វសត្វ ( ១អសង្ខេយ = ១ដាក់សូន្យពីខាងក្រោយ ១៤០សូន្យ)។

យ៉ាងណាមិញព្រះម៉ែមហានគរ លោកគ្រាន់តែជាចំណែកមួយនៃព្រះពោធិសត្វ លោកបានបំពេញនូវបុណ្យបារមី ដើម្បីឲ្យបានជាព្រះពុទ្ធមាតា(ម្ដាយព្រះពុទ្ធ) សម្រាប់ព្រះពុទ្ធអង្គណាមួយ ទៅអនាគតជាតិ។ ប្រស្នាទំនាយដែលអ្នកប្រាជ្ញបុរាណខ្មែរ បានទាយលាក់បង្កប់ទុកទៅក្នុងទិស គឺជាប្រស្នាមានជម្រៅដ៏ក្រៃលែង យើងមិនអាចរកឃើញចម្លើយ ដោយពុំបានសិក្សាស្ដីពីទិស ក្នុងគម្ពីរព្រះសម្មាសម្ពុទ្ធបានឡើយ ព្រោះដូនតាយើងបានយករឿងខ្លួន ទៅបង្កប់ទុកក្នុងព្រះពុទ្ធសាសនា។

## VII.អំពីអត្ថន័យបង្កប់ក្នុងផ្កាយ

ចំពោះផ្កាយដែលរះក្នុងលំហរអាកាសឬលើមេឃ បើយើងពុំបានយកមក រែកញែកពិចារណាទេ យើងក៏មិនអាចស្វែងយល់ ក្នុងមរតកអច្ឆរិយនេះបានឡើយ តើព្រោះហេតុអ្វី? ដោយអាថ៌កំបាំងក្នុងលេខខ្មែរ រាប់បានតែត្រឹមលេខ៩(មើលការពន្យល់ពីលេខ) នេះជាតឹកតាងបង្ហាញថា ខ្មែរជាពូជពង្សផ្កាយ។ យើងតែងមើលឃើញ ភាគច្រើននៃប្លង់ប្រាសាទខ្មែរ គឺតែងតែមានប្រាង្គប្រាសាទ៥ ហើយប្រាង្គទី៥តែងនៅចំកណ្ដាល មានប្រាង្គទាំង៤អមជុំវិញ។ ហើយប្លង់រួមទាំងមូលរបស់ប្រាសាទ តែងតែមានដីពូនចាក់ជារាងយោនី(ភេទស្ត្រី) ដោយមានគូទឹកព័ទ្ធជុំវិញ។ ដោយគាត់ខ្លាចកូនខ្មែរ ជំនាន់ក្រោយមើលពុំយល់ ទើបគាត់បានឆ្លាក់យោនីឬទ្វារមាស ដែលមានកង៥គ្រាប់នៅជាប់ពីខាងក្នុង ទុកនៅបាតស្ទឹងភ្នំគូលែន (មើលការពន្យល់រូបក្នុងលេខ១០)។ បណ្ដាំផ្ទៃដែលជាភាសាគនេះ ដូនតាចង់ឲ្យយើងជាកូននាគ ដោះប្រស្នាភាសាគឬភាសាក្ដាមរបស់គាត់ បើកូននាគដោះចេញ នឹងដឹងសាវតាខ្លួនជាពូជផ្កាយ បើដោះមិនចេញទេ គឺមិនអាចដឹងឬសគែរជាពូជផ្កាយបានឡើយ។ បើយើងយកគ្រាប់ទាំង៥មករាយ ឲ្យមានលំនាំដូចម្រាមដៃ កុំឲ្យមានគ្រាប់ណាមួយជាប់ក្នុងឃុំ រួចយើងគូសបន្ទាត់ភ្ជាប់គ្រាប់ពីមួយទៅមួយ យើងនឹងបានឃើញរូបរាងផ្កាយកើត

ឡើង បង្ហាញពីសាវតាលេខ៥នេះជាពុំខាន។ នេះជាហេតុដែលនាំឲ្យ លេខរាយក្មេរមានត្រឹមលេខ៥ អប្សរារាំបង្ហាញម្រាម៥ ប្រាសាទភាគច្រើនមានកំពូល៥ រីឯរូបភាពនៅក្នុងរង្វង់មូល តំណាងឲ្យប្រក្រតីទិនរបស់ជនជាតិម៉ាយ៉ាន នៅប្រទេសម៉ិចស៊ិកូ ក៏មានកង៥នៅពីខាងក្រោម រូបក្បាលដែលមានលានអណ្ដាត ហើយជាប់ឃុំក្នុងរង្វង់កង៥ព័ទ្ធជុំវិញ។ បានន័យថាបុព្វជូនតា នៃជនជាតិម៉ាយ៉ាននេះ ពួកគេសុទ្ធតែជាពូជផ្កាយដូចយើងដែរ ហើយសុទ្ធតែជាអ្នកជាប់ឃុំ ប៉ុន្តែអ្នកស្នងមរតកជំនាន់ខាងក្រោយ នៃក្រុមប្រាសាទដែលទាក់ទងនឹងផ្កាយទាំងនោះ ពុំបានដឹងពីបំណងរបស់អ្នកជំនាន់មុនឡើយ ថាតើពួកគាត់ចង់បានអ្វីពីខ្លួន ដែលពួកគាត់បានសរសេររៀបរាប់ ទុកក្នុងភាសាគ (ភាសារូប)ទាំងនោះ?

**ក.ផ្កាយក្រពើ**

ផ្កាយក្រពើនេះ តែងតែរះឡើងនៅទិសខាងជើង បើមើលការផ្គុំរូបរាងទ្រង់ទ្រាយរបស់វា គឺពុំដូចជាសត្វក្រពើឡើយ វាដូចជាសត្វនាគបើកវែក(ពពារ) ឬដូចជារាងខ្លែងដែលគេបង្ហោះ តើហេតុអ្វីបានជាដូនតាយើង ហៅផ្កាយនេះថាផ្កាយក្រពើ? ពួកអ្នកស្រាវជ្រាវ រុករកអាថ៌កំបាំងប្រាសាទនៅលើពិភពលោក(Discovery) បានផ្គុំពួកប្រាសាទនៅតំបន់អង្គរ ដែលមានប្រាសាទអង្គរតូចជាក្បាល និងប្រាសាទបន្ទាយសំរែជាកន្ទុយ បង្កើតបានជារាងសត្វនាគមួយ ឬរាងខ្លែងមួយ ដែលរាងនេះ ដូចជាផ្កាយក្រពើសព្វថ្ងៃ។ ពួកគេឆ្ងល់ថា ជនជាតិខ្មែររាប់ពាន់ឆ្នាំមុន ធ្វើប្រាសាទនៅលើដី ហេតុអ្វីឆ្លុះទៅនឹងផ្កាយលើមេឃ? ចម្លើយគឺបានត្រឹមតែឆ្ងល់តែប៉ុណ្ណោះ ព្រោះពួកគេអ្នកស្រាវជ្រាវ ពុំមែនជាខ្មែរ ពុំមែនជាពូជផ្កាយ ពុំមែនជាពូជអច្ឆរិយ...។ល។ ចំពោះការស្រាវជ្រាវរបស់ខ្ញុំបាទវិញ ខ្ញុំឆ្ងល់ថាផ្កាយនេះជាផ្កាយនាគ ឬផ្កាយខ្លែងទិសខាងជើង ហេតុអ្វីបានជាដូនតាហៅថាផ្កាយក្រពើ ព្រោះក្នុងច្បាប់បុរាណខ្មែរ សត្វក្រពើជានិមិត្តរូប តាងឲ្យមនុស្សរមិលគុណ គឺមិនដឹងគុណ។ ក្នុងច្បាប់ធម្មជាតិសត្វដែលរមិលគុណ ចិត្តមិនអាចទៅបដិសន្ធិឬកើត នៅឋានផ្កាយឬទេវលោកបានឡើយ គឺមានតែធ្លាក់ចុះឬច្យុតិ ទៅទីទាបគឺអបាយភូមិ ហេតុអ្វីបានជាសត្វក្រពើ អាចកើតជាផ្កាយបាន? ចម្លើយន័យប្រស្នាផ្កាយក្រពើនេះ យើងទៅមើលការបកស្រាយ នៅក្នុងល្បែងប្រស្នាចាក់ទឹកដូងលើកទី១ ទើបស្រាយនូវចម្ងល់នេះបាន។

ចាក់ទឹកដូងពីទ្រូងម៉ែ **កន្ទុយខ្លែងក្មេរពាក់ក្បាលក្រពើ**

ក្រពើជិះសេះខ្ញុំជិះដំរី ក្រពើចង់ឆីខ្ញុំឡើងផ្ទះ

ក្រពើត្របាក់ ខ្ញុំប្រឹងរុល

ក្រពើភ្នែកទុល ខ្ញុំញីម្ទេស។

តើឲ្យផ្កាយនេះមានឈ្មោះថាផ្កាយនាគ ឬផ្កាយខ្លែងម៉ែម្តេចបាន? បើកូននាគបានយកក្បាលក្រពើ គឺក្បាលមិនដឹងគុណ ទៅពាក់ពីលើក្បាលនាគទៅហើយនោះ ធ្វើម្តេចផ្កាយនោះអាចមានឈ្មោះជាផ្កាយនាគ ឬផ្កាយខ្លែងទិសខាងជើងបាន? ផ្កាយខ្លែង មានផ្កាយខ្លែងទិសខាងជើង ទិសកណ្តាល និងទិសខាងត្បូង។ ក្រៅពីផ្កាយខ្លែងទិសខាងជើង ផ្កាយខ្លែងដទៃទៀតពុំមានកន្ទុយឡើយ គឺមានតែផ្កាយខ្លែង ទិសខាងជើងមួយតែប៉ុណ្ណោះ ដែលមានកន្ទុយ។ ដូច្នេះហើយទើបម្ចាស់សំណង់ប្រាសាទ ដែលមានមុនខ្មែរ ហើយសំណង់ប្រាសាទទាំងនោះ ឆ្លុះទៅនឹងផ្កាយលើមេឃ ដែលអ្នកជំនាន់ក្រោយរបស់ពួកគេ ត្រូវដាច់តំណឹងតំណរបស់ដូនតាខ្លួន ព្រោះនិមិត្តរូបផ្កាយខ្លែងគ្មានកន្ទុយ ព្រោះកន្ទុយតំណាងឲ្យ អ្នកជំនាន់ក្រោយរបស់ខ្លួន។ ចំណែកឯខ្មែរយើង ផ្កាយខ្លែងទិសខាងជើងមានកន្ទុយ ព្រោះអ្នកទទួលតំណមរតកអច្ឆរិយ នៅសល់កេរមរតកពូជផ្កាយ គឺព្រះពុទ្ធសាសនាឬពូជនាគ ដែលធ្វើឲ្យកូននាគសម័យក្រោយ អាចបើកនៅគម្របអាថ៌កំបាំងនេះបាន។ ពេលនេះផ្កាយក្រពើ ត្រូវបានបើកអាថ៌កំបាំងហើយ តើកូននាគត្រូវហៅផ្កាយនេះ ថាផ្កាយក្រពើឬក៏ផ្លាស់ឈ្មោះមកជាផ្កាយនាគ ឬផ្កាយខ្លែងទិសខាងជើងវិញ? ពេលដែលកូននាគ ទទួលស្គាល់ខ្លួនឯងជាពូជនាគ ក្បាលក្រពើត្រូវតែជ្រុះចេញពីក្បាលនាគ ហើយពេលនោះពូជនាគ ដែលរស់នៅលើមាតុភូមិនេះ ត្រូវឆ្លុះទៅរកផ្កាយនៅលើមេឃ ព្រោះហេតុអ្វី? បុគ្គលដែលទ្រទ្រង់នូវធម៌កតញ្ញូនិងកតវេទី ពុំអាចធ្លាក់ចុះទៅកាន់អបាយភូមិឡើយ គឺតែងតែទៅបដិសន្ធិនៅទេវលោក។ ដូចជាព្រះឥន្ទ្រាធិរាជសព្វថ្ងៃ លោកអាចកើតជាព្រះឥន្ទ្របាន កាលលោកនៅជាមឃមាណព លោកបានសម្មាទានធម៌៧យ៉ាងគឺ៖

១.ចិញ្ចឹមបីបាច់ថែរក្សាមាតាបិតាអស់មួយជីវិត

២.គោរពត្រកូលរៀមច្បងអស់មួយជីវិត

៣.ពោលពាក្យសម្តីផ្អែមល្ហែមទន់ភ្លន់អស់មួយជីវិត

៤.ឲ្យទានដល់បដិគ្គាហក:(បុគ្គល) ទាំងសមណ:ព្រាហ្ម ឬស្មូមយាចករស់មួយជីវិត

៥.លះបង់នូវពាក្យសម្តីញុះញង់បំបែកបំបាក់អ្នកដទៃអស់មួយជីវិត

៦.ពោលតែពាក្យសច្ច:ទៀងត្រង់អស់មួយជីវិត

៧.តមហាមចិត្តមិនឲ្យក្រោធខឹងអស់មួយជីវិត

ធម៌ទាំង៧យ៉ាងនេះ ដែលមឃមាណពបានសម្មាទាន និងបានប្រព្រឹត្តធ្វើហើយ នាំឲ្យគាត់បានទទួលសេចក្តីសុខ ក្នុងបច្ចុប្បន្នផងនិងទៅសោយសុខ ក្នុងបរលោកផង។ យ៉ាងណាមិញពូជនាគ ដែលជាពូជផ្កាយនៅលើមេឃ(ផ្កាយនាគ) តើគួប្រព្រឹត្តខ្លួនឲ្យជាបុគ្គលអកតញ្ញូ(ក្រពើ) ឬក៏ប្រព្រឹត្តខ្លួនឲ្យមាននូវធម៌កតញ្ញូនិងកតវេទី?

**ខ.ផ្កាយកូនមាន់**

ផ្កាយកូនមាន់នេះ ខ្ញុំបានបកស្រាយរួចម្តងហើយ នៅក្នុងភាគទី២ ដែលនិយាយអំពីរឿងបុណ្យអុំទូក អកអំបុក សំពះព្រះខែ។ ដែលលើកយកមកបកស្រាយជាបន្ថែមនេះ គ្រាន់តែចង់ឲ្យកូន នាគបានយល់ថា យើងបច្ចុប្បន្ននិមិត្តរូប គឺផ្កាយកូនមាន់ដែលជាពូជផ្កាយ រឺឯមេមាន់វិញពីមុន បានធ្លាក់ទៅរងទុក្ខក្នុងអបាយភូមិ ព្រោះហេតុតែតាំងខ្លួនជាម៉ែ(ស្ករតាំងម៉ែ)។ ឥឡូវនេះព្រះម៉ែ ដែលធ្លាក់ទៅជាប់ឃុំក្នុងអបាយភូមិនោះ បានរួចពីទុក្ខ ហើយទៅសោយនូវសម្បត្តិជាសុខ ក្នុងទេវលោកវិញហើយ គឺបដិសន្ធិក្នុងឋានផ្កាយ តើយើងជាកូនក្មេរ ដែលជាពូជពង្សខាងក្រោយរបស់គាត់ គួជេរប្រមាថគាត់(ជេរម៉ែ) មើលងាយគាត់ ឬគួរដឹងគុណគាត់ ហើយធ្វើដំណើរតាមផ្លូវគាត់បច្ចុប្បន្ននេះ។ ដូច្នេះបើយើងដឹងប្រវត្តិសាវតា ថាខ្លួនជាពូជផ្កាយ ដាច់ខាតពេលស្លាប់ទៅវិញ ក៏ជាពូជផ្កាយ បុគ្គលដែលមាននូវកតញ្ញូ ពុំធ្លាក់ទៅកាន់អបាយភូមិឡើយ។

**គ.ផ្កាយយាម**

ផ្កាយយាមនេះ បានឆ្លុះស្រមោលទៅនឹងប្រាសាទពីរ៉ាមីតទាំងបី នៅប្រទេសអេស៊ីប បើតាមមើលការស្រាវជ្រាវ របស់ពួកអ្នករុករកអាថ៌កំបាំង(Discovery)។ ពាក្យនិយាយថាយាម ន័យទីមួយគឺយាមនង្គ័ល ន័យទីពីរពេលវេលា(យាមទី១យាមទី២) ន័យទីបីគឺការពារកុំឲ្យរត់រួចឬបាត់បង់ ដូចជាពួកឆ្មាំទ្វារឬទ្វារបាល ជាអ្នកយាមទ្វារកុំឲ្យបាត់បង់ របស់ដែលមាននៅខាងក្នុង មិនថាទ្រព្យមានជីវិត ឬឥតជីវិតឡើយ ន័យទីបួនថង់សំពត់មានដៃ ឬយោគស្តាយបាន ថង់យាម ន័យទីប្រាំគឺឋាន

ស្ថគិដាន់ទី៣ គឺឋានយាមៈ ឬយាមា។ បើយើងក្រឡេកមើល ពួកប្រាសាទរាងសាជីទាំងអស់ ដែលមាននៅក្នុងពិភពលោកនេះ ទោះបីព្រះអាទិត្យតែមួយដួង ក្នុងថ្ងៃ២១ខែមីនានិង២១ខែកញ្ញា បានរះចំកណ្ដាលកំពូលពីរ៉ាមីតដ៏ច្រើន ក៏នៅតែមិនអាចឲ្យពន្លឺនៃព្រះសូរិយា ចាំងជះពន្លឺកម្ដៅចូលទៅក្នុងពីរ៉ាមីតទាំងនោះបានឡើយ នេះជាប្រស្នាសំណង់ប្រាសាទថ្ម ដែលឆ្លុះនឹងផ្កាយ។ ដូចជាសាជីដែលគ្របពីលើបាយស្រី នៅក្នុងពិធីមង្គលការ ទាល់តែមានអ្នករាំបើកគម្របសាជីឬបាយស្រី ទើបដឹងអាថ៌កំបាំងវត្ថុ ដែលនៅក្នុងគម្របសាជីនោះ ថាជាព្រះមេ (មើលការពន្យល់បាយដែលតាងឲ្យព្រះមេក្នុងភាគ១)។ យ៉ាងណាមិញប្រាសាទ មានរាងជាសាជី(ពីរ៉ាមីត) ដែលមាននៅក្នុងពិភពលោកនេះ ប្រស្នា អាថ៌កំបាំងដែលមាននៅក្នុងគម្រប ប្រាសាទរាងសាជីទាំងនោះ យើងអាចដឹងរឿងខាងក្នុងបាន លុះត្រាតែអ្នកជំនាន់ក្រោយ ព្រមចុះចូលទៅក្នុងទ្រូងម៉ែឪ ទើបអាចដឹងអាថ៌កំបាំងនៅក្នុង ទ្រូងសាជីទាំងនោះបាន។ ប្រស្នាអាថ៌កំបាំងភាសាគ ដែលអ្នកប្រាជ្ញពូជផ្កាយទាំងនោះបានទុកនៅស្នាដៃគំនិត សម្រាប់ឲ្យអ្នកជំនាន់ក្រោយរបស់ពួកគេ អាចស្រាយបំភ្លឺប្រស្នារូបបាន លុះត្រាតែអ្នកជំនាន់ក្រោយនោះ ព្រមបើកគម្រប ឬក៏ចូលទៅក្នុងទ្រូងរបស់សាជីទាំងនោះ ទើបដឹងរឿងពិតនៃម្ចាស់ប្រាសាទថ្ម។

**<u>ឃ.ផ្កាយយោង</u>**

ផ្កាយយោងនេះ បើយើងពិនិត្យតាមន័យឈ្មោះ បានបញ្ជាក់ប្រាប់យើងថា គឺទាញស្រង់យកឡើងមកខាងលើ។

**<u>ពន្យល់ពាក្យ</u>**

**យោង** ( កិ. ) កើចទាញពីខាងក្រោមមកខាងលើដោយចាប់កាន់ខ្សែឬពួរ : យោង ទឹកអណ្ដូង ។ នាំមុខ, អន្ទងពីមុខ : ដើរយោងមុខ, ជិះសេះយោងមុខគោ ។ ធ្វើឲ្យអណ្ដែតឡើង, ធ្វើឲ្យឡើងពីក្រាប : យោងមុខបូស, ព័ទ្ធបូសយោងមុខឲ្យឡើង ។ ជួយស្រោចស្រង់សង្គ្រោះ ដោយនាំមុខឲ្យបានប្រយោជន៍, ឲ្យបានស្រួល : យោងឲ្យរួចពីក្រីក្រ, យោងញាតិ, រកស៊ីយោងគ្នា, និយាយយោងគ្នា, ឆ្លើយយោងគ្នា ។ នាំយកគ្រឿងធ្ងន់ទៅមក, ទទួលបន្ទុកធ្ងន់ : យោងសម្ពាយពីរបីតែ ម្នាក់ឯង; ធ្ងន់ណាស់យោងមិនរួចទេ ។ គូសជាគំនូសឬជីកជាខ្សែទៅរកគ្នា, សរសេរឆ្លើយរកគ្នា : គូសយោង, សរសេរយោង, ដាក់លេខយោង ។ យោងខ្លួន ឬ យោងអាត្មា នាំខ្លួនឲ្យរួច, ធ្វើខ្លួនឲ្យបានសុខស្រួល ។ យោងដំណើរ ឬ យោងសេចក្ដី ធ្វើដំណើរឬសេចក្ដីឲ្យអណ្ដែតឡើង, ឲ្យច្បាស់លាស់ ។ យោងយឹត ឬ យឹតយោង ជួយឲ្យរួចពី

ទុក្ខភ័យ, ឲ្យបានរួចពីការក្រ; ជេរប្រទេចផ្តាសា បួរបាច់ឲ្យវិនាស ។ យោងអន្លង ដឹកនាំឲ្យបានរួចពីការក្រ, ណែនាំ ឲ្យកើតប្រយោជន៍ ។ ខ្យល់យោងទឹក ខ្យល់ដែលបក់យោងទឹកឲ្យឡើងឬយោងទឹកឲ្យធ្លាក់ភ្លៀង ។ អណ្តូងយោង អណ្តូងដែលជ្រៅ ដងទឹកបានតែដោយយោង ។ល។ (ដកចេញពីវចនានុក្រមសម្តេច)

**យោង** ( ន. ) ប្រដាប់សម្រាប់ដងទឹកទាញយកមកខាងលើ, ប្រដាប់សម្រាប់ទាញឡើង : យោងដងទឹក, ខ្សែយោង, ដងយោង ។(ដកចេញពីវចនានុក្រមសម្តេច)

ផ្កាយយោងនេះ បើរះនៅទិសខាងលិច(ទ្បិច) ដូនតាយើងតែងហៅថាផ្កាយចោរ បើរះនៅទិសខាងកើត ដូនតាយើងហៅថាផ្កាយព្រឹក ឬផ្កាយយោង។ ផ្កាយព្រឹកនេះហើយ ដែលមាននៅក្នុងរឿងព្រេងភ្នំប្រុសភ្នំស្រី រឿងព្រេងនេះបានបង្ហាញពី អត្ថន័យរឿងរបស់មេពីអតីត ក្នុងការកកើតរឿងរបស់ខ្លួន ពូនទៅជាភ្នំ។ កាលរះនៅពីខាងលិច មានឈ្មោះថាផ្កាយដែរ តែជាចោរ ដល់បង្វែរទិសនៅពីខាងកើត ប្រែឈ្មោះថាផ្កាយព្រឹកឬផ្កាយយោង តើយោងអ្នកណាឡើង?

**<u>ខ.រូបផ្កាយក្នុងសុរិយគតិ</u>** (ការគិតដំណើររូបផ្កាយ តាមដំណើរព្រះអាទិត្យ)

១.**មករា**(ផ្កាយរូបសត្វម្ករ) ២.**កុម្ភៈ** (ផ្កាយរូបក្អម) ៣.**មីនា** (ផ្កាយរូបសត្វត្រី) ៤.**មេសា** (ផ្កាយរូបសត្វចៀម) ៥.**ឧសភា** (ផ្កាយរូបសត្វគោ ឬក្បាលគោ) ៦.**មិថុនា** (ផ្កាយរូបមនុស្សប្រុសនិងស្រី) ៧.**កក្កដា** (ផ្កាយរូបសត្វក្តាម) ៨.**សីហា** (ផ្កាយរូបសត្វរាជសីហ៍) ៩.**កញ្ញា** (ផ្កាយរូបស្រីក្រមុំ) ១០.**តុលា** (ផ្កាយរូបជញ្ជីង) ១១.**វិច្ឆិកា** (ផ្កាយរូបសត្វខ្ទួយ) ១២.**ធ្នូ** (ផ្កាយរូបធ្នូ)។

**<u>ច.រូបផ្កាយក្នុងច័ន្ទគតិ</u>** (ការគិតដំណើរផ្កាយតាមព្រះច័ន្ទ)

១.**មិគសិរ** (ផ្កាយរូបសត្វក្តាន់) ២.**បុស្ស** (ផ្កាយរូបសត្វក្តាម) ៣.**មាឃ** (ផ្កាយរូបសត្វស្វាព្រាម) ៤.**ផល្គុន** (ផ្កាយរូបសត្វគោញីឈ្មោល) ៥.**ចេត្រ** (ផ្កាយរូបសត្វខ្លា) ៦.**ពិសាខ** (ផ្កាយរូបសត្វក្របី) ៧.**ជេស្ឋ** (ផ្កាយរូបសត្វពពែ) ៨.**អាសាឍ** (ផ្កាយរូបសត្វរាជសីឈ្មោលញី) ៩.**ស្រាពណ៍** (ផ្កាយរូបផ្កាឈើ) ១០.**ភទ្របទ** (ផ្កាយរូបរមាសញីឈ្មោល) ១១.**អស្សុជ** (ផ្កាយរូបសត្វសេះ) ១២.**កត្តិក** (ផ្កាយរូបសត្វកូនមាន់)។

**<u>ឆ.ផ្កាយប្រចាំសប្តាហ៍</u>**

ក្នុងក្បួនបុរាណ អ្នកប្រាជ្ញលោកបាន រកឃើញនៅភពទាំង៧ជាយូរលុងណាស់មកហើយ គឺមុនសម័យព្រះសម្មាសម្ពុទ្ធត្រាស់ដឹងទៅទៀត ការដឹងពីដំណើរផ្កាយទាំងនេះ គឺដោយសាការ

ចំរើន ឈានសមាបត្តិ ជាលោកីយរបស់ពួកព្រាហ្មណ៍ទាំងឡាយសម័យមុន។ អ្នកប្រាជ្ញខាងសាសនា បានដឹងភពទាំងនេះ មុនវិទ្យាសាស្ត្របច្ចុប្បន្នទៅទៀត អ្នកប្រាជ្ញសព្វថ្ងៃគ្រាន់តែ ទៅស្វែងរកតាមលំអាន អ្នកប្រាជ្ញពីបុរាណតែប៉ុណ្ណោះ។ តាមការត្រាស់សម្តែង របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានពន្យល់ថា ផ្កាយឬភព នៅក្នុងចក្រវាលនេះ មិនមានចំនួនអាចរាប់បានឡើយ (អនន្ត) ដូចជាចំនួនព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គបានត្រាស់ដឹង នឹងបរិនិព្វានហើយ ច្រើនដូចជាគ្រាប់ខ្សាច់ ដែលមាននៅក្នុងមហាសាគរយ៉ាងណា ចំនួនភពទាំងនោះក៏ដូច្នោះដែរ។ កំណើតផ្កាយ ដែលមាននៅក្នុងក្បួនហោរាសាស្ត្រខ្មែរ ដែលដកចេញពីគម្ពីរព្រហ្មញ្ញសាសនា បង្កប់ចូលក្នុងមរតកអច្ឆរិយខ្មែរ។

**<u>១.ព្រះអាទិត្យ</u>**

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះអាទិត្យឡើង ដោយយកសត្វរាជសីហ៍៦មកវាយដោយវេទ(វេទមន្ត) ឲ្យល្អិតជាផង់ ហើយហុំព័ទ្ធដោយសំពត់ ពណ៌ក្រហមចាស់ រួចប្រោះព្រំដោយទឹកអម្រឹត ក៏បង្កើតជាអង្គព្រះសូរិយា(ព្រះអាទិត្យ) ទេពនិករឡើង មានពណ៌កាយក្រហមទ្រង់ទិព្យអាភរណ៍ ឆ្មៀលឆ្វាត់ព្រោងព្រាតទៅដោយកែវបទុមរាគ ឯវិមានប្រាសាទមានពណ៌ក្រហម ទ្រង់រាជសីហ៍ជាពាហនៈ ស្ថិតនៅក្នុងទិសឦសាន្ត(ព្រះអាទិត្យមានកម្លាំង៦)។

**<u>២.ព្រះច័ន្ទ</u>**

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះច័ន្ទពីទេពកញ្ញា១៥រូប ដោយយកទេពកញ្ញាទាំង១៥ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ ហើយរុំព័ទ្ធទៅដោយសំពត់ពណ៌លឿងខ្ចី រួច ប្រោះ ព្រំដោយទឹកអម្រឹត ក៏បង្កើតបានជាព្រះច័ន្ទទេវបុត្រឡើង។មានពណ៌កាយជាពណ៌ស៊ីនួន(សម្បុរស លាយលឿង) ទ្រង់ទិព្យអាភរណ៍ កែវប្រពាលវិចិត្ត វិមានប្រាសាទមានពណ៌កែវមុក្តា ទ្រង់ អស្សរាជ(សេះ) ជាពាហនៈស្ថិតក្នុងទិសបូព៌(ព្រះច័ន្ទមានកម្លាំង១៥)។

**<u>៣.ព្រះអង្គារ</u>**

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះអង្គារពីមហិង្សា(ក្របី) ៨ រូប ដោយក្របីទាំង៨ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ ហើយរុំព័ទ្ធទៅដោយសំពត់ពណ៌ ក្រហម ស្ទើរ(ស៊ីជំពូ ឬពណ៌ទទឹម) គឺពណ៌របស់កែវពិទាយ រួចប្រោះព្រំដោយទឹកអម្រឹត ក៏បង្កើតបាន ជាអង្គព្រះអង្គារទេវបុត្រឡើង។ មានពណ៌កាយជាកែវពិទាយ ទ្រង់វត្ថកោមិនជាអាភរណ៍ មាន វិមានប្រាសាទពណ៌ទទឹមទ្រង់រាជកាសរ (ក្របី) ជាពាហនៈនៅស្ថិតក្នុងទិសអគ្នេយ៍(មានកម្លាំង៨)។

## ៤.ព្រះពុធ

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះពុធ ពីស្ដេចគជសា(ស្ដេចដំរី)១៧រូប ដោយយកដំរីទាំង១៧ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ ហើយរុំព័ទ្ធទៅដោយសំពត់ពណ៌បៃតង (ស្លឹកឈើចាស់) រួចប្រោះព្រំដោយទឹកអម្រឹត ក៏បង្កើតបានជាអង្គព្រះពុធទេវបុត្រឡើង។ មានពណ៌ កាយជាពណ៌កែវមរកត ទ្រង់ទិព្វអាភរណ៍មានវិមានពណ៌កែវមណីមានគជេន្ទ្រ (ដំរី) ជាពាហនៈស្ថិតនៅក្នុងទិសទក្សិណ (ព្រះពុធមានកម្លាំង១៧)។

## ៥.ព្រះព្រហស្បតិ៍

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះព្រហស្បតិ៍ ពីឥសី១៩រូប ដោយយកឥសីទាំង១៩ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ ហើយរុំព័ទ្ធទៅដោយសំពត់ពណ៌លឿងទុំ រួចប្រោះ ព្រំដោយទឹកអម្រឹត ក៏បង្កើតបានជាអង្គព្រះព្រហស្បតិ៍ទេវបុត្រឡើង។ មានពណ៌កាយជាកែវពិទូរ្យ (ពេជ្រភ្នែកឆ្មា) ទ្រង់ទិព្វអភរណ៍សុវណ្ណរត្នរូជី ស្មៀតដោយមុក្តាហារ មានវិមានពណ៌ស្រគាំ ឬ បុស្រាខាំ ទ្រង់ម្រិគរាជ(សត្វក្ដាន់ ឬសត្វកង្កែប) ជាពាហនៈស្ថិតនៅក្នុងបស្ចិមទិស (ព្រះព្រហស្បតិ៍ មានកម្លាំង១៩)។

## ៦.ព្រះសុក្រ

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះសុក្រ ពីគាវី(គោ) ២១រូប ដោយយកគោទាំង២១ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ ហើយរុំព័ទ្ធទៅដោយសំពត់ពណ៌ទឹកប្រាក់ ឬក្រាម រួចប្រោះព្រំដោយទឹកអម្រឹត ក៏បង្កើតបានជាអង្គព្រះសុក្រទេវបុត្រឡើង។ មាន

ពណ៌កាយជាពណ៌ព្រះ ព័ស្ត្រសទ្រង់អាភរណ៍ សំឡុយព្រះព័ស្ត្រឱភាស មានវិមានពណ៌មាស គង់លើគោឧសុភរាជជា ពាហនៈ ស្ថិតនៅក្នុងទិសឧត្តរ (ព្រះសុក្រមានកម្លាំង២១)។

**៧.ព្រះសៅរ៍**

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះសៅរ៍ ពីព្យគ្ឃៈ(ខ្លា) ១០ រូប ដោយយកខ្លាទាំង១០ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ ហើយរុំព័ទ្ធទៅ ដោយសំពត់ពណ៌ ខ្មៅរួច ប្រោះព្រំដោយទឹកអម្រឹត ក៏បង្កើតបានជាអង្គព្រះសៅរ៍ទេវបុត្រឡើង។ ដែលមានពណ៌កាយខ្មៅស្ទើរ រតនៈនីលជាទិព្យអាភរណ៍ មានវិមានពណ៌មរកត ទ្រង់ព្យគ្ឃៈ (ខ្លា) ជាពាហនៈ ស្ថិតនៅក្នុងនីរតីទិស (ព្រះសៅរ៍មានកម្លាំង១០)។

**៨.ព្រះរាហូ**

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះរាហូ ពីក្បាលខ្មោច១២ រូប ដោយយកក្បាលខ្មោចទាំង១២ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ រួចប្រោះព្រំដោយទឹកអម្រឹត ក៏បង្កើតបានជា អង្គព្រះអសុរិន្ទរឿងរឹទ្ធិមហាក្លៀវក្លាឡើង។ មានពណ៌កាយជាពណ៌សំរឹទ្ធ ទ្រង់ទិព្យសុវណ្ណសែង ពណ៌ផ្កាស្អាត មានវិមានជាពណ៌នីល មានមហាសុបណ្ណរាជឬគ្រុឌ ជាពាហនៈ ស្ថិតនៅក្នុងពាយព្យទិស (ព្រះរាហូអសុរិន្ទមានកម្លាំង១២)។ ព្រះរាហូជានាមផ្កាយទី៨ ដែលផ្កាយរាហូនេះ មានជាប់ទាក់ទងទៅនឹង ប្រវត្តិសាវតាមាតាមហានគរ ព្រោះហេតុអ្វី? ១២ តំណាងឲ្យធាតុទឹក និមិត្តរូបឲ្យមាតា ព្រះម៉ែត្រូវយក្សចាប់យកទៅដាក់ទោស ដូច្នេះយក្សរាហូមានកំណើតកើតឡើងបាន ដោយសារសាកសពទាំង១២របស់ព្រះមាតា ព្រោះ១២ខែ = ១ឆ្នាំ (មើលការពន្យល់រូបក្នុងភាគ៣ រូបភាពទី២៦)។ ពេលដែលមិនទាន់មានកូននាគ ចេញមកច្បាំងនឹងយក្សអាថិកំបាំងនេះ គឺពុំមាននរណាដឹងឡើយ លុះត្រាតែមានកូននាគ ចេញមកច្បាំងនឹងយក្ស ធាក់យក្សឲ្យដួល ទើបយក្សព្រមក្អែរឿងចេញ។ នៅក្នុងពោះយក្សនោះ ពេលដែលក្អែចេញមក គឺមានព្រះមាតាព្រះបិតា បុត្រីបុត្រា រួមទាំងមរតកទ្រព្យទាំងអស់ គឺនគរខ្មែរទាំងមូលជារបស់យក្ស ព្រោះយើងទាំងអស់គ្នា ស្ថិតក្នុងពោះយក្ស ដូច្នេះទើបយក្សតែងតែស្រែកអរ(យក្សអរ)។ ហើយយក្សឬរាហូនេះទៀតសោត មានគ្រុឌជាយានជំនិះ ដែលគ្រុឌនេះជាសេនា ជាយានជំនិះរបស់យក្សឈ្មោះរាហូ ឬក្រុងរាពណ៍ និមិត្តរូបគ្រុឌជាសញ្ញារបស់ជនជាតិសៀម។ រាហូគឺជាផ្កាយមួយដួង អាចមាន

រូបរាងកើតឡើង ដោយសារក្បាលខ្មោចទាំង១២ ដែលតំណាងឲ្យព្រះម៉ែមហានគរ គាត់បានដេកស្លាប់នៅក្នុងពោះយក្សនេះ ដោយត្រូវទណ្ឌកម្មគឺយក្សលេប ហេតុនេះទើបក្នុងតម្រាផ្កាយ មានរឿងរាហូចាប់ច័ន្ទ រាហូតំណាងឲ្យយក្ស ចំណែកឯព្រះច័ន្ទតំណាងឲ្យទិព្វសេតាច័ន្ទ វិមានច័ន្ទសោមាឬសោម.... ដែលជាឈ្មោះរបស់មាតាមហានគរ។ ដូច្នេះចង់ដឹងពីប្រវត្តិសាវតាព្រះម៉ែមហានគរ កូននាគត្រូវតែច្បាំងតតាំងបំបែកបេះដូងយក្ស ទើបដឹងអាថ៌កំបាំងខាងក្នុងពោះយក្សបាន នេះជាប្រស្នាអាថ៌កំបាំងដែលមានលាក់ទុករឿង ក្នុងដួងផ្កាយរាហូនេះ រីឯផ្កាយផ្សេងៗទៀត សូមកូននាគជួយត្រិះរិះឈ្វេងយល់។

**៩.ព្រះកេតុ**

ជានាមផ្កាយដួងទី៩ ក្នុងតំណាលវេទកំណើត មិនបានពោលទុកថាសាងដោយអ្វីឡើយ ហើយក៏មិនបានប្រាប់ថា ជាផ្កាយដែលសោយអាយុមនុស្សផង ហោរាចារ្យប្រើពិធីកាញ់គ្មោះ ក្នុងការចងដួងជតា សម្រាប់ឲ្យគ្រប់ចំនួនផ្កាយ៩ដួង។ ក្នុងក្រាំងជាតម្រាបុរាណ ហោរាសាស្ត្រ និងដួងកាលចក្របានពោលថា ព្រះកេតុនេះសាងឡើង ដោយស្ដេចនាគ១០ ជាវិញ្ញាណធាតុ ស្ថិតនៅត្រង់កណ្ដាលភ្នែក ជាផ្កាយព្រះគ្រោះទី៨ គឺថាមិននៅក្នុងទិសណាៗ។ ព្រះកេតុទេវរាជ ទ្រង់ទិព្យសុវណ្ណអករណ៍វិភូសិទ ទ្រង់ម៉ង្គរឿងរិទ្ធិជាពាហណៈ ព្រមដោយទេពសុរារិទ្ធិ ចោមរោមជាបរិវា ស្ថិតក្នុងទិសបស្ចិម អាស្រ័យផ្ទះជាមួយនឹងព្រះព្រហស្បតិ៍។

**១០.ម្រឹត្យូវ**

ម្រឹត្យូវនេះជាអាកាសធាតុ ថាមិនមែនផ្កាយក៏មិនបាន ព្រោះមានគោចរក្នុងទំនង ហោរាសាស្ត្របានពោលថា ស្រដៀងគ្នានឹងផ្កាយព្រះគ្រោះ ប៉ុន្តែដើរយូរជាងផ្កាយគ្រប់ដួងទាំងអស់។ (ក្បួនតារាសាស្ត្រនេះ ដកស្រង់ចេញពីក្បួនហោរាសាស្ត្របុរាណ)

បើយើងមើលទៅលើដួងផ្កាយ ដែលបានរៀបរាប់ខាងលើ គឺបានបញ្ជាក់ប្រាប់យើងថា ព្រះឥសូរ បានបង្កើតភពឬផ្កាយ ដោយវេទ(វេទមន្ត) តើកូននាគមានឆ្ងល់ទេ បើព្រះឥសូរជាអ្នកបង្កើតផ្កាយ ភព ធម្មជាតិ សត្វលោកមកហើយ ហេតុអ្វីចាំបង្កើតទុក្ខសោក ព្រាត់ប្រាស់ រោគាព្យាធិមរណៈ លោភៈ ទោសៈ មោហៈ........ មកឲ្យសត្វលោកធ្វើអ្វី? ម្ដេចក៏មិនបង្កើតតែសេចក្ដីល្អៗទៅ ការឆ្ងល់នេះធ្វើឲ្យយើង ត្រូវតែស្វែងរកនូវសច្ចភាពគឺធម៌ពិត តើភពផ្កាយមនុស្ស សត្វ ធម្មជាតិ

.... ទាំងអស់ដែលមានក្នុងចក្រក្រវាល មិនមាន ទីបំផុតនេះ អ្នកណាជាអ្នកបង្កើត? គឺគ្មានអាទិទេពណា ជាអ្នកបង្កើតឬសាងលោកនេះឡើយ គឺវាកើតឡើងទៅតាមកម្លាំងកម្ម ជាធម្មតា(ធម្ម:)របស់វា។ ចំណែកឯរឿង អ្នកបង្កើតនគរនិងជាតិ គឺមាតាមហានគរក្តី សំណង់ប្រាសាទក្មេរនិងសំណង់ប្រាសាទនៅលើពិភពលោក ដែលឆ្លុះទៅនឹងដួងផ្កាយក្តី សុទ្ធតែទាក់ទង នឹងកើតឡើង ដោយកម្លាំងកម្ម។ មនុស្សអាចដឹង កាលអតីតបច្ចុប្បន្នអនាគត ក៏វាទាក់ទងទៅនឹងកម្មដែរ ព្រោះការប្រព្រឹត្តអំពើ(កម្ម)ដោយកាយវាចាចិត្ត វាបង្កើតបានជាខ្សែច្រវាក់មួយ គឺវដ្តសង្សារដែលទាក់ទងគ្នាមិនដាច់ ត្រូវនាំចិត្តទៅបដិសន្ធិក្នុងភពតូច និងភពធំ(កាមភព រូបភព និង អរូបភព)។ នៅពេលណាដែលសត្វទាំងអស់ រស់នៅក្នុងភពទាំងបីនេះ ពុំបានលះបង់ចោលនៅសេចក្តីប្រកាន់មាំ ក្នុងបញ្ចក្ខន្ធគឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណទេនោះ ខ្សែនៃតណ្ហាត្រូវចងភ្ជាប់ឲ្យសត្វ ទាំងអស់ជាប់នៅក្នុងភពបីនេះ ស្រាយចំណងពុំរួចឡើយ។ ដូចជាបុគ្គលបង្ហោះខ្លែង ខ្លែងតែងហោះទៅកាន់វេហ៊ា ទោះជាបុគ្គលអ្នកបង្ហោះ ខំប្រឡាយខ្សែឲ្យវែង រហូតដល់មើលតួខ្លែងមិនឃើញក៏ដោយ ខ្លែងនោះមិនអាចហោះទៅឲ្យបានផុត ពីខ្សែដែលគេចងនៅដើមទ្រូងបានឡើយ។ យ៉ាងណាមិញបុគ្គលដែលអាចចម្រើនឈាន មានរិទ្ធិមានអភិញ្ញា បើមិនបានកាត់ផ្តាច់នូវឫសគល់ គឺអវិជ្ជានិងតណ្ហានោះទេ ក៏មិនអាចចេញរួច ពីវដ្តសង្សារនេះបានឡើយ។ ដូចជាព្រះមាតាបិតា និងបុត្រអ្នកបង្កើតនគរនេះ លោកជាបុគ្គលចម្រើននូវឈានសមាបត្តិ មានរិទ្ធិអភិញ្ញាជាលោកិយ អាចហោះទៅកាន់ទេវលោកបាន កាលពីជាង២០០០ឆ្នាំមុន។ ដោយចិត្តលោភ អ្នកទាំងបីនោះគឺឪពុកម្តាយកូន ពួកគាត់បានទៅលួចយកកែវមណី ពីឋានយក្សរាហូឬក្រុងរាពណ៍ រួចត្រូវយក្សតាមចាប់យកទៅដាក់ទោស មិនឲ្យពួកគាត់ងូតទឹកចំនួន២ថ្ងៃ គឺស្មើនឹងរយ:ពេលស្ថានមនុស្ស២០០០ឆ្នាំ។ នេះជាហេតុដែលនាគក្មេរមានតែក្បាល ឯខ្លួនត្រូវយក្សលេប គឺវាជានិមិត្តរូបទោស ដែលយក្សហាមមិនឲ្យងូតទឹក បុណ្យពួកគាត់ត្រូវ ឲ្យទៅបដិសន្ធិក្នុងព្រហ្មលោក ដោយអំណាចឈានសមាបត្តិជាលោកិយ ផ្ទុយទៅវិញពួកគាត់បែរជាទៅសោយផលបាប ដោយអំណាចតណ្ហាលោភ: ទោស: មោហ: និងសេចក្តីប្រកាន់មាំ។ ចំណែកនាគនៅម៉ាយ៉ានប្រទេសម៉ិចស៊ិកូ នាគចម្លាក់របស់ពួកគេក៏មានតែក្បាលដែរ ក្នុងមួយឆ្នាំស្រមោលព្រះអាទិត្យ ថ្ងៃ២១មីនានិង២១កញ្ញា បង្កើតជាស្រមោលខ្លួននាគបានពីរថ្ងៃ គឺមានខ្លួននឹងគេដែរ តែខ្លួនជាស្រមោលចណាំងថ្ងៃ គ្មានរូបភាពពិតដូចជានាគក្មេរឡើយ នាគក្មេរមានខ្លួនពិតតែជាខ្លួនយក្ស(និមិត្តរូប)។ នេះជាហេតុដែលអ្នកប្រាជ្ញ ខាងរុករក

អាថ៌កំបាំងប្រាសាទ ពួកគេមានការងឿងឆ្ងល់រកចម្លើយនេះមិនឃើញ ព្រោះចម្លើយវាមានទាក់ទងទៅនឹងភពផ្កាយខាងលើ ក្នុងភាសាព្រះធម៌ព្រះពុទ្ធសាសនា គឺកម្ម និងវិបាករបស់កម្ម។ បឹងយក្សឡោមនៅខេត្តរតនៈគិរី សព្វថ្ងៃយើងនាំគ្នាសន្មត់ថា ជារណ្ដៅបន្ទុះភ្នំភ្លើង ដូនតាយើងបានដាក់ឈ្មោះទីនោះ ដោយប្រាប់ហេតុថា គឺយក្សឡោមព័ទ្ធដេញចាប់មនុស្សបីនាក់ ដែលទៅលួចយកកែវមណីរបស់គេ។ ពួកគាត់លួចយកកែវមណីមក ដើម្បីចាក់សោការពារទ្រព្យ ដែលខ្លួនធ្វើសង្គ្រាមពង្វាតទឹកដី រួចប្រមូលដណ្ដើមយកមក ពីប្រទេសជាចំណុះរាប់រយ ដើម្បីទុកឲ្យបានគង់វង្សមាំមួនកុំឲ្យបាត់បង់ សម្រាប់ទុកជាមរតក ឲ្យពូជក្មេរជំនាន់ក្រោយ។ ទីបំផុតអ្នកដែលប្រព្រឹត្ត បានត្រឹមក្លាយខ្លួនជាអ្នកទោស មានឈ្មោះជាព្រាយ ជាប្រេត ជាបិសាច ព្រោះហេតុតែមរតកទ្រព្យរបស់ខ្លួន 7 គឺមាតុភូមិនេះទាំងមូល ដែលគាត់ខំវារលូនកាប់ឆ្ការប្រមូល ទ្រព្យមរតកទាំងនេះ មកទុកឲ្យកូនក្មេរជំនាន់ក្រោយ។ ដោយខ្លាចកូនក្មេរជំនាន់ក្រោយពុំដឹងរឿងខ្លួន គាត់ខំសម្ដែងរឹទ្ធិជាចុងក្រោយ លួចចេញពីទីឃុំ ប្រមូលយកឯកសារសំណង់ប្រាសាទ ដែលមាននៅក្នុងលោកនេះទាំងមូល យកមកឲ្យកូននាគសម័យមហានគរ សង់ប្រាសាទថ្មបន្តគ្នា រួចឆ្លាក់រៀបរាប់រឿង ដែលខ្លួនបានប្រព្រឹត្តហើយត្រូវជាប់ទោស និងរឿងដែលមានកូននាគ អ្នកមកជួយឲ្យរួចពីទោស។ តំណាក់កាលចុងក្រោយពួកបរទេសគេបានស្រាវជ្រាវដឹង ពួកគេ តាមបិទតាមសន្លប់ តាមលុបដានស្នាមឈប់ឲ្យគាត់ចេញមកក្រៅឃុំរួច ដើម្បីកុំឲ្យកូនក្មេរជំនាន់ក្រោយដឹង។ ទោះបីពួកគេខំប្រឹងប្រែង បិទសន្លប់យ៉ាងណាក៏ដោយ កម្លាំងឫទ្ធិជាលោកិយ ពុំអាចឈ្នះកម្លាំងកម្មបានឡើយ កុំថាឡើយមនុស្សជាបុថុជ្ជន សូម្បីតែព្រះអរហន្តសម្មាសម្ពុទ្ធ អស់អាសវកិលេសមានឫទ្ធិអភិញ្ញា អាចឃាត់ឃាំងនៅដំណើរមារាធិរាជបាន ក៏នៅតែមិនអាចឃាត់ឃាំង នូវកម្លាំងកម្ម ដែលតាមឲ្យផលនេះបានឡើយ។ ពេលណាបាបកម្មឲ្យផលអស់ បុញ្ញកម្មក៏តាមឲ្យផលជាបន្ត វិលទៅវិលមក ម្ដងបាបឲ្យផលម្ដងបុណ្យឲ្យផល បង្កើតបានជាកងច្រវាក់មួយគឺវដ្ដសង្សារ លុះត្រាតែបុគ្គលរួចផុតពីខន្ធ កាត់ផ្ដាច់នៅខ្សែតណ្ហា ដែលមានអវិជ្ជាជាឫសគល់ ទើបនៅជាសុខលែងវិលកើតវិលស្លាប់ គឺបរិនិព្វាន។

## VIII.អំពីអត្ថន័យបន្ទប់ក្នុងនំអន្សម នំគម ដើមចេក

**ក.នំអន្សម**

នំអន្សមគឺជានំមួយ ដែលទាក់ទងទៅនឹងប្រវត្តិនំប្រពៃណីខ្មែរ ព្រោះនំនេះគេច្រើនវេច នៅរដូវបុណ្យចូលព្រះវស្សា បុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំ នៅក្នុងពិធីមង្គលផ្សេងៗ មានមង្គលការជាដើម។ល។ តើនំអន្សមនេះ មានន័យប្រស្នាអ្វី បង្កប់ទុកក្នុងរឿងមាតាមហានគ?

**ពន្យល់ពាក្យ** (អន្សម)

អន្សមជាពាក្យតម្រួត ពាក្យរាយឬសម្រាយមានពាក្យ **អន** + **សម** = **អន្សម**

***អន*** ស. ( គុ. ) ទន់, ស្រទន់ : សម្បុរអន សម្បុរស្រទន់, សម្បុរស្រគាំ; ខៀវអន ខៀវខ្ចី ។ ព. កា . សម្រាប់កវីប្រើតាមត្រូវការ, ដូចជាកាព្យថា កញ្ញាឈ្មោះអន និងនាងគូកន ពាក់អាវអនខ្ចី ដំណើរញ៉ែងញ៉ង ញិកញ៉ាក់ល្វតល្វៃ មុខមាត់ប្រិមប្រិយ៍សម្ដីស្រទន់ ។ ឬមួយបែបទៀតថា ទ្រង់ទ្រាយស្រឡូនឆវីវណ្ណអន មុខមាត់ស្រស់បស់ ពេញទាំងសព៌ាង្គ រូបរាងទាំងអស់ សុទ្ធសឹងតែស្រស់ ឥតទាស់ភ្នែកឡើយ ។ (ដកចេញពីវចនានុក្រមសម្ដេច)

***អន*** ( ន. ) ឈ្មោះបទភ្លេងបុរាណខ្មែរមួយបែប : ភ្លេងអន ។ គេលេងនៅពេលដែលត្រូវសុំឲ្យកូនស្រីចេញពីល្វែងចន្ទន៍ខាងក្នុងមកក្រាបផ្ទឹមជាមួយនឹងកូនប្រុសជាគូគ្នា, ប្រើក្នុងពិធីអាវាហមង្គល; គេច្រៀងថា : អនអើយស្រីអន សុំបើកវាំងនន អញ្ជើញអនមកផ្ទឹម លុះផ្ទឹមរួចហើយ អញ្ជើញសន្សឹម ដើរចូលតែត្រឹម ល្វែងចន្ទន៍ខាងក្នុង ។ល។ វាយទំនុកយ៉ាងណានោះ ស្រេចនឹងការឈ្លាសវៃស្ទាត់ជំនាញរបស់អ្នកច្រៀងដែលច្រៀងវាយទំនុកមិនឲ្យឆ្គង។ (ដកចេញពីវចនានុក្រមសម្ដេច)

***សម*** ស. ( ន. ) នៃសាទុបករណ៍មួយប្រភេទ មានផ្លែដែកមូលស្រួចបីទន្ទឹមគ្នាឥតង្វៀង មានដងឈើខ្លីកោងក្ងក់ សម្រាប់ចាក់ត្រី ។ ប្រដាប់មានផ្លែជាប្រាំមបួនទន្ទឹមគ្នាជាគូនឹងស្លាបព្រា សម្រាប់កាន់ចាក់ចាប់អាហារបរិភោគ ។ (ដកចេញពីវចនានុក្រមសម្ដេច)

***សម***. ( កិ. ) ហ្វឹកហាត់ឲ្យស្ទាត់, ហាត់ជាមួយគ្នាឲ្យជំនាញ, ល្បងគ្នាមើលឲ្យដឹងដំណើរស្ទាត់រាល់ខ្លួន : អ្នកប្រដាល់សមដៃគ្នា, លោកសង្ឃសមធម៌, អ្នករៀនបាលីសមប្រយោគ ។ (ដកចេញពីវចនានុក្រមសម្ដេច)

***សម***( គុ. ) ដែលរញមស្លឹក ដោយត្រូវកម្ដៅថ្ងៃខ្លាំង ឬជាំទឹកជាដើម : ឈើសមស្លឹក ។ (ដកចេញពីវចនានុក្រមសម្ដេច)

**សម** សំ សំ. បា. ( គុ. ) ដែលស្មើគ្នា, ប៉ុនគ្នា, ប្រហែលគ្នា; ស្រដៀងគ្នា : រូបរាងសមគ្នា, ប្ដីប្រពន្ធសមគ្នា ។ ដែលល្មមល្អមើល, មិនទាស់ភ្នែក, មិនឆ្គង : កាត់សក់សម, ស្លៀកពាក់សម ។ ដែលត្រូវ, ត្រូវដូច; សមដូចពាក្យគេថា; និយាយដូច្នេះមិនសមសោះ ! ។ល។ សមគប់ កិ. គប់រក, ចូលគំនិតគ្នា ។ សមគួរ គុ. ល្មម, យ៉ាងមធ្យម : ល្អសមគួរ ។ ន. ដំណើរសម្ដែងអាការកិរិយាសុភាពរៀបរយ, ការធ្វើបដិសណ្ឋារៈរកគ្នាត្រូវបែបបទ : មានសមគួរកគ្នា ។ សមគំនិត កិ. រួមគំនិតជាមួយ ។ សមជា និ. គួរជា, ល្មមជា : សមជានឹងបាន ។ សមតែ និ. គួរតែ, ល្មមតែ : សមតែនឹងឲ្យ ។ សមបី និ. គួរបី, គួរគប្បី : សមបីអ្វីនឹងដល់ម្ល៉ឹង !; មិនសមបីនឹងទៅជាយ៉ាងហ្នឹងសោះ ! ។ សមបុណ្យ គុ. ដែលគួរដល់បុណ្យ, ដែលល្មមនឹងបុណ្យ ។ សមបើ និ. គួរបើ : មិនសមបើដល់ម្ល៉ឹងសោះ ! ។ សមបំណង កិ. ឬ កិ. វិ. បានដូចបំណង; ដែលត្រូវត្រង់តាមបំណង: បានសម្រេចប្រយោជន៍សមបំណង ។ សមប្រកប កិ. ឬ កិ. វិ. បានកបដូចចិត្ត; ដែលត្រូវចួនត្រូវទំនង: រកស៊ីសមប្រកប ។ សមមាឌ កិ. ឬ. គុ. ល្មមដល់មាឌ : ខ្លាំងមិនសមមាឌ ។ សមមាត់ កិ. ឬ គុ. គួរដល់មាត់, គួរស្ដីនិយាយ, គួរហើបមាត់ថា : មិនសមមាត់នឹងនិយាយទៅរក ។ សមរម្យ (--រំ) គុ. ឬ កិ. វិ. ដែលត្រូវបែបត្រូវយ៉ាង, មិនទាស់ភ្នែក : ស្លៀកពាក់សមរម្យ , រូបឆោមសមរម្យ ។ សមសក្តិ ឬ --ស័ក្តិ ន. ឬ គុ. អំណាចដ៏សមរម្យ; អំណាចស្មើ; សមបុណ្យសមអំណាច ។ សមសារ (ម. ព. លំនាំសមសារ ផង) ។ សមសួន គុ. (សំ. បា. សម + ស. ស្វ៊ន អ. ថ. សួន "ភាគ, ចំណែក, ប៉ែក") មានភាគដ៏សម, សមតាមភាគ; សមតាមបែប, តាមភាព; ដែលត្រូវតាមខ្នាត: រូបរាងសមសួន; មានកម្ពស់សមសួន ។ល។ (ដកចេញពីវចនានុក្រមសម្ដេច)

**សម** សៈម៉ៈ សំ. បា. ( គុ. ) ស្មើ, ស្មើគ្នា, ប៉ុនគ្នា, ប្រហែលគ្នា, ដូចគ្នា (ព. ផ្ទ. វិសម) ។ ប្រើរៀងភ្ជាប់ពីខាងដើមសព្ទដទៃបានតាមគួរដល់ការប្រកប : សមគោត្ត ឬ--គោត្រ គោត្រត្រូវគ្នា, សៃត្រូវគ្នា; អ្នកដែលមានគោត្រត្រូវគ្នា ។ សមចរិយា (សៈម៉ៈចៈរ៉ិយ៉ា) ការប្រព្រឹត្តស្មើ, ការកាន់ធម៌ស្មើ គឺមិនលម្អៀង ព្រោះស្រឡាញ់, ព្រោះស្អប់, ព្រោះល្ងង់, ព្រោះខ្លាច (ម. ព. អគតិ ផង) ។ សមចារី អ្នកប្រព្រឹត្តស្មើ, អ្នកកាន់ធម៌ស្មើ (អ្នកមិនលម្អៀងដោយអគតិ ៤ យ៉ាង); បើស្ត្រីជា សមចារិនី ។ សមចិត្ត ចិត្តស្មើ; ចិត្តស្មើគ្នា ។ សមចិន្តា (--ចិន-ដា) គំនិតស្មើគ្នា ។ សមជាតិ ជាតិស្មើគ្នា; ជាតិត្រូវគ្នា ។ សមជាតិក ឬ--ជាតិកៈ អ្នកដែលមានជាតិស្មើគ្នា (បើស្ត្រីជា សមជាតិកា) ។ សមជីវិតា ការចិញ្ចឹមជីវិតស្មើ គឺចិញ្ចឹមជីវិតត្រូវតាមធម៌ តាមច្បាប់មិនខ្ពស់ៗទាបៗ ។ សមតេជះ តេជះ, អំណាច ស្មើគ្នា; អ្នកដែលមានអំណាចស្មើគ្នា ។ សមទណ្ឌ (--ទ័ន) អាជ្ញា, ពិន័យដែលសមនឹងទោសខុស ។ សមនាម ឬ សមាននាម

(សៈម៉ានៈ--) ឈ្មោះត្រូវគ្នា; អ្នកដែលមានឈ្មោះត្រូវគ្នា ។ សមភាគ ចំណែកស្មើគ្នា ។ សមភាព ភាពស្មើគ្នា, ដំណើរស្មើមុខគ្នា (ម. ព. នេះទៀតផង) ។ សមវ័យ អាយុស្មើគ្នា, ឆ្នាំដំណាលគ្នា ។ សមវិជ្ជា ឬ--វិទ្យា ចំណេះស្មើគ្នា ។ សមវិទ អ្នកដែលមានចំណេះស្មើគ្នា ។ សមវិបាក ដែលមានវិបាកស្មើគ្នា; អំពើដែលមានផលស្មើគ្នា ។ សមានុភាព (សៈម៉ា--; សំ. បា. < សម + អានុភាវ) អនុភាពស្មើគ្នា; អ្នកដែលមានអានុភាពស្មើគ្នា ។ល។(ដកចេញពីវចនានុក្រមសម្តេច)

បើតាមមើលការពន្យល់ពាក្យខាងលើ ន័យរបស់នំអន្សមគឺនំដែលមានសភាពទន់ មានរូបរាងប៉ុនគ្នា កើតឡើងដោយភាពស្ទាត់ជំនាញរបស់អ្នកវេច ត្រូវស្ងោរឲ្យរញមស្លឹកចេកដែលវេចខ្ចប់ទើបឆ្អិន។ បើបកតាមន័យអាថ៌កំបាំង បណ្តាំមាតាមហានគរ និមិត្តរូបសោឃុំឃាំងទាំង៤ជាន់ តើដូចម្តេច? ចំណាងចងនំពីខាងក្រៅ ទុកដូចជាសោទ្វារទីមួយ ស្លឹកចេកដែលវេចខ្ចប់ ទុកដូចជាសោទ្វារទីពីរ អង្ករដំណើប ទុកដូចជាសោទ្វារទីបី ចំណែកឯសណ្តែក ដែលប្រឡាក់រុំព័ទ្ធសាច់ជ្រូក គឺជាសោទ្វារទីបួន រីឯសាច់ជ្រូកតំណាងឲ្យបុគ្គលដែលជាប់ឃុំ។ ព្រោះនិមិត្តរូបសត្វជ្រូក គឺជាប់ក្នុងទ្រុងដេកលើភក់ នឹងលាមកទឹកមូត្រខ្លួនឯង ធ្វើជាសម្លៀកបំពាក់ ដូចជាប្រវត្តិរឿងមាតាមហានគរ ត្រូវដេកត្រាំក្នុងសមុទ្រទឹកដោះ ដែលស្អុយរាប់ពាន់ឆ្នាំ នៅក្នុងភក់រហូតភក់ក្លាយជាថ្ម គឺថ្មភក់។ នំអន្សមនេះរាងវែងរបស់វា គេតែងប្រដូចទៅនឹងលិង្គព្រះឥសូរ បើជានិមិត្តរូបលិង្គរបស់ព្រះឥសូរហេតុអ្វីបានជាត្រូវយកមកស្ងោរ នៅក្នុងទឹកក្តៅ?

**ខ.នំគម**

នំគមឬនំបត់ គឺជានំដែលជាគូនឹងនំអន្សម ហើយប្រវត្តិរបស់វាក៏ដូចជានំអន្សមដែរ គ្រាន់តែនំគមនេះ អភ័ពជាងនំអន្សម ព្រោះគេត្រូវយកអង្ករដំណើប ទៅកិនបំបែករាងកាយឲ្យទៅជាម្សៅ រួចយកទៅស្ងៀតឲ្យអស់ទឹក ទើបយកមកវេច (និមិត្តរូបទារុណកម្ម)។

**ពន្យល់ពាក្យ** (គម)

**គម** ( គុ. ) ដែលមានខ្នងពកកំពូកស្រដៀងនឹងបូកគោ : មនុស្សគម, ខ្នងគម, គមគាក់ គមនិងគាក់ (ម. ព. គាក់ ផង) ។ (ដកចេញពីវចនានុក្រមសម្តេច)

**គម** ( ន. ) ឈ្មោះនំ ១ យ៉ាង មានសណ្ឋានដូចខ្នងគម ធ្វើពីម្សៅដំណើបមានស្នូលដូង ឬ ស្នូលសណ្ដែកស្បាត់ស្ករ ខ្ចប់ដោយស្លឹក ចម្អិនដោយចំហុយ : នំគម ។ (ដកចេញពីវចនានុក្រមសម្ដេច)

**គម** ( ន. ) បណ្ដូល-កឈើក្នុងពួកត្នោត, ដូង, ស្លា, ជ្រៃ; ប្រើធ្វើជាបន្លែ, អន្លក់ មានរសពីសា ប្រើជួសសាឡាត់បាន : គមត្នោត, គមដូង, គមស្លា គមស្លាត្រឌិន ។ល។(ដកចេញពីវចនានុក្រមសម្ដេច)

នំគមបើមើលតាមការពន្យល់ពាក្យខាងលើ គឺជានំដែលមានរាងពកកំពូកឡើង ហើយជាបណ្ដូលនៃរុក្ខជាតិ(ពួកត្នោត ដូង ស្លា ជ្រៃ) បើប្រៀបនឹងរឿងមាតាមហានគរ គឺជាឬសកែវ។ តើនំគមមានអត្ថន័យដូចម្ដេច ទាក់ទងនឹងសាវតាមាតាមហានគរ? នំគមមានស្លឹកចេករុំព័ទ្ធជាទី១ ម្សៅដំណើបរុំព័ទ្ធជាទី២ ចំណែកស្នូលជាទី៣នៅខាងក្នុង គឺយកស្ករទៅធ្វើជាតាំងម៉ៃ ទើបដាក់ដូងឬសណ្ដែកកូរជាមួយស្ករតាំងម៉ៃឲ្យចូលគ្នាសព្វ។ ដូច្នេះន័យក្នុងអាថ៌កំបាំងមាតាមហានគរ ទី១រូបរាងនំដូចជាភេទរបស់ម្ដាយ ទី២បណ្ដូលឬស្នូលខាងក្នុង មានបង្កប់ឈ្មោះស្ករតាំងម៉ៃ ទី៣អង្ករដំណើបដែលកិនជាម្សៅ តំណាងឲ្យព្រះមេ។ ហេតុអ្វីនំអន្សម និងនំគម ត្រូវយកអង្ករដំណើបមកធ្វើ? យើងតែងឮចាស់ពីបុរាណ គាត់ជេរស្ដីប្រៀបធៀបមនុស្ស ដែលមានស្មារតីពុំគ្រប់គ្រាន់ថា មនុស្សដំណើបលាយខ្សាយ គឺមានន័យថាពុំបរិសុទ្ធគ្រប់គ្រាន់។ ចុះបើដំណើបសុទ្ធវិញ តើមានន័យដូចម្ដេច? គឺវាទន់ជ្រាយស្អិត មិនងាយនឹងមានភាពរឹងប៉ឹង ខ្លួនឯងឡើងវិញបានឡើយ ដូច្នេះត្រូវតែពឹងពាក់ភាពរឹងប៉ឹងពីខាងក្នុង គឺសច្ចៈ ខន្តិ វិរិយៈ កតញ្ញូ...។

**<u>គ.ដើមចេក</u>**

ហេតុអ្វីក៏ដើមចេកនេះ មានវាសនាខ្ពស់អ្វីម្លេះ អាចឡើងទៅកាន់ទីសក្ការៈផ្សេងៗ? នៅក្នុងពិធីបុណ្យផ្សេងៗ យើងតែងឃើញគេយកកូនចេកឬដើមចេកទៅធ្វើស្លាធម៌ បាយសី យកស្លឹកទៅវេចនំ យកស្រទបទៅធ្វើពែ....។ល។ ហើយកូនចេកនោះទៀតសោត គេច្រើនយកកូនចេកដែលមានស្លឹក៣ តើអាថ៌កំបាំងដើមចេកនេះ វាមានន័យអ្វីទាក់ទងនឹងសាវតាមាតាមហានគរ? ពាក្យនិយាយថាដាំចេក ត្រឡប់ពាក្យមកវិញគឺដេកចាំ តើអ្នកណាជាអ្នកដេកចាំ? អ្នកដែលដេកចាំអស់រយកាលរាប់ពាន់ឆ្នាំ គឺមាតាមហានគរ ដែលលោកដេកចាំយូរពេកទៅ ក៏ស្លាប់ឈ្មោះចេញពីសន្ដានចិត្តកូននាគ តើលោកដេកចាំអ្វី? គឺលោកដេកចាំកូននាគ ស្វែងរកអាថ៌កំបាំងរបស់

លោកឲ្យឃើញ ហើយនាំគ្នាជួយស្រង់លោក ឲ្យរួចផុតពីទីឃុំទាំង៣។ ដូច្នេះហើយទើបដើមចេក មានវាសនាខ្ពស់ ក្លាយជារុក្ខជាតិបូជាព្រះធម៌(ចេកស្លាធម៌) ក្លាយជាស្លឹកសម្រាប់វេចនំ និងក្លាយជា ពែដាក់អាហារ សែនឧទ្ទិសទៅឲ្យពពួកបិសាចប្រេត ចំណែកផ្លែក្លាយជាសំណែនរបស់អមនុស្ស ត្រយ៉ូង ក្លាយជារបោយសម្រាប់លាយ បំភ័ន្តជាមួយនឹងនំប៉ែនចុក។ល។

នេះគ្រាន់តែជាការបកស្រាយពន្យល់ ដោយសង្ខេបអំពីនំអន្សម នំគម ដើមចេក ដែលបាន បង្កប់ទុកក្នុងប្រវត្តិសាវតា របស់មាតាមហានគរពីរអតីតកាល សម្រាប់ឲ្យកូននាគយកទៅពិចារណា ឡើងវិញ ហេតុអ្វីបានជារបស់ទាំងនេះ មានតម្លៃជាអមតៈ ស្ថិតក្នុងសន្តានចិត្តកូនក្មេរ។

## IX.អំពីសុភាសិត

សុភាសិតគឺជាកម្រងពាក្យសម្ដី ដែលបង្កប់ន័យគំនិត ទៅតាមបញ្ញាជាលោកិយ និងជា លោកុត្តរៈ ដូច្នេះយើងអាចយល់ភាសិតទាំងនោះបាន លុះត្រាតែបានស្ដាប់ការពន្យល់បកស្រាយ ពី បណ្ឌិតឬសប្បុរសនោះ។ល។

ឧ. សុភាសិតរបស់ព្រះសម្មាសម្ពុទ្ធ

- កម្លាំងអ្វីស្មើដោយកម្លាំងកម្មគឺពុំមានឡើយ
- ទុក្ខអ្វីស្មើដោយខន្ធនេះគឺពុំមានឡើយ
- ភ្លើងអ្វីស្មើដោយភ្លើងរាគៈគឺពុំមានឡើយ
- កំហុសអ្វីស្មើដោយទោសៈគឺពុំមានឡើយ
- សុខអ្វីស្មើដោយសេចក្ដីស្ងប់គឺពុំមានឡើយ
- ធម៌ទាំងឡាយមានចិត្តជាធំ មានចិត្តប្រសើរបំផុត សម្រេចមកពីចិត្ត បើបុគ្គលមាន ចិត្តត្រូវទោសៈប្រទូស្តរ៉ាយហើយ ទោះបីនិយាយក្ដីធ្វើក្ដីក៏អាក្រក់ដែរ អំពើអាក្រក់ដែលបានធ្វើ ហើយនោះ សេចក្ដីទុក្ខរមែងដេញជាប់តាមក្រោយ ដូចជាកង់រទេះវិលតាមស្នាមជើងគោ ដែលអូស នឹមរទេះយ៉ាងដូច្នោះ។

– ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តដ៏ប្រសើរបំផុត ក៏សម្រេចមកពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ទោះបីនិយាយក្តីធ្វើក្តីក៏ល្អទាំងអស់ ព្រោះចិត្តជ្រះថ្លានោះឯង សេចក្តីសុខរមែងតាមជាប់បុគ្គលនោះ ដូចជាស្រមោលដែលអន្ទោលតាមប្រាណយ៉ាងដូច្នោះ។

– ក្នុងកាលណាមួយក៏ដោយ ធម្មតាពៀរទាំងឡាយក្នុងលោកនេះ មិនដែលស្ងប់រម្ងាប់ដោយការចងពៀរឡើយ តាមការពិតពៀរទាំងឡាយតែងស្ងប់រម្ងាប់ ដោយការមិនចងពៀរ នេះជាធម៌ចាស់មានយូរណាស់មកហើយ។

– ដំណក់ទឹកភ្លៀងតែងលេចស្រក់ចុះ ក្នុងផ្ទះដែលគេប្រក់ដំបូលមិនជិតល្អ យ៉ាងណាមិញរាគៈតែងហូរចាក់ទំលុះ នៅចិត្តដែលបុគ្គលមិនបានចម្រើនយ៉ាងនោះដែរ ដំណក់ទឹកភ្លៀងមិនអាចលេចស្រក់ចូលផ្ទះ ដែលគេប្រក់ជិតបានល្អ យ៉ាងណារាគៈក៏មិនអាចចាក់ទំលុះនូវចិត្ត ដែលបុគ្គលបានអប់រំចម្រើនដោយល្អហើយ ក៏យ៉ាងនោះដែរ។

– អ្នកធ្វើបាបកម្មរមែងសោកសៅក្នុងលោកទាំងពីរ គឺសោកសៅក្នុងលោកនេះផង សោកសៅក្នុងលោកខាងមុខផង គេរមែងសោកសៅក្តៅក្រហល់ក្រហាយ ព្រោះឃើញកម្មដែលសៅហ្មងរបស់ខ្លួន ដែលបានប្រព្រឹត្តធ្វើហើយ។

– អ្នកបានធ្វើបុណ្យទុកមកហើយ រមែងត្រេកអររីករាយក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះផង និងរីករាយក្នុងលោកខាងមុខផង គេរមែងត្រេកអររីករាយសប្បាយ នៅកម្មដែលបរិសុទ្ធរបស់ខ្លួនបានប្រព្រឹត្តហើយ។

– ពួកជនពាលមានបញ្ញាល្ងង់ខ្លៅ រមែងតាមប្រកបនូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញវិញ តែងរក្សាទុកនៅសេចក្តីមិនប្រមាទ ដូចជាបុគ្គលរក្សាទ្រព្យដ៏ប្រសើរទុកយ៉ាងនោះឯង អ្នកទាំងឡាយចូរកុំតាមប្រព្រឹត្តសេចក្តីប្រមាទឡើយ ចូរកុំត្រេកអរក្នុងកាមទាំងឡាយ ព្រោះថាអ្នកមិនប្រមាទហើយ រំពឹងពិចារណាត្រិះរិះ នឹងបានសម្រេចនូវសេចក្តីសុខដ៏ប្រសើរ។

– ទោះបីបុគ្គលនិយាយធម៌ពោលធម៌ ដែលមានប្រយោជន៍ច្រើនយ៉ាងណាក៏ដោយ តែជាអ្នកមានសេចក្តីប្រមាទ មិនប្រព្រឹត្តធ្វើតាមធម៌នោះ ដូចជាអ្នកចញ្ចឹមគោ ហើយរាប់គោឲ្យអ្នកដ៏ទៃ គឺជាអ្នកមិនមានចំណែក នៃសាមញ្ញផលយ៉ាងនោះឯង ផ្ទុយទៅវិញបើបុគ្គលនិយាយធម៌ពោលធម៌ដែលមានប្រយោជន៍ ទោះបីជាតិចតួចក៏ដោយ តែជាអ្នកប្រព្រឹត្តតាមធម៌សមគួរដល់ធម៌នោះ លះបង់ចោលនូវរាគៈ ទោសៈ មោហៈអស់ហើយ ជាអ្នកចេះដឹងសព្វគ្រប់ មានចិត្តរួចផុត

ស្រឡះហើយ ជាអ្នកមិនប្រកាន់មាំក្នុងលោកនេះ និងលោកខាងមុខ បុគ្គលនោះជាអ្នកមាននូវចំណែកនៃសាមញ្ញផល(អរិយមគ្គ និងអរិយផល) ដោយពិត។

– រូបនេះចាស់គ្រាំគ្រាទ្រុឌទ្រោមហើយ ជាទីអាស្រ័យនៅនៃរោគទាំងពួង ជារបស់ដែលផុយរលួយ កាយរបស់ខ្លួនជារបស់ស្អុយគួរខ្ពើមរអើម ហើយនឹងបែកធ្លាយ ព្រោះថាជីវិតមានសេចក្ដីស្លាប់ជាទីបំផុត។

– រាងកាយនេះ ដែលកម្មបានវិចិត្រឲ្យជាគំនរឆ្អឹងទាំងឡាយ ចងរឹតភ្ជាប់ដោយសរសៃបូកលាបដោយសាច់ឈាមនិងស្បែក ជាទីធ្លាក់ចុះនៃជរា ព្យាធិ មរណៈ ការប្រកាន់ខ្លួន និងការរមិលគុណ។

– បុរសអ្នកមានសុតៈ(ស្ដាប់)តិច គឺការបានស្ដាប់ធម៌របស់សប្បុរសតិច រមែងចាស់ទៅដូចជាគោចាស់ ដែលគេឈប់ប្រើប្រាស់យ៉ាងនោះឯង សាច់របស់បុគ្គលនោះតែងចម្រើន តែបញ្ញារបស់គេគ្មានបានចម្រើនឡើយ។

– បណ្ឌិតបើដឹងថាខ្លួនជាទីស្រឡាញ់ហើយ ត្រូវថែរក្សាខ្លួននេះឲ្យបានល្អ ត្រូវតម្កល់ចិត្តទុកក្នុងវ័យទាំងបី ក្នុងវ័យណាមួយ។

– បណ្ឌិតគួរតម្កល់ខ្លួនឯងឲ្យតាំងនូវក្នុងគុណធម៌ ដ៏សមគួរជាមុនសិន ចាំប្រដៅអ្នកដទៃជាខាងក្រោយ ទើបមិនលំបាក។

– បើបុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ក៏ត្រូវធ្វើខ្លួនជាយ៉ាងនោះដែរ បុគ្គលអប់រំខ្លួនឯងបានល្អហើយ ទើបប្រដៅអ្នកដទៃ លោកថាខ្លួនឯងនឹងហើយ ដែលទូន្មានបានដោយកម្រ។

– អំពើអាក្រក់និងកម្មឥតប្រយោជន៍ មនុស្សអាក្រក់ធ្វើបានដោយងាយ អំពើជាប្រយោជន៍ផង ល្អផង អំពើនោះឯងមនុស្សអាក្រក់ ធ្វើបានដោយកម្រ។

– កម្មល្អនិងអំពើមានប្រយោជន៍ មនុស្សល្អធ្វើបានដោយងាយ អំពើឥតប្រយោជន៍ផងអាក្រក់ផង មនុស្សល្អធ្វើបានដោយលំបាក។

– អ្នកដែលប្រមាទក្នុងកាលមុន តែពេលខាងក្រោយគេមិនប្រមាទ អ្នកនោះនឹងធ្វើឲ្យលោកនេះ ឲ្យភ្លឺស្វាងបានដូចជាព្រះច័ន្ទរះផុតស្រឡះពីពពក បំភ្លឺលោកឲ្យភ្លឺស្វាងត្រចះត្រចង់យ៉ាងនោះឯង។

ឱ.<u>សុភាសិតដូនតាក្មេរះ</u>

- ទូកទៅកំពង់នៅ
- នំមិនធំជាងនាឡិ
- អូសទូកកុំឲ្យល្អាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក
- ពេលឈើយកដំរីទៅបន់ ពេលជំងឺស្រន់ពងមាន់មួយស្លាយ
- ត្រុកៗអ្នកស្រុកមើលងាយ រលាស់គូថខ្ចាយ មានឪនមានកន្ដ
- បង្កួយក្លាយជាជាស មាសក្លាយជាសំណ ភ្នំឥតមានថ្ម ស្រីល្អឥតប្ដី
- ដឹងឆ្លើយព្រោះដង កូនឆ្កងព្រោះមេបា
- តក់ៗពេញបំពង់ ឆុងៗកន្លះត្រហែត
- គោមួយក៏យប់ គោដប់ក៏ល្ងាច
- លឿនដេកផ្លូវ សូវៗដល់ផ្ទះ
- ឈើកោងវល្លិពន្ធ័ មនុស្សខ្ចាត់ព្រាត់កុំយកខ្លួនបៀត
- នាងរត់រកអ្នក កណ្ដាចលក្ខណ៍ជួបនឹងកំបាក់អង្ក្រា ជំទាវរត់រក៏ឧកញ៉ា បវកញ្ញារត់រក៏ប្រធាន
- ដាក់ទូឲ្យស្រាស់បន្លា អារសាច់ជូនខ្លា ទើបនៅស្រុកបាន
- ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី(ការចងពៀរគ្នា)
- បើចេះឲ្យគេកោត បើឆោតឲ្យគេអាណិត
- ឃើញឈើពុកកុំដាក់គូថលើ
- កុំខ្វើកតាមខ្យល់ កុំខ្វល់តាមរលក
- គុណមួយសំពៅ ទោសមួយចូលទៅរលាយគុណអស់
- ត្រីមួយត្រកស្អុយមួយ ស្អុយទាំងអស់
- ខ្វាក់អ្វីមិនស្មើនឹងខ្វាក់បញ្ញា ងងឹតអ្វីមិនស្មើនឹងអវិជ្ជា
- បួញមាត់បត់ដុំដៃ
- ត្រីងៀតឆ្អៀតពង
- ចាក់អង្ករយកអង្កាម
- ចោលសាច់ស្រវាឆ្អឹង ដល់ទំពារទៅរឹង ទើបស្រវារកសាច់
- កុំយកឆ្អឹងព្យួរក
- លើកច្រវាសំឡឹងត្រើយ

- ហុតទឹកសំឡឹងកាក
- ដំរីខ្វាក់ ទ្រមាក់ឆ្កួត
- ត្រជាក់លូកនឹងដៃ ក្ដៅស្ទុះរករំរែក
- សឹមៗកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា
- ចង់ចេះឲ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាយកភ្លើងដុតគល់
- បើគេបបួលកុំឲ្យខាន បើគេបានកុំឲ្យទៅ
- ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ
- មានសម្រាមទើបឆ្កែវាដុះ មានប្រឡាយទើបទឹកវាហូរ
- ចេះដប់មិនស្មើប្រសប់មួយ
- ព្នសូរផ្គរកុំអាលចាក់ទឹកពាងចោល
- កាប់បំពង់រងចាំទឹកភ្លៀង
- ដល់កំពង់លង់ទូក
- កុំពត់ស្រឡៅ កុំប្រដៅមនុស្សខូច
- ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក
- គ្នាតិចអន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ
- ចុះទឹកក្រពើ ឡើងទៅលើខ្លា
- បួសនេនសងគុណម្ដាយ បំពេញភិក្ខុសងគុណឪពុក
- ថ្វាយបង្គំព្រះ ប្រយ័ត្នប្រទះស៊ីមង់ត៍ សំពះសង្ឃប្រយ័ត្នប៉ះកូនអ្នកស្រុក
- ស្លៀកស្បង់មិនកោរសក់ ឆ្លុះកញ្ចក់ច្រួចនេត្រា
- សូវស្លាប់ឬាកុំឲ្យស្លាប់មេ សូវលង់ទូកកណ្ដាលទន្លេ កុំឲ្យភ្លើងឆេះផ្ទះ
- ចង់ឆ្ងាញ់ឲ្យរកអន្លក់ ចង់ស្រនុកឲ្យនឿយពីក្មេង
- គិតហើយសឹមគូរ
- ចិត្តត្រជាក់ស៊ីត្រីអាំង ចិត្តខ្លាំងស៊ីដុំអំបិល
- ថោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់
- ភ្លើងឆេះពីសម្រាម
- បង់បោយមិនមើលប្រាណ ដាំជើងក្រានមិនប្រមាណឆ្នាំង
- អ្នកឡើងបានតែបេះ អ្នកប្រឡេះបានស៊ី
- ភូតនៅហោរ ចោរនៅជាង
- ធ្វើស្រែឲ្យមើលស្មៅ ទុកដាក់កូនចៅឲ្យមើលផៅសន្តាន

- ដាងដែកហែកនឹងដៃ ដាងកន្ត្រៃសក់កន្ទើង
- ដាងមិនកើតកុំបន្ទោសដែក
- ក្ដៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ
- ស្លឹកឈើមិនជ្រុះឆ្ងាយពីគល់
- ត្រឡាចវាទៅ ល្ពៅវាមក
- ទំពក់វាទៅទើបញ្ចៅវាមក
- ផ្កាញ់ជាព្រះ ឈ្នះលើពួកមារ
- ដំរីសាស្លាប់យកចង្អេរទៅបាំង
- ឈាមស្រែកស្បែកហៅ
- ស្រីខ្មៅក្រញ៉េះដូចគូថអំបែង ចេះតុបតែងប្ដីលែងមិនបាន ស្រីសដូចចានមារយាទមិនបានដូចឆ្កែក្រោមផ្ទះ។
- កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្ក្រម៍ កុំទុកចិត្តអភិប្រាយ ប្រើទំលែងខ្ពស់ រំពឹងឲ្យឆ្ងាយ ស្ដាប់ពាក្យបរិយាយ បណ្ដាំមេដី

ឧ.<u>នេះជាសុភាសិតខ្ញុំបាទ៖</u>

- ពេលប្រើប្រាស់ទឹកត្រូវនឹកឃើញម្ដាយ ពេលបានហូបបាយនឹកឃើញព្រះមេ
- បេះស្លឹកផ្កាផ្លែនឹកឃើញគល់ឬស ចង់ដឹងន័យទិសនឹកដល់ព្រះសាស្ដា
- ហូបអំបុកនំប៉ែនចុក នឹកឃើញទុក្ខវេទនា ប្រើប្រាស់គង្គានឹកឃើញដល់ម៉ែ
- នំគមអន្សមស្លោកស្លឹកព្រោះក្ដៅ ម៉ែយាព្រោះចៅ ក្លាយជាជីដូន
- ដូងចេកម្លូស្លាសាវតាម្ចាស់ជាតិ គ្រប់ញាតិក្នុងដែនចោលកេរបាត់ជាតិ
- រឿងកើតលើដីផ្លុះផ្កាយលើមេឃ
- ជ័យឈ្នះទីមួយដោះប្រស្នាឪឡឹកបី ជ័យឈ្នះទីពីរប្រើភាសាក្ដាម ជ័យឈ្នះទីបីបង្ហោះខ្លែងឯក
- ព្រហ្មពិតស្ថិតនៅលើដី ពូជក្មេរប្រុសស្រីកើតចេញពីព្រហ្ម
- ទេវបុត្រព្រហ្មមានមុខតែមួយ ព្រហ្មមានតែត្បូយ(ក្បាល)មានមុខបួន
- សម្ដៅក្មេរទឹកខ្នាយពណ៌បៃតង ការីក្រហមដាំបំបែកប្រស្នាចង្វាយទ្វារមាស
- ក្របីគីបីក្រ ក្រូចពីដេកក្នុងភក់ ក្រូចពីនឹម ក្រូចពីសត្វតិរិច្ឆាន

- ១២តាងម្ដាយ ២១តាងឪពុក ស្រាយរឿងតាមទំនុកឃើញព្យញ្ជនៈ៣៣
- បើមើលទៅថ្មឃើញរឿងដំរី មើលប្រាសាទលើដីឆ្លុះផ្កាយលើមេឃ
- ទឹកចិត្តហូរចេញពីទ្រូង ទឹកដូងដក់នៅក្នុងផ្លែ ទឹកចិត្តឪម៉ែជាព្រហ្មដណ្ដប់លើកូន
- បើស្គាល់ឈ្មោះជាតិត្រឹមខ្មែរ ពូជម៉ែត្រូវខ្ទេចខ្ទីល្ហែ
- បើស្គាល់ឈ្មោះជាតិក្មេរក្មែរ ត្រូវស្គាល់ពូជនាគ ពូជព្រហ្ម ពូជផ្កាយពូជអច្ឆរិយ
- ដូនតាប្រតិស្ឋានទុកស្នាមព្រះបាទ កូននាគសង្វាតលាងតែខ្នងជើង
- ១២តាងទឹកឲ្យទូករអណ្ដែត ដី២១ជាហេតុ ឲ្យមនុស្សសត្វចម្មជាតិរអាស្រ័យនៅ
- មានឈ្មោះជាកែវតែកប់ក្នុងដី ផ្លែស្លឹកផ្កាប្រពៃឈ្មោះតាមតម្រា

នេះគ្រាន់តែជាការសាកល្បង តាក់តែងជាសុភាសិត សម្រាប់ទុកជាគតិពិចារណា ទៅលើមរតកដូនតា ដែលពួកគាត់សុទ្ធតែជាអ្នកប្រាជ្ញ បណ្ឌិត ហើយពួកគាត់បានបន្ទោរនៅកាកគំនិតទាំងនេះ ទុកឲ្យយើងស្រាយ ដើម្បីជាក្បួនអប់រំទូន្មានចិត្ត ឲ្យក្លាយជាពូជ នាគ ផ្កាយ ព្រហ្ម អច្ឆរិយ....។

# X.អំពីខ្នាតរង្វាស់រង្វាល់របស់ក្មេរបុរាណ

## ក.ខ្នាតរង្វាល់

- មួយស្មើស្មើ២សន្លឹកគួបគ្នា
- មួយត្របកស្មើនឹង២០សន្លឹកឬ១០ស្មើ
- មួយគូស្មើ២
- មួយដំបស្មើ៤
- មួយឡូស្មើ៣ដំបស្មើ១២
- មួយថ្លូនស្មើ១០ដំបស្មើ៤០ បើស្មើនឹង៥២ត្រូវថែមក្បាច់
- មួយស្លឹកស្មើ១០ថ្លូនស្មើ៤០០
- មួយនាលិស្មើ១៦តម្លឹង
- មួយនាឡិស្មើខ្នាតរង្វាល់ត្រឡោកដូង ឬរង្វាល់តូចមួយប្រភេទ សម្រាប់វាល់គ្រាប់សណ្ដែកបាយជាដើម
- មួយចុងស្មើ៣០គីឡូក្រាម

- មួយហាបស្មើទម្ងន់១០០នាលិឬពីចុងស្មើ៦០គីឡូក្រាម
- មួយចិប = ម្រាមមេដៃនឹងចង្អុលដៃផ្គុំគ្នា(សាបមួយដៃប្រៃមួយចិប)
- មួយជ្រិបឬជ្រិក = ម្រាមដៃប្រាំផ្គុំគ្នា (អាចិកំបាំងប្រស្នាពូជប្រាំ ពូជផ្កាយ)
- មួយក្ដាប់ = មួយក្ដាប់ដៃឬមួយពំនូត
- មួយទូកដៃ = ម្រាមដៃទាំងប្រាំក្ដោបចូលគ្នា
- មួយកំបង់ដៃ = ពីរទូកដៃចូលគ្នា
- មួយក្ដោប = ពីរទូកដៃលើកបញ្ឈរ
- បួនកន្ដាំង = មួយកញ្ជើឬតៅ
- ពីរកញ្ជើ = មួយថាំងស្មើចំនួន ២ តៅ ឬ ចំណុះ ៥០ ឬ ៦០ នាឡិ : ស្រូវមួយថាំង

**ខ.ខ្នាតរង្វាស់ប្រវែង**

- មួយថ្នាំងដៃ
- មួយចង្អុលដៃ
- មួយធ្នាប់ម្រាមដៃ
- មួយចង្អាម
- មួយគក់
- មួយហត្ថ
- មួយលូក
- មួយព្យាម
- មួយជំហាន
- លិក្ខា បា. ឬ សំ. ( ន. ) ពងចៃ ។ ឈ្មោះមាត្រាវាស់យ៉ាងល្អិតទំហំមួយពងចៃ; រាប់តាមលំដាប់ថា : ៣៦ បរមាណូ ជា ១ អណូ, ៣៦ អណូ ជា ១ តជ្ជារី, ៣៦ តជ្ជារី ជា ១ រថរេណូ, ៣៦ រថរេណូ ជា ១ លិក្ខា ឬ លិក្សា, ៧ លិក្ខា ជា ១ ឩកា, ៧ ឩកា ជា ១ ធញ្ញមាស, ៧ ធញ្ញមាស ជា ១ អង្គុលៈ (អង្គុលី), ១២ អង្គុលៈ ជា ១ វិទត្ថិ (មួយចំអាម), ២ វិទត្ថិ ជា ១ រតនៈ (មួយហត្ថ), ៧ រតនៈ ជា ១ យដ្ឋិ, ២០ យដ្ឋិ ជា ឧសភៈ (= ១៤០ ហត្ថ), ៨០ ឧសភៈ ជា ១ គាវុត (= ១១.២០០ ហត្ថ) ៤ គាវុត ជា ១ យោជន៍ (= ៤៤.៨០០ ហត្ថ; ន័យខ្លះថា ៤០០ សិន) ។ (ដកចេញពីវចនានុក្រមសម្ដេច)

ខ្នាតប្រវែងនេះ ហេតុជាដំបូងគឺកើតចេញពីម្រាមដៃ ដែលជាអវយវៈមានក្នុងរាងកាយនេះ ហើយខ្នាតម្រាមដៃ គឺបានបង្កប់នូវប្រស្នាអាថ៌កំបាំងលេខ៥ ដែលបង្កប់ក្នុងរឿងប្រវត្តិសាវតាអ្នកបង្កើតទឹកដីនេះ។ល។

**ឃ.ខ្នាតពេលវេលា**

ដូនតាយើងពីបុរាណ ប្រើខ្នាតវាស់វែងពេលវេលា គឺយាម ដែលក្នុង១យាមស្មើនឹង៣ម៉ោងឬ៤ម៉ោង ថ្ងៃមួយយប់មួយមាន៨យាម ឬ៦យាម ត្រូវជា២៤ម៉ោង ហៅថាមួយថ្ងៃមួយយប់។ ក្នុងសម័យបុរាណ យាមទី១ហៅបឋមយាម ឬប្រថមយាម យាមទី២ហៅថាមជ្ឈិមយាម ឬមធ្យមយាម យាមទី៣ហៅថាបច្ឆិមយាម ឬបស្ចិមយាម។ ពាក្យថាយាមនេះ បានទាក់ទងទៅនឹងផ្កាយដែលរះនៅលើមេឃ បើតាមន័យពន្យល់ពាក្យក្នុងវចនានុក្រមសម្ដេច បានពន្យល់ថា៖

**យាម** ( ន. ) ប្រដាប់របស់នង្គ័លដែលភ្ជាប់ផ្ទៀងនិងដងមានសណ្ឋានវៀវខាងចុង រាងកោងស្រួចមកខាងក្រោយសម្រាប់កាន់ភ្ជួរ : យាមនង្គ័ល ។

**យាម** សំ. បា. ( ន. ) វេលាដែលបែងជាសង្កាត់ៗ ក្នុងថ្ងៃមួយៗ, បើគិតជាម៉ោង ក្នុងមួយយាមមានបីម៉ោង ឬបួនម៉ោង, ក្នុងថ្ងៃមួយយប់មួយមាន ៨ យាម ឬ៦ យាម ត្រូវថា ២៤ម៉ោង ហៅរួមថាមួយថ្ងៃ ។ ក្នុងសម័យបុរាណ ច្រើនប្រើហៅថា យាម តែក្នុងវេលាយប់ៗមួយមានបីយាមគឺ យាម ទី ១ ហៅបឋមយាម ឬ ប្រថមយាម, ទី ២ ហៅ មជ្ឈិមយាម ឬ មធ្យមយាម, ទី ៣ ហៅ មច្ឆិមយាម ឬ បស្ចិមយាម (ក្នុងយាមមួយៗ បើគិតជាម៉ោងមាន ៤ ម៉ោង) ។ យាមយោគ ដំណើរប្រកបផ្សំតាមពេលយាមគឺការកំណត់ពេលយាមថាមានជោគល្អ ឬ ការទាយតាមពេលយាម ។ យាមយោគយាត្រា ដំណើរចេញចរ, តាមយាមយោគ គឺការពិនិត្យមើលពេលតាមក្បួនតម្រារួចទើបចេញ ដើរ ។ ចាប់យាម សង្កេតពេលយាមតាមក្បួនតម្រា ហើយទាយតាមក្បួនប្រាប់ពិតខ្លះទេខ្លះ ។ល។

**យាម** ស. ( ន. ) ថង់សំពត់មានដៃឬយោគស្ពាយបាន : ស្ពាយយាម ។

**យាម** ( កិ. ) ចាំរក្សាឬក្រវែលឃ្លាំមើល ដោយការប្រយ័ត្នក្នុងពេលមានកំណត់ : យាមឃ្លាំង, យាមផ្លូវ, យាមគុក ។ យាមល្បាត ល្បាតឃ្លាំមើល ក្នុងពេលមានកំណត់ ។

ដូច្នេះគ្រាន់តែពាក្យយាមមួយមាត់ ទាក់ទងនឹងផ្កាយលើមេឃផង ទាក់ទងនឹងប្រដាប់ភ្ជួររាស់ ទាក់ទងនឹងពេលវេលា ទាក់ទងនឹងថង់ស្ពាយ ទាក់ទងនឹងការយាមល្បាត សរុបសេចក្ដីមក គឺទាក់ទងប្រវត្តិសាវតា របស់អ្នកនគរនេះ ព្រោះវាជាកេរមរតកអច្ឆរិយ ឬអច្ឆរា។

ម្ដាយជាទូទៅប្រសូត្របុត្រឈឺពោះឆ្លងទន្លេយ៉ាងយូរ រយៈពេល៧ថ្ងៃ ទើបសម្រាលបុត្រ គឺមានតែមាតាព្រះសិរីលីទេ ដែលលោកត្រូវរងការឈឺចាប់ជាប់នៅក្នុងផ្ទៃមាតា ៧ឆ្នាំ ៧ខែ ៧ថ្ងៃទើបប្រសូត្រ។ ចំណែកឯមាតាមហានគរវិញ ខ្ញុំបាទត្រូវប្រសូត្រគាត់ និងប្រវត្តិរឿងរបស់គាត់ចេញពីទ្វារមាស(យោនី) ដែលគាត់ទូលនៅលើក្បាល ត្រូវប្រើរយៈពេលជាង១២ឆ្នាំ ទើបគាត់អាចរួចពីទោសនេះបាន។ ក្នុងការស្រាវជ្រាវរកប្រវត្តិសាវតាជូនចាស់ម្នាក់នេះ ដែលខ្ញុំបានជួបគាត់ក្នុងសុបិន្តនោះ ដោយគាត់ជាអ្នកទោស ត្រូវគេដាក់ទោសមិនឲ្យងូតទឹកអស់រយៈពេលជាងមួយពាន់ឆ្នាំ គឺពីឆ្នាំដែលបានជួបគាត់ក្នុងសុបិន្ត (១៩៩៨) រយៈពេលស្វែងរកប្រវត្តិសាវតា និងបើកទ្វារឃុំជូនចាស់នេះ ប្រើពេលវេលាជាង១២ឆ្នាំ ពេលវេលាដែលត្រូវប្រសូត្រ និងបើកទ្វារឃុំទាំង៤លើក៖

**លើកទី១** ថ្ងៃព្រហស្បត៍១៥រោច ខែភទ្របទ ឆ្នាំរោង ព.ស២៥៤៤ ត្រូវនឹងថ្ងៃ២៨កញ្ញា ឆ្នាំ២០០០

**លើកទី២** ថ្ងៃពុធ ១២រោច ខែបុស្ស ឆ្នាំមមី ព.ស២៥៤៦ ត្រូវនឹងថ្ងៃទី២៩មករា ឆ្នាំ២០០៣

**លើកទី៣** ថ្ងៃអាទិត្យ ១៥កើត ខែមិគសិរ ឆ្នាំវក ព.ស២៥៤៨ ត្រូវនឹងថ្ងៃទី២៦ធ្នូ ឆ្នាំ២០០៤

**លើកទី៤** ថ្ងៃព្រហស្បត៍ ១កើត ខែជេស្ឋ ឆ្នាំថោះ ព.ស២៥៥៥ ត្រូវនឹងថ្ងៃ២ មិថុនា ឆ្នាំ២០១១។

ក្នុងទ្វារចុងក្រោយនេះ ការទន្ទឹងរងចាំ ដែលខ្ញុំបាទបានសន្យាជាមួយនឹងគាត់ កាលពីជួបលើកដំបូងឆ្នាំ១៩៩៨ ថានឹងជួយដោះលែងគាត់ឲ្យបានរួចពីទោស ពេលវេលាបានពន្យាជាង១២ឆ្នាំ ចុងក្រោយទើបបានឮសម្លេងជូនចាស់នេះ ពោលប្រាប់ខ្ញុំថា ម៉ែអស់កម្មពៀរហើយកូន ម៉ែត្រូវទៅសោយសម្បត្តិទេវលោកហើយ ពាក្យមួយម៉ាត់នេះ ខ្ញុំបាទត្រូវប្រើរយៈពេលជួយគាត់ជាង១២ឆ្នាំ ដើម្បីប្រសូត្រគាត់ឲ្យរួចពីសេចក្ដីទុក្ខ នេះជាកិច្ចដែលខ្ញុំបានបំពេញរួចហើយ ក្នុងនាមជាកូនក្មេរម្នាក់ ដែលបានទទួលកេរមរតកពួកគាត់។

ដូច្នេះភាគទី៤នេះ ខ្ញុំបាទមិនអាចមិនសរសេរគឺមិនបាន ព្រោះខ្ញុំចង់ឲ្យកូននាគទូទាំង មាតុភូមិនេះ ទាំងក្នុងទឹកដីបច្ចុប្បន្ន និងក្នុងអតីតឲ្យបានដឹងថា ម្ចាស់មរតកអច្ឆរិយនេះ លោកបានសោយនៅក្នុងទុក្ខជាង២០០០ឆ្នាំ ព្រោះហេតុតែមាតុភូមិ ដែលជាកេរមរតករបស់លោកនេះ លោកក៏បានរួចផុតពីទោស សព្វថ្ងៃកំពុងសោយផលសុខ រួមទាំងញាតិវង្សរបស់លោក ដែលមាននិស្ស័យត្រេកអរបុណ្យជាមួយនឹងខ្ញុំ។ ខ្ញុំបាទក៏សូមអភ័យទោសដល់ញាតិទាំងអស់ ចំពោះការស្រាវជ្រាវ និង

ចងក្រងទាំង៤ភាគនេះ ហាមមិនឲ្យយកទៅថតចម្លង បោះពុម្ពធ្វើអាជីវកម្មឡើយ ព្រោះខ្ញុំបាទខិតខំបំពេញកិច្ចនេះមួយជីវិត គឺដើម្បីទុកជាប្រយោជន៍ ដល់ពូជនាគទាំងអស់។

ជាទីបញ្ចប់ខ្ញុំព្រះករុណាខ្ញុំបាទ ក៏សូមអភ័យទោសគ្រប់សំណាក់ញាតិអ្នកអាន ទាំងបព្វជិត និងគ្រហស្ថនូវរាល់កំហុសឆ្គងទាំងឡាយ ដែលកើតមានក្នុងស្នាដៃ ខ្ញុំបាទបានស្រាវជ្រាវទាំង៤ភាគនេះ។ ខ្ញុំព្រះករុណាខ្ញុំបាទ សូមប្រគេនបុណ្យ ជូនបុណ្យ ឧទ្ទិសបុណ្យ ដែលខ្ញុំបាទខំប្រឹងប្រែងមួយជីវិត ដើម្បីស្វះស្វែងរកនូវយុត្តិធម៌ ជូនដល់ដូនតាម្ចាស់នគរនេះ សូមឲ្យមហាកុសលនេះ កើតមានដល់ព្រះគុណម្ចាស់គ្រប់ព្រះអង្គ លោកឪពុកអ្នកម្តាយ ដែលលោកបានបង្កើតរូបខ្ញុំ ឲ្យខ្ញុំបានបំពេញកិច្ចនេះ និងជូនដល់ញាតិធម៌ ដែលសុទ្ធតែជាអ្នកមានឧបការគុណទាំងអស់ និងសព្វសត្វទាំងអស់ក្នុងទិសទាំង១០ ដែលសុទ្ធតែជាញាតិរបស់ខ្ញុំក្នុងសង្សារវដ្ត គ្រប់កាលទាំងបីឲ្យបានរួចផុតចាកទុក្ខ ឲ្យជួបតែពរទាំងឡាយ៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ ហើយនឹងអាចត្រាស់ដឹងនូវសច្ចៈធម៌ ក្នុងកាលជាអនាគត កុំបីក្លាយជាប្រការដទៃឡើយ។

ខេត្តព្រះសីហនុថ្ងៃអាទិត្យ**៤**កើត ខែទុតិយាសាឍ ឆ្នាំរោង ចត្វាស័ក ព.ស**២៥៥៦**
ត្រូវនឹងថ្ងៃទី**២២** ខែកក្កដា ឆ្នាំ**២០១២**

ការខិតខំស្រាវជ្រាវនេះ សូមរក្សាសិទ្ធិទាំងស្រុង

ពីខ្ញុំករុណាខ្ញុំបាទឧបាសក **គៀត ចាន់ធុន**

អតីតសិស្សសាលាវិចិត្រសិល្បៈ **គៀត ចាន់ធុន**